# ផ្លូវកណ្ដាល

(ជីវិត សកម្មភាព និងទស្សនវិជ្ជា របស់ព្រះពុទ្ធសមណគោតម)



ព្រះពុទ្ធរូបប្រក់នាគនាបថខ្មែរ ស.វ. ទី១៣ នៅសាមន្ទីរជាតិភ្នំពេញ

ព្រះសុមេធវង្ស បណ្ឌិត **ញ៉ែម គឹមតេង**(វជិរប្បញ្ញោ)

# ផ្លូវកណ្ដាល

(ជីវិត សកម្មភាព និងទស្សនវិជ្ជា របស់ព្រះសមណគោតម)

ដោយ

ព្រះសុមេធវង្ស **ញ៉ៀម គឹមតេង** (វជិរប្បញ្ញោ)

បណ្ឌិតទស្សនវិជ្ជាពុទ្ធសាសនានៃសាកលវិទ្យាល័យញូដែល្លី, ឥណ្ឌា

ប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សា

នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ, កម្ពុជា

រក្សាសិទ្ធិ

ព.ស. ២៥៥៥ គ.ស. ២០១២

# ប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ

ព្រះសុមេធវង្ស បណ្ឌិត **ញ៉ែម គឹមតេង** (វជិរប្បញ្ញោ)
ប្រសូតនៅថ្ងៃពុធ ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥០៤ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៦០ នៅភូមិបន្ទប់ខ្សាច់ ឃុំមេសថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។
ឪពុកឈ្មោះ ញ៉ែម សូរ ម្តាយឈ្មោះ យុត លឹម

| | |
|---|---|
| ឆ្នាំ១៩៧៣ | បួសជាសាមណេរ |
| ឆ្នាំ១៩៧៥ | ភៀសខ្លួនទៅប្រទេសវៀតណាម (កម្ពុជាក្រោម) |
| ឆ្នាំ១៩៨០ | បំពេញឧបសម្បទាជាភិក្ខុ |
| ឆ្នាំ១៩៨៤ | ចៅអធិការវត្តព្រៃឆ្លាក់ ក្រុងស្វាយរៀង ខេត្តស្វាយរៀង |
| ឆ្នាំ១៩៩៣ | អគ្គលេខាធិការមជ្ឈមណ្ឌលសម្តេចព្រះមហាឃោសានន្ទ កម្ពុជា |
| ឆ្នាំ១៩៩៤ | នាយកប្រតិបត្តិអង្គការសន្តិសេនា |
| ឆ្នាំ២០០២ | បញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកប្រវត្តិសាស្ត្រនិងសាសនា នៅប្រទេសឥណ្ឌា |
| ឆ្នាំ២០០៧ | បញ្ចប់ថ្នាក់អនុបណ្ឌិតខាងទស្សនវិជ្ជាពុទ្ធសាសនា (MA) នៅសាកលវិទ្យាល័យញូដេល្លី ប្រទេសឥណ្ឌា |
| ឆ្នាំ២០១០ | បញ្ចប់ថ្នាក់បណ្ឌិតទស្សនវិជ្ជាពុទ្ធសាសនា(PhD.) នៅសាកលវិទ្យាល័យញូដេល្លី ប្រទេសឥណ្ឌា ។ |
| ឆ្នាំ២០១១ | ទទួលតំណែងជាប្រធានផ្នែកពុទ្ធិកឧត្តមសិក្សា និងក្រោយឧត្តមសិក្សា នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ។ |

# អារម្ភកថា

មានប្រជាជនខ្មែរយើងចំនួនច្រើន បានប្រកាសប្រាប់គេឯងថាខ្លួនជាពុទ្ធសាសនិក គឺជាអ្នកកាន់ព្រះពុទ្ធសាសនាមួយរយភាគរយ ។ ប៉ុន្តែនៅពេលមានគេស្នើឲ្យពន្យល់ប្រាប់ខ្លះៗ ពីរឿងរ៉ាវរបស់ព្រះពុទ្ធ និងអ្វីដែលជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ក៏តាំងយកដៃអេះក្បាល រួចពោលថា ...ខ្ញុំមិនសូវច្បាស់ដែរ...។ រឿងនេះស្តាប់ឮទៅ ពិតជាគួរឲ្យខ្មាស់ណាស់... ។

សៀវភៅនៅក្នុងដៃរបស់លោកអ្នកនេះ មានចំណងជើងថា "ផ្លូវកណ្តាល" ដែលរៀបរាប់ពីរឿងរ៉ាវនៃជីវិត សកម្មភាព និងពាក្យប្រដៅរបស់ព្រះពុទ្ធជាបរមគ្រូ ជាពិសេសបង្ហាញពីផ្លូវមួយ ដែលព្រះពុទ្ធសមណគោតម ធ្លាប់បានពិសោធក្នុងការដើរឆ្ពោះទៅ រកការត្រាស់ដឹងដែលហៅថា ផ្លូវកណ្តាល ។ ម្យ៉ាងវិញទៀត សាសនាព្រះពុទ្ធក៏ជាផ្លូវកណ្តាល សម្រាប់ឲ្យក្រុមមនុស្សដែលចាត់ខ្លួនឯងថានៅថ្នាក់ខ្ពស់ និងក្រុមមនុស្សដែលត្រូវបានគេចាត់ទុកថាថ្នាក់ទាប មានឱកាសបានដើរលើផ្លូវនេះជាមួយគ្នា, អាចនិយាយបានម្យ៉ាងទៀតថា ផ្លូវកណ្តាលជាផ្លូវមិនតឹងពេកនិងមិនធូរពេក ។ ខ្លឹមសារនៅក្នុងសៀវភៅនេះ ខ្ញុំបានសិក្សាស្រាវជ្រាវចេញពីប្រភពជាច្រើន មានទាំងឯកសារខ្មែរយើង និងឯកសារជាភាសាបរទេស មករៀបរៀងជាសៀវភៅនេះឡើង ។ ខ្ញុំបានព្យាយាមប្រើ

ពាក្យពេចន៍សាមញ្ញៗ ដើម្បីងាយស្រួលដល់អ្នកអានទូទៅ អាចយល់បាន ដោយមិនលំបាក, តែទោះបីយ៉ាងនេះក៏ដោយ ក៏នៅតែមិនអាចចៀសផុត ពីពាក្យមួយចំនួន ជាពាក្យបច្ចេកទេសសម្រាប់ប្រើខាងសាសនាដែរ ។ ខ្ញុំ បានធ្វើជាសទ្ទានុក្រម ពន្យល់ពាក្យដែលពិបាកនៅខាងចុងសៀវភៅនេះ ហើយកន្លែងខ្លះទៀត ពន្យល់នៅក្នុងលេខយោងខាងក្រោមស្រាប់ ។

ខ្ញុំសង្ឃឹមថា សៀវភៅនេះអាចជួយផ្តល់ចំណេះដឹង ពីរឿងរ៉ាវនៃ បទពិសោធន៍ ក្នុងជីវិតរបស់ព្រះពុទ្ធ ក៏ដូចជាផ្នែកទ្រឹស្តីអប់រំខាងពុទ្ធ សាសនាដល់លោកអ្នក ក្នុងការតម្រង់ទិសនៃជីវិតរបស់យើងម្នាក់ៗ ទៅ រកសេចក្តីសុខខាងផ្លូវចិត្ត ។

ខ្ញុំបានសរសេរសៀវភៅនេះចប់រួចរាល់ តាំងពីដើមឆ្នាំ២០១០ ម្ល៉េះ ប៉ុន្តែមិនមានឱកាសបោះពុម្ពផ្សាយទេ ដោយមូលហេតុគ្មានថវិកា ទើបនៅចុងឆ្នាំ២០១១នេះ សហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក បាន ពិនិត្យឃើញថាសៀវភៅនេះ មានប្រយោជន៍ដល់អ្នកអាន ក៏ទទួលចេញ ថវិកាបោះពុម្ពចំនួន១000ក្បាល សម្រាប់ចែកផ្សាយ ។ ទោះបីជាខ្ញុំមាន កិច្ចការងារមមាញឹកយ៉ាងណាក៏ដោយ មុននឹងបោះពុម្ពចេញ ខ្ញុំបានយក អត្ថបទនេះមកពិនិត្យមើលម្តងទៀត ដើម្បីធ្វើឲ្យសៀវភៅនេះបានល្អ ប្រសើរជាងមុនបន្តិច ។

ខ្ញុំមានចិត្តរីករាយយ៉ាងក្រៃលែង ដោយបានឃើញសៀវភៅជាស្នាដៃរបស់ខ្ញុំនេះ បានប្រសូតចេញជារូបរាង តាមបំណងប្រាថ្នារបស់ខ្ញុំជាអ្នកសរសេរ ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជគុណសង្ឃាធិបតី **សៅ ឃន** ធម្មថេរោ ប្រធានសហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិក បានសម្រេចបរិច្ចាគថវិកាបោះពុម្ព និងសូមអរគុណចំពោះអ្នកស្រី ម៉ែន ម៉ាយ៉ា ដែលបានជួយសម្របសម្រួល លើការងារខាងលើនេះ ។

ខ្ញុំសូមអភ័យទោសទុកជាមុន នូវរាល់កំហុសឆ្គងពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ ដែលកើតមានក្នុងសៀវភៅនេះ ដោយអចេតនា ឬ ដោយសមត្ថភាពរបស់ខ្ញុំនៅមានកម្រិត ។

សូមឧទ្ទិសបុណ្យកុសលទាំងអស់ ជូនចំពោះឪពុក **ញ៉ៀម សូរ** ដែលបានទទួលអនិច្ចកម្មទៅហើយ និងម្ដាយ **ឃុត លឹម** ដែលមានជីពជន្មរស់នៅសព្វថ្ងៃ ព្រមទាំងបុត្តការីជនទាំងអស់ ។

សូមជូនបុណ្យកុសល ដល់លោកអ្នកទាំងឡាយ បានជួបសេចក្ដីសុខ-ចំរើន គ្រប់ទិវារាត្រីកុំបីអាកឡើយ ៕

ថ្ងៃទី១ ខែមករា ត្រូវនឹងថ្ងៃ៧ ៊ើ ២ ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥ / គ.ស. ២០១២

# មាតិកា

<u>ចំណងជើង</u> <u>លេខទំព័រ</u>


១. ព្រះសិទ្ធត្ថ

| | |
|---|---|
| -ប្រសូត | ១ |
| -ការថ្វាយព្រះនាម | ៣ |
| -ពិធីច្រត់ព្រះនង្គ័ល | ៥ |
| -យុវវ័យរបស់ព្រះសិទ្ធត្ថ | ៧ |
| -ចេញសាងអភិនេស្រ្កមណ៍ | ៩ |
| -ស្វែងរកមោក្សធម៌ | ១៤ |
| -បំពេញទុក្ករកិរិយា | ១៧ |
| -ការផ្ចាញ់មារ | ១៩ |
| -ផ្លូវកណ្តាល | ២៣ |
| -ការត្រាស់ដឹង | ២៤ |

២. ក្រោយការត្រាស់ដឹង

| | |
|---|---|
| -ឧទានគាថា | ២៩ |
| -សត្តមហាស្ថាន | ២៩ |
| -ប្រោសពាណិជពីរនាក់បងប្អូន | ៣៤ |

៣. ការសម្តែងព្រះធម៌

| | |
|---|---|
| -និមន្តសម្តែងព្រះធម៌ប្រោសសត្វ | ៣៧ |
| -ផ្លូវទៅក្រុងពារាណសី | ៤០ |
| -បញ្ចវគ្គីយភិក្ខុ | ៤៧ |

៤. បឋមទេសនា

-ធម្មចក្កប្បវត្តនសូត្រ ៥៩

៥. កាផ្សាយសាសនា

-ប្រោសយសកុលបុត្រ ៥៩
-ការបញ្ជូនសមណទូតលើកដំបូង ៦០
-ប្រោសយុវជន ៣០ នាក់ ៦២
-ប្រោសកស្សបៈ៣នាក់បងប្អូន ៦៣
-ប្រោសស្តេចពិម្ពិសារ ៦៤
-ប្រោសព្រះសារីបុត្រ និងព្រះមោគ្គល្លាន ៦៦

៦. ដំណើរយាងទៅកាន់នគរកំណើត

-ស្តេចសុទ្ធោទនៈជួបព្រះពុទ្ធ ៧៤
-ព្រះពុទ្ធនិមន្តចេញបិណ្ឌបាត្រ ៧៦
-ប្រោសនាងយសោធរា (ពិម្ពា) ៧៨
-ប្រោសនន្ទ ៨១
-ប្រោសរាហុល ៨៣
-ព្រះពុទ្ធ និងព្រះអានន្ទ ៨៥
-ព្រះពុទ្ធ និងទេវទត្ត ៨៧

៧. បេសកកម្មរបស់ព្រះពុទ្ធ

-ទីតាំងគង់ចាំព្រះវស្សា ៩០
-ការបំបួសភិក្ខុនី ៩២
-ប្រោសអង្គុលិមាល៍ ៩៨
-អនាថបណ្ឌិកសេដ្ឋី ១០០
-នាងវិសាខា ១០២

៨. ពុទ្ធកិច្ចទាំង ៥ យ៉ាង

-ពុទ្ធកិច្ចប្រចាំថ្ងៃ ១០៥

## ៩. ភាពសំខាន់របស់ព្រះពុទ្ធ


-ព្រះពុទ្ធនិងប្រព័ន្ធវណ្ណៈ ១១៧
-ព្រះពុទ្ធ និងការលើកកំពស់ស្ត្រីភេទ ១១៩
-អធ្យាស្រ័យព្រះពុទ្ធចំពោះសត្វ ១២១
-ភាពសំខាន់របស់ព្រះពុទ្ធ ១២២


## ១០. បរិនិព្វាន


-ផ្ចាញ់មារ ១២៦
-ការប្រៀនប្រដៅរបស់ព្រះពុទ្ធ ១២៧
-ព្រះធម្មារាមថេរ គោរពព្រះពុទ្ធ ១២៨
-ចង្ហាន់ចុងក្រោយ ១២៩
-ប្រោសសាវ័កចុងក្រោយ ១៣២
-នាទីចុងក្រោយ ១៣៧


## ១១. កម្ម


-កុសលកម្ម ១៤០
-អកុសលកម្ម ១៤២
-មូលហេតុនៃកម្ម ១៥១
-នរណាកសាងកម្ម ១៥១
-កម្មស្ថិតនៅទីណា? ១៥២
-ការចាត់កម្មជាថ្នាក់ ១៥៣
-កម្មចាត់ជា៤ថ្នាក់តាមមុខងារ ១៥៧
-តើអ្វីទាំងអស់សុទ្ធតែជាកម្មឬ? ១៥៧


## ១២. ការកើតឡើងវិញ


-ហេតុផលទៅរកជំនឿក្នុងអតីតជាតិ ១៦០
-មូលហេតុនៃដំណើរការកើតឡើងវិញ ១៦៦

-របៀប ៤ យ៉ាងនៃការកើតនិងការស្លាប់ ១៦៨
-តើកំណើតថ្មីកើតឡើងយ៉ាងដូចម្តេច? ១៧២
-តើអ្វីដែលទៅកើតទៀត? ១៧៧
-តើការកើតទៀតអាចប្រព្រឹត្តទៅដោយគ្មាន
ព្រលឹងបានឬទេ? ១៨២
១៣. ចតុរារិយសច្ច
-អរិយសច្ច៤ ១៨៤
១៤. និព្វាន
-និយមន័យ ១៩០
-តើនិព្វានសូន្យឬ? ១៩១
-និព្វានមានលក្ខណៈខុសគ្នា៣យ៉ាង ១៩៣
-ព្រះនិព្វាននៅឯណា? ១៩៥
-អ្វីដែលនាំឲ្យសម្រេចព្រះនិព្វាន? ១៩៦
១៥. អដ្ឋង្គិកមគ្គ
-ផ្លូវប្រកបដោយអង្គប្រាំបី ១៩៨
១៦. នីវរណធម៌
-នីវរណធម៌ ២០៨
១៧. សង្គាយនា
-បឋមសង្គាយនា ២១៥
-ត្រៃបិដក ២១៧
-ទុតិយសង្គាយនា ២២១
-វត្ថុ១០យ៉ាងដែលមិនមែនជាវិន័យ ២២១
-តតិយសង្គាយនា ២២៤
១៨. ស្តេចធម្មាសោក និងបេសកកម្ម

-ព្រះអង្គម្ចាស់អសោក ២២៨
-ព្រះអង្គម្ចាស់អសោកក្លាយជាស្តេច ២៣០
-ការងាកមកគោរពព្រះពុទ្ធសាសនា ២៣១
-បេសកកម្មរបស់ស្តេចធម្មាសោក ២៣៧
-បេសកកម្មទៅកាន់ប្រទេសស្រីលង្កា ២៤០
១៩. មង្គលសូត្រ ២៤៣
២០. បរាភវសូត្រ ២៤៧
២១. មេត្តាសូត្រ ២៥២
២២. ព្យគ្ឃបជ្ជសូត្រ ២៥៥
២៣. ពន្យល់ពាក្យ ២៦៤
២៤. ឯកសារយោង ២៦៨

# ១.ព្រះសិទ្ធត្ថ

## ប្រសូត

ព្រះសិទ្ធត្ថប្រសូតនៅថ្ងៃសុក្រ ១៥កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំច វេលាថ្ងៃត្រង់ មុនគ.ស.៦២៣ឆ្នាំ[១] នៅក្នុងឧទ្យានលុម្ពិនី ស្ថិតនៅត្រង់ចន្លោះខ្សែព្រំដែននៃនគរកបិលវត្ថុ និងនគរទេវទហៈ បច្ចុប្បន្ននេះនៅក្នុងដែនដីប្រទេសនេប៉ាល់ ។ ព្រះបិតាឈ្មោះសុទ្ធោទនៈ ជាស្ដេចគ្រប់គ្រងនៅនគរកបិលវត្ថុ ដែនសក្កៈ, ឯព្រះមាតាឈ្មោះសិរីមហាមាយា ។ ព្រះនាងសិរីមហាមាយាសោយទិវង្គតទៅ បន្ទាប់ពីប្រសូតព្រះរាជបុត្របានប្រាំពីរថ្ងៃ ។ ស្ដេចសុទ្ធោទនៈបានតែងតាំង ព្រះនាងបជាបតិគោតមី ជាប្អូនស្រីរបស់ព្រះនាងសិរីមហាមាយា ធ្វើជាព្រះអគ្គមហេសី ហើយឲ្យទទួលចិញ្ចឹមព្រះកុមារតមក ។

ប្រជារាស្ដ្រនិងពួកមន្ត្រីទាំងឡាយ នៅក្នុងព្រះនគរ មានចិត្តរីករាយសាទរឥតឧបមា ដោយបានឮដំណឹងពីការប្រសូត នៃព្រះកុមារកាលណាមក ។ ចំណែកអសិតតាបស មានឈ្មោះម្យ៉ាងទៀតថាកាឡទេវិល ជា

[១] ពុទ្ធសករាជ មិនរាប់ដូចគ.ស.ទេ គឺចាប់រាប់យកពីក្រោយថ្ងៃព្រះពុទ្ធបរិនិព្វាន មួយថ្ងៃ គឺនៅមុនគ.ស. ៥៤៣ឆ្នាំ ។

ព្រះជីតុនរបស់ស្ដេចសុទ្ធោទនៈ ក៏រីករាយក្នុងព្រះទ័យខ្លាំងណាស់ដែរ ។ នៅពេលបានឮដំណឹងដ៏អស្ចារ្យនេះ តាបសបាននិមន្តចូលទៅក្នុងព្រះរាជវាំងភ្លាម ដើម្បីបានទតនិងថ្វាយព្រះពរ ដល់ព្រះកុមារដែលទើបប្រសូតមកថ្មី ។ ស្ដេចមានព្រះទ័យរីករាយ បានឲ្យគេនាំព្រះរាជបុត្រ ចេញមកថ្វាយតាបសទត និងបានទទួលពរជ័យខ្លះៗផងដែរពីព្រះអង្គ, ប៉ុន្តែគួរឲ្យអស្ចារ្យណាស់ ព្រះបាទាទាំងទ្វេរបស់ព្រះកុមារ បែរជាទៅប្រតិស្ឋាននៅលើផ្នួងសក់ របស់កាឡទេវិលតាបសទៅវិញ ។ តាបសបានក្រោកចេញចាកពីអាសនៈ ហើយថ្វាយបង្គំព្រះកុមារ ដោយសេចក្ដីគោរពក្រៃលែង ។ ដោយឃើញកាឡទេវិលតាបស ថ្វាយបង្គំព្រះរាជបុត្រដូច្នោះ ស្ដេចសុទ្ធោទនៈជាបិតាក៏ចុះពីអាសនៈ ហើយថ្វាយបង្គំព្រះរាជបុត្រដូចតាបសដែរ ។

ក្រោយការថ្វាយបង្គំព្រះកុមារមក កាឡទេវិលតាបសក្រោកឈរឡើង រួចញញឹមដោយអាការៈរីករាយ, ប៉ុន្តែបន្ទាប់ពីនោះមក ក៏ប្រែជាយំដោយអារម្មណ៍ក្ដុកក្ដួលទៅវិញ ។ មានគេសួរទៅតាបស ពីមូលហេតុអ្វីដែលធ្វើឲ្យលោកសើចរួចយំយ៉ាងដូច្នេះ, តាបសឆ្លើយថា ការដែលលោកសើចនោះ ពីព្រោះតែព្រះកុមារនេះនឹងបានត្រាស់ដឹង ជាព្រះពុទ្ធមួយអង្គនៅក្នុងលោកនេះពិតប្រាកដ, ចំណែកការយំវិញនោះ ពីព្រោះតែរូបលោកស្លាប់ទៅ និងបានទៅកើតក្នុងស្ថានអរូបព្រហ្ម នៅមុនពេលព្រះកុមារនេះ

បានត្រាស់ដឹងជាព្រះពុទ្ធ ដែលធ្វើឲ្យលោកខកខានស្តាប់នូវព្រះសទ្ធម្ម ជាធម៌ពិត ធម៌មែន អាចឲ្យបានដល់នូវព្រះនិព្វាន ។

## ការថ្វាយព្រះនាម

បន្ទាប់ពីព្រះកុមារប្រសូតបានប្រាំថ្ងៃមក ស្តេចសុទ្ធោទនៈជាបិតាបានបញ្ជាឲ្យរៀបចំពិធីមង្គលមួយឡើង ដើម្បីជ្រើសព្រះនាមថ្វាយដល់បុត្ររបស់ព្រះអង្គ ។ ព្រះកុមារត្រូវបានថ្វាយព្រះនាមជា ផ្លូវការថា "សិទ្ធត្ថ" ដែលមានន័យថា "អ្នកញ៉ាំងប្រយោជន៍ឲ្យសម្រេច" ។ ព្រះអង្គមានត្រកូលជាគោតម ព្រោះហេតុនោះហើយ ទើបទ្រង់មានព្រះនាមមួយទៀតថា ព្រះគោតម[២] ឬក៏ព្រះសមណគោតម ។

---

[២] គោតម ជាឈ្មោះប្រចាំត្រកូល ឯសាក្យៈ ឬ សក្យៈ ជាឈ្មោះរាជវង្សរបស់ព្រះអង្គ ប្រពៃណីបានលើកឡើងថា ព្រះរាជបុត្ររបស់ស្តេចឱក្កាករាជ ជារាជវង្សរបស់ព្រះ បាទមហាសន្មត ដែលត្រូវបានបណ្តេញចេញ ដោយមាតាចុងដែលគ្មានចិត្តមេត្តា ។ ព្រះរាជបុត្រទាំងនោះ បានធ្វើដំណើរផ្សងព្រេងរហូតទៅដល់ជើងភ្នំហេមពាន្ត បាន ជួបនឹងតាបសឈ្មោះកបិល, តាបសបានឲ្យដំបូន្មានព្រះរាជបុត្រទាំងនោះ ឲ្យ កសាងនគរនៅទីនោះ ។ ព្រះរាជបុត្រមានវ័យក្មេង បាននាំគ្នាកសាងនគរតាមការ ពន្យល់របស់តាបសហើយបានដាក់ឈ្មោះរាជធានីនៃនគរនោះថា កបិលវត្ថុ តាមនាមរបស់តាបស ។ ដោយបានឮដំណឹងពីការផ្តើមកសាងព្រះរាជធានីរបស់ ព្រះរាជបុត្រទាំងនោះ ធ្វើឲ្យស្តេចឱក្កាករាជជាបិតាលាន់ព្រះឱស្ឋថា "សាក្យ វត ភូ រាជកុមារា" ប្រែថា "ព្រះរាជកុមារទាំងនេះ មានសត្តភាពល្អអស្ចារ្យណាស់" ។ ព្រោះ ហេតុនោះ ព្រះរាជវង្សនិងអាណាចក្រនេះមានឈ្មោះថាសាក្យវង្ស តរៀងមក ។ អាណាចក្រសព្វថ្ងៃស្ថិតនៅក្នុងប្រទេសនេប៉ាល់ភាគខាងត្បូង ។

នៅក្នុងពិធីមង្គលជាប្រពៃណីនេះ ព្រាហ្មណ៍១០៨រូបត្រូវបាននិមន្ត មកកាន់ព្រះរាជវាំង ដើម្បីចូលរួមក្នុងពិធីថ្វាយនាមដល់ព្រះកុមារ, ពួក ព្រាហ្មណ៍ទាំងនោះ បានទទួលការថ្វាយភត្តាហារពីព្រះរាជា ប្រកបដោយ កិត្តិយសក្រៃលែង ។ ក្រោយការទទួលភត្តាហាររួចមក មានតែព្រាហ្មណ៍ ប្រាំបីរូបប៉ុណ្ណោះ ដែលជាអ្នកចេះដឹងជ្រៅជ្រះក្នុងក្បួនត្រៃវេទ ត្រូវបាន ជ្រើសរើស ដើម្បីទាយមហាបុរិសលក្ខណៈថ្វាយព្រះរាជកុមារ, ឯព្រាហ្ម ណ៍ដទៃទៀតឲ្យនិមន្តត្រឡប់ទៅវិញ ។ ព្រាហ្មណ៍ប្រាំពីរនាក់ខាងដើម បាន លើកម្រាមដៃពីរឡើង ហើយថ្វាយទំនាយថា បើព្រះរាជកុមារនៅជា ឃរាវាស នឹងបានជាស្តេចចក្រពត្រាធិរាជ គ្រប់គ្រងពិភពលោកនេះ, តែ បើព្រះអង្គចេញបួស នឹងបានត្រាស់ដឹងជាព្រះពុទ្ធមួយអង្គ នៅក្នុងលោក នេះមិនខានឡើយ ។ ចំណែកព្រាហ្មណ៍ឈ្មោះកោណ្ឌញ្ញៈ ដែលមានវ័យ ក្មេងជាងគេ បានលើកម្រាមដៃតែមួយឡើង ហើយប្រកាសថាព្រះសិទ្ធត្ថ កុមារ ពិតជាត្រាស់ដឹងជាព្រះពុទ្ធមួយអង្គក្នុងលោកមែន ។

## ពិធីច្រត់ព្រះនង្គ័ល

មានហេតុការណ៍គួរឲ្យកត់សម្គាល់មួយ បានកើតឡើងដល់ព្រះ ពោធិសត្វ កាលទ្រង់នៅជាព្រះកុមារ ជាហេតុការណ៍មិនធ្លាប់កើតមានពី មុនមក និងជាចំណុចសំខាន់សម្រាប់ឈានទៅរកការត្រាស់ដឹង ។ ហេតុ ការណ៍នេះបានកើតឡើង នៅក្នុងឱកាសពិធីបុណ្យច្រត់ព្រះនង្គ័លមួយ

ដែលជាប្រពៃណីរបស់ពួកសាក្យៈ ។ ពិធីបុណ្យច្រតព្រះនង្គ័លនេះ ជាពិធីមួយដែលមនុស្សម្នាស្ទើរទាំងអស់គ្នា នៅក្នុងព្រះនគរ មានពួកខត្តិយត្រកូល ពួកត្រកូលអភិជន និងពពួកមនុស្សសាមញ្ញទូទៅ បាននាំគ្នាតុបតែងខ្លួនប្រាណ ដោយសម្លៀកបំពាក់ល្អៗ ដើម្បីចូលរួមសប្បាយ ។ ក្នុងឱកាសនោះ ក៏មានកម្មវិធីសម្តែងមហោស្រពសិល្បៈ ជូនដល់អ្នកចូលរួមទាំងអស់ទស្សនាកំសាន្តផងដែរ ។ ព្រះសិទ្ធត្ថកុមារក៏ត្រូវបានព្រះមហាក្សត្រ អនុញ្ញាតឲ្យពួកស្រីស្នំជាបរិវារ នាំយកទៅកាន់ទីរៀបចំព្រះរាជពិធីបុណ្យនោះដែរ ។ ពួកស្រីស្នំបានរៀបចំដាក់ព្រះកុមារ ឲ្យផ្ទំនៅក្នុងព្រះពន្លាល្អមួយ ដែលបិទបាំងការពារដោយសំណាញ់ និងក្រាលដោយកម្រាលព្រំល្អប្រណិត ស្ថិតនៅក្នុងទីសុវត្ថិភាព ក្រោមម្លប់ត្រជាក់នៃដើមព្រីងធំមួយ ។ នៅពេលពិធីបុណ្យប្រព្រឹត្តទៅ បានជាងពាក់កណ្តាល ពួកស្រីស្នំទាំងឡាយ នាំគ្នាដើរចេញទៅក្រៅ ដើម្បីមើលពិធីច្រតព្រះនង្គ័ល ហើយទុកព្រះកុមារឲ្យគង់នៅស្ងាត់តែមួយអង្គឯង ។ ព្រះសិទ្ធត្ថកុមារពេញដោយការគិត, ទ្រង់មានបញ្ញាចាស់ក្លាជាងវ័យ, ដោយឃើញថាមិនមាននរណាម្នាក់ស្ថិតនៅទីជិតព្រះអង្គ និងជាឱកាសស្ងាត់ល្អកម្រមាន ទ្រង់ក្រោកឡើងហើយអង្គុយពែនភ្នែន រួចបានកំណត់ខ្យល់អស្សាសបស្សាសៈជាអារម្មណ៍, ទ្រង់ចម្រើនអាណាបានុស្សតិ ដរាបដល់ចិត្តស្ថិតនៅជាឯកតារម្មណ៍ ពេលនោះចិត្តរបស់ព្រះអង្គ បានដល់នៅបឋមជ្ឈាន ។

ពួកស្រីស្នំទាំងឡាយមានការសប្បាយរីករាយ ក្នុងចិត្តក្រៃលែង រហូតភ្លេចស្មារតី ធ្វេសប្រហែសក្នុងការមើលថែព្រះកុមារ, តែក្រោយមក ក៏បាននឹកឃើញវិញ ហើយនាំគ្នាស្ទុះរត់មករកព្រះសិទ្ធត្ថកុមារ ដែល គង់នៅតែមួយអង្គឯង, ក៏ស្រាប់តែឃើញព្រះកុមារ កំពុងគង់ស៊ុបនៅក្នុង សមាធិ ទើបនាំគ្នាយកដំណឹងនោះ ទៅទូលថ្វាយស្ដេចឲ្យបានជ្រាបភ្លាម ។ ស្ដេចសុទ្ធោទនៈយាងទៅកាន់ទីនោះយ៉ាងប្រញាប់ប្រញាល ទ្រង់បានទត សម្លឹងទៅព្រះរាជបុត្រឥតព្រិចព្រះនេត្រ នៅក្នុងអាការៈសញ្ជឹងគិត រួចក៏ លុតជង្គង់ចុះ ហើយលើកព្រះហស្ដទាំងទ្វេ ថ្វាយបង្គំព្រះរាជបុត្រ ដោយ ពោលពាក្យឡើងថា “ឱបុត្រស្ងួនសម្លាញ់បិតា, ពេលនេះបិតាថ្វាយបង្គំ បុត្រជាលើកទីពីរហើយណាបុត្រ” ។

## យុទ្ធវិជ្ជារបស់ព្រះសិទ្ធត្ថ

ព្រះសិទ្ធត្ថកុមារបានទទួលការសិក្សារៀនសូត្រ ចំណេះដឹងល្អៗ ទោះបីជាក្នុងឯកសារមិនបាននិយាយលំអិត ពីការសិក្សារៀនសូត្ររបស់ ព្រះអង្គក៏ដោយ ។ តាមពិតព្រះអង្គជាពន្លកនៃត្រកូលក្សត្រ ត្រូវតែបាន ទទួលការហ្វឹកហ្វឺនពិសេសមួយ នៅក្នុងចំណេះដឹងផ្សេងៗ ក៏ដូចជាសិល្បៈ សង្គ្រាមមិនខានឡើយ ។

នៅក្នុងព្រះជន្ម១៦ព្រះវស្សា ព្រះសិទ្ធត្ថកុមារបានរៀបអភិសេកជាមួយព្រះនាងយសោធរា (ពិម្ពា) ជាបុត្រីរបស់ស្ដេចសុប្បពុទ្ធនៃនគរទេវទហៈ និងត្រូវជាបងប្អូនជីដូនមួយនឹងព្រះអង្គផងដែរ ។ ព្រះនាងពិម្ពាជានារីមានរូបសម្រស់ស្អាត លើស្រីផងនានានៅក្នុងរាជត្រកូល, ព្រះនាងប្រសូតនៅក្នុងថ្ងៃដំណាលគ្នានឹងព្រះសិទ្ធត្ថដែរ ។ បន្ទាប់ពីការរៀបអភិសេកមក ព្រះសិទ្ធត្ថបានរស់នៅក្នុងជីវិតពេញដោយសេចក្ដីសុខក្រៃលែងមិនដែលបានឃើញ ឬបានស្គាល់សេចក្ដីទុក្ខលំបាក នៃជីវិតខាងក្រៅព្រះរាជវាំងឡើយ ។

ជីវិតព្រះសិទ្ធត្ថកុមារពេញដោយសេចក្ដីសុខ ដូចដែលព្រះពុទ្ធអង្គបានបញ្ជាក់ថា "តថាគតរស់នៅក្នុងជីវិតដ៏ប្រណិត មានសេចក្ដីសុខហួសប្រមាណ ។ នៅក្នុងរាជវាំងនៃបិតារបស់តថាគត មានស្រះឈូកចំនួនបីដែលបានកសាងឡើង សម្រាប់ឲ្យតថាគតក្រសាលសប្បាយតាមបំណងប្រាថ្នា ។ ស្រះមួយមានឈូកពណ៌ខៀវ មានផ្ការីកស្គុះស្គាយ, ស្រះមួយទៀតមានឈូកពណ៌ក្រហម និងស្រះទីបីមានឈូកពណ៌-ស គួរឲ្យរីករាយក្នុងចិត្តណាស់ ។ តថាគតបានប្រើឈើខ្លឹមចន្ទន៍សម្រាប់ដុត ធ្វើឲ្យមានក្លិនប្រអូបឈ្ងុយ ដែលបានមកពីដែនកាសី ។ សំពត់ជូតក្បាល អាវធំក្រៅសម្លៀកបំពាក់ និងសំពត់សម្រាប់ដណ្ដប់របស់តថាគត ក៏សុទ្ធសឹងតែបានមកពីដែនកាសីទាំងអស់ ។ តថាគតត្រូវបានគេបាំងពីលើដោយក្លស់ពណ៌-

ស ទាំងយប់ទាំងថ្ងៃ ដើម្បីការពារកំដៅថ្ងៃ ត្រជាក់ ធូលី ស្លឹកឈើ និងទឹកសន្សើមជាដើម" ។

"ប្រាសាទល្អៗចំនួនបី ត្រូវបានកសាងឡើងជាពិសេស សម្រាប់តែតថាគតមួយអង្គឯងគត់, ប្រាសាទមួយសម្រាប់គង់នៅក្នុងរដូវត្រជាក់ មួយសម្រាប់រដូវក្តៅ និងមួយទៀតសម្រាប់រដូវភ្លៀង ។ ក្នុងរដូវភ្លៀងទាំងបួនខែ តថាគតគង់នៅតែក្នុងប្រាសាទសម្រាប់រដូវភ្លៀង និងរីករាយដោយតូរ្យតន្ត្រី ដែលសម្តែងយ៉ាងប៉ិនប្រសប់ដោយពួកស្រីក្មេង ដែលមានរូបសម្ផស្សស្អាតគួរបេតី, តថាគតមិនចាំបាច់ត្រូវការយាងចុះ ពីប្រាសាទឡើយ ។ នៅក្នុងផ្ទះរបស់ជនដទៃៗ ពួកទាសីនិងអ្នកបម្រើទាំងអស់ ត្រូវបានប្រគល់ឲ្យនូវម្ហូបអាហារ ត្រឹមតែបាយចម្អិនពីអង្ករលាយដោយស្រូវជាមួយនឹងម្ហូបមានរសជូរដូចផ្អូម និងមានក្លិនខ្មោះៗ, ចំណែកនៅក្នុងប្រាសាទរបស់តថាគតវិញ ពួកទាសីនិងកម្មករទាំងអស់ ត្រូវបានផ្តល់ឲ្យនូវបាយដែលចម្អិនពីអង្ករល្អៗ និងម្ហូបលាយដោយសាច់និងបន្លែ" ។

## ចេញសាងអភិនេស្ក្រមណ៍

ពេលវេលានៃជីវិតរបស់ព្រះសិទ្ធត្ថ បានរះឡើងនិងឈានទៅមុខបន្តិចម្តងៗ, ការសញ្ជឹងគិតនិងទឹកចិត្តប្រកបដោយ មហាករុណាមិនមានព្រំដែន មិនអនុញ្ញាតឲ្យព្រះអង្គរីករាយនិងត្រេកអរ ដល់ការរស់នៅក្នុង

ព្រះរាជវាំងតទៅទៀតឡើយ ។ ព្រះអង្គមិតអារម្មណ៍យ៉ាងជ្រៅ ទៅក្នុងសេចក្ដីអាណិតអាសូរដល់សត្វលោក ដែលកំពុងដេកត្រាំនៅក្នុងសេចក្ដីទុក្ខ, ទ្រង់បានទតឃើញយ៉ាងច្បាស់ នូវសាកលភាពនៃសេចក្ដីទុក្ខនោះ ។

ក្នុងទិវាប្រកបដោយនក្ខត្តឫក្សមួយ ព្រះសិទ្ធត្ថបានយាងចេញពីព្រះរាជវាំង ដើម្បីទស្សនាស្ថានភាពខាងក្រៅ, ទ្រង់ដំណើរ យាងដោយត្រង់ និងគ្មានការរៀបចំទុកជាមុនឡើយ ដើម្បីចង់ស្វែងយល់ឲ្យបានច្បាស់ពីដំណើរពិត នៃភាពទុក្ខសោកនិងភាពសោះកក្រោះនៃជីវិតសត្វលោក ។ នៅក្នុងរបាំងនៃព្រះរាជវាំង ព្រះសិទ្ធត្ថបានទតឃើញតែជ្រុងមួយនៃជីវិតប៉ុណ្ណោះ ប៉ុន្តែនៅមានសល់ជ្រុងដទៃទៀត ដែលត្រូវបានគេបិទបាំងពីរង្វង់ព្រះនេត្ររបស់ព្រះអង្គ ។ ព្រះនេត្រដ៏មុតនិងវៃឆ្លាតរបស់ព្រះសិទ្ធត្ថ បានទតឃើញនូវទិដ្ឋភាពចម្លែកៗ ពិសេសមនុស្សចាស់ជរា មនុស្សឈឺ សាកសពនៃមនុស្សស្លាប់ និងភេទអ្នកបួសដែលមានឥន្ទ្រីយ៍ស្រគត់ស្រគំ ។ ការឃើញទិដ្ឋភាពទាំងបីដំបូង បានញ៉ាំងព្រះសិទ្ធត្ថឲ្យយល់កាន់តែច្បាស់ និងជឿជាក់ពីធម្មជាតិពិតរបស់ជីវិត ដែលមិនអាចដាក់ល័ក្ខខ័ណ្ឌ ឬអង្វរករបានឡើយ, ពិសេសជម្ងឺដម្កាត់គ្រប់យ៉ាង ដែលបានគ្របដណ្ដប់មកលើរូបកាយនៃសត្វលោកទូទៅ ។ ទិដ្ឋភាពទីបួន មានន័យថាជាមធ្យោបាយសម្រាប់យកជោគជ័យលើសេចក្ដីទុក្ខ ដែលគ្របដណ្ដប់មកលើជីវិត និងជម្រុញសត្វលោក ឲ្យឈានទៅដល់ទីបរមសុខបាន ។

បន្ទាប់ពីការសញ្ជឹងគិតយ៉ាងយូរមក ព្រះសិទ្ធត្ថក៏សម្រេចព្រះទ័យជាចុងក្រោយថា ត្រូវតែរកច្រកយាងចេញទៅសាងអភិនេស្រ្កមណ៍ ។ ក្នុងពេលជាមួយគ្នានោះដែរ ក៏មានដំណឹងគួរឲ្យរីករាយមួយ ដែលត្រូវបានគេនាំទៅទូលថ្វាយចំពោះព្រះអង្គ គឺការប្រសូតបុត្ររបស់ព្រះនាងពិម្ពា ។ ខុសគ្នាស្រឡះពីឪពុកដទៃទៀត ទ្រង់មិនមានព្រះទ័យរីករាយ ចំពោះការបានឮដំណឹងនោះឡើយ, ប៉ុន្តែទ្រង់គិតឃើញជាដំបូង ទៅដល់បុត្រថាជាឧបសគ្គរាំងដំណើរទៅវិញ, ទ្រង់បានបន្លឺវាចាខ្លាំងៗឡើងថា “រាហុលោ ! រាហុលោ ! (ឧបសគ្គ)បានកើតឡើងហើយហ្ន៎ !, ចំណងបានកើតឡើងហើយហ្ន៎ !” ។ ព្រោះហេតុនោះ ពេលព្រះរាជបុត្ររបស់ព្រះអង្គចម្រើនវ័យឡើង ក៏ត្រូវបានស្ដេចសុទ្ធោទនៈជាព្រះអយ្យកោ ថ្វាយនាមថា “រាហុល” តមក ។

ព្រះរាជវាំងគឺជាកន្លែងដែលគួរឲ្យចូលចិត្ត តែមិនបានស្ថិតនៅយូរក្នុងព្រះទ័យ របស់ព្រះពោធិសត្វឡើយ ។ ពេលវេលាទុំជោរណាស់ហើយ ក៏បានជម្រុញព្រះសិទ្ធត្ថឲ្យយាងចេញ ដើម្បីស្វែងរកមោក្ខធម៌ ។

ព្រះសិទ្ធត្ថបានប្រាប់ទៅនាយសារថី របស់ព្រះអង្គឈ្មោះឆន្ន ឲ្យបំពាក់ទ្រនាប់អានលើខ្នងសេះកណ្ឋកៈ ទុកឲ្យហើយជាស្រេច, ចំណែកព្រះអង្គវិញ ទ្រង់យាងចូលទៅក្នុងប្រាសាទព្រះនាងពិម្ពា ក្នុងដំណើរប្រញាប់ប្រញាល, ទ្រង់ឈរទុចនៅប្របមាត់ទ្វារចូលបន្ទប់ រួចចោលព្រះ

នេត្រសម្លឹងមើលទៅព្រះមហេសី និងព្រះរាជបុត្រទើបប្រសូត ដែលកំពុងផ្ទុំលក់យ៉ាងស្កប់ស្កល់ ។ ដូចជាមនុស្សដទៃទៀតក្នុងលោកនេះដែរ សេចក្តីអាណិតអាសូរ និងសេចក្តីស្នេហាចំពោះមហេសីនិងកូនជាទីស្រឡាញ់បានគ្របសង្កត់មកលើបេះដូងរបស់ព្រះអង្គ នៅក្នុងខណៈនៃការព្រាត់និរាសគ្នាបែបនេះ, តែព្រះសិទ្ធត្ថមិនព្រួយបារម្ភពីសេចក្តីសុខ និងសុភមង្គលរបស់មាតានិងបុត្រទាំងទ្វេនោះទេ ព្រោះទ្រង់មានការជឿជាក់ថាពួកគេពិតជាមានអ្វីៗទាំងអស់គ្រប់យ៉ាង និងត្រូវបានថែរក្សាការពារយ៉ាងល្អមិនខានឡើយ ។

ព្រះអង្គបានបន្សល់ទុកបេះដូងភ្លឺថ្លានៅខាងក្រោយ, ទ្រង់បានយាងចេញពីរាជវាំង នៅពេលអាធ្រាតស្ងាត់ ដោយគង់លើខ្នងសេះឈ្មោះកណ្ឋកៈ, ទ្រង់បានបំបោលសេះក្នុងល្បឿនលឿនដូចព្រួញ កាត់ទម្លុះស្បៃរាត្រីថ្ងៃពេញបូណ៌មី ១៥កើត ខែអាសាឍ្ហៈ ដែលមានឆន្នអាមាត្យតែម្នាក់រត់តាមក្រោយ ។ ដូចជាអ្នកផ្សងព្រេងដ៏កំសត់ម្នាក់ដែរ ព្រះសិទ្ធត្ថបានចេញដំណើរស្វែងរកសច្ចធម៌ និងមោក្សធម៌ ពេញដោយសេចក្តីសុខក្រៃលែង ។

ពេលវេលាបានផ្លាស់ប្តូរយ៉ាងលឿន, ក្នុងព្រះជន្ម២៩ព្រះវស្សា ព្រះសិទ្ធត្ថបានចេញមហាដំណើរជាប្រវត្តិសាស្ត្រ, ទ្រង់ធ្វើដំណើរឆ្ងាយទៅៗរហូតឆ្លងស្ទឹងអនោមាទើបឈប់ ហើយគង់សម្រាកឥរិយាបថយ៉ាងស្ងប់ស្ងៀម នៅលើមាត់ស្ទឹងនោះឯង ។ នៅទីនោះ ព្រះសិទ្ធត្ថបានកាត់ព្រះ

កេសាឲ្យនៅខ្លី និងប្ដូរសម្លៀកបំពាក់ព្រះអង្គម្ចាស់ចេញ ហើយប្រគល់ទៅឲ្យឆន្នអាមាត្យ រួចទ្រង់ស្លៀកដណ្ដប់សំពត់កាសាវៈពណ៌លឿង ជារបស់អ្នកបួសជំនួសវិញ ។ ព្រះសិទ្ធត្ថបានប្រកាន់យកជីវិតជាអ្នកគ្មានផ្ទះ ហើយទ្រង់ប្រាប់ឆន្នអាមាត្យឲ្យវិលត្រឡប់ទៅរាជវាំងវិញ ដើម្បីពាំនាំដំណឹងនេះប្រាប់ ដល់ព្រះញាតិវង្សទាំងអស់ឲ្យបានជ្រួតជ្រាប ។

តាបសសិទ្ធត្ថ ឬសមណគោតម មានកំណើតចេញពីព្រះអង្គម្ចាស់មួយអង្គ ធ្លាប់រស់នៅក្នុងជីវិតខ្ពង់ខ្ពស់ ពេញដោយភាពរុងរឿង, ឥឡូវនេះបានក្លាយជាអ្នកថ្មើរជើងគ្មានគោលដៅ ចិញ្ចឹមជីវិតដោយអាហារសៅហ្មងតិចតួច ដែលបានមកដោយការដើរសុំតាមដំបូលផ្ទះ នៃពួកអ្នកស្រុក ។ សមណៈអង្គនេះមិនមានលំនៅស្ថានជាអចិន្ត្រៃយ៍ទេ ទ្រង់យកម្លប់ឈើនិងរូងភ្នំធ្វើជាទីជម្រក ទ្រង់និមន្តដើរដោយជើងទទេ មានព្រះកេសកោររលីង ហើយគ្មានអ្វីបាំងពីលើឡើយ, ទ្រង់និមន្តដើរកាត់កំដៅថ្ងៃស្ទើរឆេះ និងជួនកាលដើរកាត់លំហអាកាសធាតុត្រជាក់ស្ទើរផ្ទុះក្បាល ។ សំពត់ស្លៀកដណ្ដប់ជាប់ខ្លួន ធ្វើឡើងពីរបស់ដែលគេបោះចោល ជារបស់គ្មានតម្លៃ ជាសំពត់កន្ទបមានសាច់គគ្រើម ។ ព្រះអង្គគ្មានទ្រព្យសម្បត្តិជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ មានតែបាត្រសម្រាប់ស្វែងរកសុំអាហារតាមដំបូលផ្ទះអ្នកស្រុក, មានត្រៃចីវរគ្រាន់តែល្មមប្រើប្រាស់ប៉ុណ្ណោះ, ទ្រង់ចម្រើន

សមាធិគ្រប់ពេល ហើយបានប្រើប្រាស់ថាមពលដែលមានទាំងប៉ុន្មាន ដើម្បីស្វែងរកមោក្ខធម៍និងសច្ចធម៌ ។

## ការស្វែងរកមោក្ខធម៌

ជាអ្នកស្វែងរកអំពើល្អម្នាក់ (កុសលគវេសី) ពេញដោយ សន្តិភាព, ព្រះសមណគោតម បាននិមន្តសន្សឹមៗ ចូលទៅរកអាស្រមអាឡារតាបស កាឡាមគោត្រ ជាមហាគ្រូដ៏មានកិត្តិនាមល្បីរន្ទឺម្នាក់ ដើម្បីសិក្សាពីរបៀបស្វែងរកសច្ចធម៌ និងមោក្ខធម៌, ទ្រង់បានសិក្សាក្នុងរយៈពេលឆាប់បំផុតពីលទ្ធិរបស់តាបសរូបនោះ ធ្វើឲ្យព្រះអង្គបានសម្រេចត្រឹមតែឈានថ្នាក់ទី៧ (អកិញ្ចញ្ញាយតនៈ) ដែលកើតចេញមកពីការប្រឹងចម្រើនសមាធិប៉ុណ្ណោះ ។

អាឡារតាបសមានចិត្តរីករាយខ្លាំងណាស់ ដោយបានដឹងថាសិស្សថ្មីរបស់គាត់ បានទទួលជោគជ័យក្នុងការសិក្សា ប្រកបដោយកិត្តិយស ហើយវាក៏បានផ្តល់ត្រឡប់ឲ្យគាត់វិញ នូវកិត្តិយសដ៏ខ្ពង់ខ្ពស់ផងដែរ ។ អាឡារតាបសបានលើកតម្កើងព្រះសមណគោតម ឲ្យមានកិត្តិយសស្មើនឹងខ្លួនគាត់ដែរ ដោយការពោលពាក្យសរសើរថា “នែសម្លាញ់ ខ្ញុំរីករាយណាស់, ខ្ញុំរីករាយក្នុងចិត្តឥតឧបមា ព្រោះថាខ្ញុំបានសិក្សាស្រាវជ្រាវមក នូវលទ្ធិដែលខ្ញុំបានចេះដឹងនេះដូចរូបអ្នកដែរ, ឥឡូវនេះអ្នកបាន

ចេះដឹងអស់ហើយ នូវអ្វីដែលខ្ញុំបានចេះដឹងនោះដែរ, ដូច្នេះចំណេះដឹងរបស់ខ្ញុំមានតែប៉ុណ្ណឹងឯង ។ មកសម្លាញ់ ! យើងទាំងពីរនាក់រួមគ្នា ដឹកនាំតាបសជាសិស្សទាំងអស់នេះជាមួយគ្នា ។ ព្រះសមណគោតមមិនពេញចិត្ត ជាមួយនឹងការអប់រំតាមវិធីនោះឡើយ ព្រោះថាវិធីនោះមិនអាចនាំព្រះអង្គទៅដល់ព្រះនិព្វានបានឡើយ ។ ព្រះអង្គមិនពេញចិត្តនឹងការសិក្សា តាមបែបអាឡារតាបសកាឡាមគោតទេ[៣], ទ្រង់និមន្តចេញពីទីនោះ ហើយចូលទៅកាន់សំណាក់ឧទកតាបសរាមបុត្រ ជាមហាគ្រូដែលមានឈ្មោះល្បីមួយរូបទៀត ដើម្បីស្វែងរកការសិក្សាបន្ត ។

ព្រះសមណគោតម មានប្រាជ្ញាញាណមុះមុតណាស់ បានសិក្សាត្រឹមតែរយៈពេលខ្លី ក៏យល់ដឹងអស់នូវលទ្ធិរបស់ឧទកតាបសនោះទៀត ដែលធ្វើឲ្យព្រះអង្គបានសម្រេច ត្រឹមតែនេវសញ្ញានាសញ្ញាយតនៈ ជាឈានថ្នាក់ខ្ពស់នៅក្នុងការអប់រំចិត្តនោះ[៤] ។ នៅពេលណាវិញ្ញាណបានក្លាយជាសភាវៈល្អិតទៅៗ ដោយការដុសខាត់ចិត្តឲ្យបរិសុទ្ធ ដែលមិនអាចនិយាយបានថា វិញ្ញាណនោះមាន ឬមិនមានឡើយ ។ មហាគ្រូបានផ្តល់កិត្តិយសដល់ព្រះសមណគោតម ឲ្យទទួលខុសត្រូវលើសាវ័កទាំង

---

[៣] មហាគ្រូទីមួយនេះ បានបង្រៀនព្រះពោធិសត្វ អំពីឈានដែលអាចឲ្យបានទៅកើតនៅក្នុងអរូបភព ។

[៤] មហាគ្រូទីពីរនេះ បានបង្រៀនព្រះពោធិសត្វ នូវការអភិវឌ្ឍន៍ខាងផ្លូវចិត្តដ៏ខ្ពស់បំផុតដែលធ្វើឲ្យបានទៅកើតនៅក្នុងស្ថានព្រហ្មនេវសញ្ញានាសញ្ញាយតនៈ ។

អស់ដូចជាគ្រូម្នាក់ ដោយពាក្យថា “នែសម្លាញ់ ! ខ្ញុំរីករាយណាស់ ដែលបានជួបតាបសគួរជាទីគោរពដូចរូបអ្នក, លទ្ធិដែលខ្ញុំបានចេះមក ឥឡូវនេះ អ្នកបានចេះអស់ហើយ ។ ចូរមកសម្លាញ់ហើយស្នាក់នៅទីនេះ, ចាប់ពីពេលនេះតទៅ យើងនឹងដឹកនាំសាវ័កទាំងអស់ជាមួយគ្នា” ។

ព្រះសមណគោតមនៅតែយល់ថា ដំណើរស្វែងរកមោក្សធម៌របស់ព្រះអង្គ មិនទាន់បានសម្រេចដល់ចំណុចគោលដៅទេ, មានតែព្រះនិព្វានប៉ុណ្ណោះទេ ទើបជាទីបញ្ចប់នៃសេចក្តីទុក្ខ, ទ្រង់មិនពេញចិត្តជាមួយនឹងការសិក្សា តាមបែបឧទកតាបសរាមបុត្រឡើយ ទើបនិមន្តបន្តដំណើរទៅមុខទៀត ។

ព្រះសមណគោតមគិតឃើញថា គ្មាននរណាម្នាក់មានសមត្ថភាពបង្រៀនព្រះអង្គ នូវអ្វីដែលទ្រង់កំពុងស្វែងរកនោះបានឡើយ, ទ្រង់លះបង់ចោលនូវការស្វែងរកជំនួយពីខាងក្រៅ ដើម្បីជួយដល់ការស្វែងរកសច្ចៈ និងសេចក្តីសុខពិត ដោយគិតថាសច្ចៈនិងសេចក្តីសុខ ពិតជាត្រូវបានរកឃើញនៅខាងក្នុងចិត្តយ៉ាងប្រាកដ ។

## បំពេញទុក្ករកិរិយា

ព្រះសមណគោតមជួបនូវការអស់សង្ឃឹមច្រើន ប៉ុន្តែព្រះអង្គមិនបានរារែកក្នុងចិត្តឡើយ, ទ្រង់បានស្វែងរកសេចក្តីសុខដ៏ខ្ពស់លើសលុប

មួយ ដែលមិនមានអ្វីប្រៀបផ្ទៀបបានឡើយ, ទ្រង់និមន្តត្រាច់ចរតាមផ្លូវ ឆ្ពោះទៅកាន់ទីក្រុងរាជគ្រឹះ ហើយបានបន្តនិមន្តទៅដល់ទីប្រជុំជនមួយ ឈ្មោះសេនានិគម ស្ថិតនៅក្នុងដែនដីស្រុកឧរុវេល ។ នៅទីនោះ ព្រះសមណគោតម បានសង្កេតឃើញដែនដីគួរឲ្យស្រឡាញ់ មានឧទ្យានប្រកបដោយរុក្ខជាតិដុះឡើងគួរឲ្យពេញចិត្ត, ស្ទឹងមានទឹកហូរតិចៗជាមួយនឹងគ្រាប់ខ្សាច់ល្អិតៗ ដែលផុសឡើងស-ក្បុស និងមានផ្លូវដើរឆ្លងកាត់គួររីករាយក្រៃលែង, ម្យ៉ាងទៀត ទីនោះស្ថិតនៅជិតភូមិអ្នកស្រុក ងាយស្រួលដល់ការនិមន្តចេញទៅ ដើម្បីស្វែងរកអាហារប្រចាំថ្ងៃផងដែរ ។ រឿងសំខាន់មួយទៀត ទីកន្លែងនោះមានលក្ខណៈងាយស្រួល ដល់ការចម្រើនសមាធិបរិស្ថានពោរពេញដោយសន្តិភាព និងព័ទ្ធជុំវិញដោយជួរភ្នំវែងៗ ជាទិដ្ឋភាពគួរជាទីរីករាយ ព្រមដោយទេសភាពគួរឲ្យស្រឡាញ់ ។ ព្រះសមណគោតមបានតាំងចិត្តថា ត្រូវតែគង់នៅទីនោះតែមួយអង្គឯង ដើម្បីធ្វើឲ្យគោលបំណងធំ របស់ព្រះអង្គបានសម្រេច ។

កោណ្ឌញ្ញៈជាឈ្មោះព្រាហ្មណ៍ម្នាក់ ដែលមានវ័យក្មេងជាងគេ នៅក្នុងចំណោមព្រាហ្មណ៍ ដែលបានទាយលក្ខណៈថ្វាយព្រះអង្គ កាលទ្រង់នៅជាព្រះសិទ្ធត្ថកុមារ និងកូនប្រុសរបស់ព្រាហ្មណ៍បួននាក់ផ្សេងទៀត មានឈ្មោះភទ្ទិយៈ វប្បៈ មហានាម និងអស្សជិ ដោយបានដឹងដំណឹងថា ព្រះ

សិទ្ធត្ថយាងចេញទៅបួសហើយ ក៏បានលះបង់ផ្ទះសម្បែង ចេញទៅបួសតាមព្រះអង្គដែរ ។

នៅក្នុងប្រទេសឥណ្ឌាសម័យបូរាណ ទង្វើដែលសំខាន់បំផុតនោះ គឺពិធីកម្មខាងសាសនា, ពិធីបុណ្យជាមង្គល, ការប្រព្រឹត្តតបៈ និងការបូជាយញ្ញថ្វាយដល់អាទិទេព ។ ជំនឿប្រកបដោយប្រជាប្រិយ៍ដើម្បីរំដោះខ្លួននេះ គឺមិនមានមធ្យោបាយណាមួយ ក្រៅពីការនាំជីវិតដើរតាមគន្លង នៃការប្រព្រឹត្តតបៈតឹងរ៉ឹងនោះឡើយ ។ រយពេលប្រាំមួយឆ្នាំគត់ ព្រះសមណគោតម បានប្រព្រឹត្តទុក្ករកម្មយ៉ាងតឹងតែងបំផុត រហូតដល់រូបកាយរបស់ព្រះអង្គ ក្លាយជាស្គមស្គាំងស្ទើរមើលលែងយល់, ទ្រង់បានធ្វើទារុណកម្មលើរូបកាយរបស់ព្រះអង្គផ្ទាល់ ហួសពីការរៀបរាប់បាន ។

## ការផ្ចាញ់មារ

ព្រះសមណគោតមបានធ្វើទុក្ករកម្មដ៏លំបាកនេះ អស់កាលដ៏យូរ តែមិនបាននាំមក នូវប្រយោជន៍ដល់ព្រះអង្គ សូម្បីត្រឹមតែបន្តិចឡើយ, អំពើនោះគ្រាន់តែធ្វើឲ្យលំបាកដល់រូបកាយ ឥតប្រយោជន៍តែប៉ុណ្ណោះ ។ ទោះបីព្រះសមណគោតម ធ្លាប់មានរូបកាយមាំមួនក៏ដោយ ឥឡូវនេះរូបកាយនេះមិនអាច សូម្បីត្រឹមតែក្រោកឈរបានឡើយ ។ រូបកាយដ៏សង្ហាររបស់ព្រះអង្គ ក្លាយជាស្វិតស្រពោនស្ទើរមើលមិនស្គាល់, សម្បុរដូចមាស

នៃរូបកាយនេះក្លាយជាស្តែកស្តាំង, ឈាមហាក់រីងស្ងួតហួតអស់ទៅ ឯសាច់សរសៃស្វិតស្រពោន ព្រះនេត្រទាំងគូប្រែជាងងឹត និងឃើញគួរឲ្យខ្លាច ។

នៅពេលនោះ មារចិត្តបាបបានចូលទៅជិតព្រះសមណគោតម ហើយពោលថា "នៃសមណៈ ! អ្នកមានរូបកាយស្គមកំព្រឹង ស្ទើរតែក្លាយជាពិការជនទៅហើយ ឬក៏ហៀបនឹងក្ស័យជីពជន្មទៅហើយ ។ ជាច្រើនពាន់ផ្នែកនៃរូបកាយរបស់អ្នក កំពុងឈានទៅរកសេចក្តីស្លាប់ហើយ, ឯផ្នែកដែលរស់នៅមានតែមួយប៉ុណ្ណោះ ។ នៃសមណៈ ! ចូររស់ឡើង, ជីវិតប្រសើរជាងអ្វីៗទាំងអស់ ។ ប្រសិនបើអ្នកមានជីវិតរស់នៅ អ្នកអាចធ្វើបុណ្យកុសលបានតាមចិត្តដែលអ្នកចង់ ។ ការរក្សាជីវិតឲ្យស្ថិតនៅក្នុងព្រហ្មចារីយ៍ ហើយបូជាភ្លើងទៅ អ្នកពិតជាទទួលបាននូវកុសលដ៏ច្រើនពុំខានឡើយ ។ តើអ្នកបានទទួលផលអ្វីខ្លះទៅ ជាមួយនឹងការតមអាហារបែបនេះហ្ន៎ ?, ឱសមណៈអើយ ! តាមពិតវាមិនមែនជាការងាយស្រួលក្នុងការប្រព្រឹត្តបែបនេះទៅឡើយ..." ។

ព្រះសមណគោតមឆ្លើយតបមារ[៥]ថា "ឱមារអើយ, អ្នកគឺជាញាតិនៃសេចក្តីប្រមាទ, តើអ្នកមកទីនេះបានផលប្រយោជន៍អ្វីខ្លះដល់ខ្លួនអ្នកទៅ ?

---

[៥] នៅក្នុងព្រះពុទ្ធសាសនា មារមាន៥យ៉ាង ១.ខន្ធមារ មារគឺខន្ធប្រាំ, ២.អភិសង្ខារមារ មារគឺបុណ្យនិងបាប, ៣.មច្ចុមារ មារគឺសេចក្តីស្លាប់, ៤.កិលេសមារ មារពោលគឺកិលេស និងទេវបុត្តមារ មារគឺទេវបុត្រ ។

ស្ងួម្បីបុណ្យកុសលតិចតួចបំផុតក៏មិនមានផង, មែនទេ ?។ ម្នាលមារ ! អ្នកគប្បីនិយាយដូច្នេះថា សទ្ធា គឺការជឿ, តបៈ គឺការគ្រប់គ្រងខ្លួនឯង, វិរិយៈ គឺសេចក្ដីព្យាយាម និងបញ្ញា គឺការដឹងច្បាស់ ហើយដែលកើតចេញមកពីវិបស្សនាញាណរបស់តថាគត ។ តើហេតុអ្វីក៏អ្នកនៅតែសួរតថាគតអំពីរឿងជីវិតនោះទៀត...?”។

“ស្ងួម្បីទឹកស្ទឹងទាំងឡាយ ក៏នឹងរីងស្ងួតទៅដោយកម្លាំងខ្យល់ ចុះហេតុអ្វីឈាមនៃបុគ្គលព្យាយាមរឹងមាំ រីងហួតទៅមិនបាន ? នៅពេលឈាមរីងហួតហើយ ប្រម៉ាត់ស្លេស្មក៏នឹងរីងហួតដែរ ។ នៅពេលសាច់របស់តថាគតស្វិតស្រពោនអស់ទៅ ចិត្តរបស់តថាគតនឹងបានភ្លឺថ្លាច្បាស់ ហើយបើធ្វើសតិឲ្យតាំងនៅក្នុងបញ្ញាបានហើយ សមាធិនឹងបានរឹងមាំមិនខាន” ។

“ពេលដែលតថាគតនៅមានជីវិត ចិត្តរបស់តថាគតមិនប្រកបដោយតណ្ហាឡើយ និងបានទ្រទ្រង់នូវភាពបរិសុទ្ធនៃជីវិតនេះ...” ។

-សត្រូវទីមួយរបស់តថាគតគឺរាគៈ(តម្រេក)និងកាមៈ(ប្រាថ្នា)

-សត្រូវទីពីរគឺ អរតិ (ការមិនពេញចិត្ត),

-សត្រូវទីបីគឺ ខុប្បិបាសៈ (ការស្រេក),

-សត្រូវទីបួនគឺ តណ្ហា (ចំណង់)

-សត្រូវទីប្រាំគឺ ថីនមិទ្ធៈ (ការងោកងុយ)

-សត្រូវទីប្រាំមួយគឺ ភយៈ (ការខ្លាច),

-សត្រូវទីប្រាំពីរគឺ វិចិកិច្ឆា (ការសង្ស័យ),

-សត្រូវទីប្រាំបីគឺ មក្ខៈ និង ថម្ភៈ (ការរមិលគុណ និងការចចេសរឹងរូស) ។

-សត្រូវទីប្រាំបួនគឺ លាភៈ (ការចង់បានតែផលប្រយោជន៍) សិលោកៈ (ការសរសើរ) សក្ការៈ (ចង់បានការគោរព) យសៈ (ចង់បានកិត្តិយស, កិត្តិស័ព្ទ),។

-សត្រូវទីដប់គឺការសរសើរខ្លួនឯង និងមើលងាយអ្នកដទៃ

នេះជាកងទ័ពរបស់តថាគត ជាអ្នកច្បាំងនឹងពួកពលមារ, កងទ័ពនោះមិនខ្លាចនឹងយកជ័យជំនះទេ ប៉ុន្តែជាជ័យជំនះនាំមកនូវសេចក្តីសុខ” ។

“ម្នាលមុញ្ជៈ[៦] តថាគតបានបង្ហាញអ្នកហើយតើ, តើអ្នកបានចំណេញប្រយោជន៍អ្វីខ្លះទៅ ពីជីវិតនៅក្នុងលោកនេះ ។ ចំពោះតថាគតវិញ ការស្លាប់នៅលើសមរភូមិប្រសើរជាងការរស់នៅ និងឈ្នះដទៃដោយខ្វះសីលធម៌ ! ” ។

---

[៦] មុញ្ជៈ គឺជាអ្នកចម្បាំងដែលពាក់ស្មៅមុញ្ជៈ មានរាងដូចសិរមាន់នៅលើក្បាល ឬដាវលំពែង ឬក៏ទង់បាដារបស់ពួកគេ ដើម្បីបង្ហាញថាពួកគេ នឹងមិនដកថយពីសមរភូមិឡើយ ។

ព្រះសមណគោតមបានបណ្តេញមារចេញ ជាមួយពាក្យពេចន៍ទាំងនេះ រួចធ្វើការអធិដ្ឋានប្តេជ្ញាចិត្តយ៉ាងរឹងមាំ ដើម្បីឲ្យបានសម្រេចគោលបំណង ជាព្រះពុទ្ធមួយអង្គ ។

## ផ្លូវកណ្តាល

ឥឡូវនេះ ព្រះសមណគោតម មានការជឿជាក់ក្នុងចិត្តយ៉ាងមាំ ព្រោះទ្រង់បានឆ្លងកាត់បទពិសោធមកយ៉ាងច្រើន ជាបទពិសោធគ្មានប្រយោជន៍ ដោយការប្រព្រឹត្តអត្តកិលមថានុយោគកម្ម, ទ្រង់បានលះបង់អំពើនោះចោលចេញ ហើយងាកមកដើរតាមផ្លូវត្រង់មួយ ហៅថាមជ្ឈិមបដិបទា ជាផ្លូវកណ្តាលប្រកបដោយអង្គប្រាំបី ។

ព្រះសមណគោតមបាននឹកឃើញពីរបៀប កាលដែលបិតារបស់ព្រះអង្គ បាននាំទ្រង់ទៅចូលរួមក្នុងពិធីបុណ្យច្រតព្រះនង្គ័ល, ទ្រង់អង្គុយពែនភ្នែន នៅក្រោមម្លប់ដ៏ត្រជាក់នៃដើមព្រឹងធំមួយ ហើយបានសម្រេចនូវបឋមជ្ឈាន ។ ព្រះអង្គបានគិតយ៉ាងច្បាស់ថា នេះគឺជាផ្លូវឆ្ពោះទៅកាន់ការត្រាស់ដឹង ។

ព្រះសមណគោតមយល់ច្បាស់ថា ការត្រាស់ដឹងមិនអាចសម្រេចបាន ជាមួយនឹងរូបកាយទន់ខ្សោយទេ, ដូច្នេះទ្រង់បានសម្រេចព្រះទ័យថា ត្រូវងាកមកឆាន់អាហារដូចធម្មតាវិញ ។ តាបសទាំងប្រាំរូប ដែលបានដើរ

តាមព្រះអង្គ អស់សង្ឃឹមក្នុងចិត្តយ៉ាងខ្លាំង ដោយបានឃើញការផ្លាស់ប្តូរវិធីប្រតិបត្តិ ដែលមិនគួរឲ្យគោរពរបស់ព្រះសមណគោតម ហើយក៏នាំគ្នាបោះបង់ព្រះអង្គចោល រួចធ្វើដំណើរទៅកាន់ព្រៃឥសីបតនមិគទាយវ័ន ។ ពួកគេនិយាយគ្នាថា "ព្រះសមណគោតម បានក្លាយជាអ្នកបួសម្នាក់លែងប្រតិបត្តិតឹងរ៉ឹងទៀតហើយ, ព្រះអង្គបានបញ្ឈប់ការតមអាហារ ហើយងាកទៅរកជីវិតងាយៗ ស្រួលៗវិញហើយតើ, វាពិតជាគួរឲ្យចង់សើចមែនទែនហ្ន៎" ។

បន្ទាប់ពីព្រះសមណគោតមឆាន់ចង្ហាន់ ដែលនាងសុជាតាបានថ្វាយមក ធ្វើឲ្យរូបកាយព្រះអង្គរឹងប៉ឹងឡើងវិញ រហូតបានសម្រេចនូវការត្រាស់ដឹង ។

## ការត្រាស់ដឹង

នៅរាត្រីថ្ងៃពេញបូណ៌មី ១៥កើត ខែវិសាខ ព្រះសមណគោតមគង់នៅក្រោមដើមអស្សត្ថព្រឹក្សដ៏ឧត្តមមួយ[៧] នៅតំបន់ពុទ្ធគយា ទ្រង់មានចិត្តស្ងប់និងបរិសុទ្ធក្រៃលែង ។ នៅក្នុងយាមទីមួយ ព្រះអង្គសម្រេចបាននូវ

---

[៧] មុនសម័យព្រះពុទ្ធត្រាស់ដឹង រុក្ខជាតិនេះមានឈ្មោះថា អស្សត្ថព្រឹក្ស ប្រែថាដើមឈើឲ្យប្រយោជន៍ដល់សត្វសេះ ។ ប៉ុន្តែចាប់ពីក្រោយព្រះសមណគោតម បានត្រាស់ដឹងនៅក្រោមដើមឈើនោះមក ក៏មានឈ្មោះថាដើមពោធិតមក ហើយកូនចៅនៃរុក្ខជាតិនេះ ត្រូវបានហៅថាដើមពោធិ រហូតមកដល់សព្វថ្ងៃ ។ ពោធិ ប្រែថា ត្រាស់ដឹង, ខ្មែរយើងហៅត្រឹមតែដើមពោធិ៍ប៉ុណ្ណឹង ។

វិជ្ជាទីមួយ ហៅថា បុព្វេនិវាសានុស្សតិញាណ ជាញាណរលឹកដល់ជាតិកំណើតទាំងអស់ ដែលមានពីអតីតកាលកន្លងមក, យាមទីពីរ ព្រះអង្គសម្រេចបាននូវវិជ្ជាទីពីរ ហៅថា ចុតូបបាតញ្ញាណ ជាញាណដឹងពីការចុះចាប់កំណើត និងការច្យុតទៅវិញរបស់សត្វលោក, ហើយយាមទីបី ជាយាមចុងក្រោយនៃរាត្រីនោះ ទ្រង់បានសម្រេចនូវវិជ្ជាទីបី ហៅថា អាសវក្ខយញ្ញាណ គឺញាណជាគ្រឿងកំចាត់ចោលនូវអាសវៈ ហើយបានសម្រេចការត្រាស់ដឹង សម្មាសម្ពោធិញ្ញាណដោយបរិបូណ៌ ។ នៅក្នុងព្រះជន្មគម្រប់៣៥វស្សា, ព្រះសមណគោតមបានសម្រេចនូវការត្រាស់ដឹង ហើយក៏ក្លាយជាព្រះពុទ្ធ[៨]មួយអង្គក្នុងលោក ។ ព្រះអង្គបានឧទ្ទិសពេលវេលា ដ៏មានតម្លៃនៃជីវិតរបស់ទ្រង់ និមន្តសម្ដែងធម៌ទេសនាប្រោសសត្វ ដែលមាននិស្ស័យគួរប្រោសបាន ។

ព្រះពុទ្ធគឺជាមនុស្សសាមញ្ញមួយរូប ទ្រង់បានប្រសូតឡើងនៅក្នុងលក្ខណៈជាមនុស្សធម្មតា រស់នៅក្នុងភាពជាមនុស្សធម្មតា និងស្លាប់ទៅវិញក៏ដូចមនុស្សធម្មតាដែរ ។ ព្រះអង្គជាមនុស្សម្នាក់ ប៉ុន្តែជាមនុស្សអស្ចារ្យ ។ ព្រះពុទ្ធទ្រង់បានសង្កត់ធ្ងន់លើរឿងនេះ ដោយទ្រង់មិនបំណងឲ្យ

---

[៨] ពុទ្ធ ចេញមកពីឫសពាក្យថា ពុធៈ ។ ព្រះអង្គមានព្រះនាមថា ព្រះពុទ្ធ ពីព្រោះព្រះអង្គបានត្រាស់ដឹង នូវអរិយសច្ចៈទាំងបួន, តាមធម្មតាសាវ័ករបស់ព្រះអង្គតែងហៅព្រះអង្គថា ព្រះបរមគ្រូ, ព្រះភគវា ។ល។ ទ្រង់បានហៅខ្លួនព្រះអង្គឯង ថា តថាគត ប្រែថា អ្នកដែលមានមកយ៉ាងនេះ ។

នរណាម្នាក់យល់ខុសថា ព្រះអង្គគឺជាមនុស្សអមតៈឡើយ ។ ព្រះអង្គដាស់តឿនសាវ័កទាំងអស់ ឲ្យពឹងលើខ្លួនឯងផ្ទាល់ ដើម្បីរំដោះខ្លួននិងកំចាត់កិលេស ព្រមទាំងធ្វើខ្លួនឲ្យបានបរិសុទ្ធល្អ ដោយត្រាស់ថា “អ្នកគួរតែធ្វើការព្យាយាមដោយខ្លួនឯង, ព្រះតថាគតគ្រាន់តែជាអ្នកបង្រៀនប៉ុណ្ណោះឯង” ។

ព្រះពុទ្ធគ្រាន់តែចង្អុលប្រាប់ផ្លូវ ហើយបន្សល់ផ្លូវនោះទុកឲ្យយើងទាំងអស់គ្នាដើរតាម ដែលជាផ្លូវសម្រាប់ជួយខ្លួនយើង ។ ការពឹងអ្នកដទៃឲ្យជួយរំដោះខ្លួនគឺជារឿងអវិជ្ជមាន, ការពឹងលើខ្លួនឯងវិញទើបជារឿងវិជ្ជមាន ។ ការពឹងពាក់អ្នកដទៃមានន័យថា ព្រមចុះចាញ់លើការខិតខំប្រឹងប្រែងរបស់ខ្លួន ។

ព្រះអង្គចាប់ផ្ដើមពីមនុស្សសាមញ្ញម្នាក់ រហូតបានទៅជាព្រះពុទ្ធ ហើយបានប្រកាសប្រាប់ពិភពលោក នូវសមត្ថភាពដ៏កំបាំង និងអំណាចប្រកបដោយប្រឌិតញ្ញាណរបស់មនុស្ស ជំនួសអាទិទេព ដែលមានឫទ្ធិអំណាចច្រើន និងមិនអាចមើលឃើញដោយមនុស្សឡើយ ។ ព្រះអង្គបានធ្វើជំនឿនោះឲ្យមានប្រយោជន៍ ដោយលើកឡើងនូវតម្លៃនៃមនុស្សធម៌, ទ្រង់បានបង្រៀនថា មនុស្សអាចរំដោះខ្លួនពីសេចក្ដីទុក្ខបាន ដោយការព្យាយាមផ្ទាល់ខ្លួន, គ្មានការពឹងពាក់លើអាទិទេព ឬពួកអ្នកបួសណាមួយដើម្បីឲ្យជួយសម្របសម្រួល ឬក៏ធ្វើការបូជាយញ្ញនិងការបួងសួងឡើយ

ព្រះអង្គបានជំទាស់ទៅនឹងការចែកវណ្ណៈ ទ្រង់ពន្យល់ពីភាពស្មើគ្នានៃមនុស្សគ្រប់រូប, ហើយទ្រង់បានប្រកាសថា ទ្វារនៃជោគជ័យនិងភាពរុងរឿងបានបើកចំហរសម្រាប់អ្នកទាំងអស់គ្នា ។

ព្រះសមណគោតម បានបើកសេរីភាពយ៉ាងពេញលេញខាងផ្នែកគំនិត ទ្រង់ឲ្យយើងខំប្រឹងបើកភ្នែកខ្លួនយើង ដើម្បីសម្លឹងមើលឲ្យឃើញនូវធម្មជាតិពិត, ទ្រង់បានលើកទឹកចិត្តមនុស្សដោយព្រះធម៌ទេសនារបស់ព្រះអង្គ ។ ព្រះពុទ្ធបានជួយផ្គត់ផ្គង់ដល់អ្នកជម្ងឺ ដែលគេបានបោះបង់ហើយ, ទ្រង់ជួយអ្នកក្រីក្រដែលគេមិនបានយកចិត្តទុកដាក់ ។ ព្រះអង្គបានលើកដម្កើងជីវិតមនុស្សទន់ទាប និងបានធ្វើនូវបន្សុទ្ធកម្មដល់ជីវិតដែលស្ទើរតែស្អុយរលួយហើយ, ជាមួយគ្នានេះដែរទ្រង់លើកទឹកចិត្ត និងបង្រួបបង្រួមឡើងវិញនូវការបែកបាក់, ទ្រង់បានត្រាស់ដឹងដោយព្រះអង្គឯង ហើយបានធ្វើឲ្យភ្លឺច្បាស់នូវអ្វីដែលអាថ៌កំបាំង, ទ្រង់បានប្រាប់ផ្លូវដល់អ្នកដែលយល់ខុស ។ ព្រះពុទ្ធបានស្ថាបនាឡើងវិញនូវគ្រឹះ និងបានធ្វើឲ្យមានកិត្តិយសដល់ពួកអភិជន ទាំងអ្នកមានក្តី អ្នកក្រក្តី បណ្ឌិតក្តី ពាលក្តី ស្តេចដែលល្មោភអំណាច និងស្តេចត្រឹមត្រូវ, ព្រះអង្គម្ចាស់ដែលមានកិត្តិស័ព្ទរន្ទឺ សេដ្ឋីមានចិត្តល្អ និងសេដ្ឋីមានចិត្តកំណាញ់, មនុស្សដើររកអាហារដោយខ្លួនឯង ឬមនុស្សត្រូវគេជិះជាន់ ឃាតកកំណាចទាំងឡាយ ស្រីពេស្យាដែលគួរឲ្យស្អប់... ដែលទាំងអស់គ្នា សុទ្ធសឹងតែបាទទួលផល

ប្រយោជន៍ពីប្រាជ្ញាញាណ និងមហាករុណារបស់ព្រះអង្គ ។ ឧទាហរណ៍សារនៃសន្តិភាពរបស់ព្រះអង្គ ត្រូវបានទទួលអបអរសាទរដោយមនុស្សទាំងអស់គ្នា ជាមួយនឹងចិត្តរីករាយ ដែលមិនអាចបរិយាយបាន ។

# ២. ក្រោយការត្រាស់ដឹង

## ឧទានគាថា

ជាតិកំណើតដ៏ច្រើននៅក្នុងវាលវដ្តសង្សារនេះ ដែលតថាគតបានត្រាច់រង្គត់ ដើម្បីស្វែងរកជាងផ្ទះ, ប៉ុន្តែមិនបានជួបប្រទះឡើយ ។ ជាតិកំណើតប្រកបដោយសេចក្តីទុក្ខដដែលៗ ។ ម្នាលជាងផ្ទះ ! ស្នាដៃរបស់អ្នក យើងបានរកឃើញហើយ, ឥឡូវនេះអ្នកមិនអាចសង់ផ្ទះឲ្យតថាគតបានទៀតឡើយ, ព្រោះឆ្អឹងជំនីគឺបង្កង់ និងផ្ទោងជាររបស់អ្នក ត្រូវបានកាច់បំបាក់អស់ហើយ, មេដំបូលរបស់អ្នកក៏ត្រូវបានវាយបំបែកខ្ចាត់ខ្ចាយអស់ដែរ, ចិត្តរបស់តថាគតបានដល់ហើយនូវអសង្ខតធម៌, ចិត្តតថាគតបានទៅដល់ទីបំផុតនៃតណ្ហាហើយ ។

## សត្តមហាស្ថាន

ថ្ងៃប្រកបដោយនក្ខត្តឫក្សមួយ នៅមុនពេលត្រាស់ដឹង ព្រះសមណគោតមបានឆាន់មធុបាយាស ជាអាហារពិសេសម្យ៉ាង ដែលនាងសុជាតាជាស្ត្រីមានចិត្តជ្រះថ្លាពីកំណើត បាននាំមកថ្វាយព្រះអង្គ ។ បន្ទាប់ពីការបានត្រាស់ដឹង ក្នុងរយៈពេលប្រាំពីរសប្តាហ៍មក ព្រះពុទ្ធអង្គមិនសោយ

អាហារទេ, ទ្រង់គង់នៅក្រោមដើមពោធិព្រឹក្ស និងនៅក្នុងទីផ្សេងៗទៀត ជុំវិញទីស្ថាននោះ ។

សប្តាហ៍ទី១ ព្រះពុទ្ធគង់នៅក្រោមដើមពោធិព្រឹក្ស ក្នុងឥរិយាបថតែមួយ មិនកម្រើកព្រះកាយ, ទ្រង់រីករាយនឹងវិមុត្តិសុខ ដែលព្រះអង្គបានទទួល, ហើយនៅថ្ងៃទី៧ ព្រះអង្គក្រោកចេញពីគល់ពោធិព្រឹក្សជាទីត្រាស់ដឹង ។ នៅយាមទីមួយ នៃរាត្រីនោះទ្រង់ពិចារណាទៅដល់ធម្មជាតិ ដែលកើតបន្តគ្នាជាអនុលោម ហៅថា "បដិច្ចសមុប្បាទ" ទៅតាមលំដាប់ថា "នៅពេលដែលនេះមាន នោះក៏មានដែរ, បើហេតុកើតឡើង ផលក៏កើតឡើងដែរ" ។ នៅយាមទីពីរនៃរាត្រីដដែលនោះ ព្រះអង្គពិចារណាយ៉ាងជ្រៅទៅដល់ការរលត់ជាបដិលោម តាមលំដាប់ថា "បើនេះមិនមាន នោះក៏មិនមាន ។ បើហេតុមិនមាន ផលក៏មិនមានដែរ, បើហេតុរលត់ទៅ ផលក៏រលត់ទៅដែរ" ។ នៅយាមទីបីនៃរាត្រីដដែលនោះ ព្រះអង្គទ្រង់បានពិចារណា ពីការកើតឡើងអាស្រ័យគ្នាតាមលំដាប់ ជាអនុលោមនិងជាបដិលោមដូច្នេះថា "នៅពេលនេះមាន នោះក៏មាន, បើហេតុមាន ផលក៏មានដែរ, បើនេះមិនមាន នោះក៏មិនមានដែរ, បើហេតុមិនមានផល ក៏មិនមានដែរ, បើហេតុរំលត់ហើយ ផលក៏រលត់ដែរ" ។

ក្នុងសប្តាហ៍ទី២ ព្រះពុទ្ធគង់នៅលើអនិមិស្សចេតីយ៍ សម្លឹងមើលដើមពោធិព្រឹក្ស ប្រកបដោយការដឹងគុណក្រៃលែង ព្រោះដើមពោធិព្រឹក្ស

នោះ បានផ្តល់ម្លប់ដ៏ត្រជាក់ថ្វាយព្រះអង្គ ក្នុងពេលគង់ចម្រើននូវព្រះអានាបានុស្សតិកម្មដ្ឋាន និងការផ្ចាញ់មារាធិរាជព្រមទាំងសេនាដ៏ច្រើនរហូតដល់បានត្រាស់ដឹង ។ ក្នុងរយៈពេល៧ថ្ងៃនេះ ព្រះអង្គទ្រង់ឈរសម្លឹងទៅរកដើមពោធិព្រឹក្ស គ្មានព្រិចព្រះនេត្រឡើយ ។

សប្តាហ៍ទី៣ ព្រះពុទ្ធបាននិមន្តដើរចង្រ្កមចុះឡើងៗ នៅក្បែរដើមពោធិព្រឹក្ស ហៅថា "រតនចង្កមៈ" ។

សប្តាហ៍ទី៤ ព្រះអង្គគង់សមាធិនៅក្នុងផ្ទះកែវ ហៅថា "រតនឃរៈ" ដើម្បីពិចារណាព្រះអភិធម្ម ។

សប្តាហ៍ទី៥ ព្រះអង្គគង់នៅក្រោមដើមអជបាលនិគ្រោធ នៅជិតបរិវេណដើមពោធិព្រឹក្ស ។ នៅទីនោះព្រះអង្គគង់នៅក្នុងឥរិយាបថតែមួយក្នុងរយៈពេលប្រាំពីរថ្ងៃពេញ, ទ្រង់រីករាយនឹងវិមុត្តិសុខ ដែលបានមកពីការត្រាស់ដឹង ។ នៅពេលព្រះអង្គចេញចាកសមាធិ តុច្ឆព្រាហ្មណ៍បានចូលទៅរកព្រះពុទ្ធអង្គ ហើយទូលសួរថា: "បពិត្រព្រះសមណគោតម តើព្រះអង្គយល់យ៉ាងដូចម្តេចដែរ ចំពោះបុគ្គលដែលហៅថាព្រាហ្មណ៍ៗនោះ? ហើយអ្វីទៅដែលធ្វើបុគ្គលឲ្យទៅជាព្រាហ្មណ៍ ? " ។

ព្រះពុទ្ធបន្លឺនូវវាចាតបថា "ជនឯណាបានលះបង់ចោលនូវអំពើបាបហើយ មិនពោលពាក្យអំនួត មានពាក្យថា ហុំ ហុំ លះបង់ចោលហើយ, មិនមានកិលេសជាគ្រឿងសៅហ្មង, គ្រប់គ្រងខ្លួនបានល្អហើយ,

មានចំណេះដឹងក្នុងវេទ (គឺមគ្គញ្ញាណទាំង៤) ជាបុគ្គលបានដឹកនាំជីវិតទៅតាមផ្លូវល្អ គួរហៅគាត់ថាព្រាហ្មណ៍ ម្យ៉ាងទៀតព្រាហ្មណ៍ឯណា មិនមានការរីករាយក្នុងគំនរ គឺរាគាទិកិលេសក្នុងអារម្មណ៍បន្តិចបន្តួច ក្នុងលោកសន្និវាសនេះ ជននោះគួរនឹងហៅខ្លួនថាព្រាហ្មណ៍ដោយធម៌បាន” ។

ព្រះពុទ្ធសមណគោតម បានយាងចេញពីដើមអជបាលនិគ្រោធ បន្តដំណើរទៅកាន់ស្រះមុច្ចលិន្ទ, ទ្រង់គង់នៅទីនោះនៅក្នុងសប្តាហ៍ទី៦ ។ នៅស្រះមច្ចុលិន្ទ ព្រះពុទ្ធបានគង់នៅរយៈពេលប្រាំពីរថ្ងៃ ដើម្បីសោយវិមុត្តិសុខ ។ ទីនោះដែរ ក៏មានហេតុការណ៍អស្ចារ្យមួយកើតឡើង ដែលពុំធ្លាប់មានពីមុន គឺមហាមេឃបង្អុរភ្លៀងយ៉ាងខ្លាំង រយៈពេលប្រាំពីរយប់ប្រាំពីរថ្ងៃ ដែលបណ្តាលឲ្យមានទឹកជោរជន់ឡើង និងមានអាកាសធាតុត្រជាក់យ៉ាងខ្លាំង ។

គ្រានោះ មុច្ចលិន្ទជាស្តេចនាគរាជបានចេញមក ហើយរមូរខ្លួនព័ទ្ធជាភ្នែនចំនួនប្រាំពីរជុំធ្វើជាបល្ល័ង្ក និងផើបក្បាលបើកពពារដ៏ធំ គ្របពីលើព្រះកេសរបស់ព្រះពុទ្ធអង្គ ដើម្បីការពារទឹក ខ្យល់ របោម សុច មមង់ សត្វល្អូន និងកំដៅថ្ងៃថ្វាយព្រះពុទ្ធអង្គ ។

ប្រាំពីរថ្ងៃគត់ ទើបពពកខ្មៅរសាត់បាត់អស់ពីផ្ទៃមេឃ នាគមុច្ចលិន្ទក៏រើខ្លួនចេញពីព្រះអង្គ ហើយកាឡាខ្លួនពីសត្វនាគរាជ[៩]ទៅជាបុរសវ័យក្មេងមួយរូប ឈរប្រណមហត្ថា នៅចំពោះមុខព្រះមានព្រះភាគ ។

នៅពេលនោះ ព្រះពុទ្ធអង្គឧទានឡើងថាៈ

“សេចក្តីស្ងាត់ចាកកិលេសរបស់បុគ្គលត្រេកអរ (ដោយមគ្គញាណ) មានធម៌ប្រាកដហើយ បានឃើញធម៌ (ដោយញាណចក្ខុ) ជាគុណឲ្យកើតសេចក្តីសុខ, ការមិនព្យាបាទ និងការសង្រួមមិនបៀតបៀនសត្វទាំងឡាយ ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក, ការនឿយណាយចាករាគៈ និងការប្រព្រឹត្តកន្លងកាមទាំងឡាយ ជាគុណឲ្យកើតសេចក្តីសុខក្នុងលោក, កិរិយាកំចាត់បង់នូវអស្មិមានៈឯណា កិរិយាកំចាត់បង់នូវអស្មិមានៈនោះ ជាសុខក្រៃលែង ។

សប្តាហ៍ទី៧ ព្រះពុទ្ធគង់នៅក្រោមដើមរាជាយតនៈ “ដើមកែស” នៅទីនោះ ព្រះអង្គទ្រង់គង់នៅក្នុងឥរិយាបថតែមួយ រយៈពេលប្រាំពីរថ្ងៃ ហើយទ្រង់សោយនូវវិមុត្តិសុខដោយរីករាយ។

---

[៩] ស្តេចនាគនេះមិនអាចទៅជាមនុស្សទេ ។ សេចក្តីនៅក្នុងវិន័យបាននិទាន ពីរឿងរ៉ាវគួរឲ្យចាប់អារម្មណ៍បំផុត របស់នាគរាជដែលក្លែងរូបជាមនុស្ស ហើយរស់នៅមួយរយៈដូចជាភិក្ខុសង្ឃមួយអង្គ ។

# ប្រាសនាយពាណិជពីរនាក់

នៅពេលនោះ មានអ្នកជំនួញពីរនាក់ជាបងប្អូន, បងឈ្មោះបុស្ស: និងប្អូនឈ្មោះភល្លិក: ។ ឈ្មួញទាំងពីររូបនេះ ធ្វើដំណើរត្រឡប់មកពីស្រុកឧក្កលា (សព្វថ្ងៃនេះ គឺជារដ្ឋអូរីស្សា ប្រទេសឥណ្ឌា) ទៅកាន់ស្រុកភូមិរបស់ពួកគេ ។ មានទេវតាមួយអង្គធ្លាប់ជាញាតិ នៃបុរសទាំងពីរនាក់នោះ បាននិយាយប្រាប់ពួកគេ ដោយសេចក្ដីដូចខាងក្រោម:

“នែបុរសដ៏ចម្រើន! ព្រះមានព្រះភាគកំពុងគង់នៅទៀបគល់ដើមរាជាយតនៈ, ព្រះអង្គទើបតែបានត្រាស់ដឹងថ្មីៗ ។ ចូរអ្នកទៅកាន់ទីនោះ ហើយថ្វាយសាដូវផង់និងទឹកឃ្មុំ ដល់ព្រះអង្គនោះទៅ, អ្នកនឹងបានទទួលផលជាសេចក្ដីសុខ-ចម្រើន អស់កាលជាអង្វែង” ។

គ្រានោះ នាយពាណិជទាំងពីរនាក់បងប្អូន បាននាំយកសាដូវផង់និងទឹកឃ្មុំ ហើយចូលទៅរកព្រះពុទ្ធអង្គ រួចទូលថា:

“ភន្តេ បពិត្រព្រះមានព្រះភាគដ៏ចម្រើន ! សូមព្រះអង្គមេត្តាទទួលយកនូវសាដូវផង់និងទឹកឃ្មុំនេះ ដើម្បីសេចក្ដីសុខនិងសេចក្ដីចម្រើន ដល់ខ្ញុំព្រះអង្គអស់កាលជាអង្វែង” ។

ព្រះពុទ្ធទ្រង់ត្រាស់តបថា:

“ប្រពៃណីរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ មិនដែលទទួលអាហារដោយផ្ទាល់ដៃទេ, តថាគតទទួលសាដូវផង់និងទឹកឃ្មុំ របស់អ្នកបានយ៉ាងដូចម្ដេចទៅ ? ”

គ្រានោះ មហារាជទាំងបួនបានជ្រាបពីព្រះតម្រិះ របស់ព្រះពុទ្ធបរមគ្រូ ហើយក៏យាងចេញមកពីទិសទាំងបួន នាំយកបាត្រថ្មមួយៗ[១០] មកថ្វាយដល់ព្រះពុទ្ធអង្គ ដោយពោលពាក្យថា:

“បពិត្រព្រះមានព្រះភាគដ៏ចម្រើន ! សូមព្រះមានព្រះភាគទទួលយកនូវសាដូវផង់ និងទឹកឃ្មុំនេះតាមការគួរចុះ” ។

ព្រះពុទ្ធបរមគ្រូទទួលយកបាត្រថ្មនោះ ពីមហារាជទាំងបួន ជាស្ដេចចតុលោកបាល រួចទទួលសាដូវផង់និងទឹកឃ្មុំ ដោយបាត្រនោះ និងឆាន់នៅពេលនោះទៅ ។

ពេលព្រះពុទ្ធបញ្ចប់ការឆាន់អាហារ នាយពាណិជទាំងពីរនាក់បងប្អូន ក៏បង្អោនខ្លួនថ្វាយបង្គំព្រះពុទ្ធអង្គ ហើយពោលនូវពាក្យថា:

“បពិត្រព្រះមានព្រះភាគ យើងខ្ញុំព្រះអង្គសូមយកព្រះពុទ្ធ ព្រះធម៌ ជាទីពឹងទីរលឹក ។ សូមព្រះមានព្រះភាគរាប់យើងខ្ញុំជាឧបាសក យកព្រះ

[១០] បាលីអដ្ឋកថាបញ្ជាក់ថា ព្រះពុទ្ធអធិដ្ឋានបាត្រទាំងបួននេះ បញ្ចូលឲ្យនៅតែមួយ

ពុទ្ធព្រះធម៌[១១] ជាទីពឹងចាប់អំពីថ្ងៃនេះតទៅ” ។ នាយពាណិជទាំងពីរនាក់បងប្អូននេះ បានក្លាយជាសាវ័កដំបូងគេ ដែលបានដល់នូវទ្វេចិកសរណគមន៍ នៅក្នុងព្រះពុទ្ធសាសនានេះ ។

[១១] ព្រះពុទ្ធ និង ព្រះធម៌ (ពុទ្ធំ សរណំ គច្ឆាមិ, ធម្មំ សរណំ គច្ឆាមិ) ចំណែកព្រះសង្ឃពុំទាន់មានទេពេលនោះ ។ បាលីអដ្ឋកថាជាតកបានបញ្ជាក់ នៅពេលនាយពាណិជទាំងពីររូបនេះ បានថ្វាយខ្លួនជាសាវ័កហើយ ក៏បានទូលសុំព្រះពុទ្ធអង្គ នូវវត្ថុសម្រាប់គោរពបូជា ។ ព្រះពុទ្ធបានយកព្រះហស្តស្ទាបព្រះកេស ហើយប្រទាន ដល់ពួកគេនូវសក់ចំនួន៨សរសៃ ។

# ៣. ការសម្តែងព្រះធម៌

## និមន្តចេញប្រោសសត្វ

គ្រានោះ ព្រះពុទ្ធបរមគ្រូ គង់នៅក្នុងទីស្ងប់ស្ងាត់តែមួយអង្គ នៅក្រោមដើមអជបាលនិគ្រោធ ទ្រង់មានព្រះតម្រិះថា "តថាគតត្រាស់ដឹងព្រះធម៌នេះ បានដោយលំបាកណាស់ ពីព្រោះព្រះធម៌នេះ មិនងាយស្រួលដល់ការយល់ដឹង សម្រាប់សត្វលោកដែលក្រាស់ដោយ រាគៈ ទោសៈ មោហៈទេ ។ សត្វលោកក្រាស់ដោយកាម រុំព័ទ្ធដោយភាពងងឹតគឺអវិជ្ជា មិនអាចមើលឃើញច្បាស់នូវព្រះធម៌ឡើយ, ព្រះធម៌នេះមានគម្ភីរភាព និងល្អិតសុខុមក្រៃលែង" ។ ព្រះពុទ្ធអង្គទ្រង់គង់ក្នុងភាពស្ងប់ស្ងៀម ទ្រង់មិនសម្តែងធម៌ ដែលព្រះអង្គបានត្រាស់ដឹងនោះ ដល់សត្វលោកភ្លាមៗទេ ។

គ្រានោះឯង មានព្រហ្មមួយអង្គឈ្មោះសហម្បតី បានជ្រាបពីព្រះតម្រិះរបស់ព្រះពុទ្ធហើយ ក៏គិតក្នុងចិត្តថា "លោកនេះនឹងវិនាសធំហើយ ដោយសារការមិនបានស្តាប់ ព្រះធម៌នេះជាក់មិនខាន" ហើយក៏ចូលទៅរកព្រះសម្មាសម្ពុទ្ធ រួចពោលអារាធនានិមន្តព្រះអង្គ ឲ្យសម្តែងធម៌ដោយពាក្យថា:

“បពិត្រព្រះមានព្រះភាគដ៏ចំរើន ! សូមព្រះដ៏មានព្រះភាគសម្តែងធម៌, សូមព្រះសុគតសម្តែងធម៌ ត្បិតសត្វទាំងឡាយដែលមានធូលី គឺរាគាទិកិលេសស្រាលស្តើងក្នុងភ្នែក តែខានស្តាប់ព្រះធម៌ហើយ មុខជានឹងសាបសូន្យមិនខាន, សត្វទាំងឡាយបម្រុងនឹងត្រាស់ដឹងនូវធម៌ ក៏គង់មានដែរ” ។

នៅសម័យបូរាណ ដែនមគធៈជាទីកើតឡើងនូវព្រះធម៌ ព្រោះមានភាពមិនបរិសុទ្ធកើតឡើង និងចម្រើនដោយអំពើអាក្រក់គ្រប់យ៉ាងបណ្តាលមកពីកង្វះសីលធម៌ ។ ទ្វារនៃអមតៈបានរបើកហើយ សូមសត្វលោកនាំគ្នាស្តាប់ព្រះធម៌ និងយល់ច្បាស់នូវព្រះធម៌ ដោយមិនមានភាពសៅហ្មងឡើយ ដូចជាបុគ្គលក្រោកឈរនៅលើកំពូលភ្នំ អាចមើលឃើញទិដ្ឋភាពដែលនៅជុំវិញបាន, សូម្បីបុគ្គលមានប្រាជ្ញា ក៏អាចមើលឃើញនូវអ្វីៗទាំងអស់បាន ហើយឡើងទៅលើរាជវាំងនៃព្រះធម៌ ជាបុគ្គលមិនមានទុក្ខព្រួយ តែងសម្លឹងចុះក្រោម មើលនូវពពួកមនុស្សដែលលិចលង់ក្នុងសេចក្តីទុក្ខ និងនៅក្នុងអំណាចនៃជាតិជរា” ។

“ព្រះដ៏មានជោគកើតឡើងហើយ ជាអ្នកមានជ័យជំនះនៅលើសមរភូមិ ជានាយសារថី ជាបុគ្គលរួចពីបំណុល និងជាអ្នកត្រាច់ចរទៅក្នុងលោក, សូមព្រះដ៏មានព្រះភាគ មេត្តាសម្តែងនូវព្រះធម៌ ត្បិតថានឹងមានសត្វលោកខ្លះ អាចយល់បាននូវព្រះធម៌នោះ” ។

នៅពេលសហម្បតិព្រហ្ម ទូលអារាធនាព្រះពុទ្ធអស់វារៈបីដង, ព្រះអង្គទ្រង់ពិចារណាមើលសត្វលោក ប្រកបដោយពុទ្ធតម្រិះយ៉ាងជ្រៅដូចមហាសមុទ្រ ។

ការទតមើលដោយពុទ្ធតម្រិះ ចំពោះសត្វលោកយ៉ាងនេះ ព្រះអង្គបានជ្រាបដោយពុទ្ធញាណថា សត្វទាំងឡាយមានធូលីនៅក្នុងភ្នែកតិចតួចក៏មាន ច្រើនក៏មាន ជាមួយនឹងប្រាជ្ញាវាងវៃនិងល្ងង់ខ្លៅ, ជាមួយនឹងចរិតល្អនិងមិនល្អ ជាសត្វងាយឬលំបាកដើម្បីបង្រៀន, ពួកជនតិចតួចដែលរស់នៅ តែងបានដឹងពីផលនៃអំពើអាក្រក់ ទៅក្នុងកំណើតអនាគត ។

ដោយហេតុនោះហើយ ព្រះពុទ្ធអង្គក៏ទទួលយល់ព្រមតាមការអារាធនារបស់សហម្បតិព្រហ្ម ដោយមានព្រះវាចាថា:

“ទ្វារទាំងឡាយនៃព្រះនិព្វានរបើកហើយ ពួកជនណាដែលមានសោតបសាទល្អ សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធាចុះ ។ ម្នាលមហាព្រហ្ម! តថាគតមិនបានបង្ហាញការបៀតបៀនទេ ដើម្បីសម្តែងព្រះធម៌ក្នុងសំណាក់មនុស្សទាំងឡាយ ជាព្រះធម៌ដែលតថាគតស្មាត់ហើយ ជាធម៌ដ៏ឧត្តម” ។

សហម្បតិព្រហ្មមានចិត្តត្រេកអរណាស់ រួចត្រិះរិះថា: “យើងនឹងធ្វើដោយខ្លួនយើងផ្ទាល់នូវឱកាសល្អនេះ ចំពោះព្រះមានព្រះភាគ ដើម្បីឲ្យ

ព្រះអង្គសម្ដែងព្រះធម៌” រួចក៏ថ្វាយបង្គំព្រះពុទ្ធអង្គដោយសេចក្ដីគោរព ហើយក៏បាត់ខ្លួនពីទីនោះមួយរំពេចទៅ ។

## ផ្លូវទៅក្រុងពារាណសី

ព្រះពុទ្ធអង្គទ្រង់មានព្រះតម្រិះ នៅមុនពេលព្រះអង្គចេញដំណើរនិមន្តទៅសម្ដែងធម៌ថា “តើតថាគតគួរសម្ដែងធម៌ប្រោសនរណាមុនគេទៅ ? តើនរណាទៅដែលអាចយល់ព្រះធម៌នេះបានឆាប់រហ័ស ? ”។ អាឡារតាបសកាឡាមគោត្រ ជាមហាគ្រូចាស់ជាមនុស្សឈ្លាសវៃ មានបញ្ញាខ្ពស់ ហើយមានធូលីតិចតួចនៅក្នុងភ្នែក ។ តើតថាគតទៅសម្ដែងធម៌ ដល់គាត់យ៉ាងដូចម្ដេចទៅ ? តើគាត់អាចយល់ធម៌នោះបានឆាប់រហ័សទេហ្ន៎ ?” ។

ខណៈនោះ មានទេវតាមួយអង្គប្រាកដឡើង នៅចំពោះព្រះភ័ក្ត្រព្រះដ៏មានព្រះភាគហើយទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ! អាឡារតាបសកាឡាមគោត្រ បានស្លាប់កន្លងទៅមួយសប្ដាហ៍ហើយ ។ ព្រះពុទ្ធទ្រង់បានជ្រាបរឿងនោះ ដោយទិព្វចក្ខុពិតដូចជាទេវតាទូលមែន, បន្ទាប់ពីនោះមកទ្រង់នឹកទៅដល់ឧទកតាបសរាមបុត្រ, តែទេវតានោះបានទូលព្រះអង្គទៀតថា មហាគ្រូនោះក៏បានស្លាប់តាំងពីល្ងាចម្សិលម៉ិញដែរ ។ ព្រះអង្គបានជ្រាបរឿងនោះដោយទិព្វចក្ខុ ថាបានកើតឡើងយ៉ាងនោះពិតប្រាកដមែន ។

នៅទីបំផុត ព្រះអង្គបានគិតទៅដល់បញ្ចវគ្គិយតាបស ដែលធ្លាប់គាល់បម្រើ ក្នុងពេលដែលព្រះអង្គកំពុងស្វែងរកមោក្ខធម៌ ដើម្បីបានត្រាស់ដឹង ។ ទិព្វចក្ខុរបស់ព្រះអង្គខុសពីចក្ខុរបស់មនុស្សធម្មតា ហេតុនោះព្រះអង្គអាចទ្រង់ជ្រាបថា ពួកបញ្ចវគ្គិយតាបសទាំងនោះ កំពុងគង់នៅព្រៃឥសីបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ គ្រានោះ ព្រះពុទ្ធអង្គទ្រង់បានគង់អាស្រ័យនៅឯឧរុវេលនិគម ជាចម្ងាយផ្លូវមួយ ដែលព្រះអង្គត្រូវចេញដំណើរទៅកាន់ក្រុងពារាណសី ។

ព្រះពុទ្ធយាងចេញពីតំបន់គយា ទៅកាន់ក្រុងពារាណសី, នៅតាមផ្លូវទ្រង់បានជួបអាជីវកឈ្មោះឧបកៈ ជាអ្នកដើរគ្មានគោលដៅ ។ ឧបកាជីវកបានជួបព្រះពុទ្ធហើយ ក៏ទូលសួរព្រះអង្គថាៈ

“នែសម្លាញ់ ! អ្នកមានឥន្ទ្រីយ៍ស្រគត់ស្រគំល្អណាស់, ពណ៌សម្បុររបស់អ្នកក៏ភ្លឺថ្លាផូរផង់ដែរ ។ សូមសម្លាញ់ប្រាប់យើងមើល តើអ្នកបួសឧទ្ទិសចំពោះគ្រូណាទៅ ? នរណាជាគ្រូរបស់អ្នក ? តើគេបង្រៀនធម៌អ្វីខ្លះដល់អ្នកដែរ ?” ។

ព្រះពុទ្ធឆ្លើយតបថាៈ

“តថាគតបានឈ្នះនូវភូមិកធម៌ទាំងអស់, តថាគតបានដឹងនូវចតុភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់, បានលះបង់ចោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះ

ហើយ ព្រោះអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯង ចាំបាច់ពឹងចំពោះបុគ្គលណាទៅ ?”

តើនរណាជាគ្រូរបស់តថាគតទៅ ? ។ ទេ ! តថាគតមិនមានគ្រូទេ, មិនមានអ្នកណាអាចប្រៀបផ្ទឹមស្មើនឹងតថាគតបានទេ, ព្រោះតថាគតជាអរហន្តក្នុងលោក ជាសាស្តាចារ្យខ្ពស់បំផុត ជាអ្នកត្រាស់ដឹងខ្លួនឯងដោយប្រពៃ, តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់ហើយ ។

ឥឡូវនេះតថាគត និមន្តទៅកាន់ក្រុងនៃពួកជនដែនកាសី[១២] ដើម្បីនឹងសម្តែងធម្មចក្រ, តថាគតនឹងទូងនូវស្គរ គឺអមតមហានិព្វានចំពោះសត្វលោក ដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់ហើយ ។

ឧបកាជីវកក៏តបថា “នៃសម្លាញ់, អ្នកយល់ថាខ្លួនអ្នកយ៉ាងណាអ្នកគប្បីបាននូវឈ្មោះថាអនន្តជិនយ៉ាងដូច្នោះឯង” ។

ព្រះពុទ្ធមានតម្រាស់តបថា: “ជនទាំងឡាយណាបានដល់នូវធម៌សម្រាប់ធ្វើអាសវៈឲ្យអស់ទៅ, ជនទាំងឡាយនោះឈ្មោះថាជិនៈ (ជាអ្នកឈ្នះកិលេស) ប្រាកដដូចជាតថាគតដែរ, តថាគតបានឈ្នះបាបធម៌ទាំងឡាយហើយ ។

[១២] កាសី ជាឈ្មោះអាណាចក្រមួយ ក្នុងចំណោមទាំង១៦ នៅក្នុងប្រទេសឥណ្ឌាសម័យបូរាណ ។ អាណាចក្រនេះមានរាជធានីឈ្មោះពារាណសី ជាដែនដែលមានឈ្មោះល្បីខាងផលិតផលទឹកអប់ និងសំពត់ត្បាញពីសូត្រ ។

ឧបកាជីវកពោលយ៉ាងសោះកក្រោះខ្ពីៗថា: “អាចជាអញ្ចឹងមែន ហើយសម្លាញ់” រួចងក់ក្បាល ហើយបន្តដំណើរតាមផ្លូវទៅមុខទៀតទៅ ។

ទ្រង់មិនខ្វល់ឡើយ, ព្រះពុទ្ធអង្គនិមន្តចេញពីកន្លែងមួយទៅកាន់កន្លែងមួយទៀត ទីបំផុតបានទៅដល់ព្រៃឥសីបតនមិគទាយវ័ន ជិតក្រុងពារាណសីតាមបំណងមែន ។

ចំណែកតាបសទាំងប្រាំរូប បានឃើញព្រះពុទ្ធអង្គនិមន្តមក ពីចម្ងាយហើយក៏និយាយគ្នាថា យើងទាំងអស់គ្នាមិនត្រូវក្រោកទទួល ឬក៏រៀបអាសនៈ និងគោរពដល់ព្រះសមណគោតមឡើយ ។ ពួកតាបសទាំងនោះ មានការយល់ខុសចំពោះព្រះពុទ្ធអង្គ ដែលថាព្រះសមណគោតមបានដាក់ចុះនូវការព្យាយាម ក្នុងការស្វែងរកនូវការត្រាស់ដឹង ។ ទោះបីពួកតាបសទាំងនោះ បានពោលពាក្យសន្យាគ្នាយ៉ាងនេះក៏ដោយ, ចំណែកព្រះពុទ្ធទ្រង់និមន្តចូលទៅជិត តាបសទាំងប្រាំរូបនោះតាមធម្មតា ធ្វើហាក់មិនដឹងរឿងអ្វីទាំងអស់ ។ មហាបុរិសលក្ខណៈរបស់ព្រះអង្គគួរឲ្យគោរព បានធ្វើឲ្យពួកតាបសទាំងនោះ ភ្លេចការសន្យាគ្នា ហើយបង្ខំចិត្តក្រោកទទួលព្រះពុទ្ធអង្គប្រកបដោយកិត្តិយស និងការទឹករលឹកក្រៃលែង ។ តាបសទាំងនោះ បានពោលពាក្យទៅកាន់ព្រះពុទ្ធអង្គ ដោយពាក្យសាមញ្ញៗថា “អាវុសោ”, តាមពិតពាក្យនេះ គេប្រើជាទូទៅចំពោះតែអ្នកដែលមានអាយុតិចជាង ឬវស្សាតិចជាង ។ ព្រះមានព្រះភាគបានឲ្យដំបូន្មានដល់ពួក

តាបសទាំងនោះថា កុំឲ្យប្រើពាក្យនោះមកលើព្រះអង្គទៀត ពីព្រោះព្រះអង្គ បានសម្រេចនូវការត្រាស់ដឹងហើយ, ប៉ុន្តែត្រូវបានតាបសទាំងនោះបដិសេធ ក្នុងការជឿលើព្រះតម្រាស់របស់អង្គ ។ ព្រះពុទ្ធបានឲ្យដំបូន្មានដល់ពួកតាបសទាំងនោះ ជាលើកទីពីរនិងលើកទីបីទៀត, តែពួកតាបសទាំងនោះនៅតែបដិសេធ លើការទទួលស្គាល់ការត្រាស់ដឹងដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ ។

ជាចុងក្រោយ ព្រះពុទ្ធមានបន្ទូលថា:[១៣]

"ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយដឹងទេ ថាតើតថាគតធ្លាប់ពោលពាក្យនេះ ប្រាប់ដល់អ្នកទាំងឡាយពីមុនមកទេ ? " ។

"មិនធ្លាប់ទេព្រះអង្គ" តាបសទាំងអស់ឆ្លើយតប ។

"ម្នាលភិក្ខុទាំងឡាយ, តថាគតមិនមែនជាអ្នកត្រេកអរក្នុងវត្ថុប្រណិតទេ, មិនបានលះបង់ការព្យាយាមទេ, មិនបានយល់ព្រមយកជីវិតដែលសម្បូណ៌ដោយកាមឡើយ ។ ម្នាលភិក្ខុទាំងឡាយ, បុគ្គលដ៏មានជោគនោះគឺតថាគតនឹងឯង ជាបុគ្គលត្រាស់ដឹងយ៉ាងពិតប្រាកដ ។ ម្នាលភិក្ខុទាំងឡាយចូរស្តាប់ ព្រះនិព្វានគឺតថាគតបានធ្វើឲ្យសម្រេចហើយ, តថាគត

---

[១៣] ព្រះពុទ្ធបានធ្វើបកាសនវាចានេះ ពីព្រោះព្រះអង្គបានសម្រេចនូវការត្រាស់ដឹងដោយព្រះអង្គឯង ដោយគ្មានគ្រូអាចារ្យណាបង្រៀនព្រះអង្គឡើយ ។ ព្រះអង្គមាន-គ្រូបង្រៀនពីមុនការត្រាស់ដឹង ប៉ុន្តែគ្មានគ្រូណាបង្រៀនព្រះអង្គ នូវផ្លូវទៅកាន់ការ ត្រាស់ដឹងជាព្រះពុទ្ធទេ ។

នឹងសម្តែងធម៌នោះ ប្រសិនបើអ្នកធ្វើតាមការប្រៀនប្រដៅរបស់តថាគត, អ្នកនឹងយល់ច្បាស់ដោយបញ្ញាញាណផ្ទាល់របស់អ្នក បន្ទាប់មកអ្នកនឹងបានសម្រេចនូវភាពជាព្រះអរិយៈ ក្នុងជីវិតនេះដោយខ្លួនឯង ។

ខណៈនោះ ឧទានវាចាបានលាន់ចេញពីព្រះឱស្ឋដ៏ពិសិដ្ឋរបស់ព្រះពុទ្ធអង្គ ។ ពួកតាបសទាំងប្រាំដែលមានចិត្តចចេសរឹងរូស ទៅតាមការយល់ឃើញរបស់ពួកគេ ឥឡូវនេះបានជឿលើការត្រាស់ដឹងរបស់ព្រះពុទ្ធហើយ តាមរយៈការប៉ិនប្រសប់ក្នុងការបង្រៀននូវ របៀបអប់រំផ្លូវចិត្តដល់ពួកគេ ។

ព្រះពុទ្ធបានបង្រៀនដល់ភិក្ខុពីរអង្គ ក្នុងខណៈដែលភិក្ខុបីអង្គទៀតនិមន្តចេញទៅខាងក្រៅ ដើម្បីបិណ្ឌបាត្រអាហារ ។ អាហារបិណ្ឌបាត្របានមក ត្រូវបានចែកចាយគ្នាទាំងប្រាំមួយរូបដើម្បីឆាន់ ។ បន្ទាប់មកព្រះពុទ្ធបង្រៀនដល់ភិក្ខុបីអង្គ នៅខណៈដែលភិក្ខុពីរអង្គ និមន្តចេញទៅក្រៅដើម្បី បិណ្ឌបាត្រម្តង ។

ព្រះពុទ្ធបានលើកយកធម្មចក្កប្បវត្តនសូត្រ ធ្វើជាប្រធានបទសម្រាប់បង្រៀន ដល់ភិក្ខុទាំងប្រាំរូបនោះ ។ ព្រះកោណ្ឌញ្ញៈជាភិក្ខុដែលមានអាយុច្រើនជាងគេ បានស្តាប់ហើយក៏បានសម្រេចជំហានដំបូង ជាព្រះអរិយបុគ្គលថ្នាក់សោតាបត្តិ, ចំណែកភិក្ខុបួនអង្គទៀត បានសម្រេចសោតាបត្តិ ជាខាងក្រោយបន្តបន្ទាប់ ។ បន្ទាប់ពីបានស្តាប់នូវអនត្តលក្ខណ

សូត្រ ជាប្រធានបទទីពីរ ដែលទាក់ទងដល់ភាពមិនមែនជារបស់ខ្លួនមក, ពួកភិក្ខុទាំងអស់នោះក៏បានសម្រេចអរហត្តផល ជាជំហានចុងក្រោយបំផុតរបស់អរិយបុគ្គល ។

## បញ្ចវគ្គិយភិក្ខុ

ភិក្ខុទាំងប្រាំរូបដែលបានសម្រេចអរហត្តផល ក៏ក្លាយជាសាវ័កដំបូងបំផុតរបស់ព្រះពុទ្ធអង្គ គឺមានព្រះកោណ្ឌញ្ញៈ, ភទ្ទិយៈ, វប្បៈ, មហានាម, និង អស្សជិ ។

កោណ្ឌញ្ញៈ ជាព្រាហ្មណ៍ដែលមានវ័យក្មេងជាងគេ ក្នុងចំណោមពួកព្រាហ្មណ៍ទាំងប្រាំបីរូប ដែលបានចូលរួមក្នុងពិធីថ្វាយព្រះនាមដល់ព្រះសិទ្ធត្ថ ។ គាត់តែម្នាក់ឯងគត់ ដែលបានលើកម្រាមដៃមួយឡើង ហើយទាយថាព្រះកុមារនឹងបានត្រាស់ដឹងជាព្រះពុទ្ធ, ចំណែកសាវ័កបួនរូបទៀតជាកូនព្រាហ្មណ៍ ក្នុងចំណោមព្រាហ្មណ៍ប្រាំពីររូបដទៃទៀត ។ ព្រាហ្មណ៍ទាំងប្រាំរូបនេះឯង បានបបួលគ្នាចេញទៅបួស ជាតាបសនៅក្នុងព្រៃតាមព្រះសមណគោតម ។ ពួកគេបានចេញដំណើរទៅកាន់តំបន់ឧរុវេលដើម្បីចូលរួមជាមួយព្រះសមណគោតម នៅពេលដែលព្រះអង្គកំពុងព្យាយាមឲ្យបានត្រាស់ជាព្រះពុទ្ធ, ប៉ុន្តែនៅពេលព្រះសមណគោតម លះបង់ការអត់អាហារ និងការប្រព្រឹត្តតបៈដ៏តឹងរ៉ឹងចោល ធ្វើឲ្យពួកតាបសទាំងនោះអស់ជំនឿ ហើយនាំគ្នារត់ចោលព្រះអង្គ ទៅកាន់ព្រៃឥសីតបន

មិគទាយវ័ន ។ បន្ទាប់ពីពួកតាបសទាំងនោះចេញដំណើរបន្តិចទៅ ព្រះសមណគោតមក៏បានសម្រេច ការត្រាស់ដឹងជាព្រះពុទ្ធ ។ រយៈពេលប្រាំពីរសប្តាហ៍ បន្ទាប់ពីការបានត្រាស់ដឹងមក ព្រះពុទ្ធអង្គបាននិមន្តទៅកាន់ព្រៃឥសីបតនមិគទាយវ័ន ហើយសម្តែងធម៌ទេសនា ដល់ភិក្ខុទាំងប្រាំរូបនោះ ដែលហៅបញ្ចវគ្គិយភិក្ខុ ។

ព្រះកោណ្ឌញ្ញៈ បានសម្រេចជាព្រះអរហន្តដំបូងគេ និងជាសាវ័កចម្បងលើសង្ឃ ។ ព្រះអស្សជិជាសាវ័កមួយអង្គ ក្នុងចំណោមទាំងប្រាំរូបនោះ បានជាអ្នកសម្តែងធម៌ដល់ព្រះសារីបុត្រ ជាអគ្គសាវ័ករបស់ព្រះពុទ្ធអង្គដែរ ។

# ៤. បឋមធម្មទេសនា

## ធម្មចក្កប្បវត្តនសូត្រ

បានស្ដាប់មកយ៉ាងនេះថា: សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅព្រៃឥសីបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ គ្រានោះ ព្រះអង្គទ្រង់សម្ដែងធម៌ ប្រោសបញ្ចវគ្គិយភិក្ខុមានគ្នាប្រាំរូប ដោយសេចក្ដីដូចខាងក្រោម:

អន្តធម៌[១៤] គឺធម៌ជាផ្លូវប្រតិបត្តិអមខាង ដ៏អាក្រក់លាមកទាំងឡាយមានពីរប្រការ, ជាធម៌ដែលបព្វជិតគួរលះបង់ចោល និងមិនគួរសេពគប់ឡើយ ។

អន្តធម៌ទាំងពីរប្រការនោះគឺ ១-កាមសុខល្លិកានុយោគ ជាធម៌ដែលប្រកបខ្លួនឲ្យជាប់ជំពាក់ដោយកាម, ជាធម៌ថោកទាប, ជាធម៌របស់អ្នកស្រុក, ជាធម៌របស់បុថុជ្ជន, និងមិនមែនជាធម៌របស់អរិយបុគ្គល ឬក៏ជាធម៌ដល់នូវការរីកចម្រើនទេ ។ ២-អត្តកិល្លមថានុយោគ ធម៌ណាដែល

---

[១៤] ព្រះអង្គបានទេសទេសនាជាឱវាទដល់ព្រះសង្ឃទាំងនោះ ឲ្យគេចចេញពីការជ្រុលនិយម នៅក្នុងការធ្វើខ្លួនឲ្យជាប់ជំពាក់ក្នុងកាម (កាមសុខល្លិកានុយោគ) និងការធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍ (អត្តកល្លមថានុយោគ) ។ ធម៌ទីមួយធ្វើឲ្យយឺតដល់ការរីកលូតលាស់ខាងបញ្ញាស្មារតី និងធម៌ទីពីរធ្វើឲ្យបញ្ញាចុះខ្សោយ ។

ប្រកបសេចក្ដីលំបាកដល់ខ្លួន ជាធម៌នាំឲ្យលំបាកកាយទទេៗ មិនប្រកបដោយប្រយោជន៍ឡើយ [១៥]។

ម្នាលភិក្ខុទាំងឡាយ, សេចក្ដីប្រតិបត្តិជាកណ្ដាល មិនលាយច្រឡំដោយអន្តធម៌ទាំងឡាយពីរយ៉ាងនេះ តថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ ដើម្បីបាននូវអភិញ្ញា និងដើម្បីព្រះនិព្វាន គឺការរំលត់សេចក្ដីទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ, តើអ្វីទៅជាមជ្ឈិមបដិបទា ឬជាផ្លូវកណ្ដាលដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្ដីដឹងច្បាស់ប្រាកដ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ ដើម្បីបាននូវអភិញ្ញា និងដើម្បីព្រះនិព្វាននោះ ? ។

អរិយមគ្គប្រកបដោយអង្គប្រាំបីប្រការ គឺៈ

១-សម្មាទិដ្ឋិ ការយល់ឃើញត្រូវ, ២-សម្មាសង្កប្បោ ការត្រិះរិះត្រូវ, ៣-សម្មាវាចា សម្ដីត្រូវ, ៤-សម្មាកម្មន្តោ ការងារត្រូវ, ៥-សម្មាអាជី

---

[១៥] ព្រះអង្គធ្លាប់ឆ្លងកាត់អន្តធម៌ទាំងពីរនេះដោយផ្ទាល់ ទើបអាចត្រាស់សម្ដែងពីភាពមិនមានប្រយោជន៍ របស់អន្តធម៌ទាំងពីរនេះ ។ ព្រះអង្គបានតិះដៀលការ ប្រព្រឹត្តរបៀបនោះ ហើយបង្ហាញផ្លូវនៃការប្រតិបត្តិ ប្រកបដោយវិចារណញ្ញាណ ជា ផ្លូវប្រកបដោយគុណប្រយោជន៍ ដែលដឹកនាំបុគ្គលទៅកាន់ភាពបរិសុទ្ធតែម្យ៉ាង ។

វោ ការចិញ្ចឹមជីវិតត្រូវ, ៦-សម្មាវាយាមោ ការព្យាយាមត្រូវ, ៧-សម្មាសតិ ការរលឹកត្រូវ, ៨-សម្មាសមាធិ ការតម្កល់ចិត្តត្រូវ ។

ម្នាលភិក្ខុទាំងឡាយ, នេះជាផ្លូវកណ្តាល ប្រកបដោយអង្គប្រាំបីប្រការ ដែលតថាគតបានត្រាស់ដឹងហើយ ។

១-ម្នាលភិក្ខុទាំងឡាយ, ទុក្ខអរិយសច្ចៈមានការកើតនៃខន្ធ ជាហេតុនាំមកនូវទុក្ខ, ការចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ, ជម្ងឺដម្កាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ, ការបែកធ្លាយនៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ, ការជួបប្រទះសត្វនិងសង្ខារទាំងឡាយដែលមិនពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ, ការព្រាត់ប្រាស់ចាកសត្វ និងសង្ខារទាំងឡាយ ដែលជាទីពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ, ចិត្តចង់បាននូវវត្ថុណាហើយ មិនបាននូវវត្ថុនោះ ការមិនបាននោះក៏ជាហេតុនាំមកនូវទុក្ខ, ដោយសង្ខេបមកឧបាទានខន្ធទាំងប្រាំ ដែលតថាគតសម្តែងហើយ ក៏ជាហេតុនាំមកនូវទុក្ខ, កងទុក្ខមានជាតិទុក្ខជាដើម ឈ្មោះថាទុក្ខអរិយសច្ច ។

២-ម្នាលភិក្ខុទាំងឡាយ, ទុក្ខសមុទយអរិយសច្ចៈ មានតណ្ហាដែលតាក់តែងភពថ្មី ប្រកបដោយតម្រេក ដោយអំណាចរាគៈ និងការរីករាយក្នុងអារម្មណ៍នោះ ។ តណ្ហានោះមាន៣គឺៈ កាមតណ្ហា ការត្រេកអរក្នុងកាម១, ភវតណ្ហា ការត្រេកអរក្នុងភព១, វិភវតណ្ហា ការត្រេកអរក្នុងភពមិនមានរូប១ ។

៣-ម្នាលភិក្ខុទាំងឡាយ, ទុក្ខនិរោធអរិយសច្ចៈ មានការរំលត់បង់នូវតណ្ហា ដោយអរិយមគ្គមិនឲ្យមានសេសសល់, ការលះបង់នូវតណ្ហា, ការរលាស់ចោលនូវតណ្ហា, ការរួចផុតចាកតណ្ហា, ការមិនមានអាល័យក្នុងតណ្ហា ។

៤-ម្នាលភិក្ខុទាំងឡាយ, ទុក្ខនិរោធគាមិនីបដិបទាអរិយមគ្គ ជាផ្លូវប្រកបដោយអង្គប្រាំបីប្រការគឺៈ ការយល់ឃើញត្រូវ ការត្រិះរិះត្រូវ សម្ដីត្រូវ ការងារត្រូវ ការចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្ដី រលឹកត្រូវ ការតម្កល់ចិត្តឲ្យនឹងត្រូវ ។

១- ក.ទុក្ខអរិយសច្ចៈ

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ដែលមិនធ្លាប់បានស្ដាប់ បានឮពីមុនមក ។

ខ.ទុក្ខអរិយសច្ចៈ ជាបរិញ្ញេយ្យកិច្ច គឺជាកិច្ចគប្បីកំណត់ដឹងដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ដែលមិនធ្លាប់បានស្ដាប់ បានឮពីមុនមក ។

គ.ទុក្ខអរិយសច្ចៈ ជាកិច្ចដែលតថាគតកំណត់ដឹងបានហើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

២- ក.ទុក្ខសមុទយអរិយសច្ចៈ

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

ខ.ទុក្ខសមុទយអរិយសច្ចៈ ជាបហានកិច្ច គឺជាកិច្ចដែលត្រូវលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាង កើតឡើងហើយ ដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

គ.ទុក្ខសមុទយអរិយសច្ចៈ ជាកិច្ចដែលតថាគតលះបង់បានហើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

៣- ក.ទុក្ខនិរោធអរិយសច្ចៈ

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

ខ.ទុក្ខនិរោធអរិយសច្ចៈ ជាសច្ឆិកាតព្វកិច្ច គឺជាកិច្ចត្រូវធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាង កើតឡើងហើយ ដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

គ.ទុក្ខនិរោធអរិយសច្ចៈ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

៤- ក. ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

ខ.ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ ជាភាវេតព្វកិច្ច គឺជាកិច្ចគប្បីចម្រើនឲ្យកើត ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណ

កើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាង កើតឡើងហើយដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

គ.ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ តថាគតចម្រើនឲ្យកើតបានហើយ ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគត ដែលមិនធ្លាប់បានស្តាប់ បានឮពីមុនមក ។

ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាឃើញច្បាស់នូវអរិយសច្ច៤ ស្ថិតនៅក្រោមទិដ្ឋភាព៣ (បរិវដ្តៈ) មានអាការៈ១២, នៅមិនទាន់បរិសុទ្ធល្អ មានដល់តថាគតដរាបណា, តថាគតក៏មិនបានទទួលស្គាល់ថា ជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏វិសេសអស់កាលត្រឹមណោះនៅឡើយទេ ។

បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់ កើតឡើងហើយដល់តថាគតដូច្នេះថា សេចក្តីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះភពថ្មី គឺការត្រឡប់កើតទៀត មិនមានឡើយ ។

ព្រះមានព្រះភាគ បានទេសនាព្រះធម៌នេះចប់ហើយ ភិក្ខុទាំងឡាយក៏បានត្រេកអរ រីករាយ នឹងពាក្យសុភាសិតរបស់ព្រះដ៏មានព្រះភាគដោយក្រៃលែង ។ នាកាលវាទៈនេះ ព្រះមានព្រះភាគកំពុងត្រាស់ទេសនា, ធម្មចក្ខុ គឺសោតាបត្តមគ្គ ដ៏ប្រាសចាកធូលីគឺរាគៈ ប្រាសចាកមន្ទិលគឺអកុសលកើតឡើងហើយ ដល់ព្រះកោណ្ឌញ្ញៈដ៏មានអាយុ ។

នៅក្នុងខណៈដែលព្រះពុទ្ធ ទ្រង់បានសម្តែងធម្មចក្រចប់ហើយ ភុម្មទេវតាទាំងឡាយបានស្រែកប្រកាស លាន់ឮសម្លេងឡើងដូច្នេះថាៈ

ចក្រគឺព្រះធម៌នេះ ឥតមានចក្រណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណាមួយក្នុងលោកក្តី សម្តែងពុំបានឡើយ, មានតែព្រះមានព្រះភាគព្រះអង្គទ្រង់សម្តែងហើយ ក្នុងព្រៃឥសីបតនមិគទាយវន ជិតក្រុងពារាណសី ។

កាលបានឮសម្លេងនោះហើយ, ទេវតាស្ថានចាតុម្មហារាជិកា, តាវតិង្ស, យាមា, តុសិតា, និម្មានរតី, បរនិមិត្តវសវត្តី និងព្រហ្មលោកមាន ព្រហ្មបារិសជ្ជា, ព្រហ្មបុរោហិតា, មហាព្រហ្មា, បរិត្តាសុភា, អប្បមាណភា, អាភស្សរា, បរិត្តាសុភា, អប្បមាណសុភា, សុភកិណ្ហា, វេហប្ផលា, អសញ្ញីសត្តា អវិហា, អតប្បា, សុទស្សា, សុទស្សី និង អកនិដ្ឋា បានបន្លឺឡើងនូវសម្លេងរីករាយសាទរដូចៗគ្នា ។

នៅរាល់ៗខណៈ នៅរាល់រំពេច សម្លេងសាធុការលាន់ឮឡើង ដោយអាការៈលាន់ឮតៗគ្នា ដរាបដល់ព្រហ្មលោក, ទាំងមួយហ្មឺនលោកធាតុញាប់ញ័រ ទាំងខាងលើទាំងខាងក្រោម និងញាប់ញ័រក្នុងទីទាំងពួង ។ ទាំងរស្មីរុងរឿងក្រៃពេក នឹងប្រមាណមិនបានកន្លង លើសទេវានុភាពទាំងឡាយ ក៏កើតឡើងប្រាកដក្នុងលោក ។ ព្រះដ៏មានព្រះភាគ ទ្រង់បានបន្លឺនូវឧទានវាចាថា ឱកោណ្ឌញ្ញៈបានដឹង ហើយហ្ន៎ ! ឱកោណ្ឌញ្ញៈបានដឹង ហើយហ្ន៎ ! ។

ព្រោះហេតុនោះ ពាក្យថា កោណ្ឌញ្ញៈបានមកជាឈ្មោះនៃព្រះកោណ្ឌញ្ញៈតរៀងមក ។

# ៥. ការផ្សាយសាសនា

## ប្រោសយសកុលបុត្រ

នៅទីក្រុងពារាណសី មានយុវជនម្នាក់ឈ្មោះយស ជាកូនប្រុសទោលរបស់គ្រួសារសេដ្ឋី ដែលជាមូលហេតុធ្វើឲ្យយុវជននោះ មានសេចក្ដីសុខដោយទ្រព្យសម្បត្តិ និងការស្រឡាញ់ថ្នាក់ថ្នមពីឪពុកម្ដាយ ។ ដោយការមើលឃើញច្បាស់ពីធម្មជាតិពិត នៃជីវិតថាមិនមានខ្លឹមសារ គាត់ក៏បានលបគេចចេញពីផ្ទះទាំងកណ្ដាលរាត្រី ហើយដើរតម្រង់ទៅកាន់ព្រៃឥសីបតនមិគទាយវន ជាកន្លែងព្រះពុទ្ធកំពុងគង់អាស្រ័យនៅ ។ ព្រះពុទ្ធបានទតឃើញយសមុន ក៏បានហៅគាត់ឲ្យចូលមករកព្រះអង្គ រួចទ្រង់សម្ដែងធម៌ទេសនា, ពេលយុវជនយសបានស្ដាប់ធម៌ទេសនាហើយ ក៏បានសម្រេចនូវសោតាបត្តិមគ្គ បន្ទាប់មកបានសម្រេចជាព្រះអរហន្ត ។ ឪពុករបស់យសសោកសង្រេងយ៉ាងក្រៃលែង បានដើរស្វែងរកកូនប្រុសដែលបាត់ខ្លួន ដោយមិនដឹងដានយ៉ាងនេះ ។ ក្រោយមកឪពុករបស់យស បានជួបនឹងព្រះពុទ្ធអង្គ នៅក្នុងព្រៃឥសីបតនមិគទាយវន ហើយបានស្ដាប់ធម៌ទេសនា ក្នុងសំណាក់ព្រះពុទ្ធអង្គ រួចបានថ្វាយខ្លួនជាឧបាសកដំបូងគេដែលបានយកព្រះរតនត្រ័យគឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទី

រលឹក ។ បន្ទាប់មក សេដ្ឋីបាននិមន្តព្រះពុទ្ធអង្គនិងភិក្ខុយស ទៅទទួលចង្ហាន់បិណ្ឌបាត្រនៅផ្ទះរបស់គាត់ ។ នៅផ្ទះសេដ្ឋី ព្រះពុទ្ធទ្រង់សម្តែងធម៌ទេសនា ញ៉ាំងម្តាយនិងនាងជាអតីតៈភរិយារបស់ភិក្ខុយស ឲ្យមានសទ្ធាជ្រះថ្លាក្នុងព្រះអង្គ ហើយថ្វាយខ្លួនជាឧបាសិកាមុនគេ ដែលយកព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទីរលឹកតរៀងមក ។

ព្រះភិក្ខុយស មានសម្លាញ់ប្រុសចំនួន៥៤នាក់ផ្សេងទៀត បានស្តាប់ការពន្យល់ធម៌របស់លោកហើយ មានចិត្តជ្រះថ្លាបានស្ម័គ្រចិត្តចូលបួសទាំងអស់គ្នា ហើយក៏បានសម្រេចជាព្រះអរហន្តទាំងអស់អង្គ នៅក្នុងខណៈនោះទៅ ។

## ការបញ្ជូនសមណទូតដំបូង

នៅពេលនោះ មានព្រះអរហន្ត៦០អង្គនៅក្នុងលោកនេះ ដោយមិនរាប់ព្រះពុទ្ធអង្គរួមជាមួយទេ ។ ព្រះដ៏មានព្រះភាគបានបញ្ជូនព្រះអរហន្តទាំង៦០អង្គនោះ ទៅកាន់តំបន់និគមជនបទផ្សេងៗគ្នា ដើម្បីបង្រៀនព្រះធម៌ ដោយបន្លឺនូវពុទ្ធប្រកាសដូចខាងក្រោមៈ

“ម្នាលភិក្ខុទាំងឡាយ, តថាគតបានរួចចាកចំណងទាំងអស់ហើយ ទោះបីមនុស្ស ឬទេវតា ។ ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយក៏បានរួចពីចំណងទាំងអស់នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ, ចូរអ្នកទាំងឡាយត្រាច់

ទៅកាន់ចារិក (គឺស្រុក និគម រាជធានី) សម្តែងធម៌ដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ និងដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ... អ្នកទាំង ឡាយកុំទៅពីរនាក់តាមផ្លូវតែមួយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្តែងធម៌ ឲ្យបានពិរោះបទខាងដើម បទកណ្តាល និងបទខាងចុង ។ អ្នកទាំងឡាយចូរប្រកាស នូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធប្រកបដោយអត្ថៈនិងព្យញ្ជនៈ ឲ្យពេញបរិបូណ៌ទាំងអស់ ។ សត្វទាំងឡាយដែលមានធូលី គឺរាគាទិក្កិលេសតិចក្នុងភ្នែកក៏មាន, សត្វទាំងឡាយនោះនឹងសាបសូន្យ (ចាកមគ្គផល) ព្រោះមិនបានស្តាប់ព្រះធម៌, សត្វទាំងឡាយដែលបម្រុងនឹងត្រាស់ដឹងក៏គង់នឹងមាន" ។

ព្រះពុទ្ធអង្គមានតម្រាស់បន្តទៀតថាៈ

"ម្នាលភិក្ខុទាំងឡាយ, តថាគតធ្វើដំណើរទៅកាន់ឧរុវេល នៅក្នុងសេនានិគម ក៏ក្នុងបំណងដើម្បីសម្តែងព្រះធម៌ដែរ" ។ ជាមួយនឹងការដាស់តឿននេះ ព្រះពុទ្ធអង្គបានបញ្ជូនសាវ័កទាំង៦០អង្គ ជាលើកទីមួយទៅកាន់ទិសផ្សេងៗគ្នា ។

## ប្រោសយុវជន ៣០ រូប

នៅរដូវភ្លៀង ព្រះពុទ្ធអង្គគង់ចាំព្រះវស្សា នៅក្នុងព្រៃឥសិបតនមិគទាយវន ជិតក្រុងពារាណសី ។ បន្ទាប់ពីចេញវស្សាភ្លាម ទ្រង់និមន្ត

ចេញដំណើរឆ្ពោះទៅកាន់ឧរុវេល តាមដងផ្លូវព្រះអង្គសម្រាកព្រះកាយ នៅទៀបគល់ឈើមួយ ។

នៅពេលនោះ ពួកយុវជនក្មេងៗមានគ្នាប្រមាណ៣០រូប កំពុងប្រឡែងលេងនឹងភរិយាក្មេងរបស់ពួកគេ ក្នុងអារម្មណ៍ស្រើបស្រាល និងសប្បាយរីករាយទៅតាមកាមារម្មណ៍ នៅក្នុងចំការដ៏ធំមួយ ។ យុវជនម្នាក់មិនមានភរិយាដូចគេទេ គាត់បាននាំស្រីផ្កាមាសក្មេងម្នាក់មកជាមួយ ។ នៅពេលដែលពួកគេ កំពុងតែសប្បាយភ្លេចខ្លួន ស្រីផ្កាមាសនោះបានរត់គេចខ្លួន ដោយលួចយករបស់មានតម្លៃទាំងអស់ទៅជាមួយផង ។ យុវជនក្មេងៗទាំងនោះ បានដើរស្វែងរកនាង ហើយក៏ជួបនឹងព្រះពុទ្ធ, ពួកគេទូលសួរព្រះអង្គ ថាតើព្រះអង្គមានឃើញស្រីផ្កាមាសនោះ ដើរឆ្លងកាត់ផ្លូវនោះដែរឬទេ ។

ព្រះពុទ្ធសួរតបទៅបុរសក្មេងៗទាំងនោះថា: “ម្នាលយុវជនទាំងឡាយ ចូរអ្នកគិតទៅមើលការស្វែងរកស្រីម្នាក់ និងការស្វែងរកខ្លួនអ្នក តើណាមួយប្រសើរជាង ? ” ។

ពួកយុវជនទាំងនោះឆ្លើយថា: “បពិត្រព្រះអង្គដ៏ចម្រើន ! ការស្វែងរកខ្លួនឯងប្រសើរជាង” ។

ព្រះពុទ្ធមានបន្ទូលថា: “ល្អហើយ, អញ្ជើងចូរអ្នកអង្គុយចុះ មកតថាគតនឹងសម្តែងព្រះធម៌ ប្រាប់ដល់អ្នកទាំងឡាយ” ។

ពួកយុវជនទាំង៣០រូបបានស្តាប់ធម៌ ដែលព្រះពុទ្ធអង្គសម្តែងដោយការតាំងចិត្តយ៉ាងស៊ុប ទីបំផុតធម្មចក្ខុក៏បានកើតឡើង ដល់ពួកគេទាំងអស់គ្នា ។ បន្ទាប់មកពួកយុវជនទាំងនោះ បានស្ម័គ្រចិត្តបួសក្នុងសំណាក់ព្រះពុទ្ធ ហើយបានជាឯហិភិក្ខុទាំងអស់អង្គ ។

## ប្រោសកស្សបៈ៣នាក់បងប្អូន

នៅឧរុវេលនិគម មានពួកជដិល (អ្នកបួសមូរជុំសក់ញ៉ុកចូលដូចកណ្តាញ់) ៣នាក់រស់នៅ មានឈ្មោះឧរុវេលកស្សប នទីកស្សប និង គយាកស្សប ។ ជដិលទាំង៣រូបនេះ ជាបងប្អូននឹងគ្នា តែរស់នៅបែកគ្នា, ឧរុវេលកស្សបជាបង មានជដិលជាបរិវារ៥០០, នទីកស្សបជាប្អូនកណ្តាលមានជដិលជាបរិវារ៣០០ និងគយាកស្សបជាប្អូនពៅ មានជដិលជាបរិវារ២០០ ។ ពួកជដិលទាំងនោះបានព្យាយាមយ៉ាងខ្លាំង រហូតដល់អាចប្រើអំណាចខាងផ្លូវចិត្ត បានយ៉ាងស័ក្តិសិទ្ធិ ។ ព្រះពុទ្ធបាននិមន្តទៅប្រោសឧរុវេលកស្សប មានវ័យចាស់មុនគេបង្អស់ ។ នៅគ្រានោះ ឧរុវេលកស្សបជាមួយនឹងសាវ័កទាំង៥០០ បានជ្រះថ្លានឹងព្រះពុទ្ធ ហើយចូលបួសជាឯហិភិក្ខុទាំងអស់ទៅ ។ ចំណែកជដិលពីររូបទៀត ព្រមទាំងសាវ័កទាំង

អស់របស់ពួកគេ ក៏បានលះបង់នូវទិដ្ឋិ ហើយជ្រះថ្លាក្នុងព្រះពុទ្ធ បានចូលមកបួសសម្រេចជាឯហិភិក្ខុទាំងអស់អង្គដែរ ។

ពួកភិក្ខុទើបបួសថ្មីទាំងអស់អង្គនោះ បានដង្ហែព្រះពុទ្ធទៅកាន់គយាសីសៈ ត្រង់កន្លែងដែលព្រះពុទ្ធសម្តែងអាទិត្តបរិយាយសូត្រ ធ្វើឲ្យភិក្ខុទាំង១០០០អង្គ បានសម្រេចនូវអរហត្តផលទាំងអស់អង្គ ។

## ប្រោសស្តេចពិម្ពិសារ

ជាមួយភិក្ខុសង្ឃជាបរិវារយ៉ាងច្រើន សុទ្ធសឹងតែជាព្រះអរហន្ត, ព្រះពុទ្ធអង្គបានប្តេជ្ញាជាមួយស្តេចពិម្ពិសារ តាំងពីមុនពេលបានត្រាស់ដឹងថា បើព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ពេលណានឹងយាងមកសម្តែងធម៌ប្រោសស្តេច ដល់ក្រុងរាជគ្រឹះភ្លាម ។

ស្តេចពិម្ពិសារបានជ្រាបថា ព្រះពុទ្ធយាងមកដល់អាណាចក្ររបស់ព្រះអង្គហើយ ទ្រង់យាងចេញជាមួយរាជបរិវារជាច្រើន ដើម្បីទទួលស្វាគមន៍និងគោរពចំពោះព្រះពុទ្ធបរមគ្រូ ។ គ្រានោះ ភិក្ខុកស្សបក៏ត្រូវបានទទួលការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ ពីមនុស្សម្នានៅតំបន់នោះដែរ ។ មនុស្សជាច្រើនគិតមិនយល់ ថាតើព្រះពុទ្ធជាសាវ័ករបស់កស្សប ឬមួយកស្សបជាសាវ័ករបស់ព្រះពុទ្ធ ។ ព្រះពុទ្ធបានបង្ហាញឲ្យអស់ក្តីសង្ស័យ

ដោយសួរទៅព្រះភិក្ខុកស្សបពីមូលហេតុ ដែលលោកបានលះបង់ការបូជាភ្លើងចោល ។

ព្រះកស្សបបានទូលតបព្រះពុទ្ធបរមគ្រូ ដោយការគោរពយ៉ាងខ្ពង់ខ្ពស់ថា:

"បពិត្រព្រះមានព្រះភាគ ! ព្រះអង្គជាបរមគ្រូ, ខ្ញុំព្រះអង្គគឺជាសាវ័ក, ព្រះមានព្រះភាគគឺជាបរមគ្រូ ខ្ញុំព្រះអង្គពិតជាសាវ័កមែន" ។

ពួកមនុស្សដែលមានភក្តីភាព មានចិត្តរីករាយជាខ្លាំងដោយបានឮការសន្ទនានោះដោយផ្ទាល់ត្រចៀក ។

នៅគ្រានោះដែរ ព្រះពុទ្ធទ្រង់បានលើកយកមហានារទកស្សបជាតក មកសម្តែងជាធម៌ទេសនាយ៉ាងពិស្តារ ដើម្បីបង្ហាញថា ពួកគេបានងាកមកគោរពព្រះពុទ្ធសាសនាបែបនេះ ដូចគ្នាពីអតីតជាតិដែរ ។

ធម្មចក្ខុ[១៦]បានកើតឡើង ដល់អ្នកស្តាប់ទាំងអស់គ្នា ស្តេចពិម្ពិសារក៏បានសម្រេចសោតាបត្តិ ។ នៅក្នុងគ្រានោះដែរ ស្តេចបាននិមន្តព្រះពុទ្ធបរមគ្រូ និងសាវ័កទាំងអស់ យាងទៅកាន់ព្រះបរមរាជវាំង ដើម្បីទទួលអាហារបិណ្ឌបាត្រ ។ នៅខាងចុងនៃការទទួលភត្តថ្ងៃបន្ទាប់ ស្តេចបានវេរឧទ្យាន

---

[១៦] ពាក្យនេះសំដៅទៅដល់អរិយមគ្គទាំង៣ មានសោតាបត្តិមគ្គ សកទាគាមិមគ្គ និងអនាគាមិមគ្គ ។

ឫស្សី (វេឡុវនារាម)របស់ព្រះអង្គ ធ្វើជាអារាមដល់ព្រះពុទ្ធ និងសង្ឃសាវ័ក ទាំងអស់ ដែលទុកជាអារាមដំបូងបំផុត ។

## ប្រោសព្រះសារីបុត្រ និងព្រះមោគ្គល្លាន

មិនឆ្ងាយពីទីក្រុងរាជគ្រឹះប៉ុន្មាន មានភូមិមួយឈ្មោះភូមិឧបតិស្ស: ដែលគេស្គាល់ម៉្យាងទៀតថាភូមិនាឡក: ជាទីកន្លែងកំណើតរបស់យុវជន មានប្រាជ្ញាឈ្លាសវៃម្នាក់ ឈ្មោះសារីបុត្រ (កូនប្រុសរបស់នាងសារី) ។ ចាប់តាំងពីលោកបានក្លាយ ជាអ្នកដឹកនាំនៃគ្រួសារនោះមក លោកត្រូវបានហៅឈ្មោះថាឧបតិស្ស: ។ ឧបតិស្ស:មានបងប្អូនស្រី៣នាក់គឺ នាងចាល:, នាងឧបចាល:, និងនាងសីសូបចាល: និងបងប្អូនប្រុស៣នាក់ទៀតគឺ: ឧបសេន:, ចុន្ទ: និងរេវត: ។

សូម្បីតែមានការអប់រំពីទស្សនវិជ្ជា នៅក្នុងព្រហ្មញ្ញសាសនាដ៏ទូលាយយ៉ាងណាក៏ដោយ ក៏ជីវិតនិងបញ្ញាដ៏ទុំជោរបានបង្ខិតបង្ខំលោកឲ្យលះបង់ នូវសាសនាពីបុព្វបុរសរបស់គាត់ចោល ហើយងាកទៅរកពាក្យប្រៀនប្រដៅ ប្រកបដោយមេត្តាករុណា និងបែបជាវិទ្យាសាស្ត្ររបស់ព្រះពុទ្ធសមណគោតម ។ បងប្អូនប្រុសស្រីទាំងអស់របស់លោក បានដើរតាមគំរូដ៏ប្រសើរនេះដែរ ។ ឪពុករបស់លោកឈ្មោះវង្គន្ត: មានជំនឿស៊ប់ទៅក្នុងព្រហ្មញ្ញសាសនា ។ ម្ដាយរបស់លោកផ្ទុយពីឪពុករបស់លោក,

នាងបានងាកមកគោរព ព្រះពុទ្ធសាសនាដោយខ្លួនឯង នៅមុនពេលដែលនាងលះលោកនេះទៅ ។

ឧបតិស្សៈត្រូវបានចិញ្ចឹម និងថែរក្សានៅក្នុងភាពរុងរឿងដោយសេចក្តីសុខ, លោកមានសម្លាញ់ជិតស្និទ្ធម្នាក់ឈ្មោះកោលិតៈ នៅមានឈ្មោះម៉្យាងទៀតថាមោគ្គល្លាន ដែលលោកបានសេពគប់យ៉ាងជិតស្និទ្ធតាំងពីក្មេងៗមក ។ ថ្ងៃមួយ សម្លាញ់ទាំងពីររូបនេះបានទៅចូលរួមកំសាន្តនៅក្នុងពិធីបុណ្យកំសាន្តភូមិមួយ ដែលប្រារព្ធឡើងនៅលើកំពូលភ្នំគិរគ្គសមជ្ជៈ ។ ក្រោយពីការទស្សនាមហោស្រពហើយ យុវជនទាំងពីរនាក់នេះយល់ច្បាស់ថា ការមើលមហោស្រពនេះ ជាការឥតប្រយោជន៍ វាគ្រាន់តែជាការ នាំចិត្តឲ្យត្រេកត្រអាល ក្នុងផ្លូវកាមតែម៉្យាងប៉ុណ្ណោះ ។ បន្ទាប់មក ពួកគេបានសម្រេចចិត្តចេញបួស ដើម្បីស្វែងរកផ្លូវរំដោះខ្លួន ។

ការដកខ្លួនចេញ ពីការចូលរួមទស្សនារបាំមហោស្រព របស់ពួកគេ មិនមានការផ្តល់ដំណឹងដល់ឪពុកម្តាយឡើយ ។ យុវជនទាំងពីរនាក់នេះ បានដើរត្រាច់ចរគ្រប់ច្រកល្ហក ពីកន្លែងមួយទៅកន្លែងមួយ ក្នុងដំណើរស្វែងរកសេចក្តីសុខខាងផ្លូវចិត្ត ។

មុនដំបូង សម្លាញ់ទាំងពីររូបនេះ បានធ្វើដំណើរទៅកាន់សំណាក់អាចារ្យសញ្ជ័យ ដែលមានកូនសិស្សប្រាំរយនាក់ បានគិតគ្នាថា ត្រូវចូលបួសនៅក្នុងសំណាក់នៃអាចារ្យសញ្ជ័យនោះ ។ យុវជនទាំងពីររូបនេះ បាន

ទទួលចំណេះដឹងស្តួចស្តើងណាស់ ពីគ្រូបង្រៀន, ពួកគេមិនពេញចិត្តនឹងពាក្យប្រៀនប្រដៅរបស់គ្រូនោះឡើយ ហើយក៏បានដើរចេញពីសំណាក់គ្រូនោះទៅ ។ ឧបតិស្សៈនិងកោលិតៈ គ្រោងជួបគ្នាដោយគ្មានការណាត់ទុក ឬកំណត់ទីកន្លែងឡើយ ហើយបានធ្វើដំណើរត្រឡប់ទៅកាន់ភូមិកំណើតរបស់ពួកគេវិញរៀងៗខ្លួន ។ ទីបំផុត មានការយល់ព្រមរវាងពួកគេទាំងពីរនាក់ថា នរណាក៏ដោយបើបានស្វែងរកឃើញនូវមោក្សធម៌មុនត្រូវតែប្រាប់ដល់គ្នាម្នាក់ទៀត ឲ្យបានដឹងផងដែរ ។

នៅគ្រានោះ ព្រះអស្សជិជាភិក្ខុមួយរូបក្នុងចំណោមភិក្ខុជាបញ្ចវគ្គីយ៍ កំពុងនិមន្តតាមផ្លូវទៅកាន់ក្រុងរាជគ្រឹះ ។ លោកស្លៀកដណ្តប់ចីវរប្រកបដោយបរិមណ្ឌលយ៉ាងស័ក្តិសម មានឥន្ទ្រីយ៍សង្រួមស្រគត់ស្រគំឈានជើងដើរពីផ្ទះមួយទៅផ្ទះមួយ ស្វែងរកអាហារបិណ្ឌបាត្រ តាមលក្ខណៈជាអ្នកបួស ។ ឥរិយាបថដែលគួរឲ្យជ្រះថ្លានេះ បានធ្វើឲ្យឧបតិស្សៈដែលកំពុងដើរតត្រុក នៅក្នុងក្រុងរាជគ្រឹះ មានការចាប់អារម្មណ៍យ៉ាងខ្លាំង ។

ឧបតិស្សៈបានគិតក្នុងចិត្តតែម្នាក់ឯងថាៈ “យើងមិនដែលបានឃើញអ្នកបួសដូចនេះពីមុនមកទេ, លោកប្រាកដជាអ្នកបួសម្នាក់ ដែលបានដល់នូវភាពជាព្រះអរហន្ត ឬក៏ជាបុគ្គលដែលកំពុងដើរលើផ្លូវ ទៅ

កាន់ភាពជាព្រះអរហន្តមិនខានឡើយ, អាត្មាអញគួរតែចូលទៅរកលោកម្ចាស់អង្គនេះ ហើយសួរនូវសំណួរខ្លះៗល្បងមើល...”។

ទោះបីជាយ៉ាងណាក៏ដោយ ឧបតិស្សៈបានអត់ធ្មត់ មិនសួរនូវសំណួរនោះភ្លាមៗទេ ដោយយល់ថាលោកម្ចាស់អង្គនោះ កំពុងនិមន្តតាមចន្លោះផ្លូវដើម្បីបិណ្ឌបាត្រ ។

ព្រះអរហន្តអស្សជិ បានទទួលអាហារបិណ្ឌបាត្រតែបន្តិចប៉ុណ្ណោះ ល្មមត្រឹមតែលោកត្រូវការ ហើយក៏ស្វែងរកទីកន្លែងសមគួរដើម្បីឆាន់ ។ ឧបតិស្សៈបានឃើញដូច្នេះ មានចិត្តរីករាយណាស់ គិតថាគាត់មានឱកាសបានថ្វាយអាសនៈ និងទឹកជារបស់ខ្លួនផ្ទាល់ដល់ព្រះអស្សជិ ។ កិច្ចដំបូងលោកបានធ្វើការបដិសណ្ឋារៈ យ៉ាងរីករាយជាមួយព្រះថេរៈ បន្ទាប់មកក៏លើកឡើងនូវសំណួរ ដោយសេចក្តីគោរពថាៈ

“សូមគោរពលោកម្ចាស់ ! លោកម្ចាស់មានមុខញញឹម មានឥន្ទ្រិយ៍ស្រគត់ស្រគំ និងមានពណ៌សម្បុរភ្លឺថ្លាល្អ, តើប្រយោជន៍អ្វីទៅ ដែលលោកម្ចាស់គេចខ្លួនពីលោកនេះ ?, នរណាជាគ្រូរបស់លោកម្ចាស់ទៅ ?, តើលោកម្ចាស់ប្រតិបត្តិតាម ពាក្យប្រៀនប្រដៅរបស់គ្រូណាទៅ ? ” ។

មិនបានអួតអាងអ្វីឡើយ, ព្រះអរហន្តអស្សជិបានឆ្លើយយ៉ាងរម្យទមថាៈ

“ម្នាលឧបាសក ! អាត្មាភាពទើបតែបួសថ្មីទេ, អាត្មាភាពមិនអាចសម្តែងធម៌ជូនឧបាសកបានពិស្តារទេ” ។

“ខ្ញុំករុណាឈ្មោះឧបតិស្សៈណាម្ចាស់ថ្លៃ សូមលោកម្ចាស់មេត្តាសម្តែងធម៌តិចឬច្រើន តាមតែសមត្ថភាពរបស់លោកម្ចាស់ទៅចុះ ហើយទុកឲ្យខ្ញុំករុណាជាអ្នកយល់នូវព្រះធម៌នោះ វាប់រយពាន់ទៀតចុះ”។

ឧបតិស្សៈបានទូលព្រះអស្សជិបន្តទៀតថា: “តិចឬច្រើនតាមសមត្ថភាពលោកម្ចាស់, សូមមេត្តាសម្តែងប្រាប់ត្រឹមតែខ្លឹមធម៌ប៉ុណ្ណោះបានហើយ ។ តើខ្ញុំករុណាសុំត្រឹមតែខ្លឹមធម៌ប៉ុណ្ណោះបានទេលោកម្ចាស់ ? ឯពាក្យច្របូកច្របល់ដទៃៗទៀត មិនមានប្រយោជន៍ឡើយ” ។

ព្រះអស្សជិភិក្ខុ បានពោលនូវគាថាមួយមានបួនឃ្លា (បួនបាថ), សង្ខេបសេចក្តីពីទស្សនវិជ្ជា ដែលបានសម្តែងឡើងដោយព្រះពុទ្ធបរមគ្រូនៅក្នុងន័យរបស់អរិយសច្ចធម៌ថា:

**យេ ធម្មា ហេតុប្បភវា, តេសំ ហេតុំ តថាគតោ,**
**តេសញ្ច យោ និរោធោ, ឯវំ វាទី មហាសមណោ។**

ធម៌ទាំងឡាយណាដែលកើតចេញពីហេតុ ព្រះតថាគតតែងពោលនូវហេតុនៃធម៌នោះ, ម្យ៉ាងវិញទៀត សេចក្តីរលត់ និងឧបាយឯណាជាគ្រឿងរលត់នៃធម៌នោះ, ព្រះតថាគតបានពោលហើយ

នូវសេចក្តីរលត់នោះ, ព្រះមហាសមណៈមានប្រក្រតី ពោលពាក្យយ៉ាងនេះឯង ។

ព្រះអស្សជិភិក្ខុ បានសម្តែងប្រាប់ឧបតិស្សៈ នូវអ្វីដែលលោកបានចេះចាំបន្តិចបន្តួច ដូចបញ្ជាក់ក្នុងន័យខាងលើ ។ គ្រាន់តែបានឮនូវសេចក្តីពីរឃ្លាខាងលើកាលណាហើយ ក៏ធ្វើឲ្យឧបតិស្សៈបានសម្រេចនូវសោតាបត្តិមគ្គភ្លាម ។

ឧបតិស្សៈបានថ្វាយបង្គំលាព្រះអស្សជិ ហើយត្រឡប់ទៅរកកោលិតៈ ដើម្បីប្រាប់ដំណឹងដ៏គួរឲ្យរីករាយនេះ ។ កោលិតៈក៏បានសម្រេចនូវសោតាបត្តិមគ្គ ដូចជាមិត្តរបស់គាត់ដែរ នៅពេលបានស្តាប់គាថាទាំងមូល ដែលឧបតិស្សៈសម្តែងប្រាប់បន្តហើយ ។ ដោយការរំភើបចិត្តជាខ្លាំង ជាមួយការរីករាយនៅក្នុងការសន្និដ្ឋាន ប្រកបដោយជោគជ័យ ក្នុងការស្វែងរករបស់ពួកគេ ។ ឧបតិស្សៈនិងកោលិតៈ បានធ្វើដំណើរទៅកាន់អារាមគ្រូដើមរបស់ពួកគេ ហើយបានជួបនឹងអាចារ្យសញ្ជ័យ ខិតខំប្រឹងពន្យល់នូវសាសនាថ្មីនេះប្រាប់ដល់គ្រូ ។ មិនបានសម្រេចដូចគោលបំណងឡើយ ឧបតិស្សៈនិងកោលិតៈ ដែលដង្ហែដោយកូនសិស្សចំនួន២៥០ ជាសាវ័ករបស់អាចារ្យសញ្ជ័យ បានចេញដំណើរតម្រង់ឆ្ពោះទៅវត្តវេឡុវន ដើម្បីជួបព្រះពុទ្ធបរមគ្រូ ។

ក្នុងការយល់ព្រមលើសំណើរបស់ពួកគេ ព្រះពុទ្ធទ្រង់បាន អនុញ្ញាតឲ្យពួកគេទាំងពីរ បួសតាមសទ្ធាជាឯហិភិក្ខុនាគ្រានោះទៅ ។

កន្លះខែក្រោយមក ព្រះសារីបុត្របានសម្រេចជាព្រះអរហត្ត ដោយសារការបានស្តាប់ព្រះពុទ្ធ សម្តែងធម៌ទេសនា ពីបរិគ្គហសូត្រ ប្រោសអាជីវកទីឃនខៈ ។ នៅរសៀលថ្ងៃជាមួយគ្នានោះដែរ ព្រះពុទ្ធបាន កោះប្រជុំសាវ័កទាំងអស់ ដើម្បីប្រកាសតែងតាំងព្រះសារីបុត្រ នូវមុខ ងារជាអគ្គសាវ័ក និងព្រះមោគ្គល្លានដែលបានសម្រេចអរហត្តផល មួយ សប្តាហ៍មុនព្រះសារីបុត្រ ក្នុងតំណែងជាសាវ័កទីពីរ នៅក្នុងសហគមន៍ សង្ឃ ។

# ៦.យាងទៅកាន់នគរកំណើត

## ស្ដេចសុទ្ធោទនៈជួបព្រះពុទ្ធ

បានឮថា ព្រះពុទ្ធកំពុងសម្ដែងធម៌ទេសនា នៅក្នុងក្រុងរាជគ្រឹះ, ស្ដេចសុទ្ធោទនៈ មានបំណងចង់ឃើញព្រះពុទ្ធអង្គយ៉ាងខ្លាំង ។ អាមាត្យចំនួន៩រូប, ក្នុងអាមាត្យម្នាក់ៗ មានបរិវារយ៉ាងច្រើន ត្រូវបានបញ្ជូនឲ្យទៅចំនួន៩ដង ដើម្បីនិមន្តព្រះពុទ្ធមកកាន់ក្រុងកបិលវត្ថុ ។ ផ្ទុយពីក្ដីសង្ឃឹមរបស់ព្រះរាជា អាមាត្យនិងអ្នករួមដំណើរបានបួសទាំងអស់គ្នា ហើយក៏បានសម្រេចនូវអរហត្តផល គ្មានសល់ម្នាក់ណាឡើយ ។ តាំងតែពីពួកគេបានបួស ហើយបានសម្រេចធម៌ជាព្រះអរហន្តមក មិនបាននឹកនាទៅដល់រឿងរ៉ាវជាលោកីយ៍នោះឡើយ, ពួកគេមិនបាននាំសាររបស់ព្រះរាជាទូលថ្វាយដល់ព្រះពុទ្ធឡើយ ។

ស្ដេចអស់សង្ឃឹមខ្លាំងណាស់ ទីបំផុតបានបញ្ជូនកាឡុទាយិ ដែលប្រសូតក្នុងថ្ងៃតែមួយជាមួយព្រះសិទ្ធត្ថដែរ ។ គាត់បានយល់ព្រមទៅក្នុងល័ក្ខខ័ណ្ឌមួយថា គាត់ប្រហែលជាត្រូវព្រះពុទ្ធអង្គឲ្យចូលបួសដែរ ។

កាឡុទាយិអាមាត្យដូចជាអ្នកមុនៗដែរ កាលបើបានស្ដាប់ធម៌ទេសនាហើយ ក៏បានសម្រេចនូវអរហត្តផល ហើយក៏ទូលសុំចូលបួស

ដូចដែលបានគិតមែន ។ ប៉ុន្តែមិនដូចអ្នកដទៃទៀតទេ, ភិក្ខុកាឡុទាយិបាន នឹកឃើ ដល់ក្រុងកបិលវត្ថុ ក្នុងកំឡុងពេលពីរខែគត់ ។

ព្រះរាជាទ្រង់បញ្ជាគេឲ្យចាត់ចែង ថ្វាយព្រះពុទ្ធអង្គនិងព្រះសង្ឃជាសាវ័ក នៅកន្លែងស្នាក់នៅក្នុងឧទ្យាននិគ្រោធ ជាកម្មសិទ្ធិរបស់រាជវង្សសក្យៈ ។ គ្មានការគោរពនិងស្ដាប់តាមឱវាទរបស់ព្រះអង្គឡើយ, ក្រុមព្រះញាតិវង្សទាំងនោះ ឲ្យតែពួកក្មេងៗប៉ុណ្ណោះចូលទៅគោរពព្រះអង្គ ។ ព្រះពុទ្ធបានបង្ក្រាបនូវអស្មិមានៈរបស់ក្រុមព្រះញាតិវង្ស ដោយការហោះឡើងទៅលើអាកាស ហើយសម្ដែងឲ្យពួកញាតិវង្សទាំងនោះ បានមើលឃើញនូវ“អច្ឆរិយភាព”របស់ព្រះអង្គ ។ ស្ដេចបានឃើញនូវទិដ្ឋភាពដ៏អស្ចារ្យបែបនេះ បានឱនកាយថ្វាយបង្គំព្រះអង្គភ្លាម ដោយមានព្រះរាជឱង្ការថា នេះជាការថ្វាយបង្គំលើកទី៣ហើយ ។ ពួកសាក្យៈទាំងអស់ក៏ឱនកាយថ្វាយបង្គំព្រះពុទ្ធអង្គ តាមព្រះរាជាដោយសេចក្ដីគោរពដែរ ។

គ្រានោះ ព្រះពុទ្ធបានយាងចុះពីអាកាសមកក្រោមវិញ ហើយគង់នៅលើអាសនៈ ដែលគេបានរៀបបម្រុងទុក ។ ព្រះញាតិវង្សទាំងអស់ ក៏នាំគ្នាអង្គុយចុះហើយស្ដាប់ព្រះអង្គ ។

បន្ទាប់មក បាតុភូតដ៏ចម្លែកមួយបានកើតឡើង, ភ្លៀងយ៉ាងធំមួយមេ ក៏បង្អុរធ្លាក់ចុះមក ប៉ុន្តែភ្លៀងទទឹកចំពោះតែជនណាដែលប្រាថ្នាចង់ទទឹក ហើយបើជនណាមិនប្រាថ្នាក៏មិនទទឹកដែរ ។ នៅពេលដែលពួក

សាក្យៈ កំពុងស្ងប់ស្ងែងដល់បាតុភូតនោះ ព្រះពុទ្ធបានលើកយករឿងវេស្សន្តរជាតកមកទេសនា ដើម្បីបង្ហាញថារឿងដូចគ្នានេះធ្លាប់បានកើតឡើង នៅចំពោះវត្តមាននៃព្រះញាតិវង្សរបស់ព្រះអង្គ តាំងតែពីអតីតជាតិមកម្ល៉េះ ។

## ព្រះពុទ្ធនិមន្តចេញបិណ្ឌបាត្រ

ថ្ងៃបន្ទាប់មក គ្មានអ្នកណាម្នាក់នឹកឃើញ និមន្តព្រះពុទ្ធទទួលភត្តាហារថ្ងៃត្រង់ទេ ។ ព្រះពុទ្ធអង្គមានបាត្រទ្រជាប់នឹងព្រះហស្ត បាននិមន្តពីផ្ទះមួយទៅផ្ទះមួយទៀត តាមដងវិថីនៅក្នុងទីក្រុងកបិលវត្ថុ ដើម្បីស្វែងរកអាហារ ជាមួយនឹងភិក្ខុសង្ឃសាវ័កជាច្រើនរូប ។ រឿងរ៉ាវនេះបានលិចឮទៅដល់ព្រះរាជា ដែលញ៉ាំងឲ្យព្រះអង្គរំជួលព្រះទ័យយ៉ាងខ្លាំង និងឈឺចាប់ចំពោះទិដ្ឋភាពនោះក្រៃលែង ទើបទ្រង់ទូលសួរទៅព្រះពុទ្ធថា ហេតុអ្វីក៏ព្រះអង្គធ្វើឲ្យអាម៉ាស់មុខ ដល់ក្រុមព្រះញាតិវង្សយ៉ាងនេះ ។

ព្រះពុទ្ធឆ្លើយតបស្តេចជាបិតាថា “បពិត្រព្រះរាជា, នេះជាប្រពៃណីនៃវង្សត្រកូលរបស់យើង” ។

“បពិត្រព្រះអង្គដ៏ចម្រើន, តើពិតយ៉ាងហ្នឹងឬ ? ប្រពៃណីនៃត្រកូលរបស់យើង គឺជាអ្នកធ្វើសង្គ្រាមតវង្សមក តាំងពីព្រះបាទមហាសន្មត

ហើយគ្មានបុគ្គលណាមួយបានប្រព្រឹត្តទៅ ក្នុងការស្វែងរកសុំទានអាហារគេបែបនេះទេ” ។

“បពិត្រមហារាជ, វង្សត្រកូលបែបនោះ ជាប្រពៃណីរបស់ព្រះរាជា, ចំណែកតថាគតវិញជាវង្សត្រកូលព្រះពុទ្ធ” ។

ទ្រង់ឈរនៅលើផ្លូវ ព្រះពុទ្ធអង្គបានប្រទានដំបូន្មាន ដល់ព្រះរាជាដូច្នេះថា:

“សូមប្រយ័ត្នប្រយែង ! កុំធ្វេសប្រហែសឲ្យសោះ ! ចូរនាំជីវិតទៅតាមផ្លូវត្រូវ ។ ជីវិតត្រឹមត្រូវល្អ តែងរីករាយក្នុងលោកនេះផង និងលោកខាងមុខផង”។

ព្រះរាជាបានទតឃើញពន្លឺនៃសច្ចៈ ហើយក៏បានសម្រេចនូវថ្នាក់សោតា ។ បន្ទាប់មក ព្រះអង្គសុំយកបាត្រពីព្រះពុទ្ធ និងបាននាំព្រះពុទ្ធអង្គ និងភិក្ខុសង្ឃសាវ័កទាំងអស់ យាងទៅកាន់ព្រះរាជវាំង ហើយថ្វាយនូវភត្តាហារយ៉ាងបរិបូណ៌ ។ បន្ទាប់ពីទទួលភត្តមក ព្រះពុទ្ធអង្គបានសម្ដែងធម៌ទេសនាដូច្នេះ៖

“ចូរនាំជីវិតទៅតាមផ្លូវត្រូវ ហើយកុំធ្វើអ្វីមួយដែលមិនល្អ ។ ជីវិតដែលបានធ្វើល្អហើយ តែងនាំមកនូវការរីករាយក្នុងលោកនេះផង និងលោកខាមុខផង ។

គ្រានោះ ស្តេចសុទ្ធោទនៈក៏បានសម្រេចធម៌ថ្នាក់សកទាគាមី ជាឯកពិធី, ចំណែកព្រះនាងបជាបតិគោតមីបានសម្រេចសោតា ជាអរិយបុគ្គលថ្នាក់ទីមួយ ។ នៅឱកាសខាងក្រោយ ដោយបានស្តាប់ធម្មបាលជាតក ស្តេចក៏បានសម្រេចអនាគាមី ជាអរិយបុគ្គលថ្នាក់ទីបី ។ នៅក្នុងខណៈព្រះអង្គផ្ទុំលើគ្រែ ទៀបនឹងចូលទិវង្គតហើយបានស្តាប់ធម៌ដែលព្រះពុទ្ធអង្គ សម្តែងក្នុងនាទីចុងក្រោយក៏បានសម្រេចអរហត្តផល ។

## ប្រោសនាងយសោធរា (ពិម្ពា)

នៅខណៈព្រះពុទ្ធនិមន្ត ទៅកាន់ព្រះរាជវាំងកបិលវត្ថុ សមាជិកព្រះញាតិវង្សទាំងអស់ បានមកថ្វាយបង្គំព្រះអង្គ លើកលែងតែព្រះនាងពិម្ពា (យសោធរា) ។ ព្រះនាងយសោធរាបានគិតថា:

“ប្រសិនបើខ្ញុំមានបុណ្យកុសល ព្រះអង្គនឹងយាងមកកាន់កន្លែងខ្ញុំ ហើយខ្ញុំនឹងបានគោរពព្រះអង្គមិនខាន” ។

ព្រះពុទ្ធទ្រង់ហុចបាត្រទៅព្រះរាជា ហើយព្រះអគ្គសាវ័កទាំងពីរអង្គ បានដង្ហែព្រះពុទ្ធចូលទៅក្នុងប្រាសាទ របស់ព្រះនាងយសោធរា រួចគង់នៅលើអាសនៈ ដែលគេបានរៀបថ្វាយយ៉ាងសមគួរ ទើបមានបន្ទូលថា:

“សូមឲ្យព្រះនាងយសោធរា គោរពតាមដែលព្រះនាងចូលចិត្តចុះ” ហើយទ្រង់មិនមានបន្ទូលអ្វីទៀតទេ ។

ព្រះនាងយសោធរា បានស្ទុះចេញយ៉ាងលឿនមកក្រៅបន្ទប់ លូកដៃទាំងពីរចាប់ព្រះបាទា របស់ព្រះអង្គយ៉ាងណែន រួចដាក់សិរសាកើយលើព្រះបាទទាំងគូរបស់ព្រះអង្គ ដើម្បីសម្តែងការគោរពតាមដែលព្រះនាងចូលចិត្ត និងការនឹករលឹកដ៏ធំដូចជាមហាសាគរ ។

ព្រះរាជាបានពន្យល់ ពីសេចក្តីស្នេហារបស់នាង ថ្វាយដល់ព្រះពុទ្ធថា:

“បពិត្រព្រះអង្គដ៏ចម្រើន, នៅពេលព្រះនាងយសោធរា បានឮដំណឹងថា ព្រះអង្គស្លៀកដណ្តប់សំពត់ពណ៌លឿង ព្រះនាងក៏ស្លៀកដណ្តប់សំពត់ពណ៌លឿងដែរ, នៅពេលបានដំណឹងថា ព្រះអង្គសោយអាហារតែម្តងក្នុងមួយថ្ងៃ ព្រះនាងក៏សោយអាហារតែម្តងក្នុងមួយថ្ងៃដែរ, នៅពេលព្រះនាងបានដំណឹងថា ព្រះអង្គលះបង់ទីផ្ទំនិងទីគង់ដ៏ល្អប្រណិត ព្រះនាងក៏បានធ្វើដូចគ្នា, នៅពេលព្រះនាងបានដំណឹងថា ព្រះអង្គបានលះបង់កម្រងផ្កានិងក្លិនក្រអូប ព្រះនាងក៏បានលះបង់ចោលដូចគ្នាដែរ, នៅពេលព្រះញាតិបានបញ្ជូនរាជសារ ដែលនិយាយថា ពួកគេជួយរ៉ាប់រងថែរក្សាព្រះនាង, ព្រះនាងមិនសម្លឹងមើលសូម្បីតែម្តងផង ។ ដូច្នេះនេះជាគុណរបស់ព្រះនាងយសោធរា ។

ព្រះពុទ្ធមានបន្ទូលថាៈ “ព្រះនាងធ្លាប់ស្មោះត្រង់នឹងព្រះតថាគត មិនមែនតែនៅក្នុងជាតិនេះទេ គឺធ្លាប់មានមកតាំងពីអតីតជាតិម្ល៉េះ” ។ រួច ទ្រង់លើកយកចន្ទកិន្នរជាតក មកសម្ដែងយ៉ាងពិស្ដារដើម្បីលួងចិត្តនាង បន្ទាប់ពីចប់ធម៌ទេសនា ព្រះអង្គក៏យាងចេញពីព្រះរាជវាំងទៅ ។

បន្ទាប់ពីស្ដេចសុទ្ធោទនៈចូលទិវង្គតទៅ ព្រះនាងមហាបជាបតិគោតមីបានបួសជាភិក្ខុនី, ឯព្រះនាងយសោធរាក៏បានចូលបួសដែរ ហើយមិនយូរប៉ុន្មានបានសម្រេចអរហត្តផលទៅ ។ សូមបញ្ជាក់ថា ព្រះនាងយសោធរាមានព្រះជន្មដំណាលគ្នា នឹងព្រះពុទ្ធដែរ ។

## ព្រះនន្ទ

ពីរថ្ងៃបន្ទាប់ពីព្រះពុទ្ធ យាងមកដល់ទីក្រុងកបិលវត្ថុ, ព្រះអង្គម្ចាស់នន្ទ ជាព្រះរាជបុត្ររបស់ព្រះនាងបជាបតិគោតមី រៀបមង្គលាភិសេក (អាវាហវិវាហមង្គល) ។ ពិធីមង្គលនេះ ជាឱកាសល្អមួយ ដែលព្រះពុទ្ធបានយាងចូលទៅខាងក្នុងព្រះរាជវាំង ។ ព្រះអង្គបានហុចបាត្រទៅព្រះអង្គម្ចាស់នន្ទ ហើយសូត្រនូវធម៌ពរជ័យ ថ្វាយដល់ព្រះអង្គម្ចាស់នន្ទ តែទ្រង់មិនបានយកបាត្រពីព្រះអង្គម្ចាស់វិញទេ ។ ព្រះអង្គម្ចាស់នន្ទបានដើរតាមក្រោយព្រះពុទ្ធសន្សឹមៗ, ចំណែកនាងជនបទកល្យាណី កាលឃើញព្រះអង្គម្ចាស់នន្ទ យាងតាមក្រោយព្រះពុទ្ធដូចនេះ ក៏ពោលឡើងថាៈ

“ម្ចាស់ថ្លៃអូនអើយ ! សូមបងប្រញាប់ត្រឡប់មកវកអូនវិញឆាប់ៗវ៉ា” ។ ពាក្យប៉ុន្មានម៉ាត់របស់ព្រះនាងជនបទកល្យាណី បានមុតយ៉ាងជ្រៅ ទៅក្នុងបេះដូងរបស់ព្រះអង្គម្ចាស់នន្ទ ប៉ុន្តែជាមួយនឹងសេចក្តីគោរពចំពោះព្រះពុទ្ធ ទ្រង់មិនហ៊ានត្រឡប់ក្រោយឡើយ ហើយក៏ត្រូវបានព្រះពុទ្ធសុំឱ្យព្រះអង្គម្ចាស់នន្ទ បួសក្នុងសហាគមន៍សង្ឃទៅ ។ ដោយការទើសទ័លក្នុងចិត្ត ព្រះអង្គម្ចាស់នន្ទក៏បានយល់ព្រមចូលបួស គ្រាន់តែដើម្បីការគោរពព្រះអង្គដែលជាព្រះពុទ្ធ និងជាបងប្រុសប៉ុណ្ណោះឯង, ប៉ុន្តែនៅក្នុងចិត្តរលឹករឿយៗ ដល់សម្តីរបស់នាងជនបទកល្យាណីជាគូសង្សារ ។ ព្រះពុទ្ធអង្គបានទ្រង់ប្រើញាណមើលឃើញ ការគិតរបស់នន្ទ ហើយបានរកមធ្យោបាយដើម្បីស្រោចស្រង់នន្ទ ទៅរកផ្លូវត្រូវជាមួយនឹងការបង្ហាញនន្ទ ពីនាងអប្សរនៅស្ថានសួគ៌ គឺទ្រង់ប្រើឫទ្ធិរបស់ព្រះអង្គ នាំភិក្ខុនន្ទទៅកាន់ស្ថានសួគ៌ ។ នៅតាមផ្លូវព្រះពុទ្ធបានបង្ហាញនន្ទភិក្ខុ នូវស្វាញីឯកាមួយ ត្រូវភ្លើងឆេះដើរខ្ទើចៗ នៅលើវាលដែលភ្លើងឆេះខ្លោច ។ លុះបានទៅដល់ស្ថានសួគ៌ នន្ទភិក្ខុបានសម្លឹងមើលពួកស្រីអប្សរសួគ៌ ដោយការពេញចិត្តយ៉ាងខ្លាំង, ភិក្ខុនន្ទបានប្រៀបនាងជនបទកល្យាណី ដូចជាមេស្វាចាស់ដែលលោកបានឃើញតាមផ្លូវ ។

ព្រះពុទ្ធបានសួរទៅនន្ទភិក្ខុថា “ម្នាលនន្ទ, តើអ្នកពេញចិត្តនឹងស្រីអប្សរសួគ៌ទាំងនោះទេ ? ”

នន្ទភិក្ខុដូចជាកូនក្មេងម្នាក់ ឆ្លើយតបទៅព្រះពុទ្ធយ៉ាងរហ័សថា "បពិត្រព្រះអង្គដ៏ចម្រើន, ពេញចិត្តណាស់, ពេញចិត្តណាស់" ។

"ល្អហើយ, តថាគតធានាថាអ្នកអាចបានពួកស្រីអប្សរទាំងនោះ ប្រសិនបើអ្នកខិតខំព្យាយាមតាមដែលតថាគតបង្រៀនអ្នក។

ដោយបានឮថានន្ទភិក្ខុ បានប្រឹងប្រែងដើម្បីឱ្យបានឈ្នះរង្វាន់ស្រីអប្សរសួគ៌ ភិក្ខុទាំងឡាយនាំគ្នាសើចចំអកឱ្យនន្ទ ដោយបានហៅនន្ទថា "អ្នកបួសស៊ីឈ្នួល" ។ នន្ទភិក្ខុមានការអៀនខ្មាស់ខ្លាំងណាស់ ចំពោះពួកភិក្ខុទាំងឡាយ ហើយក៏បានខិតខំព្យាយាម រហូតបានសម្រេចជាព្រះអរហន្ត ។

# ប្រោសរាហុល

ថ្ងៃទីប្រាំពីរ បន្ទាប់ពីព្រះពុទ្ធយាងមកដល់ទីក្រុងកបិលវត្ថុ ព្រះនាងយសោធរា បានតុបតែងកាយយ៉ាងស្អាត ឱ្យព្រះអង្គម្ចាស់រាហុលកុមារ រួចលើកដៃចង្អុលទៅរកព្រះពុទ្ធ ដោយមានព្រះសុរណ្ណីថា:

"ម្នាលបុត្រ, ចូរបាសម្លឹងមើលនោះន៎ មហាសមណៈដែលមានដំណើរ ប្រកបដោយសីហវិលាសនោះ ជាព្រះបិតារបស់បុត្រហើយ ។ ចូរបុត្រទៅរកព្រះអង្គ ហើយទូលសុំកំណាប់ទ្រព្យទាំងបួនពីព្រះអង្គមក" ។

រាហុលបានចុះដើរទៅរកព្រះពុទ្ធ ហើយទូលសុំព្រះអង្គនូវកំណប់ទ្រព្យ តាមការណែនាំរបស់ម្ដាយ ។ ដោយបាននិយាយសម្ដីគួរឲ្យស្រឡាញ់ថាៈ

"បពិត្រព្រះមហាសមណៈ! ម្លប់របស់ព្រះអង្គធ្វើឲ្យខ្ញុំរីករាយខ្លាំងណាស់" ។

បន្ទាប់ពីទទួលភត្តាហារថ្ងៃរួចមក រាហុលកុមារបានដើរតាមព្រះពុទ្ធ ដោយព្រះអង្គមានបន្ទូលយ៉ាងច្រើន ។ គ្មានអ្នកណាមួយប៉ុនប៉ង ដើម្បីបញ្ឈប់រាហុលកុមារឡើយ ឬក៏ព្រះពុទ្ធអង្គបានហាមរាហុល កុំឲ្យដើរតាមព្រះអង្គឡើយ ។ ពេលនិមន្តទៅដល់ឧទ្យាននិគ្រោធារាម ព្រះពុទ្ធហៅព្រះសារីបុត្រមក ហើយមានបន្ទូលថា "រាហុលបានមកទីនេះ ហើយសុំកំណប់ទ្រព្យទាំងបួនពីតថាគត ។ ឥឡូវនេះ តថាគតប្រគល់ឲ្យរាហុលកុមារ នូវអរិយទ្រព្យប្រាំពីរប្រការវិញ ដែលតថាគតបានទទួលនៅទៀបគល់ពោធិព្រឹក្ស ហើយនឹងធ្វើរាហុលឲ្យជាម្ចាស់នៃអរិយទ្រព្យនោះប្រសើរជាង ។ ម្នាលសារីបុត្រ ចូរបំបួសរាហុលកុមារទៅ នៅបង្អង់អ្វីទៀត" ។

រាហុលកុមារ ទើបតែមានអាយុប្រាំពីរឆ្នាំប៉ុណ្ណោះ ក៏បានចូលបួសជាសាមណេរ នៅក្នុងសហគមន៍សង្ឃពេលនោះទៅ ។ ស្ដេចសុទ្ធោទនៈមានការក្រៀមក្រំក្នុងព្រះទ័យយ៉ាងខ្លាំង ដោយបានទទួលដំណឹងថារាហុលកុមារ ចៅជាទីស្រឡាញ់របស់ព្រះអង្គ ត្រូវបានបំបួសជាសាមណេរយ៉ាង

នេះ ។ ស្ដេចបានយាងទៅជួបព្រះពុទ្ធ ហើយទូលសុំដោយផ្ទាល់ចំពោះព្រះអង្គ ឲ្យឈប់បំបួសកុលបុត្រណាមួយ ដែលមិនទាន់បានទទួលការអនុញ្ញាត ពីឪពុកម្ដាយរបស់គេជាមុន ។ ព្រះពុទ្ធអង្គក៏បានយល់ព្រមតាមសំណូមពរនោះ ។

មានព្រះធម៌ទេសនាជាច្រើន ដែលព្រះពុទ្ធអង្គបានសម្ដែងជាពិសេសចំពោះរាហុលសាមណេរ ។ នៅពេលអាយុចម្រើនឡើង រាហុលសាមណេរក៏បានឧបសម្បទា ហើយបានសម្រេចអរហត្តផល ក្នុងកាលគួរមួយទៅ ។

## ព្រះអានន្ទ

ព្រះអានន្ទជាបងប្អូនជីដូនមួយនឹងព្រះពុទ្ធ លោកបានចូលបួសជាមួយនឹងពួកសាក្យៈមាន អនុរុទ្ធ ភទ្ទិយៈ ភគុ កិម្ពិលៈ និង ទេវទត្ត ។ ដោយបានស្ដាប់ព្រះធម៌ទេសនា ពីសំណាក់ព្រះថេរៈមន្តានិបុត្តៈ ក៏បានសម្រេចសោតាបន្នៈ ។

លោកមានសតិចងចាំមិនភ្លេច និងពេញដោយអំណាចផង, លោកមាននិស្ស័យខាងការស្ដាប់ ព្រះធម៌ទេសនាទាំងអស់ ដែលព្រះពុទ្ធបានសម្ដែងហើយ ព្រោះលោកស្ថិតនៅជិតនឹងព្រះពុទ្ធអង្គ ហើយក្រោយមកលោកត្រូវបានទទួលការ តែងតាំងជា“ឃ្លាំងធម៌” (ធម្មភណ្ឌាគារិក) ។

ចាប់ពីត្រឹមព្រះពុទ្ធអង្គ មានព្រះជន្មគម្រប់៥៥ព្រះវស្សា រហូតដល់ទ្រង់ចូលនិព្វាន នៅក្នុងព្រះជន្ម៨០វស្សា ព្រះអានន្ទត្រូវបានជ្រើសឲ្យបម្រើព្រះពុទ្ធផ្ទាល់ មានឈ្មោះថាពុទ្ធុបដ្ឋាក ។

ព្រះអានន្ទបានជួយអន្តរាគមន៍ ឲ្យពួកស្ត្រីបានបួសជាភិក្ខុនី នៅក្នុងព្រះពុទ្ធសាសនា ។ នៅបឋមសង្គាយនា ព្រះអានន្ទត្រូវបានជ្រើសតាំងដើម្បីផ្ទៀងផ្ទាត់ព្រះធម៌ ។ ដូច្នេះរាល់គម្ពីរព្រះសូត្រសុទ្ធសឹងតែផ្តើម ដោយពាក្យរបស់ព្រះអានន្ទថា “ឯវម្មេ សុតំ... ខ្ញុំ(គឺអានន្ទ)បានស្តាប់មកហើយយ៉ាងនេះថា....”។

ព្រះអានន្ទត្រូវបានគេយល់ថា ជាអ្នកដឹកនាំមួយផ្នែកនៅក្នុងបឋមសង្គាយនា ដែលបានបង្កើតឡើងដោយក្រុមព្រះអរហន្តមានឈ្មោះល្បីៗ ។ លោកបានព្យាយាមយ៉ាងតឹងតែង រហូតបានសម្រេចព្រះអរហត្តផល នៅខណៈដែលលោកដាក់ខ្លួនទម្រេតចុះទៅលើគ្រែ នៅពេលរាត្រីមួយ មុនបឋមសង្គាយនាត្រូវបានប្រារព្ធឡើង ។ ព្រះអានន្ទជាសាវ័កមួយអង្គ ដែលបានសម្រេចអរហត្តផល មិនស្ថិតនៅក្នុងឥរិយាបថអង្គុយ ឈរ ដើរ ឬក៏ដេកដូចសាវ័កដទៃឡើយ ។

# ទេវទត្ត

ទេវទត្តជារាជបុត្ររបស់ស្តេចសុប្បពុទ្ធ ជាបងប្អូនជីដូនមួយ និងជាបងថ្លៃរបស់ព្រះសិទ្ធត្ថ ។ លោកបានចូលបួស នៅក្នុងសំណាក់ព្រះពុទ្ធ ហើយបានទទួលនូវគុណវិសេសមួយ គឺលោកិយឈាន ដែលអាចសម្តែងឫទ្ធិដោយកាយ ធ្វើឲ្យលោកបានទទួលនូវកិត្តិយស និងអ្វីៗជាលោកីយ៍ ។ ទេវទត្តបានប្តូរជីវិត ឲ្យក្លាយជាគូបដិបក្សធំបំផុត ជាមួយព្រះពុទ្ធ ។

គ្រាមួយនោះ លោកបានចូលទៅរកព្រះពុទ្ធ ហើយទូលថ្វាយពីបំណងរបស់លោក ដើម្បីដឹកនាំសង្ឃដូចជាគ្រូម្នាក់ ។ ព្រះពុទ្ធបានបដិសេធគំនិតនោះ, ហេតុនោះហើយ នាំឲ្យភិក្ខុទេវទត្តចាប់ផ្តើមធ្វើនូវអំពើអាក្រក់ជាច្រើន ចំពោះព្រះពុទ្ធអង្គ ដែលចុងក្រោយធ្វើឲ្យទេវទត្តទទួលរងទុក្ខវេទនានៅក្នុងនរកអវចី ។

ដោយបានដឹងច្បាស់ថា ព្រះពុទ្ធមិនយល់ព្រមតាមសំណើរបស់ខ្លួន ទេវទត្តក៏រកលេសបង្ខូចកិត្តិនាមព្រះអង្គ ហើយដណ្តើមយកឈ្នះលើការគាំទ្រ ពីអ្នកស្រុកដែលមិនយល់ ។ លោកបានទូលស្នើព្រះពុទ្ធ ដើម្បីឲ្យភិក្ខុសង្ឃក្នុងសាសនានេះ ប្រតិបត្តិវិន័យទាំង៥យ៉ាង មានដូចខាងក្រោម៖

១- ព្រះសង្ឃត្រូវគង់នៅក្នុងព្រៃអស់មួយជីវិត ។

២-ព្រះសង្ឃត្រូវរស់នៅ ដោយអាហារដែលបានមក ដោយការដើរបិណ្ឌបាត្រ អស់មួយជីវិត។

៣-ព្រះសង្ឃត្រូវស្លៀកដណ្ដប់សំ ពត់បង្សុកូល (ជាសំពត់ធ្វើពីកំទេចសំណល់ ដែលបានមកពីគំនរសម្រាម) ។

៤-ព្រះសង្ឃត្រូវរស់នៅទៀបគល់ឈើ ដរាបអស់មួយជីវិត

៥- ព្រះសង្ឃមិនត្រូវឆាន់ត្រី ឬសាច់ទេ ។

ព្រះពុទ្ធអង្គទ្រង់ទតឃើញវែងឆ្ងាយ ទ្រង់បានប្រកាសថា ចំពោះអ្នកណាដែលប្រាថ្នាប្រតិបត្តិតាមទេវទត្ត អាចធ្វើបានតាមចិត្តចុះ ប៉ុន្តែព្រះអង្គទ្រង់មិនបញ្ញត្តសំណើនោះ ជាវិន័យដល់ភិក្ខុសង្ឃទូទៅឡើយ ។

ទេវទត្តបានបដិសេធនូវពុទ្ធប្រកាសនោះ ដែលជាអាវុធមួយបណ្ដាលឲ្យទំនាស់យ៉ាងធំកើតឡើង នៅក្នុងជួរព្រះសង្ឃ ។ ដើម្បីឈានទៅរកជោគជ័យ ទេវទត្តបានបញ្ចុះបញ្ចូលព្រះអង្គម្ចាស់អជាតសត្តុ ឲ្យធ្វើឃាតស្ដេចពិម្ពិសារជាបិតា ។ ការបរាជ័យនៅក្នុងការប្រឹងប្រែង ដើម្បីបំផ្លាញព្រះពុទ្ធអង្គម្ដងហើយម្ដងទៀត ទីបំផុតទេវទត្តបានធ្វើដោយខ្លួនឯងផ្ទាល់ នូវការប៉ុនប៉ងមិនបានជោគជ័យមួយ ដើម្បីសម្លាប់ព្រះពុទ្ធ ដោយការប្រមៀលដុំថ្ម ឲ្យធ្លាក់សង្កត់លើព្រះកេសព្រះពុទ្ធអង្គ ។ ឯកសារបានបញ្ជាក់ថា ទៅក្នុងអនាគតដ៏ឆ្ងាយ ទេវទត្តនឹងបានត្រាស់ជាព្រះបច្ចេកពុទ្ធមួយអង្គ ឈ្មោះថាអត្ថិស្សរៈ ជាផលនៃការប្រតិបត្តិដ៏ប្រសើរនិងត្រឹមត្រូវ ដែលលោកបានធ្វើនៅមុនពេល លោកបានធ្វើអំពើអាក្រក់នោះ ។

# ៧. បេសកកម្មរបស់ព្រះពុទ្ធ

បេសកកម្មពេញដោយជោគជ័យរបស់ព្រះពុទ្ធ អស់ពេល៤៥ វស្សា រាប់ចាប់តាំងពីព្រះអង្គមានព្រះជន្ម៣៥វស្សា ជាកាលបរិច្ឆេទនៃការត្រាស់ដឹង រហូតដល់ព្រះអង្គបរិនិព្វាន នៅក្នុងព្រះជន្ម៨០វស្សា, ព្រះពុទ្ធបានបម្រើមនុស្សជាតិ ដោយការធ្វើជាគម្រូក្នុងការគោរពវិន័យ ។ ពេញៗមួយឆ្នាំ ព្រះអង្គបាននិមន្តពីកន្លែងមួយ ទៅកន្លែងមួយដោយថ្មើរជើង ដើម្បីសម្តែងព្រះធម៌ទេសនាប្រៀនប្រដៅដល់មនុស្ស និងរំដោះសត្វលោកពីចំណងនៃវដ្តសង្សារ ។ នៅក្នុងរដូវភ្លៀង ព្រះអង្គគង់ចាំវស្សានៅទីកន្លែងមួយដែលជាទម្លាប់នៃពួកអ្នកបួសទាំងឡាយ ព្រោះថារដូវវស្សា មានភ្លៀងបង្អុរធ្លាក់ចុះមិនដាច់ឡើយ ។

## ទីតាំងគង់ចាំព្រះវស្សា២០ឆ្នាំដំបូង

តាមគម្ពីរពុទ្ធវង្សអដ្ឋកថា ព្រះពុទ្ធបានចំណាយពេលគង់ចាំវស្សាដូចខាងក្រោម:

### វស្សាទី១ នៅព្រៃឥសីបតនមិគទាយវ័ន

បន្ទាប់ពីការសម្តែងធម៌ទេសនា ធម្មចក្កប្បវត្តនសូត្រ នៅថ្ងៃ១៥កើតពេញបូណ៌មី ខែអាសាធមក ព្រះអង្គបានគង់ចាំវស្សាទីមួយ នៅព្រៃ

ឥសីបតនមិគទាយវន ជិតក្រុងពារាណសី ។ នៅទីនោះ មិនមានការកសាងសំណង់ជាធំដុំ ឬក៏រឹងមាំសម្រាប់ព្រះអង្គគង់អាស្រ័យនៅទេ ។

### វស្សាទី២, ទី៣, ទី៤ នៅវត្តវេឡុវន ក្រុងរាជគ្រឹះ

នៅពេលព្រះពុទ្ធនិមន្តទៅប្រោសស្តេចពិម្ពិសារ ស្តេចបានវេរឧទ្យានវេឡុវន គឺសួនឫស្សីរបស់ព្រះអង្គ ថ្វាយព្រះពុទ្ធនិងសង្ឃសាវ័ក ។ ទីនោះជាទីទួលស្ងាត់ល្អ និងស្ថិតនៅដាច់ពីភូមិអ្នកស្រុក មិនឆ្ងាយនិងមិនជិតពេកពីទីប្រជុំជន ។ ព្រះអង្គបានចំណាយពេលព្រះវស្សា គង់នៅក្នុងឧទ្យានដ៏ស្ងាត់នោះ ។

### វស្សាទី៥ នៅក្រុងវេសាលី

ក្នុងឆ្នាំនោះ ព្រះអង្គគង់ចាំវស្សានៅក្នុងកុដាគារសាលា មហាវ័ន ជិតក្រុងវេសាលី ។ ទ្រង់បានជ្រាបពីការចូលទិវង្គត របស់ស្តេចសុទ្ធោទនៈ ក៏បានយាងទៅក្រុងកបិលវត្ថុ ដើម្បីសម្តែងធម៌ទេសនាថ្វាយព្រះបិតា ។ បន្ទាប់ពីនោះភ្លាមទៅ ស្តេចសុទ្ធោទនៈក៏បានសម្រេចអរហត្តផល គង់ព្រះជន្មនៅបានរយៈពេលប្រាំពីរថ្ងៃ សោយនូវវិមុត្តិសុខ ហើយបន្ទាប់មកក៏ចូលនិព្វានទៅ ។

## ការបំបួសភិក្ខុនី

ភិក្ខុនីសង្ឃត្រូវបានបង្កើតឡើង នៅក្នុងវស្សាទីប្រាំ ។ បន្ទាប់ការចូលទិវង្គតរបស់ស្តេចសុទ្ធោទនៈមក ព្រះនាងបជាបតិគោតមីមានបំណង

ចង់បួសជាភិក្ខុនី ហើយបានចូលទៅរកព្រះពុទ្ធ ដែលពេលនោះព្រះអង្គគង់នៅក្នុងក្រុងកបិលវត្ថុ ព្រះនាងបានទូលសុំការអនុញ្ញាតឲ្យពួកស្ត្រី អាចចូលបួសនៅក្នុងសង្ឃបានផង ។ ព្រះពុទ្ធបានបដិសេធសំណើនោះម្តងហើយម្តងទៀត នៅក្នុងហេតុផលយ៉ាងច្រើន ហើយចុងក្រោយព្រះអង្គនិមន្តត្រឡប់ទៅក្រុងវេសាលីវិញ ។ ព្រះនាងមហាបជាបតិគោតមី មិនមានការលើកទឹកចិត្តឡើយ បានកោរសក់ ហើយស្លៀកដណ្តប់សំពត់ពណ៌លឿង យាងដើរដោយជើងទៅកាន់ក្រុងវេសាលី ដែលដង្ហែដោយពួកស្ត្រីក្នុងសាក្យៈត្រកូលយ៉ាងច្រើន បានដើរឆ្លងកាត់ស្ថានភាពលំបាកជាច្រើនកន្លែង ។ ពួកស្ត្រីទាំងនោះ បានជូតសំអាតជើងយ៉ាងស្អាត ហើយឈរនៅខាងក្រៅបន្ទប់ នៃកុដាគារសាលាមហាវន ជាកន្លែងដែលព្រះពុទ្ធគង់នៅ ។ ព្រះអានន្ទបានមើលឃើញ ស្ត្រីទាំងនោះគួរឲ្យអាណិត ក៏បានជួយអង្វរព្រះពុទ្ធជំនួសឲ្យពួកស្ត្រីទាំងនោះ ។ ព្រះពុទ្ធអង្គបានបដិសេធម្តងហើយម្តងទៀត អស់រយៈពេលបីដង ប៉ុន្តែនៅទីបំផុតត្រូវបានព្រះអានន្ទបញ្ចុះបញ្ចូលព្រះពុទ្ធអង្គ រហូតមានការយល់ព្រម ដោយមានដាក់ល័ក្ខខ័ណ្ឌយ៉ាងតឹងរ៉ឹង ។ ព្រះនាងបជាបតិគោតមី បានយល់ព្រមកាន់តាមនូវគរុធម៌ទាំង៨ ដូចខាងក្រោម៖

១-ភិក្ខុនី សូម្បីឧបសម្បទាបានមួយរយវស្សាក្តី ត្រូវតែថ្វាយបង្គំភិក្ខុ និងត្រូវក្រោកឡើងមុន ទោះបីភិក្ខុទើបបានទទួលឧបសម្បទាតិចថ្ងៃជាងក៏ដោយ ។

២-ភិក្ខុនីមិនគួរគង់ចាំវស្សា នៅក្នុងកន្លែងដែលមិនមានភិក្ខុឡើយ

៣-រៀងរាល់កន្លះខែម្តង ភិក្ខុនីគួរស្នើសុំពីភិក្ខុសង្ឃ នៅពេលវេលាដើម្បីប្រជុំធ្វើឧបោសថ និងពេលវេលាដែលភិក្ខុឲ្យឱវាទដល់ពួកភិក្ខុនី ។

៤-ពិធីបវារណាកម្មបន្ទាប់ពីចូលវស្សាមក ភិក្ខុនីគួរតែលើកឡើងនៅចំពោះមុខឧភតោសង្ឃ គឺភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ

៥-ទោសធ្ងន់របស់ភិក្ខុនី គួរតែដោះស្រាយដោយឧភតោសង្ឃ គឺភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ ។

៦-សាមណេរី (សិក្ខាមានា) ដែលបានចូលខ្លួនបួសរយៈពេលពីរឆ្នាំហើយ គួរតែទទួលនូវឧបសម្បទាពីឧភតោសង្ឃ គឺភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ ។

៧-ភិក្ខុនី មិនគួរស្តីបន្ទោស ឬក៏គម្រាមភិក្ខុឡើយ ។

៨-ភិក្ខុនី មិនគួរឲ្យដំបូន្មានដល់ភិក្ខុ តែភិក្ខុអាចឲ្យដំបូន្មានដល់ភិក្ខុនីបាន ។

ព្រះនាងបជាបតិគោតមី បានយល់ព្រមដោយរីករាយ ក្នុងការរស់នៅក្នុងគរុធម៌ទាំងប្រាំបីប្រការនេះ ។ ការទទួលយល់ព្រម ប្រតិបត្តិតាម

នូវគរុធម៌ទាំង៨ប្រការនេះ ព្រះនាងបានទទួលដោយស្ម័យប្រវត្តិនូវការឧបសម្បទា ។ ឯស្ត្រីសក្យៈដទៃទៀត ក៏បានទទួលយល់ព្រមផងដែរ នូវការឧបសម្បទានោះ ។ ស្ត្រីទាំងនោះក្រោយមកបានសម្រេចជាព្រះអរហត្តទាំងអស់គ្នាទៅ ។ ព្រះនាងយសោធរា និងព្រះនាងនន្ទាជាបុត្រីរបស់ព្រះនាងបជាបតិគោតមី ក៏បានចូលឧបសម្បទាជាភិក្ខុនីដែរ ។

នៅក្នុងសហគមន៍ភិក្ខុនីសង្ឃនោះ ព្រះភិក្ខុនីខេមា និងព្រះភិក្ខុនីឧប្បលវណ្ណា ត្រូវបានតែងតាំងជាអគ្គសាវិកាខាងភិក្ខុនី ដូចព្រះសារីបុត្រ និងព្រះមោគ្គល្លាន ដែលបានជាអគ្គសាវ័កខាងភិក្ខុដែរ ។

### វស្សាទី ៦ នៅលើភ្នំមង្កុល (មកដបព័ត ដែនមគធៈ)

ព្រះអង្គបានសម្តែងយមកប្បាដិហារ្យ ដើម្បីផ្ចាញ់ក្រុមព្រះញាតិវង្សរបស់ព្រះអង្គនៅក្រុងកបិលវត្ថុ, នៅទីនោះព្រះអង្គបានសម្តែងបាដិហារ្យដូចគ្នា ជាលើកទីពីរដើម្បីផ្ចាញ់ពួកនិគ្រន្ថ ។

### វស្សាទី៧ គង់នៅស្ថានតាវតិង្ស

ពីរបីថ្ងៃ បន្ទាប់ពីការប្រសូតនៃព្រះសិទ្ធត្ថមក ព្រះនាងសិរីមហាមាយា ជាព្រះមាតាបានសោយទិវង្គត ហើយបានទៅកើតនៅទេវតុសិតសួគ៌ ។ បន្ទាប់ពីការបានត្រាស់ដឹងមក គឺនៅវស្សាទី៧ ព្រះអង្គបានទេសនាអភិធម្មបិដក ប្រោសទេវតានៅស្ថានសួគ៌ ដែលដឹកនាំដោយទេវតា

ជាព្រះមាតារបស់ព្រះអង្គ ។ ជារៀងរាល់ថ្ងៃ ព្រះពុទ្ធអង្គតែងយាងចុះមកផែនដីនេះ ហើយបានសម្ដែងសង្ខេបធម៌ទេសនារបស់ព្រះអង្គ ដល់ព្រះសារីបុត្រ, ហើយព្រះសារីបុត្រក៏សម្ដែងវាទៈដូចគ្នានោះ ដោយពិស្ដារដល់សាវ័ករបស់លោកចំនួន៥០០អង្គ ដូចមាននៅក្នុងគម្ពីរអភិធម្មបិដកសព្វថ្ងៃនេះ ។ សូមបញ្ជាក់ថា ការស្ដាប់ធម៌ទេសនានេះ ញុំាងព្រះមាតារបស់ព្រះអង្គ ឲ្យបានសម្រេចធម៌ថ្នាក់សោតា ។

## វស្សាទី៨ នៅព្រៃភេសកាឡវន

នៅក្បែរថ្មសុមសមារៈ នៅក្នុងដែនភគ្គរាជបទ ។

## វស្សាទី៩ នៅព្រៃបាលិលេយ្យ

នៅក្នុងឆ្នាំនោះ ព្រះពុទ្ធគង់ចាំវស្សានៅក្នុងព្រៃបាលិលេយ្យ ដោយមានដំរីនិងស្វាបម្រើព្រះអង្គ ។

## វស្សាទី១០ ទី១១ នៅក្នុងព្រៃនាសាលេយ្យកគ្រាម

ព្រះពុទ្ធគង់នៅក្នុងដងព្រៃជិតស្រុករបស់ព្រាហ្មណ៍ ឈ្មោះសាលេយ្យកគ្រាម ។

## វស្សាទី១២ នៅក្រោមដើមស្ដៅ

ទ្រង់គង់ចាំវស្សានៅក្រោមដើមស្ដៅ ដែលនាឡេយក្ខថែរក្សា ។

## វស្សាទី១៣ នៅភ្នំបាលេយ្យកបព៌ត

ព្រះអង្គគង់ចាំវស្សាភ្នំបាលិលេយ្យកបព៌ត

## វស្សាទី១៤ នៅវត្តជេតពន ក្រុងសាវត្ថី

ព្រះភិក្ខុរាហុល បានទទួលការបំពេញឧបសម្បទា នៅពេលព្រះអង្គមានព្រះជន្មគម្រប់ម្ភៃវស្សាបរិបូណ៌ ។

## វស្សាទី១៥ នៅក្រុងកបិលវត្ថុ

ការចូលទិវង្គតគួរឲ្យរន្ធត់របស់ស្តេចសុប្បពុទ្ធ ជាបិតារបស់ព្រះនាងយសោធរា បានកើតឡើងនៅក្នុងឆ្នាំនោះឯង ។ ព្រះពុទ្ធបានចំណាយពេលមួយវស្សា គង់នៅក្នុងវត្តនិគ្រោធារាម ស្ថិតនៅក្នុងនគរកំណើតរបស់ព្រះអង្គ ។

## វស្សាទី១៦ នៅក្រុងអាឡវកៈ

ប្រោសអាឡវកៈ ជាយក្សដែលតែងស៊ីសាច់មនុស្ស បានកើតឡើងនៅក្នុងឱកាសនោះឯង ។

## វស្សាទី១៧ -១៨-១៩ នៅក្រុងរាជគ្រឹះ

ទ្រង់គង់ចាំវស្សានៅក្នុងវត្តវេឡុវន ក្រុងរាជគ្រឹះ

## វស្សាទី២០ដល់ទី២៩

នៅវត្តជេតពន ក្រុងសាវត្ថី

## វស្សាទី៣០ដល់វស្សាទី៣៥

គង់ចាំវស្សានៅវត្តបុព្វារាម ក្រុងសាវត្ថី

## វស្សាទី៣៦ ដល់វស្សាទី៤៤

គង់ចាំវស្សានៅវត្តជេតពន ជិតក្រុងសាវត្ថី

វស្សាទី៤៥

គង់ចាំវស្សានៅស្រុកវេឡុគ្រាម ជិតក្រុងវេសាលី

## ប្រោសអង្គុលិមាល៍

នៅវស្សាទី២០ ព្រះពុទ្ធបានប្រោសអង្គុលិមាល៍ ជាឃាតកដ៏សាហាវឃោរឃៅមួយរូប ។ អង្គុលិមាល៍មានឈ្មោះដើមថាអហិង្សកុមារ, លោកជាបង្គោលនៃគ្រួសារប្រកបដោយកិត្តិយសមួយ ។ ជាអកុសល កាលលោកនៅយុវជន ពួកសិស្សជាមិត្តភ័ក្តដែលអហិង្សកុមារសេពគប់ បានច្រណែនចំពោះរូបគាត់ ហើយបានប្រឌិតរឿងក្លែងក្លាយញុះញង់គ្រូឲ្យស្អប់គាត់ ។ គ្រូខឹងខ្លាំងណាស់ ដោយគ្មានការពិចារណារកខុសត្រូវឡើយ ហើយបានធ្វើផែនការដើម្បីសម្លាប់គាត់ ដោយដាក់បញ្ជាឲ្យគាត់សម្លាប់មនុស្ស យកម្រាមដៃចំនួន១០០០ មកធ្វើពិធីកម្មចុងក្រោយ ។ ដោយស្តាប់បង្គាប់គ្រូទាំងចិត្តទើសទ័ល អហិង្សកុមារបានចេញដំណើរទៅពួនក្នុងព្រៃ ដើម្បីពួនស្ទាក់ចាំចាប់មនុស្ស ហើយសម្លាប់កាត់យកម្រាមដៃ បូជាពិធីកម្មពិសេសនោះ ។ ក្រោយមក គាត់បានយកម្រាមដៃមនុស្ស ដែលកាត់បាននោះដោតធ្វើជាកម្រងពាក់ព្យួរនៅករបស់គាត់, ហេតុនេះហើយ ទើបគាត់មានឈ្មោះថាអង្គុលិមាល៍ ។ នៅពេលដែលគាត់សម្លាប់មនុស្ស បានម្រាមដៃចំនួន៩៩៩ ហើយត្រូវបំពេញឲ្យបានគ្រប់ចំនួន១០០០, ព្រះពុទ្ធក៏បានបង្ហាញវត្តមានយ៉ាងប្រាកដ នៅ

ចំពោះមុខអង្គុលិមាល៍, គាត់បានរត់ដេញតាមព្រះពុទ្ធអង្គ ក្នុងបំណង សម្លាប់ដើម្បីកាត់យកម្រាមដៃ, ប៉ុន្តែបែរជាត្រូវព្រះពុទ្ធប្រោសគាត់ ឲ្យ ឃើញនូវធម៌ជាន់ខ្ពស់ ទីបំផុតក៏បានចូលបួសក្នុងសំណាក់ព្រះពុទ្ធអង្គ ទៅ ។ មួយថ្ងៃក្រោយមក លោកបានចេញទៅបិណ្ឌបាត្រ បានឃើញស្ត្រី ម្នាក់ស្ថិតនៅក្នុងទុក្ខវេទនា ដោយការប្រសូតបុត្រមិនរួច, មានចិត្តអាណិត អាសូរខ្លាំងពេក លោកក៏ត្រឡប់ក្រោយវិញ ហើយនាំរឿងនោះទៅក្រាប ទូលព្រះពុទ្ធ ។ ព្រះពុទ្ធអង្គបានបង្រៀននូវបរិត្តសូត្រដល់អង្គុលិមាល៍ ដែល មានសេចក្ដីដូចខាងក្រោមៈ

“ម្នាលប្អូនស្រី ! តាំងពីអាត្មាបានក្លាយជាវង្សអរិយៈមក អាត្មា ដឹងខ្លួនថា មិនដែលបានប្រព្រឹត្ត នូវការបំផ្លាញជីវិតសត្វសូម្បីមួយឡើយ ។ ដោយសច្ចវាចានេះ សូមសិរីសួស្ដីកើតមានដល់នាងផង និងកូនរបស់ នាងផង” ។

លោកបានសិក្សាព្រះបរិត្តនេះ ហើយក៏និមន្តទៅរកស្ត្រីដែលកំពុង រងទុក្ខនោះ រួចគង់នៅលើអាសនៈដែលគេរៀបចំទុកហើយ នៅខាងក្រៅ របាំងរបស់ស្ត្រីនោះ ហើយសូត្រនូវសច្ចវាចានេះ, ជាលទ្ធផលស្ត្រីនោះក៏ ប្រសូតបុត្របានដោយងាយបំផុត ។ ប្រសិទ្ធភាពនៃព្រះបរិត្តនោះ ស្ថិតនៅ រហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលដ៏សមគួរមួយ ភិក្ខុអង្គុលិមាល៍ក៏បានសម្រេចនូវធម៌ជាន់ខ្ពស់ថ្នាក់អរហត្តផល ។ ព្រះអង្គបានចំណាយពេល១៩វស្សា គង់នៅក្នុងវត្តជេតពន ជិតក្រុងសាវត្ថី ដែលបានកសាងឡើងដោយអនាថបិណ្ឌិកសេដ្ឋី និងរយៈ៦ឆ្នាំគង់នៅវត្តបុព្វារាម កសាងដោយនាងវិសាខា ជាអ្នកឧបត្ថម្ភព្រះពុទ្ធសាសនា ។

# អនាថបិណ្ឌិកសេដ្ឋី

អនាថបិណ្ឌិក (អ្នកផ្តល់អាហារដល់ជនគ្មានទីពឹង) ជាសេដ្ឋីនៅក្នុងក្រុងសាវត្ថី ។ ឈ្មោះសម្រាប់ហៅ នៅក្នុងគ្រួសាររបស់គាត់គឺសុទត្ត ។ ពេលទៅកាន់ក្រុងរាជគ្រឹះ ជាទីក្រុងដែលបងថ្លៃរបស់គាត់រស់នៅ អនាថបណ្ឌិកសេដ្ឋី បានទទួលដំណឹងដ៏រីករាយគ្មានអ្វីប្រៀប គឺបានឮថាព្រះពុទ្ធអង្គ គង់នៅក្នុងឧទ្យានជិតទីនោះ ក៏មានបំណងចង់ជួបព្រះអង្គ ហើយបានធ្វើដំណើរទៅកាន់ស្ថានទីនោះ ដោយការដើរឆ្លងកាត់ទីព្រៃស្មសាន ដែលជាទីចោលសាកសពមួយ ។ ចិត្តជ្រះថ្លារបស់គាត់មុតជ្រៅទៅក្នុងព្រះពុទ្ធមានភាពខ្លាំងក្លាណាស់ រហូតធ្វើឲ្យកាយរបស់គាត់ចេញពន្លឺ, ពន្លឺនេះហើយបានលើកទឹកចិត្ត មិនឲ្យគាត់មើលឃើញសាកសព ដែលនៅក្នុងព្រៃស្មសាននោះឡើយ ។ អនាថបិណ្ឌិកសេដ្ឋីបានទៅដល់សិតាវន ជាកន្លែងព្រះពុទ្ធកំពុងនិមន្តចង្រ្កមចុះឡើង, ព្រះអង្គប្រមើលឃើញនិស្ស័យរបស់សេដ្ឋី ធ្លាក់ចូលក្នុងបណ្តាញញាណរបស់ព្រះអង្គ ។ ព្រះពុទ្ធបានហៅគាត់

ឲ្យចូលមកជិត ដោយប្រើឈ្មោះដើមរបស់គាត់ថាសុទត្ត ។ អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ធម៌ក្នុងសំណាក់ព្រះពុទ្ធ ហើយក៏បានដល់នូវសោតាបន្នៈ ។

ពេលត្រឡប់ទៅកាន់ក្រុងសាវត្ថីវិញ អនាថបណ្ឌិកសេដ្ឋីបានជាវដីឧទ្យាន ជាកម្មសិទ្ធិរបស់ព្រះអង្គម្ចាស់ជេតកុមារ ដោយតម្លៃដីស្មើនឹងការក្រាលមាសពីលើ ហើយបានកសាងវត្តដ៏ល្បីមួយ មានឈ្មោះថាវត្តជេតពន ក្នុងតម្លៃ៥៤កោដិកហាបណៈ ។ ព្រះពុទ្ធអង្គទ្រង់បានចំណាយពេលអស់១៩វស្សា គង់នៅទីនោះ ហើយទីនោះក៏ជាកន្លែងកើតរឿងរ៉ាវជាច្រើន ដែលមាននៅក្នុងព្រះធម៌ទេសនារបស់ព្រះអង្គ ។ ព្រះធម៌ទេសនាជាច្រើន ដែលមានសារៈសំខាន់សម្រាប់គ្រហស្ថ ក៏ត្រូវបានសម្តែងនៅទីនោះដែរ ។ ដោយសេចក្តីល្អរបស់គាត់ដ៏លើសលុបនោះហើយ ទើបគាត់ត្រូវបានចាត់ទុកជា មហាឧបាសកមួយរូប នៅក្នុងព្រះពុទ្ធសាសនា ។ គាត់បានទទួលការអនុញ្ញាតិពីព្រះពុទ្ធអង្គ ដើម្បីបានដាំពោធិព្រឹក្សមួយដើមនៅត្រង់ផ្លូវចូលវត្តជេតពន ឈ្មោះអានន្ទពោធិ ដែលជាឈើរស់នៅរហូតដល់សព្វថ្ងៃនេះ ។ ភរិយារបស់គាត់ឈ្មោះបុណ្ណលក្ខិណា ។ គាត់មានកូនស្រី៣នាក់ ឈ្មោះមហាសុភទ្ទា, ចុឡ្លសុភទ្ទា និង សុមនា កូនស្រីច្បងបានសម្រេចជាសោតាបន្នៈបុគ្គល ហើយកូនស្រីពៅបានសម្រេចថ្នាក់សកទាគាមី ។ គាត់មានកូនប្រុសតែម្នាក់គត់ឈ្មោះកាឡៈ ដែលដំបូងមិនជ្រះថ្លា

នឹងសាសនាទេ តែក្រោយមកបានសម្រេចសោតាបន្នៈ តាមការដឹកនាំរបស់ឪពុក ។

អនាថបិណ្ឌិកសេដ្ឋីស្លាប់ទៅ ក្រោយការបានស្តាប់ព្រះធម៌ដ៏មានជម្រៅមួយ ពីសំណាក់ព្រះសារីបុត្រ ។ បន្ទាប់ពីមរណភាពមក គាត់បានទៅកើតក្នុងស្ថានតុសិតសួគ៌ ។ គម្ពីរបានបញ្ជាក់ថា នៅពេលគាត់បានកើតជាទេវតា, នៅរាត្រីមួយ គាត់បានមកថ្វាយបង្គំព្រះពុទ្ធអង្គ ហើយពោលសរសើរពីគុណធម៌របស់ព្រះសារីបុត្រ និងបានសម្តែងការរីករាយ ដោយបានឃើញព្រះពុទ្ធ និងសាវ័ករបស់ព្រះអង្គ កំពុងគង់នៅក្នុងវត្តជេតពន ។

## នាងវិសាខា

នាងវិសាខា ជាកូនស្រីទោលរបស់ធនញ្ជ័យសេដ្ឋី ។ មាតារបស់នាងវិសាខាឈ្មោះសុមនា និងជីតាឈ្មោះមេណ្ឌកសេដ្ឋី ។

ព្រះពុទ្ធបានយាងចូលរួម ក្នុងថ្ងៃកំណើតរបស់នាង នៅពេលដែលនាងទើបមានអាយុ៧ឆ្នាំ ។ ទោះបីនៅមានអាយុតិចយ៉ាងនេះក្តី នាងបានល្ងួតលាស់ខាងសតិបញ្ញាខ្ពស់ក្រៃលែង ។ នៅពេលនាងវិសាខាបានស្តាប់ធម៌ទេសនា ពីសំណាក់ព្រះពុទ្ធជាលើកដំបូង ក៏បានសម្រេចសោតាបន្នៈ ។ គម្ពីរបានបញ្ជាក់ថា សូម្បីស្ថិតនៅក្នុងភាពក្មេងខ្ចីក៏ដោយ ក៏នាងមានកម្លាំងដូចជាបុរសដែរ ។ ជាស្ត្រីមាននិស្ស័យមន្តស្នេហ៍និងមានបញ្ញា នាង

វិសាខាមានភាពអស្ចារ្យទាំងពីរយ៉ាងគឺ បញ្ញាដ៏ធំទូលាយ និងការយល់ច្បាស់ខាងផ្លូវចិត្ត ។

នាងបានរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងស្វាមីឈ្មោះបុណ្ណវឌ្ឍនកុមារ ជាកូនប្រុសរបស់មិគារសេដ្ឋី ដែលជាត្រកូលមិនជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។ នៅក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ មានការធ្វើចំណងដៃដ៏ធំមួយ និងគ្រឿងតុបតែងដ៏ល្អឆើត (មហាលតាផលន្ធនៈ), ពរ១០ប្រការក៏ត្រូវបានគេផ្តល់ឲ្យដល់នាងវិសាខាដែរ ។ ដោយភាពឈ្លាសវៃនិងការអត់ធ្មត់ នាងវិសាខាបានជោគជ័យ នៅក្នុងការប្តូរជំនឿគ្រួសារខាងស្វាមីរបស់នាង ឲ្យទៅជាគ្រួសារពុទ្ធសាសនិកមួយដ៏រីករាយ ។ ឪពុកក្មេករបស់នាងក៏បានសម្រេចសោតាបន្នៈដែរ ហើយបានងាកមកជ្រះថ្លាក្នុងព្រះពុទ្ធសាសនាវិញ ។

តាំងពីពេលនោះមក នាងវិសាខាមានសេរីភាពក្នុងការចូលរួមនៅក្នុងសកម្មភាពសាសនា តាមដែលនាងពេញចិត្ត ។

នាងវិសាខាបានកសាងវត្តបុព្វារាម នៅខាងកើតទីក្រុងសាវត្ថីតាមការណែនាំរបស់ព្រះពុទ្ធអង្គ ។ ព្រះពុទ្ធអង្គបានចំណាយពេល៦ព្រះវស្សា គង់ចាំវស្សានៅទីនោះ ។ នាងបានក្លាយជាស្ត្រីអ្នកឧបត្ថម្ភដ៏លេចធ្លោរ ចំពោះព្រះពុទ្ធអង្គ ។ ព្រះពុទ្ធបានស្នើឲ្យនាងវិសាខា ដោះស្រាយ

ទំនាស់ដែលកើតឡើង នៅក្នុងសហគមន៍ភិក្ខុនីសង្ឃ ។ វិន័យខ្លះត្រូវបាន បញ្ញត្តចំពោះភិក្ខុ តាមការស្នើឡើងរបស់នាងវិសាខាដែរ ។

# ៨.ពុទ្ធកិច្ចទាំង ៥ យ៉ាង

ព្រះពុទ្ធបានបំពេញពុទ្ធកិច្ចរបស់ព្រះអង្គ តាមបែបជាប្រព័ន្ធ តាមផែនការណ៍ដែលបានរៀបទុកជាមុន ។ ពេញៗមួយថ្ងៃ ព្រះអង្គបានបំពេញពុទ្ធកិច្ច លើកលែងតែនៅពេលណាចាំបាច់ ដែលព្រះអង្គត្រូវយកពេល ទៅបំពេញតម្រូវការខាង សុខភាពផ្លូវកាយផ្ទាល់របស់ព្រះអង្គប៉ុណ្ណោះ ។ នៅឱកាសជាច្រើន ព្រះអង្គបានសម្តែងធម៌ទេសនា ក្នុងន័យរក្សាសេចក្តីសុខសន្តិភាពក្នុងលោកនេះ, កង្វល់ដ៏ធំរបស់ព្រះអង្គ គឺការលើកកំពស់ផ្នែកសីលធម៌របស់មនុស្ស, ទ្រង់បានត្រាស់ដឹងដោយខ្លួនឯងផ្ទាល់ ហើយខិតខំប្រឹងប្រែងបង្រៀនសាវ័កដទៃទៀត ឲ្យបានត្រាស់ដឹងផងដែរ ។

## ពុទ្ធកិច្ចប្រចាំថ្ងៃរបស់ព្រះអង្គមាន ៥ យ៉ាងគឺ:

១- ពេលព្រឹក (បុព្វណ្ហសម័យ)

២- ពេលរសៀល (សាយណ្ហសម័យ)

៣- ពេលព្រលប់ (បទូសសម័យ)

៤- ពេលកណ្តាលអាធ្រាត (អឌ្ឍរត្តិសម័យ)

៥- ពេលទៀបភ្លឺ (បច្ចូសសម័យ)

## បុព្វណ្ហសម័យ

ពេលព្រលឹម (បុព្វណ្ហសម័យ) ព្រះអង្គបានប្រមើលនិស្ស័យសត្វលោក ដោយទិព្វញាណ ឲ្យដឹងថាតើសត្វណាខ្លះដែលព្រះអង្គអាចជួយស្រោចស្រង់បាន ។ ប្រសិនបើសត្វណាមួយ ចូលក្នុងបណ្ដាញញាណរបស់ព្រះអង្គហើយ ទ្រង់យាងទៅទីនោះដោយព្រះបាទាផ្ទាល់ ដោយគ្មានការនិមន្តឡើយ ។ ម្យ៉ាងវិញទៀត តាមហេតុការណ៍ខ្លះ ទ្រង់ប្រើពុទ្ធានុភាពរបស់ព្រះអង្គ ដើម្បីដឹកនាំមនុស្សសត្វនោះៗទៅតាមផ្លូវត្រូវមួយ ។ ព្រះពុទ្ធបានយាងទៅរម្ងាប់អំពើហិង្សា និងអំពើមិនបរិសុទ្ធនានា ដោយកុសលនិងសេចក្ដីបរិសុទ្ធល្អ ដែលបានមកពីការព្យាយាមប្រឹងប្រែងរបស់ព្រះអង្គ ។

ការសិក្សាស្រាវជ្រាវខាងផ្លូវចិត្តទៅលើមនុស្ស គឺជាការសំខាន់បំផុត, ប្រសិនបើព្រះអង្គមិនត្រូវបានគេនិមន្តទៅកាន់ទីពិសេសណាមួយទេ ទ្រង់និមន្តចេញទៅបិណ្ឌបាត្រ និងគង់នៅតែមួយអង្គឯង ឬជាមួយពួកភិក្ខុសង្ឃជាសាវ័ក ។ ព្រះអង្គឆាន់ភត្តាហារនៅមុនពេលថ្ងៃត្រង់ ។

បន្ទាប់ពីការសោយអាហារថ្ងៃត្រង់ហើយ ព្រះពុទ្ធតែងប្រទាននូវធម៌ទេសនាខ្លីមួយ ចំពោះមនុស្សទាំងឡាយ, ទ្រង់បានលើកទឹកចិត្តពួកគេឲ្យស្ថិតនៅក្នុងព្រះរតនត្រ័យ និងរក្សាសីល៥, ប្រសិនណាបើពួកមនុស្សដែលចាស់ទុំ ខាងផ្លូវចិត្តស្រាប់ហើយ ទ្រង់បង្ហាញពួកគេ នូវផ្លូវទៅកាន់ភាពជាបុគ្គលគ្មានផ្ទះ (នេក្ខម្ម:=ការចេញចាកកាម) ។ នៅពេលនោះ បើ

មានអ្នកប្រាថ្នាចង់បួសម្នាក់ឬច្រើននាក់ ព្រះពុទ្ធក៏ប្រទានឱ្យនូវផ្កាសភ្លាម តមកព្រះអង្គសម្រាកនៅក្នុងគន្ធកុដិ ។

## សាយណ្ហសម័យ

បន្ទាប់ពីការឆាន់អាហារថ្ងៃត្រង់រួច ព្រះពុទ្ធគង់ប្រថាប់នៅលើអាសនៈមួយនៅក្នុងវត្ត នៅពេលនោះពួកភិក្ខុបានមកប្រជុំគ្នា ស្តាប់ព្រះអង្គសម្តែងធម៌ ។ ភិក្ខុខ្លះបានកាន់យកនូវអារម្មណ៍សមាធិ តាមចរិតនិស្ស័យរបស់ពួកគេ, ភិក្ខុខ្លះចេញទៅរកទីស្ងាត់ដាច់ដោយឡែកពីគ្នា, ពួកភិក្ខុខ្លះទៀតបាននាំគ្នាគោរពព្រះពុទ្ធអង្គ និងបានសម្រាកនៅក្នុងបន្ទប់រៀងៗខ្លួន បន្ទាប់ពីបានស្តាប់ធម៌ពេលរសៀលមក ។

ការឱ្យឱវាទដល់សាវ័កទាំងអស់រួចហើយ ព្រះពុទ្ធក៏ចូលសម្រាកនៅក្នុងបន្ទប់ (គន្ធកុដិ) ផ្ទាល់របស់ព្រះអង្គ ។ ប្រសិនបើព្រះអង្គមានបំណងសម្រាក ទ្រង់ទម្រេតព្រះកាយបែរទៅខាងស្តាំ ហើយផ្ទំនៅក្នុងសតិ ។ នៅពេលតើនឡើង ព្រះអង្គសម្រេចសមាបត្តិ ហើយទ្រង់ប្រមើលដោយទិព្វចក្ខុ ទៅក្នុងលោកទាំងមូល ជាពិសេសចំពោះពួកភិក្ខុដែលចម្រើនសមាធិ នៅក្នុងទីស្ងាត់ដាច់ពីភិក្ខុដទៃៗទៀត ដើម្បីឱ្យដំបូន្មានតាមដែលគេត្រូវការ ។ ប្រសិនបើភិក្ខុបានធ្វើខុសអ្វីត្រង់ណាមួយ ព្រះអង្គក៏បានប្រទាន

ដំបូន្មានពីចម្ងាយភ្លាម ដោយទ្រង់ប្រើពុទ្ធានុភាពដើម្បីបង្រៀនភិក្ខុទាំងនោះ រួចហើយក៏ទ្រង់សម្រួលឥរិយាបថនៅក្នុងបន្ទប់វិញ ។

ពេលរសៀល មានពុទ្ធបរិស័ទជាច្រើន បានទៅកាន់វត្តដើម្បីស្តាប់ព្រះធម៌ទេសនា ។ ការប្រមើលពីចំណាង់ចំណូលចិត្ត តាមនិស្ស័យរបស់សត្វលោកនីមួយៗដោយពុទ្ធចក្ខុ, ព្រះអង្គសម្តែងធម៌ទេសនាដល់ពុទ្ធបរិស័ទទាំងនោះ រយៈពេលប្រហែលមួយម៉ោង ។ បរិស័ទម្នាក់ៗក្នុងចំណោម សាវ័កទាំងនោះ តែងគិតថាធម៌ទេសនារបស់ព្រះពុទ្ធ សុទ្ធតែបានចង្អុលប្រាប់ផ្លូវ យ៉ាងពិសេសដល់រូបខ្លួនគេផ្ទាល់ ។ វិធីបង្រៀនរបស់ព្រះពុទ្ធ ជាវិធានដែលព្រះអង្គត្រូវប្រោសសត្វលោក មានច្រើនបែបយ៉ាងណាស់ តាមរយៈការលើកយកព្រះធម៌មកសម្តែងអធិប្បាយ ។ ព្រះអង្គបានផ្តោតលើការយល់ដឹងដោយបញ្ញា ច្រើនជាងទៅលើការរំញោចអារម្មណ៍ ។ ព្រះពុទ្ធបានប្រៀនប្រដៅដល់អ្នកស្វែងរកសច្ចធម៌ មិនឲ្យយល់ព្រមទទួលយកអ្វីមួយ ដោយគ្រាន់តែអ្នកនោះមានអំណាចទេ ប៉ុន្តែឲ្យប្រើហេតុផលផ្ទាល់ខ្លួនរបស់គេ និងវិនិច្ឆ័យដោយខ្លួនគេផ្ទាល់ ថាតើអ្វីដែលត្រូវ និងអ្វីដែលខុស ។

នៅក្នុងឱកាសមួយ កាឡាមជាបុត្ររបស់កេស្សបុត្ត បានចូលទៅរកព្រះពុទ្ធ ហើយបាននិយាយថា ពួកឥសីនិងព្រាហ្មណ៍ជាច្រើន តែងទេសនាពោលអួតអាង និងសរសើរពីលទ្ធិរបស់ពួកគេផ្ទាល់ៗ ហើយពោល

បរិហារពីលទ្ធិរបស់អ្នកដទៃ, គេបានធ្វើឲ្យច្រឡូកច្រឡំការយល់ ថាអ្នកណានិយាយត្រូវតាមសច្ចធម៌ ហើយអ្នកណានិយាយមិនត្រឹមត្រូវ ។

ព្រះពុទ្ធមានបន្ទូលថា “ម្នាលកាឡាម ! ជាការត្រឹមត្រូវហើយចំពោះអ្នកដែលមានការសង្ស័យយ៉ាងនេះ និងត្រឹមត្រូវផងដែរចំពោះអ្នកដែលចង់ប្តូរចិត្ត នៅក្នុងរឿងគួរឲ្យសង្ស័យនោះ” ។

ដោយការកត់សម្គាល់ឃើញដូច្នោះហើយ ព្រះពុទ្ធបានឲ្យដំបូន្មានដូចខាងក្រោម ដែលធ្វើឲ្យមានកម្លាំងស្មើៗគ្នា ឆ្ពោះទៅរកពួកអ្នកសនិទាននិយមសម័យថ្មី មានចំពោះពួកព្រាហ្មណ៍ ដែលសង្ស័យមកជាយូរហើយ ។

“ម្នាលកាឡាម, ចូរអ្នកកុំអាលជឿតាមអ្វីដោយគ្រាន់តែឮគេថា, កុំអាលជឿអ្វីដោយគ្រាន់តែជាប្រពៃណី, កុំអាលជឿអ្វីដោយគ្រាន់តែជារឿងនិទាន ឬជាពាក្យចចាមអារាម, កុំអាលជឿអ្វី ដោយគ្រាន់តែមានសេចក្តីស្របនឹងគម្ពីរ, កុំអាលជឿអ្វីដោយគ្រាន់តែធ្វើការសន្និដ្ឋានស្មានៗ, កុំអាលជឿអ្វីដោយគ្រាន់តែបានពិចារណាហេតុផល, កុំអាលជឿអ្វីដោយគ្រាន់តែព្រមព្រៀងគ្នា តាមការយល់ឃើញនិងតាមការគិតទុកជាមុន, កុំអាលជឿអ្វីដោយគ្រាន់តែហាក់ដូចជាអាចយល់ព្រម, កុំអាលជឿអ្វីដោយគ្រាន់តែគិតថាជាគ្រូ ឬជាអ្នកបួសដែលយើងគោរព” ។

“ម្នាលកាឡាម ! នៅពេលណាដែលអ្នកដឹងដោយខ្លួនអ្នកថា រឿងទាំងនេះជាអសីលធម៌, រឿងទាំងនេះជាអំពើអាក្រក់គួរឲ្យស្អប់ខ្ពើម, រឿង

ទាំងនេះពួកបណ្ឌិតតែងតិះដៀល រឿងទាំងនេះធ្វើទៅនាំមកនូវផលបែកបាក់និងទុក្ខព្រួយ ដូច្នេះហើយអ្នកត្រូវតែបោះបង់រឿងទាំងនោះចោល” ។

“ម្នាលកាឡាម ! នៅពេលដែលអ្នកបានដឹងដោយខ្លួនអ្នកថា រឿងទាំងនេះជាសីលធម៌, រឿងទាំងនេះល្អគួរឲ្យស្រឡាញ់, រឿងទាំងនេះពួកអ្នកប្រាជ្ញទាំងឡាយតែងសរសើរហើយ, រឿងទាំងនេះគួរតែបំពេញ គួរតែព្យាយាមធ្វើ ព្រោះនាំមកនូវសេចក្ដីសុខនិងសុភមង្គល អញ្ចឹងអ្នកត្រូវធ្វើអំពើនោះទៅ” ។

ពាក្យទាំងនេះជាព្រះពុទ្ធវចនៈ ដែលបានកើតឡើងជាងពីរពាន់ប្រាំរយឆ្នាំមុនម្ល៉េះ តែនៅមានប្រសិទ្ធភាពដដែល មិនទាន់ហួសសម័យទេ និងតែងពេញនិយមជានិច្ច ។

នៅក្នុងឱកាសខ្លះ ដូចជាករណីភិក្ខុអង្គុលិមាល៍ ភិក្ខុនីខេមា និងអ្នកឯទៀតៗ ព្រះពុទ្ធអង្គតែងប្រើឫទ្ធានុភាពរបស់ព្រះអង្គ ដើម្បីទូន្មាននិងកែប្រែការយល់របស់ពួកគេ ។

ការប្រៀនប្រដៅដ៏វិសេសរបស់ព្រះពុទ្ធ ចំពោះមនុស្សសត្វទាំងអស់ស្រដៀងៗគ្នា ។ ការប្រៀនប្រដៅពីសនិទានភាព (ហេតុផល) របស់ព្រះអង្គ ដូចជាទឹកដោះសម្រាប់ទារក និងសាច់សម្រាប់ជួយកម្លាំងដល់មនុស្សធំដែរ, អ្នកមាននិងអ្នកក្រ អ្នកត្រកូលខ្ពស់និងអ្នកត្រកូលទាប បាន

លះបង់ជំនឿចាស់របស់គេចោល ហើយផ្តោតអារម្មណ៍សារថ្មី ជាផ្លូវទៅរកសុខសន្តិភាព ។ សាសនៈ (ពាក្យប្រៀនប្រដៅ) ដែលនៅក្មេងខ្ចី ចាប់ផ្តើមដំបូងដោយភិក្ខុប្រាំរូប (បញ្ចវគ្គីយ) កើនឡើងរហូតដល់មនុស្សរាប់លានរូប បានផ្សព្វផ្សាយចេញដោយសន្តិភាព ពេញតំបន់ដែនដីកណ្តាលនៃប្រទេសឥណ្ឌាបុរាណ ។

## យាមទីមួយ

នៅសម័យនោះ ពេលរាត្រីចាប់ពីម៉ោង៦ រហូតដល់ម៉ោង១០យប់ ហៅថាយាម១, ជាពេលផ្តាច់មុខសម្រាប់ពួកភិក្ខុសង្ឃ ដែលមានការសង្ស័យ ឬមានភាពស្មុគ្រស្មាញក្នុងព្រះធម៌ អាចចូលមកជម្រះការសង្ស័យបាន ដោយការទូលសួរព្រះពុទ្ធដោយផ្ទាល់ ហើយបានទទួលការប្រៀនប្រដៅ ពីរបៀបប្រតិបត្តិសមាធិ និងបានស្តាប់ព្រះធម៌ពីសំណាក់ព្រះពុទ្ធអង្គ ។

## យាមទីពីរ

ចាប់ពីម៉ោង១០យប់ទៅ រហូតដល់ម៉ាង២ទៀបភ្លឺជាយាមទី២, ពួកទេវតាទាំងឡាយក្នុងកាមាវចរសួគ៌ ឬព្រហ្មដែលយើងមិនអាចមើលឃើញ ដោយភ្នែកមនុស្សធម្មតា បានចូលទៅរកព្រះពុទ្ធអង្គ ដើម្បីទូលនូវសំណួរ, ហើយមានព្រះសូត្រជាច្រើនដែលព្រះអង្គ បានឆ្លើយចំពោះទេវតា

ទាំងនោះ ដែលស្ទើរតែទាំងអស់ មាននៅក្នុងគម្ពីរសំយុត្តនិកាយ សុត្តន្តបិដក ។

## យាមទីបី

ពេលម៉ោងតិចជាងគេ គឺចាប់ពីម៉ោង២ទៀបភ្លឺ រហូតដល់ម៉ោង៦ព្រឹក ចាត់ជាយាមទី៣ ហើយត្រូវបានចែកជា៤ផ្នែកទៀត ។ ផ្នែកទី១ទ្រង់និមន្តដើរចង្ក្រម ដូចជាការហាត់ប្រាណខាងសុខភាពផ្លូវកាយ ។ ផ្នែកទី២ (៣-៤) ទ្រង់ទម្រេតព្រះកាយ ផ្ទុំបែរទៅទិសខាងស្តាំនៅក្នុងសតិ ។ ផ្នែកទី៣ (៤-៥) ទ្រង់ចម្រើននូវផលនៃអរហត្តផល និងសោយនូវវិមុត្តិសុខ, ម៉ោងចុងក្រោយ(៥-៦) ទ្រង់បានចំណាយពេល នៅក្នុងការសម្រេចមហាករុណាសមាបត្តិ ។ នៅខាងដើមម៉ោងនេះ ព្រះពុទ្ធផ្សាយមេត្តាឆ្ពោះទៅកាន់សត្វទាំងឡាយ និងប្រមើលមើលលោកទាំងមូលដោយពុទ្ធចក្ខុ ដើម្បីរកមើលថាតើព្រះអង្គ អាចប្រោសសត្វណាបានទៅ ។ ប្រសិនបើមានហេតុការណ៍ពិសេសណាមួយ ព្រះអង្គក៏និមន្តទៅដោយផ្ទាល់ ដើម្បីសម្តែងធម៌ប្រោសដល់បុគ្គលនោះ ។

ពេញមួយថ្ងៃ ព្រះអង្គបានបំពេញពុទ្ធកិច្ច ស្ទើរគ្មានសល់ចន្លោះពេលឡើយ ។ ព្រះអង្គផ្ទុំសម្រាកព្រះកាយ រយៈពេលតែមួយម៉ោងនៅពេលយប់ និងពីរម៉ោងនៅពេលថ្ងៃត្រង់, នៅពេលអារុណរះ ព្រះអង្គផ្សាយមេត្តាទៅកាន់ពិភពលោកទាំងមូល ។ ព្រះពុទ្ធនិមន្តចេញបិណ្ឌបាត្រ ដោយ

ផ្ទាល់ព្រះអង្គ គ្មានការលំបាកឡើយ ទ្រង់បានដឹកនាំជីវិតតាមភាព ជាអ្នកក្រី ក្រ ។ ព្រះអង្គនិមន្តបិណ្ឌបាត្រអាហារ ពីផ្ទះមួយទៅផ្ទះមួយ ទ្រង់និមន្តដើរដោយព្រះបាទផ្ទាល់ ពីកន្លែងមួយទៅកន្លែងមួយ រយៈពេលប្រាំបីខែក្នុងមួយឆ្នាំ ។ ព្រះពុទ្ធបំពេញពុទ្ធកិច្ចទាំងប្រាំយ៉ាង ដោយគ្មានពេលសម្រាក តាមរបៀបខាងលើរហូតដល់ព្រះអង្គ មានព្រះជន្ម៨០ព្រះវស្សាគត់ ។

# ៩. ភាពសំខាន់របស់ព្រះពុទ្ធ

ព្រះពុទ្ធគឺជាបុគ្គលដែលមានតែមួយគត់, ព្រះអង្គជាអ្នកគិតយ៉ាងជ្រៅបំផុត, ជាអ្នកពូកែនិយាយបញ្ចុះបញ្ចូលបំផុត, ជាអ្នកធ្វើការយ៉ាងស្វាហាប់បំផុត, ជាអ្នកកែទម្រង់ដ៏ជោគជ័យបំផុត, ជាគ្រូប្រកបដោយករុណានិងអធ្យាស្រ័យល្អបំផុត, ជាអ្នកគ្រប់គ្រងដ៏មានសមត្ថភាពបំផុត ហើយទាំងអស់ដូចដែលបានពោលខាងលើនេះ គឺជាភាពស័ក្តិសិទ្ធិនៅលើភាពស័ក្តិសិទ្ធិ ។

នៅគ្រាខាងដើម នៃការយាងចេញសាងអភិនេស្រ្កម ព្រះពុទ្ធបានស្វែងរកការប្រៀនប្រដៅពីមហាគ្រូ ដែលមានកិត្តិនាមល្បីៗ, ប៉ុន្តែព្រះអង្គមិនអាចរកបាននូវអ្វី ដែលព្រះអង្គចង់បានពីប្រភពខាងក្រៅឡើយ ។ ពេលវេលាបានបង្ខំព្រះអង្គឲ្យគិតថា ត្រូវស្វែងរកនូវគុណធម៌ខាងក្នុងដោយខ្លួនឯងវិញម្តង ។ ព្រះអង្គបានស្វែងរក, បានសញ្ជឹងគិត, បានឆ្លុះបញ្ចាំងតបទីបំផុតព្រះអង្គបានស្វែងរកឃើញ គោលដៅនៃជីវិតរបស់ទ្រង់ ។ ការស្វែងរកឃើញនូវសច្ចធម៌ ឈ្មោះថាព្រះអង្គបានបើកទ្វារនៃព្រះនិព្វានដល់អ្នកទាំងអស់ណា ដែលប្រាថ្នាដើម្បីស្តាប់ព្រះអង្គ ហើយស្វែងរកការរួចផុតចាក ការវិលវល់នៅក្នុងវដ្តៈនៃការកើតស្លាប់ដដែលៗ មិនមែនពីព្រោះតែព្រះអង្គ មានភាពអស្ចារ្យនៅក្មេងខ្ចី ក្នុងស្មារតីដែលទទួលបានតាមធម្មតាឡើយ ។

ព្រះពុទ្ធបានត្រាស់ដឹងសព្វគ្រប់, ព្រះអង្គមានចង្កើះសោរនៃចំណេះដឹងទាំងអស់ ដូច្នេះព្រះអង្គត្រូវបានគេហៅថាសព្វញ្ញុពុទ្ធ ។ ការត្រាស់ដឹងនេះ ព្រះអង្គបានទទួលមកដោយការខិតខំរបស់ព្រះអង្គផ្ទាល់ ជាផលនៃកំណើតដែលមិនអាចរៀបរាប់បានឡើយ ។ អ្វីដែលព្រះអង្គបានបង្រៀនជាផ្នែកតូចមួយនៃធម៌ដែលទ្រង់បានត្រាស់ដឹង គឺទ្រង់បង្រៀនតែអ្វីដែលសំខាន់ៗប៉ុណ្ណោះ ។ នៅក្នុងឱកាសមួយ នៅពេលដែលព្រះពុទ្ធគង់នៅក្នុងព្រៃ ទ្រង់បានចាប់យកស្លឹកឈើពេញមួយដៃ រួចមានតម្រាស់ថា:

“ម្នាលភិក្ខុទាំងឡាយ ! អ្វីដែលតថាគតបានបង្រៀនហើយ គឺប្រៀបទៅនឹងចំនួនស្លឹកឈើនៅក្នុងដៃរបស់ថាគត, ហើយអ្វីដែលតថាគតមិនបានបង្រៀនអ្នករាល់គ្នា ប្រៀបបានទៅនឹងចំនួននៃស្លឹកឈើនៅក្នុងព្រៃ” ។

ព្រះពុទ្ធប្រទានធម៌ទេសនាប្រចាំថ្ងៃ ពីវាទៈ (Doctrine) របស់ព្រះអង្គ ចំពោះព្រះសង្ឃនិងពួកគ្រហស្ថ ។ នៅពេលរសៀល ព្រះអង្គស្វែងរកបុគ្គលដែលត្រូវការជំបូន្មានពីព្រះអង្គ, បន្ទាប់ពីទទួលចង្ហាន់ថ្ងៃហើយ ព្រះពុទ្ធបានប្រៀនប្រដៅនិងបង្រៀនសង្ឃសាវ័ក ។ នៅពេលល្ងាចព្រះពុទ្ធបានទេសនាដល់បរិស័ទជាគ្រហស្ថ ដែលបានមកស្តាប់ធម៌របស់ព្រះអង្គ ប្រហែលមួយម៉ោង ។ នៅក្នុងយាមទី១នៃពេលរាត្រី ព្រះពុទ្ធបានទេសនាចំពោះសង្ឃសាវ័ក ហើយពេញមួយយាមទី២ ព្រះអង្គទទួលទេវតា

និងពួកអទិស្សមានកាយផ្សេងៗ ហើយទ្រង់ពន្យល់ធម៌ដល់ពួកគេ ។ ព្រះអង្គប្រតិបត្តិនូវអ្វីដែលព្រះអង្គបានទេសនាហើយ ទ្រង់ធ្វើការដោយមិនមានសម្រាកឡើយ អស់រយៈពេល៤៥ឆ្នាំគត់ ដើម្បីសេចក្តីល្អ សន្តិភាព និងសុភមង្គល រហូតដល់ខណៈចុងក្រោយរបស់ព្រះអង្គ ។

## ព្រះពុទ្ធ និង ប្រព័ន្ធវណ្ណៈ

ដោយភាពឈ្លាសវៃ និងមានប្រសិទ្ធភាពបំផុត ព្រះពុទ្ធបានធ្វើការរំលាយចោល នូវអំពើអាក្រក់របស់សង្គមបានដោយជោគជ័យ តាំងពីក្នុងសម័យដែលព្រះអង្គគង់ធរមាននៅ ។ ព្រះអង្គបានប្រឆាំងយ៉ាងខ្លាំងក្លានឹងប្រព័ន្ធវណ្ណៈ ដែលជាឧបសគ្គធំដល់ការរីកលូតលាស់នៃមនុស្សធម៌ ។ នៅក្នុងយោបល់របស់ព្រះអង្គគឺ: “កំណើតមិនអាចធ្វើបុគ្គលឲ្យក្លាយទៅជាព្រាហ្មណ៍ ឬក៏មិនទៅជាព្រាហ្មណ៍នោះទេ ។ មានតែទង្វើក្នុងជីវភាពទេ ទើបអាចធ្វើបុគ្គលឲ្យក្លាយទៅជាព្រាហ្មណ៍ពិតបាន, ទោះបីកំណើតរបស់ពួកគេប្រសូតចេញមកពីគ្រួសារកសិករ ពាណិជករ ពួកអ្នកជំនួញ និងអ្នកខ្ញុំគេ..., ឬកំណើតរបស់ពួកគេចេញមកពីចោរលួច ចោរប្លន់ កងទ័ពជីតុន (ទីប្រឹក្សា) ស្តេច... ។ មិនមែនដោយសារកំណើតជាគ្រួសារកសិករ, មិនមែនដោយសារតែកំណើត ជាគ្រួសារព្រាហ្មណ៍ឡើយ, តែទង្វើរបស់ពួកគេទេ ដែលធ្វើបុគ្គលឲ្យបានទៅជាសូទ្រៈ ឬជាព្រាហ្មណ៍” ។

តាមរយៈព្រះពុទ្ធអង្គ វណ្ណៈ ឬពណ៌សម្បុរមិនរារាំងបុគ្គលដែលចង់ក្លាយជាពុទ្ធសាសនិក ឬការចូលមកបួសជាភិក្ខុសាមណេរឡើយ ។ អ្នកនេសាទ, អ្នកដើររកអាហារដោយខ្លួនឯង, ស្ត្រីប្រកបមុខរបរពេស្យា, អ្នកចម្បាំង និងព្រាហ្មណ៍អាចចូលមកបួសនៅក្នុងសហគមន៍សង្ឃបានតាមត្រូវការ ហើយចូលរួមដោយរីករាយនៅក្នុងសិទ្ធិស្មើភាពគ្នា និងត្រូវបានឲ្យដោយស្មើៗគ្នានូវឋានៈនិងមុខងារ ។

ព្រះឧបាលិ ជាជាងកាត់សក់ជាឧទាហរណ៍ ដែលត្រូវបានធ្វើឲ្យពេញចិត្តដល់អ្នកទាំងអស់គ្នា សំខាន់នៅក្នុងរឿងដែលជាប់ទាក់ទងដល់ព្រះវិន័យ ។ សុនីតៈមានមុខខ្វរ ជាអ្នកដើររកអាហារដោយខ្លួនឯង ត្រូវបានទទួលយល់ព្រម ដោយព្រះពុទ្ធអង្គផ្ទាល់ ឲ្យបួសជាភិក្ខុសង្ឃ, ស្រីប្រកបរបរពេស្យាម្នាក់ឈ្មោះអម្ពបាលិ បានចូលបួសក្នុងសំណាក់ភិក្ខុនីក្រោយមកបានសម្រេចធម៌ជាន់ខ្ពស់ជាព្រះអរហន្ត, សាតិជាព្រះសង្ឃមួយអង្គ ដែលធ្លាប់បានជឿស៊ប់ក្នុងសាសនាដទៃ ជាកូនប្រុសតែមួយរបស់គ្រួសារនេសាទត្រី, នាងសុភាជាកូនស្រីរបស់ជាងមាស នាងបុណ្ណាជាស្រីបម្រើ(ទាសី) នាងចាប៉ា ជាកូនស្រីរបស់អ្នកប្រមាញ់សត្វក្តាន់ជាដើម ។ ឧទាហរណ៍ទាំងនេះអាចបង្ហាញបានថា ក្លោងទ្វារដ៏ធំរបស់ព្រះពុទ្ធសាសនា ត្រូវបានបើកចំហរយ៉ាងទូលាយ សម្រាប់ជនគ្រប់រូបដោយគ្មានរើសអើងឡើយ ។

ព្រះពុទ្ធមានបំណងលុបបំបាត់ចោល នូវរបបទាសភាពជាលើកដំបូង នៅក្នុងប្រវត្តិសាស្ត្រពិភពលោក ។

## ព្រះពុទ្ធ និងការលើកកំពស់ស្ត្រី

ព្រះពុទ្ធបានលើកឡើងពីស្ថានភាពស្ត្រី និងបានបង្រៀនពួកគេឱ្យយល់ដឹង នូវតួនាទីដ៏សំខាន់របស់គេ ពីការចូលរួមក្នុងសង្គម ។ ព្រះអង្គមិនបានបន្ទាបបង្អាប់ស្ត្រីទេ, ប៉ុន្តែទ្រង់បានគោរពដល់ស្ត្រី ដោយគិតទៅដល់ភាពទន់ខ្សោយ ខាងលក្ខណៈជីវសាស្ត្រតាមបែបធម្មជាតិរបស់ស្ត្រី, ទ្រង់បានឃើញសេចក្តីល្អពីកំណើតរបស់បុរសនិងស្ត្រី ហើយបានកំណត់ពួកគេឱ្យស្ថិតនៅក្នុងការបង្រៀនរបស់ព្រះអង្គ ។ ភេទមិនមែនជាឧបស័គ្គក្នុងការចូលបួស ឬការសម្រេចធម៌នោះទេ ។

ពាក្យបាលីបញ្ជាក់ពីស្ត្រីថា “មាតុគាមៈ” ឯពាក្យសំស្រ្កឹតថា “មាតុគ្រាម” ដែលមានន័យថា “មាតានៃស្រុក” ឬ “សង្គមនៃមាតា” ។ នៅក្នុងព្រះពុទ្ធសាសនា មាតាគឺស្ត្រីដែលត្រូវបានគេទុកដាក់ នៅត្រង់កន្លែងប្រកបដោយកិត្តិយស ។ ភរិយាត្រូវបានគោរពទុកជា “មិត្តដ៏ប្រសើរបំផុត” (បរមសខា) របស់ស្វាមី ។

ទោះបីនៅគ្រាដំបូង ព្រះពុទ្ធបានបដិសេធការព្រមទទួលយកស្ត្រីឲ្យចូលទៅក្នុងសហគមន៍សង្ឃមែន, តែក្រោយមកព្រះអង្គត្រូវបានបញ្ចុះបញ្ចូលដោយព្រះអានន្ទ រហូតបានបង្កើតជាសហគមន៍ភិក្ខុនីសង្ឃឡើង ។

ក្រោយការបានសម្រេចជាព្រះអរហន្តមក ព្រះសារីបុត្រនិងព្រះមោគ្គល្លាន ក៏ត្រូវបានតែងតាំងជាអគ្គសាវ័កទាំងពីរអង្គ នៅក្នុងជួរភិក្ខុសង្ឃ, ហើយព្រះថេរីខេមា និងព្រះថេរីឧប្បលវណ្ណា ក៏ត្រូវបានតែងតាំងជាអគ្គសាវិកានៅក្នុងជួរភិក្ខុនីសង្ឃដែរ ។ នៅមានសាវិកាជាច្រើនរូបទៀត ត្រូវបានព្រះពុទ្ធអង្គដាក់នាមឲ្យ និងផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងចំណោមសាវិកាដែលមានកិត្តិយស និងមានការគោរពជឿជាក់ចំពោះព្រះអង្គ ។

នៅមុនការមកដល់នៃព្រះពុទ្ធបរមគ្រូ ពួកស្ត្រីត្រូវបានគេដាក់ឲ្យនៅក្រោមស្ថានភាពដ៏អាក្រក់ ដូច្នេះសហគមន៍សង្ឃថ្មីនេះ បានទទួលពរសព្ទសាធុការយ៉ាងធំ ។ នៅក្នុងសហគមន៍សង្ឃថ្មីនេះ អគ្គមហេសី ព្រះនាងម្ចាស់បុត្រីរបស់ត្រកូលអភិជន ពួកស្ត្រីមេម៉ាយ ពួកម្តាយដែលអស់កូនពួកស្ត្រីគ្មានទីពឹង ពួកស្ត្រីប្រេកបរបរពេស្យា និងគ្រប់វណ្ណៈឋានៈរបស់គេបានជួបគ្នានៅក្នុងវេទិការួម, បានរីករាយពេញចិត្តនូវសេចក្តីសុខស្ងប់ និងបានស្រូបយកនូវបរិយាកាសល្អមួយ, ហើយត្រូវបានបដិសេធចោលចំពោះអ្នកដែលបានដាក់កំណត់ព្រំដែន នៅក្នុងវនាស្រមនិងលំនៅស្ថានដូច

រាជវាំង ។ ម្យ៉ាងវិញទៀត អ្នកដែលបានធ្លាក់ចុះទៅក្នុងការវង្វេងស្មារតី បានញែកខ្លួនគេនៅក្នុងផ្លូវផ្សេងៗដោយផ្ទាល់ខ្លួន និងបានជាអ្នករួចផុត ដោយការស្វែងរកទីពឹងនៅក្នុងព្រះសង្ឃ ។

## អធ្យាស្រ័យព្រះពុទ្ធចំពោះសត្វ

ការសន្តោសប្រណីរបស់ព្រះពុទ្ធ បានផ្សាយទៅមិនគ្រាន់តែមនុស្សប៉ុណ្ណោះទេ ប៉ុន្តែចំពោះសត្វផងដែរ ។ រឿងនេះ ព្រះពុទ្ធបានហាមនូវការធ្វើពិធីបូជាយញ្ញ ដោយសត្វមានជីវិត និងបានទូន្មានដល់សាវ័កទាំងឡាយរបស់ព្រះអង្គ ឲ្យផ្សាយមេត្តាចំពោះសត្វមានជីវិតទាំងអស់ ។ មិនមានមនុស្សណាមួយមានសិទ្ធិឬអំណាច បំផ្លាញជីវិតសត្វដទៃទៀតឡើយ សូម្បីត្រឹមតែផលប្រយោជន៍ក្រពះក៏ដោយ ព្រោះថាជីវិតមានតម្លៃណាស់ ។

## ភាពសំខាន់របស់ព្រះពុទ្ធ

មធ្យោបាយដ៏មានប្រសិទ្ធភាព ដែលព្រះអង្គបានប្រកាន់យក គឺការបញ្ញត្តិវិន័យដែលមានសិក្ខាបទចំនួនច្រើន សម្រាប់សាវ័ករបស់ព្រះអង្គ ជាពិសេសភិក្ខុសង្ឃនិងភិក្ខុនីសង្ឃ ដែលបានជាសាក្សីក្នុងចិរភាពនៃការគ្រប់គ្រង ។ ព្រះអង្គបានប្រមើលទុកជាមុនស្រេច ពីការគ្រប់គ្រងនេះដែលមានទម្រង់បែបជាប្រព័ន្ធសភាបច្ចុប្បន្ននេះដែរ ។ លោក ឡូតស៊ើត

ឡែនដ៍ (Lord Zetland) បានសរសេរថា "ប្រហែលជាផុសចេញមកនូវការភ្ញាក់ផ្អើលមួយ ដើម្បីបានយល់ពីសភាពុទ្ធសាសនិក នៅប្រទេសឥណ្ឌាជាងពីរពាន់ប្រាំរយឆ្នាំមកហើយ ដែលគេបានស្វែងរកឃើញនូវក្នុងបឋមវិធាន នៃការអនុវត្តក្នុងទម្រង់ជាសភា ដូចរបបសភានិយមសព្វថ្ងៃនេះដែរ" ។

លក្ខណៈគួរឱ្យកត់សម្គាល់មួយរបស់ព្រះពុទ្ធ គឺភាពបរិសុទ្ធហ្មត់ចត់ និងពិសិដ្ឋភាពពេញលេញរបស់ព្រះអង្គ ។ ព្រះពុទ្ធអង្គមានលក្ខណៈបរិសុទ្ធបំផុតនិងពិសិដ្ឋបំផុត ដែលគួរត្រូវបានហៅថា "ពិសិដ្ឋបំផុតលើពិសិដ្ឋបំផុត" ។ ព្រះពុទ្ធអង្គ គឺជាគម្រូយ៉ាងហ្មត់ហ្មង់នៃគុណធម៌ទាំងអស់ដែលព្រះអង្គបានទេសនាហើយ ។ ជីវិតរបស់ព្រះអង្គមិនមានភាពសៅហ្មងឡើយ, មិនមានឱកាសបញ្ចេញឱ្យឃើញ នូវភាពខ្សោយខាងសីលធម៌ត្រង់ណាមួយរបស់ព្រះពុទ្ធអង្គឡើយ ។ មនុស្សរាល់គ្នាដែលមកជួបព្រះពុទ្ធសុទ្ធតែបានទទួលស្គាល់នូវភាពសំខាន់របស់ព្រះអង្គ ដែលមិនអាចជំទាស់បានឡើយ និងមានឥទ្ធិពលដ៏ជ្រៅ ដោយសារមហាបុរិសលក្ខណៈដ៏ពិសេសរបស់ព្រះអង្គ ។

គោលបំណង, បញ្ញា, សេចក្តីអាណិតអាសូរ, ការបម្រើ, ការលះបង់, ភាពបរិសុទ្ធហ្មត់ហ្មង, ការធ្វើជីវិតផ្ទាល់ខ្លួនឱ្យជាគម្រូ, មេរៀនដែលមិនមានការស្តីបន្ទោស ដែលបានប្រើដើម្បីផ្សព្វផ្សាយព្រះធម៌ កត្តាទាំង

នេះហើយជាជោគជ័យចុងក្រោយ របស់ព្រះអង្គដែលបានវិភាគទាន នាំឲ្យគេថ្វាយព្រះនាមដល់ព្រះពុទ្ធថា "បរមគ្រូ" នៃសាសនា ដែលធ្លាប់រស់នៅលើផែនដីនេះ ។

លទ្ធិហិណ្ឌូបានផ្តល់កិត្តិយសដល់ព្រះអង្គ ថាជាអវតាររបស់ព្រះវិស្ណុ ផ្នែកខាងប្រាជ្ញាញាណ, លទ្ធិគ្រឹស្តបានលើកព្រះអង្គជាសន្តិបុគ្គល ដូចជាបព្វជិតស៊ូស៊ាផាត (នៅក្នុងភាសាបាលីថាព្រះពោធិសត្វ), សាសនាមូស្លីមបានគោរពព្រះពុទ្ធអង្គ ជាគ្រូអប់រំខាងផ្លូវចិត្តម្នាក់, អ្នកសនិទាននិយម (អ្នកទស្សនវិទូសម័យថ្មី) គោរពព្រះអង្គជាកំពូលអ្នកគិតតាមចិត្តចង់ ។

លោក អេច្ឆ. ជី. វ៉ែលស៍ (H.G. Wells) ជាអ្នកគិតដ៏មានកិត្តិ ស័ព្ទមួយរូប បានថ្វាយព្រះអង្គជាមហាបុរសទីមួយ ក្នុងចំណោមមហាបុរសទាំងប្រាំពីររូប នៅក្នុងពិភពលោកនេះ ។ ចិន្តកវីតាហ្គ័រ (Tagore) បានហៅព្រះពុទ្ធអង្គថា កំពូលបុរសដែលធ្លាប់កើតឡើង ។

លោកហ្វូសប៊ូល (Fausboll) ជាអ្នកប្រាជ្ញជាតិរុស្ស៊ី បានពោលសរសើរព្រះពុទ្ធថា:

"ខ្ញុំបានស្គាល់ព្រះពុទ្ធអង្គច្រើនណាស់, ខ្ញុំស្រឡាញ់ព្រះអង្គច្រើនណាស់, ខ្ញុំស្រឡាញ់ព្រះអង្គច្រើនណាស់, ខ្ញុំស្រឡាញ់ព្រះអង្គច្រើនណាស់" ។

# ១០-បរិនិព្វាន

ព្រះជន្មគម្រប់៨០ព្រះវស្សា បានឈានមកដល់ហើយ, ការចូលនិព្វានរបស់ព្រះពុទ្ធអង្គ កាន់តែខិតមកជិតណាស់ហើយដែរ ។ អគ្គសាវ័កទាំងពីររបស់ព្រះអង្គ គឺព្រះសារីបុត្រនិងព្រះមោគ្គល្លាន ក៏បានចូលនិព្វានទៅមុនព្រះអង្គហើយដែរ ។

ថ្ងៃមួយ ព្រះពុទ្ធបានប្រាប់ទៅព្រះអានន្ទថា:

"ម្នាលអានន្ទ ! អ្នកណាមួយបានចម្រើនឲ្យបរិបូណ៌ហើយ នូវឥទ្ធិបាទធម៌ទាំងបួនយ៉ាង[១៧] អ្នកនោះអាចអធិដ្ឋានឲ្យ មានជីវិតរស់នៅអស់កប្ប ឬក៏លើសកប្បទៀតបានតាមប្រាថ្នា ។ ឥឡូវនេះ តថាគតបានចម្រើនឥទ្ធិបាទធម៌ទាំងនោះ ឲ្យកើតឡើងបរិបូណ៌ហើយ"[១៨] ។

ព្រះអានន្ទ មិនបានយល់ពីន័យនៃព្រះពុទ្ធដីកានោះឡើយ ដោយសារតែពេលនោះ មារចូលជ្រែកក្នុងចិត្តរបស់លោក មិនឲ្យនឹកឃើញ

---

[១៧] ឥទ្ធិបាទធម៌៤យ៉ាងគឺ: ១-ឆន្ទៈ បំណងប្រាថ្នា, ២-វីរិយៈ ការព្យាយាម, ៣- ចិត្តៈ ការយកចិត្តទុកដាក់, ៤-វិមំសៈ ការពិនិត្យ ឬ ការសាកល្បង ។

[១៨] កប្ប ក្នុងទីនេះមានន័យថា រយៈកាលនៃជីវិតរស់នៅសម័យនោះ ចាប់ពី១០០ ដល់ ១២០ឆ្នាំ ។

ឡើយ ។ លោកមិនបានទូលសុំព្រះអង្គ ឲ្យអធិដ្ឋានឥទ្ធិបាទធម៌នោះ ដើម្បីគង់នៅអស់កាលនៃកប្បឡើយ ។ ព្រះពុទ្ធអង្គមានព្រះតម្រាស់ដដែលៗជាគម្រប់ពីរដងផង និងជាគម្រប់បីដងផង, តែព្រះអានន្ទគង់នៅស្ងៀមដដែល ។

## ផ្ចាញ់មារ

នៅពេលព្រះអានន្ទនិមន្តចេញពីព្រះពុទ្ធអង្គទៅ មារបានឱកាសចូលទៅរកព្រះដ៏មានព្រះភាគ ហើយទូលអារាធនាព្រះអង្គឲ្យចូលនិព្វាន ។

ព្រះពុទ្ធឆ្លើយតបទៅមារនោះវិញថា:

"ម្នាលមារ ! ចូរអ្នករីករាយក្នុងចិត្តចុះ, តថាគតនឹងចូលនិព្វានក្នុងពេលមិនយូរទេ ។ នៅប្រមាណ៣ខែទៀត រាប់ចាប់ពីពេលនេះទៅតថាគតនឹងបរិនិព្វានហើយ" ។

បន្ទាប់មក ព្រះពុទ្ធបានប្រាប់រឿងនោះទៅដល់ព្រះអានន្ទ, ព្រះអានន្ទបាននឹកទៅដល់ព្រះពុទ្ធដីកា ដែលព្រះពុទ្ធអង្គបានថ្លែងប្រាប់ ក៏ទូលអង្វរព្រះពុទ្ធឲ្យអធិដ្ឋានព្រះជន្ម គង់នៅអស់កាលនៃកប្ប ។ ព្រះពុទ្ធឆ្លើយតបថា "ម្នាលអានន្ទ ! អ្នកកុំអង្វរតថាគតធ្វើអ្វី, ពេលវេលាសម្រាប់អ្នកទូលសុំតថាគត បានកន្លងហួសហើយ ។ តថាគតបានរំលឹកប្រាប់ដល់អ្នក

ពីរដងរួចមកហើយ នៅលើកទីបីអ្នកគួរតែយល់ដែរ ។ ព្រោះហេតុនោះ អ្នកពិតជាខុសហើយ, នេះជាកំហុសរបស់អ្នកហើយអានន្ទ...” ។

## ការប្រៀនប្រដៅ

នៅឱកាសមួយទៀត, ព្រះពុទ្ធបានដាស់តឿនសាវ័កទាំងអស់របស់ព្រះអង្គថា:

“ម្នាលភិក្ខុទាំងឡាយ ! ឥឡូវនេះ តថាគតរំលឹកដល់អ្នករាល់គ្នាឲ្យបានដឹងថា សង្ខារទាំងឡាយមិនទៀងទេ, ចូរអ្នកទាំងឡាយព្យាយាម ដោយសេចក្តីឈ្លាសវៃចុះ ។ នៅមានពេលមិនយូរទៀតទេ ការឃ្លាតគ្នាជាលើកចុងក្រោយ របស់តថាគត ពីអ្នកទាំងឡាយនឹងកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ ! តថាគតបានដាក់អាយុសង្ខារហើយ រាប់ចាប់ពីពេលនេះថយក្រោយកំឡុង៣ខែទៀត តថាគតនឹងបរិនិព្វានហើយ...” ។

“តថាគតមានវ័យចាស់ជរាណាស់ហើយ ជីវិតរបស់តថាគតនៅសល់តិចណាស់ ។ តថាគតនឹងលាអ្នករាល់គ្នាដើម្បីចូលបរិនិព្វាន, តថាគតបានធ្វើនូវទីពឹងសម្រាប់ខ្លួនតថាគតរួចហើយ ។ ម្នាលភិក្ខុទាំងឡាយ ! ចូរសម្លឹងមើលដោយសតិនិងកុសលធម៌ ជាមួយនឹងគំនិតដែលបានរួប រួមសាមគ្គីគ្នា, ចូររក្សាសតិរបស់អ្នកផង ។ ចូរ

អ្នករស់នៅជាមួយសេចក្តីព្យាយាម ដើម្បីគេចចេញពីការកើត ចាស់ ឈឺ ស្លាប់ ដែលវិលវល់ដដែលៗ នៅក្នុងវាលវដ្តសង្សារនេះ ហើយត្រូវដាក់ចុះនូវទីបញ្ចប់សេចក្តីទុក្ខ" ។

## ព្រះធម្មារាមថេរ គោរពព្រះពុទ្ធ

ពួកសាវ័កជាបព្វជិត មានការក្រៀមក្រំក្នុងចិត្តយ៉ាងក្រៃលែង ចំពោះដំណឹង នៃការចូលបរិនិព្វានរបស់ព្រះបរមគ្រូ នៅក្នុងកំឡុងពេល ៣ខែទៀត ។ ពួកភិក្ខុសង្ឃសាវ័កបានមកប្រជុំគ្នា ដើម្បីគោរពព្រះបរមគ្រូ ជាចុងក្រោយ ។ ភិក្ខុមួយអង្គឈ្មោះធម្មារាម បានទប់ស្កាត់ភិក្ខុទាំងឡាយ ដែលមានបំណងចូលមកជួបព្រះពុទ្ធ ។ រឿងនេះត្រូវបានសាវ័កឯទៀតៗ នាំយកទៅទូលដល់ព្រះពុទ្ធបរមគ្រូឲ្យបានជ្រាប, ព្រះពុទ្ធអង្គបានកោះហៅ ភិក្ខុអង្គនោះ មកជួបព្រះអង្គផ្ទាល់ ។ នៅពេលសួរពីមូលហេតុ នៃការមិន ចូលរួមរបស់លោក ភិក្ខុនោះឆ្លើយថា:

"បពិត្រព្រះអង្គដ៏ចម្រើន ! ខ្ញុំព្រះអង្គបានដឹងថាព្រះដ៏មានព្រះភាគ នឹងយាងចូលនិព្វាន នៅក្នុងកំឡុងពេល៣ខែទៀត, ព្រោះហេតុនោះ ហើយ ទើបខ្ញុំព្រះអង្គគិតថាផ្លូវដ៏ល្អ គឺខ្ញុំព្រះអង្គត្រូវខិតខំប្រឹងប្រែង ធ្វើ យ៉ាងណាឲ្យបានសម្រេចព្រះអរហត្តផល នៅមុនពេលព្រះបរមគ្រូយាង ចូលនិព្វាន" ។

ព្រះពុទ្ធអង្គបានត្រាស់សរសើរយ៉ាងច្រើន នូវគំនិតរបស់ភិក្ខុគម្រូនោះថា “អស្ចារ្យណាស់ ! អស្ចារ្យណាស់ ! បើអ្នកទាំងឡាយគោរពស្រឡាញ់តថាគត គួរតែប្រជែងជាមួយនឹងភិក្ខុរូបនេះ ។ ភិក្ខុរូបនេះបានបូជាយ៉ាងខ្ពស់ដល់តថាគត ដោយការប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់តថាគត ឲ្យបានល្អប្រសើរ” ។

## ចង្ហាន់ចុងក្រោយ

នាយចុន្ទជាងមាស ជាអ្នកមានស្តុកស្តម្ភ មានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធអង្គ, បានឮថាព្រះពុទ្ធយាងមកដល់ស្រុកបាវា ហើយកំពុងគង់នៅក្នុងចំការស្វាយ ។ គាត់បានចេញទៅថ្វាយបង្គំព្រះពុទ្ធ ហើយបន្ទាប់ពីបានស្តាប់ធម៌ទេសនាដ៏វែងមក ក៏បានអារាធនានិមន្តព្រះពុទ្ធ និងសាវ័កទាំងអស់ទទួលភត្តាហារក្នុងថ្ងៃបន្ទាប់ នៅផ្ទះរបស់គាត់ ។

បន្ទាប់ពីរាត្រីបានកន្លងទៅ នាយចុន្ទបានរៀបចំគេហដ្ឋានរួចជាស្រេច ហើយជ្រើសរើសមុខម្ហូបគោកខ្លះម្ហូបទឹកខ្លះ ជាមួយនឹងរបស់ដែលផ្សំឡើងពីសូករមទ្ទវៈ[១៩] ហើយកំណត់ពេលថ្វាយ ព្រះមានព្រះភាគដោយពាក្យថា “បពិត្រព្រះអង្គដ៏ចម្រើន ពេលវេលាបានមកដល់ហើយ សូមនិមន្តទទួលភត្តាហារ” ។

---

[១៩] សុក្កមទ្ទវៈ នៅក្នុងអដ្ឋកថា សំដៅយកសាច់ជ្រូកព្រៃ ។ អ្នកខ្លះនិយាយថា សុក្ករមទ្ទវៈនេះ គឺជាឈ្មោះផ្សិតម្យ៉ាង ចូរមើលនៅក្នុងសៀវភៅមិលិន្ទបញ្ហាភាគ១ ។

ព្រះសម្មាសម្ពុទ្ធ បានរៀបព្រះកាយរួចជាស្រេច នៅមុនពេលថ្ងៃត្រង់ រួចកាន់យកបាត្រនិមន្តជាមួយពួកភិក្ខុ ទៅកាន់គេហដ្ឋានរបស់នាយចុន្ទ រួចគង់នៅលើអាសនៈ ដែលគេបានរៀបចំទុកជាស្រេច ។ ព្រះពុទ្ធអង្គមានតម្រាស់ទៅកាន់នាយចុន្ទថា "ម្នាលចុន្ទ ! ចូរអ្នកថ្វាយដល់តថាគតនូវអាហារសូករមទ្ទវៈ ដែលអ្នកបានរៀបចំហើយនោះចុះ, ប៉ុន្តែត្រូវថ្វាយភិក្ខុសង្ឃជាសាវ័ក របស់តថាគតនូវអាហារមុខផ្សេងវិញ ទាំងអាហារមុខគោកនិងអាហារទឹក" ។

នាយចុន្ទបានធ្វើតាមព្រះពុទ្ធតម្រាស់ថា "បពិត្រព្រះអង្គដ៏ចម្រើន ! ខ្ញុំព្រះអង្គធ្វើដូច្នោះហើយ" ។ នៅពេលនោះ ព្រះពុទ្ធមានព្រះតម្រាស់ទៅកាន់នាយចុន្ទថា "ម្នាលចុន្ទ ! ម្ហូបសូករមទ្ទវៈដែលនៅសល់នេះ ចូរអ្នកយកទៅកប់ចោលក្នុងដីឲ្យបានជ្រៅល្អ ។ ម្នាលចុន្ទ ! តថាគតបានដឹងច្បាស់ថា មិនមានអ្នកណាមួយនៅក្នុងទេវលោក មារលោក ព្រហ្មលោក និងចំណោមនៃសត្វដទៃៗទៀត, ទោះជាសមណៈក្តី ព្រាហ្មណ៍ក្តី, ទេវតា និងមនុស្សទាំងនោះ អាចបរិភោគអាហារនេះបានឡើយ, ចូរជីកដីរួចកប់វាឲ្យបានជ្រៅផងទៅ" ។

នាយចុន្ទឆ្លើយតបព្រះពុទ្ធបរមគ្រូថា "បពិត្រព្រះអង្គដ៏ចម្រើន ! ខ្ញុំព្រះអង្គធ្វើដូច្នោះ" ហើយក៏ជីកដីកប់សំណល់អាហារសូករមទ្ទវៈនោះយ៉ាងជ្រៅទៅរណ្តៅ រួចចូលទៅរកព្រះពុទ្ធ ហើយថ្វាយបង្គំព្រះអង្គដោយគោរព

ក្រែលែង ទើបអង្គុយចុះនៅជ្រុងម្ខាង ។ នៅពេលដែលនាយចុន្ទ អង្គុយចុះស្រួលបួលហើយ ព្រះពុទ្ធអង្គបានញ៉ាំងគាត់ឲ្យរីករាយ ដោយព្រះធម៌ទេសនារបស់ ព្រះអង្គ រួចហើយបានបន្តពុទ្ធដំណើរទៅមុខទៀត ។

នៅខណៈព្រះសម្មាសម្ពុទ្ធ ឆាន់អាហាររបស់នាយចុន្ទហើយ រោគមួលនិងការឈឺចុកចាប់ដ៏ធ្ងន់ បានកើតឡើងស្ទើរតែស្លាប់, ប៉ុន្តែព្រះពុទ្ធបានដឹងច្បាស់ ។ នៅពេលនោះ ព្រះអង្គធ្វើដំណើរទៅកាន់កុសិនារា ដែលមានព្រះអានន្ទ និងភិក្ខុសង្ឃជាច្រើនដង្ហែតាមក្រោយផងដែរ ។

## ប្រោសសាវ័កចុងក្រោយ

នៅពេលនោះ មានបព្វជិតអាជីវកវ័យចំណាស់ម្នាក់ ឈ្មោះសុភទ្ទ រស់នៅក្នុងក្រុងកុសិនារា ។ គាត់បានឮដំណឹងថា ព្រះសមណគោតមនឹងចូលនិព្វាន នៅក្នុងយាមទីបីនៃរាត្រីនោះ ក៏គិតថាចង់ឃើញព្រះអង្គជាចុងក្រោយ ហើយបានចូលទៅឧទ្យានសាលរបស់ពួកមល្លក្សត្ររួចទូលស្នើសុំព្រះអានន្ទថា តើគាត់អាចចូលគាល់ព្រះដ៏មានព្រះភាគបានឬទេ ។

“ម្នាលសុភទ្ទ ! មិនបាច់ទេ, ព្រះមានព្រះភាគកំពុងតែអស់កម្លាំង” ។ សុភទ្ទបានស្នើព្រះអានន្ទរហូតដល់បីដង តែព្រះអានន្ទមិន

អនុញ្ញាតឡើយ ។ ព្រះពុទ្ធទ្រង់បានជ្រាបនូវការសន្ទនានោះ ហើយបានត្រាស់ទៅព្រះអានន្ទថា:

“ម្នាលអានន្ទ ! កុំឃាត់ធ្វើអ្វី ចូរអនុញ្ញាតឲ្យសុភទ្ទចូលមកចុះ ។ អ្វីក៏ដោយដែលសុភទ្ទសួរចំពោះតថាគត ព្រោះតែប្រាថ្នាចង់ដឹង ណ្ហើយកុំធុញថប់នឹងគាត់ធ្វើអ្វី ។ អ្វីក៏ដោយដែលតថាគតពោលឡើង ពិតជានឹងធ្វើឲ្យគាត់យល់មិនខាន” ។

ដោយបានទទួលការអនុញ្ញាត សុភទ្ទបានឱកាសចូលទៅរកព្រះដ៏មានព្រះភាគ ហើយក៏បានទទួលការស្វាគមន៍ និងការសាកសួរដោយព្រះពុទ្ធអង្គ ។ សុភទ្ទនិយាយទៅរកព្រះពុទ្ធថា: “បពិត្រព្រះគោតម ! មានសមណៈនិងព្រាហ្មណ៍ខ្លះ ជាអ្នកដឹកនាំក្រុម និងសហធម្មចារី, ជាអ្នកដឹកនាំនិកាយ, ជាអ្នកមានឈ្មោះល្បី, និងជាគ្រូប្រដៅសាសនាមានកិត្តិនាមត្រូវបានគោរពថាជាមនុស្សល្អដោយជនច្រើនគ្នា ។ ឧទាហរណ៍ដូចជាមហាគ្រូបូរណកស្សប, មក្ខលិគោសាល, អជិតកេសកម្ពលិ, បកុធកច្ចាយនៈ, សញ្ជយពេលត្ថិបុត្ត, និគណ្ឋនាដបុត្ត ។ ពួកគេទាំងអស់គ្នាបានប្រកាស ដោយខ្លួនគេផ្ទាល់ថាបានដឹង ឬមិនបានដឹង, ឬក៏មានខ្លះនៃពួកគេបានយល់ និងខ្លះទៀតមិនបានយល់ដែរទេ ? ”

“ម្នាលសុភទ្ទ ! វាពិតជាដូច្នោះមែន ។ អ្នកមិនបាច់ខ្វល់ទេ ថាទាំងអស់ឬខ្លះៗបានយល់ ឬមិនបានយល់នោះឡើយ ។ ព្រះតថាគតនឹងបង្រៀន

ធម្មៈដល់អ្នក ចូរស្តាប់ហើយទ្រទ្រង់ឲ្យបានល្អទុកក្នុងចិត្ត ។ តថាគតនឹងសម្តែងឥឡូវនេះ”

សុភទ្ទបានឆ្លើយតបព្រះពុទ្ធអង្គថាៈ “បពិត្រព្រះដ៏មានព្រះភាគ ! ខ្ញុំព្រះអង្គនឹងធ្វើតាម” ។

ព្រះពុទ្ធអង្គមានព្រះតម្រាស់ដូចខាងក្រោមៈ

“អ្វីក៏ដោយដែលបានបែងចែកនៅទីនោះ ហើយមិនមាននៅក្នុងអរិយមគ្គប្រកបដោយអង្គប្រាំបីទេ, មិនមែនជាសមណៈទេ, មិនមានទីពីរ ទីបី ទីបួន ដែលត្រូវបានរកឃើញនៅក្នុងនោះទេ ។ អ្វីក៏ដោយដែលបានចែកនៅក្នុងទីនោះ ដែលមានអរិយមគ្គប្រកបដោយអង្គប្រាំបី ហើយអាចត្រូវបានរកឃើញនូវសមណៈទីមួយ, សមណៈទីពីរ, សមណៈទីបី និងសមណៈទីបួន ។ នៅទីនោះ ការចែកនេះមានអរិយមគ្គប្រកបដោយអង្គប្រាំបី ដែលអាចរកឃើញសមណៈដំបូង, សមណៈទីពីរ, សមណៈទីបី និងសមណៈទីបួន ។ និកាយនៃសាសនាដទៃទៀត មិនមានសមណៈទេ ។ ម្នាលសុភទ្ទ ! ប្រសិនបើសមណៈរស់នៅដោយត្រឹមត្រូវហើយ, លោកនេះក៏មិនអាចសូន្យចាកព្រះអរហន្តឡើយ ។ អាយុរបស់តថាគតបានម្ភៃប្រាំបួនឆ្នាំ តថាគតចេញស្វែងរកមោក្ខធម៌, ឥឡូវនេះបាន៥១ឆ្នាំហើយ រាប់ចាប់តាំងពីពេលតថាគត ចេញសាងមហាអភិនេស្រ្កមណ៍នោះមក ។

ម្នាលសុភទ្ទ ! ខាងក្រៅមិនមានបព្វជិតនៅលើវ ដែលបានធ្វើត្រឹមតែភាគខ្លះជាមួយនឹងធម្មៈដែលអាចយល់ដឹងបាននេះ” ។

សុភទ្ទបានពោលសរសើរព្រះពុទ្ធ ចំពោះការឲ្យដំបូន្មានងាយៗរបស់ព្រះអង្គ ដល់ការស្វែងរកព្រះធម៌ និងការរកទីពឹងនៅក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, ហើយបានបង្ហាញពីបំណងរបស់គាត់ ចង់បួសជាភិក្ខុនៅក្នុងព្រះពុទ្ធសាសនា ។

ព្រះពុទ្ធអង្គមានបន្ទូលថា: “ម្នាលសុភទ្ទ ! អ្នកណាក៏ ដោយដែលបានប្រព្រឹត្តនូវលទ្ធិដទៃៗទៀត ហើយមានបំណងចង់បួសជាភិក្ខុនៅក្នុងសាសនានេះ ត្រូវស្ថិតនៅក្នុងការសាកល្បងរយៈពេល៤ខែសិន ។ ទីបំផុតនៃខែទីបួន សង្ឃសាវ័កទាំងឡាយក៏យល់ព្រមឲ្យបួស, បុគ្គលនោះត្រូវបានបំបួស ហើយក៏បានឡើងជាភិក្ខុពេញលេញ ។ ទោះបីជាយ៉ាងនេះក៏ដោយជាមួយការមិនប្រមាទនោះ តថាគតធ្វើការលើកលែង រឿងនោះដល់រូបអ្នក” ។

សុភទ្ទបានយល់ព្រមអត់ទ្រាំទៅតាមវិន័យ ប៉ុន្តែព្រះពុទ្ធបានប្រើព្រះអានន្ទឲ្យបំបួសសុភទ្ទ ។ នៅចំពោះមុខព្រះដ៏មានព្រះភាគ សុភទ្ទបានទទួលការបំបួស ហើយមិនយូរប៉ុន្មានក៏បានសម្រេចជាព្រះអរហត្ត ។ ព្រះពុទ្ធបានប្រោសសុភទ្ទ ជាសាវ័កចុងក្រោយបំផុត មុននឹងចូលបរិនិព្វាន ។

# ឱកាសចុងក្រោយ

ព្រះពុទ្ធត្រាស់ចំពោះព្រះអានន្ទថា "ម្នាលអានន្ទ, អ្នកបាននិយាយថា គ្មានគ្រូសម្រាប់ទូន្មានប្រៀនប្រដៅទៀតទេ ។ អំណើះតទៅមិនមានគ្រូតទៅទៀតទេ ។ ម្នាលអានន្ទ ! មិនដូច្នោះទេ, អ្នកមិនគួរគិតដូច្នោះទេ ។ ធម៌និងវិន័យដែលតថាគត បានសម្តែងហើយក្តី បានបញ្ញត្តហើយក្តី នឹងបានទៅជាគ្រូរបស់អ្នកអំណើះតពីតថាគតទៅ" ។

ព្រះពុទ្ធសម្តែងចំពោះសាវ័ករបស់ព្រះអង្គ តទៅទៀតថា: "ម្នាលសាវ័កទាំងឡាយ ! ប្រសិនបើអ្នកទាំងឡាយមានការសង្ស័យ ឬក៏មិនច្បាស់ត្រង់ណាមួយ ជាមួយនឹងការគោរពចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ និងការប្រតិបត្តិ ក៏ចូរសួរតថាគតឥឡូវនេះចុះ ដើម្បីកុំឲ្យស្តាយក្រោយក្នុងគំនិតថាយើងស្ថិតនៅទល់មុខនឹងព្រះបរមគ្រូហើយ មិនអាចសួរព្រះអង្គនៅចំពោះមុខបានទេនោះ" ។ នៅពេលព្រះពុទ្ធមានបន្ទូលដូច្នេះ សាវ័កទាំងឡាយគង់នៅស្ងៀម ។ ព្រះពុទ្ធបានត្រាស់ ចំពោះសាវ័ករបៀបនេះជាលើកទីពីរផង និងលើកទីបីផង តែសាវ័កនៅស្ងៀមដដែល ។ បន្ទាប់មកព្រះសម្មាសម្ពុទ្ធបានប្រាប់ទៅសាវ័កទាំងអស់ថា:

"ប្រហែលជាមិនគោរពចំពោះបរមគ្រូទេដឹង ដែលអ្នកទាំងឡាយមិនសួរនូវសំណួរដល់តថាគតនោះ ។ ម្នាលសាវ័កទាំងឡាយ ! ចូរលើកកិច្ចការនេះទៅក្នុងឱកាសដទៃទៀតចុះ" ។

សាវ័កទាំងអស់នៅតែស្ងៀមដដែល ។ គ្រានោះព្រះអានន្ទបានសួរព្រះបរមគ្រូនូវសំណួរដូចខាងក្រោមនេះ៖

"បពិត្រព្រះដ៏មានព្រះភាគ ! អស្ចារ្យណាស់ ខ្ញុំព្រះអង្គរីករាយជាមួយនឹងសាវ័កទាំងអស់ ដែលបានដង្ហែព្រះអង្គ ។ មិនមានសាវ័កណាមួយមានការសង្ស័យ ឬក៏មិនច្បាស់ជាមួយការគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងការប្រតិបត្តិធម៌វិន័យឡើយ" ។

"ម្នាលអានន្ទ ! ចូរអ្នកនិយាយដោយសទ្ធាចុះ ។ ចំណោមសាវ័កទាំងឡាយ មិនមានសាវ័កណាមួយដែលសង្ស័យ ឬក៏មិនជ្រះស្រឡះក្នុងការគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងការប្រតិបត្តិព្រះធម៌វិន័យឡើយ ។ បណ្តាសាវ័កទាំងនោះ ព្រះអានន្ទជាអ្នកចុងក្រោយបង្អស់ ដែលបានសម្រេចនូវមគ្គផល" ។ ព្រះមានព្រះភាគបានត្រាស់ចំពោះសាវ័កទាំងនោះទៀតថា:

"ម្នាលសាវ័កទាំងឡាយ ! តថាគតសូមដាស់តឿនអ្នកទាំងឡាយថា សង្ខារទាំងឡាយតែងអស់ទៅជាធម្មតា, អ្នកទាំងឡាយចូរព្យាយាមជាមួយនឹងការមិនប្រមាទចុះ" ។

នេះជាបណ្តាំចុងក្រោយរបស់ព្រះពុទ្ធអង្គ ដែលហៅថាបច្ឆឹមពុទ្ធវចនៈ ។

# នាទីចុងក្រោយ

ជីវិតរបស់ព្រះពុទ្ធបរមគ្រូ បានឈានចូលដល់ទីបំផុតហើយ ។ ក្នុងខណៈចុងក្រោយនេះ ព្រះអង្គសម្រាកព្រះកាយទៅលើអាសនៈ ដែលគេបានរៀបចំហើយ ស្ថិតនៅត្រង់ចន្លោះដើមសាលព្រឹក្សទាំងគូ នៅក្នុងឧទ្យានសាលវ័ន ។ សាវ័កទាំងអស់នាំគ្នាឈរព័ទ្ធជុំវិញព្រះអង្គ ក្នុងសភាពស្ងប់ស្ងាត់ ។ ព្រះពុទ្ធបានសម្រេចនៅក្នុងបឋមជ្ឈាន, ពេលចេញពីបឋមជ្ឈាន ចូលកាន់ទុតិយជ្ឈាន, ចេញពីទុតិយជ្ឈានចូលកាន់តតិយជ្ឈាន, ចេញពីតតិយជ្ឈាន ចូលកាន់ចតុត្ថជ្ឈាន ។ បន្ទាប់មក ទ្រង់បានចេញពីចតុត្ថជ្ឈាន ចូលកាន់អាកាសានញ្ចាយតនជ្ឈាន, ចេញពីអាកាសានញ្ចាយតនជ្ឈាន ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន, ចេញពីវិញ្ញាណញ្ចាយតនជ្ឈាន ចូលកាន់អកិញ្ចញ្ញាយតនជ្ឈាន, ចេញពីអកិញ្ចញ្ញាយតនជ្ឈាន ចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន, ទ្រង់ចេញពីនេវសញ្ញានាសញ្ញាយតនជ្ឈាន ចូលកាន់សញ្ញាវេទយិតនិរោធ ។

ពេលនោះ ព្រះអានន្ទបានសង្កេតមើលដោយរសាប់រសល់ ដល់ការយាងចូលនិព្វាននៃព្រះពុទ្ធបរមគ្រូ បានសម្គាល់ថាព្រះពុទ្ធរំលត់ខន្ធចូលនិព្វានរួចហើយ, តែព្រះអនុរុទ្ធដែលបានឯតទគ្គកម្មខាងទិព្វចក្ខុ បានពន្យល់ថាព្រះពុទ្ធកំពុងគង់សម្រេចនៅក្នុងសញ្ញាវេទយិតនិរោធ ។

បន្ទាប់ពីព្រះអង្គ យាងចេញពីសញ្ញាវេទយិតនិរោធ ទ្រង់ត្រឡប់មកកាន់ចតុត្ថជ្ឈាន តតិយជ្ឈាន ទុតិយជ្ឈាន និងមបឋមជ្ឈាននៃអរូបជ្ឈាន, ហើយត្រឡប់ថយមកទៀតកាន់ចតុត្ថជ្ឈាន តតិយជ្ឈាន ទុតិយជ្ឈាន និងបឋមជ្ឈាន ជារូបជ្ឈាន ។ បន្ទាប់មក ទ្រង់ចូលបឋមជ្ឈានជាអនុលោមរហូតដល់ចតុត្ថជ្ឈាន ក្រោយយាងចេញពីឈានទីបួននោះ ព្រះពុទ្ធបរមគ្រូក៏បរិនិព្វាន នៅត្រង់ចន្លោះនោះទៅ ។

ជាមនុស្សម្នាក់ ព្រះពុទ្ធអង្គបានប្រសូតនិងរស់នៅខុសពីមនុស្សធម្មតា ហើយក៏ចូលបរិនិព្វានទៅ ។

# ១១.កម្ម

កម្មៈ ជាពាក្យបាលី, ពាក្យសំស្ក្រឹតថា កម៌ មានន័យថា អំពើដែលបានធ្វើ, ខ្មែរយើងអានត្រឹមតែកម្មប៉ុណ្ណោះ ។ នៅក្នុងន័យមួយទៀត កម្មមានន័យថា ចេតនាល្អនិងចេតនាអាក្រក់ (កុសលាកុសលចេតនា) ។

រាល់អំពើដែលប្រកបដោយចេតនា លើកលែងតែព្រះពុទ្ធ ឬព្រះអរហន្តចេញ ត្រូវបានហៅថា កម្ម ។ ព្រះពុទ្ធនិងព្រះអរហន្តទាំងឡាយ មិនមានកម្មថ្មីកើតឡើងទៀតទេ ព្រោះលោកបានបំផ្លាញចោលនូវតណ្ហាអស់ហើយ ។ នៅក្នុងពាក្យខ្លះទៀត កម្ម គឺជាច្បាប់ប្រកបដោយហេតុខាងសីលធម៌ (សហេតុកៈ) មានន័យថាវាជាកម្ម និងជាប្រតិកម្មនៅក្នុងផ្នែកអភិសមាចារ ។

កម្មមិនមានន័យពិសេស សម្រាប់តែអំពើក្នុងអតីតកាលមួយមុខទេ, តែវាអាចជាអំពើទាំងអតីតកាល និងបច្ចុប្បន្នកាលផងដែរ ។ កម្មមិនមែនជាវាសនា ឬជាគ្រោះអាក្រក់ទេ ឬក៏មិនមែនជាការកំណត់វាសនាទុកជាមុន (បុព្វវាសនា) អាចផ្តល់ឲ្យបុគ្គល ដោយអំណាចនៃអាថ៌កំបាំងណាមួយ ដែលយើងមិនដឹង ហើយបុគ្គលត្រូវតែទទួលយក ដោយគ្មានទីពឹងអ្វីទៀត

ឡើយ ។ កម្មជាទង្វើរបស់បុគ្គល ហើយផលបានប្រតិកម្មទៅលើខ្លួនគេវិញ, កម្មជាលទ្ធភាពសម្រាប់យើង ដើម្បីបង្វែរទិសនៃកម្មរបស់យើង ។

កម្ម ជាសកម្មភាព ហើយវិបាកជាផល ឬជាប្រតិកម្មរបស់អំពើនោះ, គឺជាហេតុនិងជាផល ដូចជាផ្លែស្វាយដែលកើតចេញមកពីដើមស្វាយ ។ ស្លឹកស្វាយនិងផ្កាស្វាយ គឺដូចជាផលវិបាក (ផលកម្មដែលមិនអាចជៀសរួច) ដូចយើងសាបព្រួសបណ្ដុះពូជ យើងតែងបានទទួលផលនៅក្នុងជាតិនេះ ឬក្នុងអនាគតជាតិ ។ អ្វីដែលយើងទទួលនៅក្នុងថ្ងៃនេះ គឺជាអ្វីដែលយើងបានសាបព្រួសបណ្ដុះនៅក្នុងបច្ចុប្បន្ន ឬពីអតីតជាតិ ។ កម្មគឺជាច្បាប់នៅក្នុងខ្លួនបុគ្គលផ្ទាល់, ប៉ុន្តែមិនមានអ្នកផ្ដល់កម្មឲ្យឡើយ ។ ជាធម្មតា កម្មគឺជាធម្មជាតិឧទាហរណ៍ដូចជាកម្លាំងស្រូបទាញទៅមក, មិនមានអ្នកផ្ដល់កម្មឲ្យបុគ្គលឡើយ ។ កម្មមិនទាមទារអ្នកផ្ដល់ឲ្យទេ, គឺបុគ្គលបានធ្វើ ឬប្រតិបត្តិដោយខ្លួនឯងផ្ទាល់, គ្មានអន្តរាគមន៍ពីខាងក្រៅទេ, កម្មមានភ្នាក់ងារគ្រប់គ្រងឯករាជ្យ ។

អ្វីដែលមានជាប់មកជាមួយកម្ម គឺជាសក្ដានុពលនៃការផលិតឲ្យទៅជាផល (វិបាក) សមស្របទៅតាមទំហំកម្ម ។ ហេតុបានផលិតឲ្យទៅជាផល, ផលចេញមកពីហេតុ ។ គ្រាប់ពូជផលិតឲ្យទៅជាផ្លែផ្កា, ផ្លែផ្កាបានមកពីគ្រាប់ពូជ ហើយទាំងពីរនេះត្រូវមានអន្តរៈសកម្ម (Inter-action) “ផលដែលជាផ្លែផ្កាគឺមកពីហេតុ”។

# កុសលកម្ម

កម្មជាកុសលមាន ១០ យ៉ាងគឺ:

១ .ទាន: ការឲ្យទាន នាំឲ្យបានវិញនូវទ្រព្យសម្បត្តិនៅក្នុងស្ថានមនុស្ស ឬស្ថានទេវតា ។

២.សីល: ការរក្សាសីល នាំឲ្យបានទៅកើតក្នុងកំណើតខ្ពង់ខ្ពស់ មានរូបល្អ មានសេចក្តីសុខ ។

៣.ភាវនា ការចម្រើនភាវនា នាំឲ្យបានទៅកើតក្នុងរូបភព និងអរូបភព ព្រមទាំងមានបញ្ញាខ្ពង់ខ្ពស់ បានសម្រេចមគ្គផល ។

៤.អបចាយន: ការគោរពសមណ:ព្រាហ្មណ៍ អ្នកមានសីល ចាស់ព្រឹទ្ធាចារ្យ ត្រកូលរៀមច្បង នាំឲ្យមានកិត្តិយសខ្ពង់ខ្ពស់ និងមានញាតិសន្តានល្អៗ ។

៥.វេយ្យាវច្ច: ការជួយខ្វល់ខ្វាយក្នុងកិច្ចការជាកុសល នាំឲ្យមានបរិវារចោមរោមច្រើន ។

៦.បត្តិទាន ការចែករំលែកនូវបុណ្យយកុសល ដែលបានបំពេញហើយ ឲ្យទទួលបាននូវការកាត់បន្ថយជាតិកំណើត នៅក្នុងសង្សារវដ្តនេះឲ្យតិចចុះ ។

៧.បត្តានុមោទនា ការត្រេកអរនឹងបុណ្យកុសលដែលគេ បានចែករំលែកឲ្យ នាំមកនូវកុសលដល់បុគ្គលឲ្យបានទៅកើតគ្រប់ទីកន្លែង ។

៨.ធម្មស្សវនៈ ការស្តាប់ធម៌ដោយគោរពនាំមកនូវបញ្ញា

៩.ធម្មទេសនា ការសម្តែងធម៌ឲ្យគេស្តាប់ដោយគោរព នាំឲ្យកើតបញ្ញា ។

១០.ទិដ្ឋុជុកម្ម ការធ្វើការយល់ឃើញ (ទិដ្ឋិ) ឲ្យបានត្រឹមត្រូវល្អ នាំឲ្យមានកម្លាំងខ្លាំងដល់ជំនឿ(សទ្ធា) របស់បុគ្គល ។

កុសលកម្មទាំង១០យ៉ាងនេះ ជួនកាលត្រូវបានបន្ថែម២យ៉ាងទៀតទៅជា១២យ៉ាង ។ ឯកុសលកម្ម២យ៉ាងនោះ មាន (១)-ការពោលសរសើរនូវអំពើល្អរបស់បុគ្គលដទៃ (បសំសា) នាំមកនូវការរីករាយក្នុងចិត្ត ចំពោះកុសលរបស់បុគ្គលដទៃ, និង(២)-ការយកព្រះរតនត្រ័យជាទីពឹងទីរលឹក (អនុស្សតិ) ដែលធ្វើទិដ្ឋិរបស់ខ្លួនឲ្យត្រឹមត្រូវល្អ ។

ការពោលសរសើរនូវអំពើល្អរបស់អ្នកដទៃ ហុចផលមកឲ្យវិញ គឺបុគ្គលនោះត្រូវបានគេពោលសរសើរវិញ ។ ចំណែកការយកព្រះរតនត្រ័យជាទីពឹងទីរលឹក នាំមកឲ្យបុគ្គលនូវការបំផ្លាញចោលតណ្ហាទាំងអស់ ។ សម្មាសតិនាំឲ្យបុគ្គលបាននូវសេចក្តីសុខគ្រប់ប្រការ ។ រូបជ្ឈានប្រាំនិងអរូបជ្ឈានបួន ក៏ត្រូវបានចាត់ទុកជាកុសលកម្មដែរ ដែលនាំឲ្យបានទៅកើតក្នុងរូបភពនិងអរូបភព។

## អកុសលកម្ម

កម្មជាអកុសល ឬអំពើអាក្រក់មាន១០យ៉ាង ដែលចេញមកពីទង្វើរបស់កាយ វាចា និងចិត្ត ។

អំពើអាក្រក់ដោយកាយមាន ៣ យ៉ាងគឺ:

១-បាណាតិបាតា ការសម្លាប់ ឬបៀតបៀនជីវិត

២-អទិន្នាទានា ការលួចប្លន់ទ្រព្យជាកម្មសិទ្ធិរបស់អ្នកដទៃ

៣-កាមេសុមិច្ឆាចារៈ ការប្រព្រឹត្តខុសលើកូនប្រពន្ធរបស់អ្នកដទៃ

អំពើអាក្រក់ដោយវាចាមាន ៤ យ៉ាង

១-មុសាវាទា ការពោលពាក្យកុហកឬពាក្យមិនពិត

២-បិសុណាវាទ ការពោលពាក្យបង្ខូចបង្កាច់

៣-ផរុសាវាទ ការពោលពាក្យអាក្រក់មានជេរប្រទេច

៤-សម្ផប្បលាបៈ ការពោលពាក្យរោយរាយឥតប្រយោជន៍

អំពើអាក្រក់ដោយចិត្តមាន ៣ យ៉ាង

១-អភិជ្ឈា ការរំពៃទ្រព្យរបស់អ្នកដទៃ

២-ព្យាបាទ ការចងគំនុំគំគួន អាឃាតព្យាបាទអ្នកដទៃ

៣-មិច្ឆាទិដ្ឋិ     ការយល់ឃើញខុស ។

ការសម្លាប់ មានន័យថាការបំផ្លាញជីវិតរស់នៅរបស់មនុស្សសត្វ ... នៅក្នុងពាក្យបាលី បាណៈ មានន័យថា ជីវិតប្រកបដោយកាយនិងចិត្ត ដែលទាក់ទងដល់អត្ថិភាវៈ (ជីវិត=Existence) ដោយឡែករបស់បុគ្គល ។ សត្វតូចធំក៏ត្រូវបានរាប់ចូលទៅក្នុងសត្វមានជីវិតដែរ ប៉ុន្តែដើមឈើមិនបានរាប់បញ្ចូលទេ ។

អកុសលកម្មនីមួយៗ ត្រូវវិនិច្ឆ័យទៅតាមអង្គដែលមាន បើព្រមដោយអង្គទាំងអស់ហើយ ឈ្មោះថាបានធ្វើអាក្រក់ពេញទី ។

ក-បាណាតិបាតា ការសម្លាប់មានអង្គ ៥ គឺៈ

១-បាណោ     សត្វមានជីវិត

២-បាណសញ្ញិតា     ការដឹងថាជាសត្វមានជីវិត

៣-វធកចិត្តំ     គិតនឹងសម្លាប់

៤-ឧបក្កមោ     ព្យាយាមនឹងសម្លាប់

៥-តេន មរណំ     បានស្លាប់ដោយការព្យាយាម ។

ផលនៃអំពើអាក្រក់ ដែលកើតចេញពីការសម្លាប់ ធ្វើឲ្យបុគ្គលមានអាយុខ្លីមានជម្ងឺច្រើន មានសេចក្ដីទុក្ខក្រៀមក្រំ ដែលបណ្ដាលមក ពីការបំបែកបំបាក់បុគ្គលជាទីស្រឡាញ់របស់គេ និងធ្វើឲ្យបុគ្គលនោះជួបប្រទះនូវការភ័យតក់ស្លុតជាញឹកញាប់ ។

ខ-អទិន្នាទានា ការលួចទ្រព្យសម្បត្តិគេមានអង្គ ៥ គឺៈ

១-បរបរិគ្គហិតំ ទ្រព្យដែលម្ចាស់គេហួងហែងរក្សា

២-បរបរិគ្គហិតសញ្ញិតា សេចក្តីដឹងថាទ្រព្យមានម្ចាស់ហួង ហែងរក្សា

៣-ថេយ្យចិត្តំ គិតនឹងលួច

៤-ឧបក្កមោ ព្យាយាមនឹងលួច

៥-តេន ហរណំ លួចបានមកដោយព្យាយាមនោះ

ផលនៃការលួច ធ្វើឲ្យបុគ្គលអ្នកប្រព្រឹត្តជួបប្រទះភាពក្រខ្សត់, ទទួលរងជីវភាពទីទ័លក្រមិនមានទីបំផុត, មិនអាចសម្រេចអ្វីបានតាមបំណងប្រាថ្នា ត្រូវពឹងអាស្រ័យគេដើម្បីរស់រាន ជីវិតបាន ។

គ-កាមេសុមិច្ឆាចារ ការប្រព្រឹត្តខុសផ្លូវកាមមានអង្គ៤ គឺៈ

១-អគមនីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រីដែមានគេហួងហែងរក្សា ។

២-តស្មិំ សេវនចិត្តំ គំនិតគិតសេពនូវមេថុនធម្មនឹងស្ត្រីនោះ

៣-ឧបក្កមោ ព្យាយាមនឹងសេពមេថុនធម្មនោះ

៤-មគ្គេន មគ្គប្បដិបាទនំ ញ៉ាំងមគ្គនិងមគ្គឲ្យដល់គ្នា ។

ផលនៃការប្រព្រឹត្តខុសក្នុងកាមគឺ មានសត្រូវច្រើន, មានភរិយាមិនសមតាមបំណងប្រាថ្នា, កើតជាមនុស្សស្រី ឬជាមនុស្សខ្ទើយ ។

ឃ-មុសាវាទា ការពោលពាក្យកុហក មានអង្គ៤គឺ:

១-អកថំ វត្ថុ　　　វត្ថុមិនពិត

២-វិសំវាទនចិត្តំ　　　គិតនឹងពោលឲ្យខុស

៣-តជ្ជោ វាយាមោ　　　ព្យាយាមនឹងពោលឲ្យខុស

៤-បរស្ស តទត្ថវិជាននំ ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្តីនោះ ។

ផលនៃការពោលពាក្យមិនពិត មានសត្រូវធ្វើទុក្ខបុកម្នេញដោយសម្តី ដែលប្រមាថមើលងាយ, ជាកម្មវត្ថុនៃការពោលពាក្យមួលបង្កាច់, ភាពមិនគួរឲ្យជឿ និងមាត់មានក្លិនស្អុយអាក្រក់ ។

ង-បិសុណាវាទ ការពោលពាក្យញុះញង់បំបែកបំបាក់ មានអង្គ ៤

១-ភិន្ទិតព្វោ បរោ　　　អ្នកដទៃមានរូបគឺខ្លួនគប្បីញុះញង់បំបែក

២-ភេទនបុរេក្ខារតា　　　គិតនឹងញុះញង់បំបែកអ្នកដទៃនោះ

៣-តជ្ជោ វាយាមោ　　　ព្យាយាមញុះញង់បំបែកអ្នកដទៃ

៤-តស្ស តទត្ថវិជាននំ　　　ញ៉ាំងអ្នកនោះឲ្យដឹងច្បាស់នូវដំណើរ ដែលខ្លួនញុះញង់បំបែកនោះ ។

ផលអាក្រក់នៃការពោលពាក្យញុះញង់ បំបែកបំបាក់ មានការបែកបាក់មិត្តភ័ក្ត្រ ដោយគ្មានមូលហេតុគ្រប់គ្រាន់ ។

ច-ផរុសវាចា ការពោលពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរ ប្រទេចអ្នកដទៃ មានអង្គ ៣ គឺ:

១-អក្កោសិតព្វោ បរោ អ្នកដទៃដែលមានរូបគឺខ្លួនគប្បី ជេរប្រទេច

២-កុប្បិចិត្តំ ចិត្តខឹងរន្ធត់

៣-អក្កោសនា បានជេរប្រទេចគេ

ផលនៃការពោលពាក្យអាក្រក់និងជេរប្រទេច ត្រូវបានអ្នកដទៃស្អប់ខ្ពើម ទោះបីមិនគួរឲ្យស្តីបន្ទោសក៏ដោយ និងធ្វើឲ្យមានសម្លេងអាក្រក់ ។

ឆ-សម្ផប្បលាបៈ ការពោលពាក្យរោយរាយឥតប្រយោជន៍ មានអង្គ ២ គឺ:

១-ភារតយុទ្ធសិតាហរណាទិនិរត្ថកថា ពាក្យឥតប្រយោជន៍ មានរឿងចម្បាំងនៃមហាភារតៈ និងរឿងរាពណ៍លួចនាំនាងសិតាយកទៅជាដើម ។

២-តថារូបីកថាកថនំ បានពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នោះ ។

ផលនៃការពោលពាក្យរោយរាយឥតប្រយោជន៍ មានសារីរាង្គកាយមិនពេញលក្ខណៈ និងសម្តីមិនគួរឲ្យគេជឿ ។

ជ-អភិជ្ឈា ចិត្តសម្លឹងរំពៃទ្រព្យរបស់អ្នកដទៃ ដោយគិតបម្រុងឲ្យបានមក ជាទ្រព្យរបស់ខ្លួនមានអង្គ ២ គឺ:

១-បរភណ្ឌំ ទ្រព្យជារបស់អ្នកដទៃ

២-អត្តនោ បរិណាមនំ គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះឲ្យបានមកជារបស់ខ្លួន ដោយកលឧបាយផ្សេងៗ ។

ផលនៃគំនិតប្រកបដោយអភិជ្ឈា គឺការចង់បាន (លោភ:) មិនបានសម្រេចតាមសេចក្តីប្រាថ្នារបស់បុគ្គលឡើយ ។

ឈ-ព្យាបាទោ ចិត្តចងគំនុំគុំគួនគិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាស មានអង្គ ២ គឺ:

១-បរសត្តោ អ្នកដទៃក្រៅពីខ្លួន

២-តស្ស តំ តំ វិនាសចិន្តា គិតគុំគួនប្រុងនឹងឲ្យអ្នកនោះ ដល់នូវសេចក្តីវិនាសដោយហេតុនោះៗ ។

ផលនៃគំនិតព្យាបាទនោះ មានភាពគួរឲ្យស្អប់ខ្ពើម, មានរោគច្រើននិងគួរធុញទ្រាន់ ។

ញ-មិច្ឆាទិដ្ឋិ គំនិតយល់ខុស ហើយប្រកាន់ឡើងថាជាត្រូវមាន អង្គ ២ គឺ:

១-វត្ថុនោ ច គហិតាការវិបរិតតា ចិត្តប្រែប្រួលដោយអាការ:ខុសអំពីព្រះរតនត្រ័យជាដើម ។

២. យថា ច នំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណាក៏ប្រកាន់សេចក្ដីខុសនោះថាជាត្រូវវិញ ។

ផលនៃការយល់ឃើញខុស ធ្វើឲ្យមានឧបាទានកាន់តែមាំ, ខ្វះខាតខាងបញ្ញា, មានភាពល្ងង់ខ្លៅ, មានរោគរុំរ៉ៃ និងគំនិតគួរឲ្យស្ដីបន្ទោស ។

## មូលហេតុនៃកម្ម

មិនទាន់បានដឹងរឿងពិត ពីមូលហេតុដែលធ្វើឲ្យបុគ្គលបង្កើតឡើងនូវកម្មនោះទេ ។ មិនមែនកម្មដែលត្រូវប្រមូលបានមកដោយសារ តែបុគ្គលដែលបានបំផ្លាញតណ្ហាចោលអស់ហើយនោះទេ, តែអវិជ្ជានិងតណ្ហា ជាមូលហេតុធំបំផុតរបស់កម្ម ។

## នរណាកសាងកម្ម

នរណាជាអ្នកកសាងកម្ម ? នរណាជាអ្នកទទួលផលនៃកម្ម ? ព្រះអដ្ឋកថាចារ្យពុទ្ធឃោសា បាននិយាយនៅក្នុងគម្ពីរវិសុទ្ធិមគ្គថា “បើគ្មានអ្នកធ្វើកម្ម ក៏គ្មានអ្នកទទួលរងកម្មដែរ” ។ នៅក្នុងន័យខ្ពស់មួយទៀត ពុទ្ធសាសនិកម្នាក់មិនអាចបង្កើតអង្គធាតុ ដើម្បីផ្លាស់ប្ដូររបស់ណាមួយបានទេ, ទោះបីសត្វលោកមានរូបជាទេវតា ជាមនុស្ស ឬក៏ជាសត្វក៏ដោយ ។ រូបដែលមានមកនេះ គ្រាន់តែជាការសម្ដែងចេញបណ្ដោះអាសន្ន ពីកម្លាំងរបស់កម្មតែប៉ុណ្ណោះ ។ ពាក្យថា “សត្វលោក” ប្រើក្នុងគោលបំណងសន្មត

ប៉ុណ្ណោះ, ដែលយើងហៅថា "សត្វលោក" ព្រោះត្រូវផ្សំឡើងដោយនាមនិងរូប ។

ពុទ្ធសាសនិកជឿជាក់ថា មិនមែនតួអង្គណាមួយដោយឡែកពី(កម្ម)ឡើយ, មិនមែនអ្នកដឹងដោយឡែកពីសញ្ញាក្ខន្ធឡើយ, មិនមែនអារម្មណ៍ដែលដឹងស្ថិតនៅពីក្រោយវិញ្ញាណឡើយ ។ ឆន្ទៈ និង ចេតនា ជាអ្នកធ្វើនូវកម្មដោយខ្លួនឯង, ជាផ្នែកមួយកើតចេញពីភាវៈនៃចិត្តទាំងនេះ, បើគ្មានពូជសាបព្រួសទេ ក៏គ្មានផលសម្រាប់ទទួលដែរ ។

## កម្មស្ថិតនៅទីណា?

ស្តេចមិលិន្ទបានទូលសួរព្រះនាគសេនថា:

"បពិត្រលោកម្ចាស់ ! តើកម្មនោះស្ថិតនៅត្រង់ទីណាទៅ ?" ព្រះនាគសេនឆ្លើយថា "បពិត្រមហារាជ ! កម្មមិនត្រូវបានរក្សាទុកនៅក្នុងទីណាទេ គឺនៅក្នុងវិញ្ញាណ ឬក៏នៅក្នុងផ្នែកដទៃទៀតនៃរូបកាយនេះឯង ។ ប៉ុន្តែវាអាស្រ័យទៅលើចិត្តនិងរូប (នាមរូប), កម្មសម្រាកនៅក្នុងទីនោះហើយកម្មក៏បង្ហាញខ្លួនវានៅក្នុងខណៈដែលមានឱកាស, ប្រៀបដូចជាផ្លែស្វាយមិនអាចនិយាយថាស្ថិតក្នុងទីណាទេ គឺនៅនឹងដើមស្វាយនោះឯងហើយវានឹងចេញផ្លែមក នៅក្នុងរដូវដែលសមស្រប" ។ ដូចជាខ្យល់និងភ្លើង មិនអាចតាំងនៅក្នុងកន្លែងពិសេសណាមួយឡើយ, ដូចគ្នានឹងកម្មដែរ

មិនអាចស្ថិតនៅក្នុងទីណាមួយ ឬទីដែលគ្មានរូបកាយឡើយ ។ កម្មជាកម្លាំងដែលប្តូរពីជីវិតមួយទៅកាន់ជីវិតមួយទៀតបាន ។

## ការចាត់កម្មជាថ្នាក់

មានកម្មជាកុសលនិងកម្មជាអកុសល បានផលិតនូវផលដ៏សមស្រប សម្រាប់ជីវិតនេះនិងរាល់ៗជីវិត ។ កម្មទាំងនេះហៅថា "ទិដ្ឋធម្មវេទនីយកម្ម" ជាកម្មដែលឲ្យផលនៅក្នុងបច្ចុប្បន្ន មើលឃើញនឹងភ្នែកភ្លាមៗ ។ ប្រសិនបើកម្មណាមិនបានហុចផល ឲ្យនៅក្នុងបច្ចុប្បន្នភ្លាមៗ, កម្មនោះនឹងទៅជាអហោសិកម្ម ជាកម្មមិនបានឲ្យផល ។ មានកម្មខ្លះទៀតបានឲ្យផលនៅក្នុងជីវិតបន្ទាប់, កម្មនោះឲ្យឈ្មោះថា "ឧបបជ្ជវេទនីយកម្ម" ជាកម្មឲ្យផលក្នុងជីវិតបន្ទាប់, កម្មនេះក៏មិនបានឲ្យផលទេ ប្រសិនបើវាគ្មានឱកាសនៅក្នុងជីវិតបន្ទាប់នោះឯង ។ ចំពោះកម្មដែលបានឲ្យផលនៅក្នុងជាតិណាមួយ នៅក្នុងពេលដែលសត្វកំពុងត្រាច់រង្គាត់ ក្នុងវាលវដ្តសង្សារ, កម្មនោះឲ្យឈ្មោះថា "អបរាបរិយវេទនីយកម្ម" កម្មឲ្យផលគ្មានកំណត់ ។

ការចាត់កម្មជាថ្នាក់ៗនេះ យោងសំដៅទៅលើពេលវេលា ដែលផលបានផ្តល់ចេញឲ្យមក ។

## កម្មចែកជា ៤ ថ្នាក់តាមមុខងារ (កិច្ចកម្ម)

រាល់ជាតិកំណើតដែលបានកើតមក ត្រូវអាស្រ័យលើការតាក់តែងឡើង ដោយកុសលកម្ម (កម្មល្អ) និងអកុសលកម្ម (កម្មមិនល្អ) ដែលមានចំនួនលើសលុប នៅក្នុងខណៈដែលសេចក្តីស្លាប់ចូលមកដល់ ។ កម្មដែលបានតាក់តែងជាតិកំណើតក្នុងអនាគត ហៅថា "ជនកកម្ម" កម្មឲ្យកំណើត ។

កម្មមួយបែបទៀត ដែលជួយឧបត្ថម្ភ ឬជួយថែរក្សាដល់កម្មដែលឲ្យកំណើត (ជនកកម្ម) នៅពេលដែលកម្មនេះមាននិន្នាការលំអៀង ដើម្បីពង្រឹងជនកកម្ម និងកម្មដទៃទៀតដែលទេរទៅរកកម្មដែលខ្សោយ ហើយជ្រៀតជ្រែកកម្មដែលកំពុងឲ្យផល រួចផ្តល់ផលឲ្យកម្មដែលកំពុងឲ្យកំណើតជាជំហានៗ, កម្មនោះមានឈ្មោះថា "ឧបត្ថម្ភកកម្ម" កម្មដែលជួយជ្រោមជ្រែង ដល់កម្មដែលកំពុងឲ្យផល និង "ឧបច្ឆេទកកម្ម" កម្មដែលចូលទៅជំទាស់ឬរាំងកម្មដែលកំពុងឲ្យផល ។

តាមរយៈច្បាប់កម្ម, កម្លាំងជាសក្តានុពលនៃកម្ម ដែលបានឲ្យកំណើត (ជនកកម្ម) អាចត្រូវបានចូលទៅលុបចោល ដោយឧបច្ឆេទកកម្ម (កម្មប្រឆាំង) ពីអតីតកាលដែលមានកម្លាំងខ្លាំងក្លាជាង ហើយកំពុងតែស្វែងរកឱកាស ដើម្បីឲ្យផលដោយមិននឹកស្មានទុកជាមុន, ជាកម្លាំងប្រឆាំងដ៏មានអំណាច ដែលអាចបញ្ឈប់ផ្លូវហោះហើរដ៏ចង្អៀត ហើយ

នាំចុះមកដីវិញ ឈ្មោះហៅថា “ឧបឃាតកកម្ម” ជាកម្មសម្លាប់កម្មចាស់កំពុងឲ្យផល ។ កម្មនេះមានកម្លាំងខ្លាំងជាងឧបត្ថម្ភកកម្ម និងឧបច្ឆេទកកម្មទៅទៀត, កម្មនេះមិនគ្រាន់តែជាឧបសគ្គរាំងស្ទះប៉ុណ្ណោះទេ ប៉ុន្តែបានបំផ្លាញកម្លាំងកម្មចាស់ទាំងអស់តែម្តង ។

## កម្មចែកជា ៤ ថ្នាក់ផ្សេងទៀត

ទីមួយហៅថា គរុកម្ម មានន័យថា កម្មធ្ងន់ ។ កម្មនេះត្រូវរាប់យកទាំងកម្មល្អទាំងកម្មអាក្រក់ ដែលឲ្យផលនៅក្នុងជាតិបច្ចុប្បន្ននេះ ឬទៅក្នុងជាតិបន្ទាប់ដោយពិតប្រាកដ ។ ប្រសិនបើជាកម្មល្អ បានដល់ចិត្តបរិសុទ្ធដូចជាឈានជាដើម ។

**គរុកម្ម (កម្មធ្ងន់) មាន៥យ៉ាងគឺ:**

១-មាតុឃាត ការសម្លាប់មាតា

២-បិតុឃាត ការសម្លាប់បិតា

៣-អរហន្តឃាត ការសម្លាប់ព្រះអរហន្ត

៤-លោហិតុប្បាទ ការញុំាងព្រះលោហិតរបស់ព្រះពុទ្ធឲ្យធ្លាក់ចុះ

៥-សង្ឃភេទ ការបំបែកសង្ឃ

និយតមិច្ឆាទិដ្ឋិ (ការយល់ខុសថាអ្វីៗទាំងអស់ក្នុងលោកនេះសុទ្ធតែទៀង) ត្រូវបានចាត់ទុកថាជាកម្មធ្ងន់ផងដែរ ។

អវត្តមានរបស់គរុកកម្ម ក្នុងការតាក់តែងកំណើតទៅក្នុងជាតិបន្ទាប់, កម្មនៅពេលទៀបស្លាប់ហៅថា "អាសន្នកម្ម" អាចដើរតួឲ្យផលជាកម្មដែលបុគ្គលបានធ្វើភ្លាមៗ នៅមុនខណៈសេចក្តីស្លាប់ចូលមកដល់ ។

អាចិណ្ណកម្ម ជាកម្មធម្មតាដដែលៗ គឺឲ្យផលជាបន្ទាប់បន្សំ, ជាកម្មដែលបុគ្គលធ្វើដដែលៗ និងប្រមូលផ្តុំឡើងវិញម្តងហើយម្តងទៀត និងធ្វើឲ្យបុគ្គលមានការចូលចិត្តខ្លាំង ។

កម្មទីបួនមានឈ្មោះថា "កដត្តាកម្ម" ជាកម្មដែលប្រមូលរួបរួមក្រសោបយកកម្មទាំងអស់ ដែលមិនត្រូវបានរាប់បញ្ចូលទៅក្នុងកម្មទាំងបីខាងលើទេ ។ កម្មនេះប្រដូចទៅនឹងដើមទុនដែលបានរក្សាទុក សម្រាប់ជីវិតពិសេសមួយ ។

## ការចាត់ថ្នាក់តាមទីកន្លែងដែលកម្មឲ្យផល មានឈ្មោះដូចខាងក្រោម:

១-អកុសលកម្ម កម្មអាក្រក់ឲ្យផលនៅក្នុងកាមលោក

២-កុសលកម្ម កម្មល្អឲ្យផលនៅក្នុងកាមលោក

៣-កុសលកម្ម កម្មល្អឲ្យផលនៅក្នុងរូបលោក

៤-កុសលកម្ម កម្មល្អឲ្យផលនៅក្នុងអរូបលោក

## តើអ្វីៗទាំងអស់សុទ្ធតែជាកម្មឬ?

ទោះបីព្រះពុទ្ធសាសនាបានអះអាងថា មនុស្សលោកមានភាពមិនស្មើគ្នាចំពោះកម្មក៏ដោយ ក៏ជាមូលហេតុចម្បងចំណោមភាពខុសៗគ្នាដែរ ហើយមិនបានបញ្ជាក់ថាអ្វីៗទាំងអស់ គឺជាកម្មនោះទេ ។ ប្រសិនបើអ្វីៗទាំងអស់ជាកម្ម បុគ្គលគួរតែអាក្រក់គ្រប់ពេល ហើយបុគ្គលមិនត្រូវការពិគ្រោះជាមួយគ្រូពេទ្យ ដើម្បីព្យាបាលជម្ងឺទេ ។

តាមទស្សនៈព្រះពុទ្ធសាសនា មានដំណើរការ ៥ យ៉ាង ហៅថានិយាម ដែលចាត់រូបធម៌និងនាមធម៌ (រូបនិងចិត្ត) ។

១-ឧតុនិយាម របៀបដែលគ្មានសរីរាង្គ, ឧទាហរណ៍បាតុ ភូតនៃរដូវកាលមានខ្យល់និងភ្លៀង, ភាពទៀងទាត់នៃរដូវកាល, ការផ្លាស់ប្តូរ និងព្រឹត្តិការណ៍នៃឧតុលក្ខណៈ, មូលហេតុនៃខ្យល់និងភ្លៀង, ធម្មជាតិនៃកំដៅ ។ល។

២-ពីជនិយាម របៀបមិនមែនជាសរីរាង្គកាយ, របៀបនៃជីវាណូនិងពូជ, ឧទាហរណ៍ស្រូវចេញមកពីស្រូវពូជ, រសជាតិស្ករចេញមកពីអំពៅស្ករ ឬទឹកឃ្មុំ, លក្ខណៈពិសេសនៃផលដោយពិត ។ល។ ទ្រឹស្តីវិទ្យា

សាស្ត្រនៃកោសិកានិងកំណើត ហើយនិងភាពដូចគ្នានឹងរូបកាយភ្លោះ អាចត្រូវបានសំអាងលើហេតុផលនៃរបៀបនេះ ។

៣-កម្មនិយាម របៀបនៃកម្មនិងផល, ឧទាហរណ៍អំពើសម្រេចតាមបំណង និងអំពើមិនសម្រេចតាមបំណង ដែលស្របគ្នាទៅនឹងផលល្អ និងផលអាក្រក់ ។ ដូចជាទឹកស្វែងរកឃើញនៅក្នុងផ្ទៃទឹកផ្ទាល់, កម្មក៏ដូច្នោះដែរបានស្វែងរកឱកាស ផ្តល់ផល មិនអាចជៀសផុតឡើយ ។ មិនមាននៅក្នុងទម្រង់ជារង្វាន់ ឬទណ្ឌកម្មទេ, ប៉ុន្តែជាការតៗគ្នាតាមធម្មជាតិ ។ ការតៗគ្នានៃកម្មនិងផល គឺជាធម្មជាតិនិងជាភាពពិសេស ដូចជាផ្លូវនៃព្រះអាទិត្យ និងព្រះចន្ទ្រ ។

៤.ធម្មនិយាម របៀបនៃបទដ្ឋាន ឧទាហរណ៍បាតុភូតនៃធម្មជាតិបានកើតឡើងនៅពេលមកដល់នៃព្រះពោធិសត្វ នៅក្នុងកំណើតចុងក្រោយរបស់ព្រះអង្គ ។ កម្លាំងស្របទាញ និងច្បាប់ដូចគ្នាដទៃៗទៀតរបស់ធម្មជាតិ, រដ្ឋរសម្រាប់ការធ្វើឲ្យល្អនិងទៅមុខទៀត អាចត្រូវបានរាប់បញ្ចូលនៅក្នុងក្រុមនេះ ។

៥.ចិត្តនិយាម របៀបនៃចិត្ត ឬក៏មានភ្នែកនិងត្រចៀកទិព្វ, ឧទាហរណ៍ដំណើរការនៃវិញ្ញាណ, ការកើតឡើងនិងការរលត់ទៅនៃវិញ្ញាណ, ភាពសំខាន់នៃវិញ្ញាណ, អំណាចនៃចិត្ត ។ល។ ទូរចិត្ត, ការដឹងពីបុព្វនិមិត្ត, ប្រាជ្ញាញាណ, ការមើលពីគំនិត, បាតុភូតខាងចេតសិកទាំងអស់

មិនអាចពន្យល់បានដោយវិទ្យាសាស្ត្រទំនើប  ដែលត្រូវបានរាប់បញ្ចូលនៅក្នុងថ្នាក់នេះផង ។

រាល់ៗបាតុភូតរបស់រូប  ឬចិត្ត  អាចត្រូវបានពន្យល់ដោយរបៀបទាំង៥យ៉ាង ដែលបានបញ្ជាក់មកខាងលើ ឬដំណើរការជាច្បាប់នៅក្នុងខ្លួនគេផ្ទាល់ ។

# ១២ ការកើតឡើងវិញ

ចំណុចសំខាន់ គឺកម្មបានដឹកនាំនិងឈានទៅរកការកើតឡើងវិញ ។ កម្មអតីតៈជាហេតុបច្ច័យ នាំឱ្យមានកំណើតបច្ចុប្បន្ន, ហើយកម្មបច្ចុប្បន្នលាយបញ្ចូលជាមួយកម្មអតីតៈផង ដឹកនាំឱ្យមានអនាគត ។ បច្ចុប្បន្នជាកូនចៅរបស់អតីតៈ ហើយបានបន្តវេនរបស់វាទៅអនាគតទៀត ។ អតីតៈជាមូលដ្ឋានគ្រឹះនៃសតិ ហើយអនាគត គឺជាការគិតទុកជាមុន ។

## ហេតុផលទៅរកជំនឿក្នុងអតីតជាតិ

អំណាចធំបំផុតនៃការកើតឡើងវិញគឺព្រះពុទ្ធ ។ ព្រះអង្គមានតម្រាស់ថា:

"ឈរលើទស្សនៈប្រកបដោយប្រាជ្ញាញាណ, ភាពបរិសុទ្ធនិងភាពខ្ពស់ខុសពីធម្មតា, តថាគតបានដឹងដោយវិញ្ញាណ ដែលសត្វលោកបាត់បង់ពីភាពមួយនៃអត្ថិភាវៈ និងប្រាកដឡើងនៅក្នុងទីដទៃមួយទៀត ។ តថាគតបានមើលឃើញ ចំណែកទាបនិងចំណែកខ្ពស់ ល្អនិងមិនល្អ សេចក្តីសុខនិងទុក្ខលំបាក ឆ្លងទៅតាមរយៈអំពើដែលគេបានធ្វើ" ។

គ្មានហេតុផលណាមួយ ដែលព្រះពុទ្ធប្រាប់នូវរឿងមិនពិតនោះ ដើម្បីបោកបញ្ឆោតសាវ័ករបស់ព្រះអង្គឡើយ ។ ខាងក្រោមនេះ ជាការបង្រៀនរបស់ព្រះពុទ្ធអង្គដល់សាវ័ក ដែលបានអភិវឌ្ឍនូវចំណេះដឹង ពីបុព្វេនិវាសានុស្សតិញាណ (Retrocognitive Knowledge) ហើយអាចមើលឃើញនូវអតីតជាតិដ៏វែងឆ្ងាយ របស់គេដោយខ្លួនគេផ្ទាល់ ។ ការអភិវឌ្ឍន៍នៃទស្សនៈដែលខ្ពស់ជាងធម្មតានេះ មិនត្រូវបានកំណត់ចំពោះតែព្រះពុទ្ធ ឬព្រះសាវ័ករបស់ព្រះអង្គឡើយ ។ បុគ្គលណាមួយ ទោះជាពុទ្ធសាសនិក និងមិនមែនជាពុទ្ធសាសនិក ក៏អាចមានលទ្ធភាពក្នុងផ្នែកនេះដែរ ។ ពួកឥសីជាតិឥណ្ឌាខ្លះ សូម្បីនៅមុនការបានត្រាស់ដឹង របស់ព្រះពុទ្ធក្តី ក៏បានសម្រេចនូវអំណាចពិសេសមានទិព្វសោតៈ (Clairaudience) ជាដើម, ប្រាជ្ញាញាណ (Clairvoyance) ការឃើញគំនិត(របស់អ្នកដទៃ) (Thought reading) និងអ្វីៗជាច្រើនទៀត ។

តាមរយៈព្រះធម៌ មានបុគ្គលខ្លះៗបានកើតឡើងដោយឯកឯង (សយម្ភូ) នូវការរលឹកឃើញពីអតីតជាតិរបស់គេ និងបាននឹកឃើញនូវផ្នែកខ្លះ នៃជាតិកំណើតពីមុនៗមករបស់គេផងដែរ ។ ករណីដែលបានបញ្ជាក់ខ្លះៗនេះ បានកើតឡើងនៅប្រទេសខ្មែរយើង ភូមា ឥណ្ឌា អាល្លឺម៉ង់ អង់គ្លេស ។ល។

ការពិសោធន៍ខុសពីធម្មតា របស់អ្នកចិត្តសាស្ត្រដែលអាចទុកចិត្តបាននាសម័យទំនើបនេះ និងករណីចម្លែកនៃបុគ្គលភាពដែលផ្លាស់ប្តូរ និងច្រើនសន្ទឹកសន្ធាប់ ដែលងាកទៅរកការឆ្លងកាត់ពន្លឺមួយ អាស្រ័យលើជំនឿក្នុងការកើតឡើងវិញ ។

បាតុភូតនៃបុគ្គលភាពទីពីរដែលមាន ត្រូវបានពន្យល់ដូចជាអ្វីៗដែលនៅសល់ ពីការឆ្លងកាត់របស់សត្វលោកនីមួយៗ នៅក្នុងអតីតជាតិ ឬជា "ជីវិតដែលមាន" ។ ការពន្យល់ពីមុនបានជាសម្តែង ដែលអាចមានហេតុផលបន្ថែម, ប៉ុន្តែក្រោយមក មិនអាចត្រូវបានលះបង់ចោលទាំងស្រុងទេ ។

នៅក្នុងភារៈទាំងឡាយដែលសម្រាប់សណ្តំ ខ្លះក៏អាចទាក់ទងដល់បទពិសោធ នៃអតីតជាតិរបស់គេដែរ, ក្នុងខណៈដែលអ្នកដទៃទៀតមានតិចតួច ដូចជាអេដហ្គាកាសីរបស់អាមេរិក (Edgar Casey of America) មានសមត្ថភាពមិនគ្រាន់តែមើលឃើញ ពីអតីតជាតិរបស់បុគ្គលដទៃតែប៉ុណ្ណោះទេ ប៉ុន្តែអាចធ្វើជម្ងឺអ្នកដទៃជាសះស្បើយបាន ។

ជួនកាលយើងក៏ធ្លាប់ឆ្លងកាត់បទពិសោធប្លែកៗ ដែលមិនអាចពន្យល់បាន ប៉ុន្តែតាមរយៈការកើតឡើងវិញ ។

ជារឿយៗ យើងបានជួបពួកមនុស្ស ដែលយើងមិនដែលបានជួបពីមុនមក ហើយមានអារម្មណ៍ខាងក្នុងគិតថាតើពួកគេ អាចស្និទ្ធស្នាលចំពោះយើងយ៉ាងម៉េចទៅ ? ជារឿយៗតើយើងបានទស្សនាកន្លែងថ្មីៗ ហើយចាប់អារម្មណ៍ថា តើយើងត្រូវស្គាល់ច្បាស់នូវអ្វីខ្លះ ដែលនៅជុំវិញពួកគេ ?

នៅក្នុងពិភពលោកនេះ មានមហាបុរសដ៏អស្ចារ្យដូចជាព្រះពុទ្ធបានកើតឡើង ហើយបានធ្វើការអភិវឌ្ឍយ៉ាងខ្ពស់នូវបុគ្គលិកលក្ខណៈ ។ តើពួកគេអាចវិវត្តឡើងយ៉ាងឆាប់រហ័សទេ ? តើពួកគេអាចទៅជាផលនៃអត្ថិភាវៈទោលឬទេ ?

តើយើងអាចធ្វើការរៀបរាប់ ចំពោះនិស្ស័យដ៏ធំមហិមា ដូចជាខុងជឺ, ប៉ាមិនិ, ហូមឺ និង ផ្លាតូ, មនុស្សដែលមានទេពកោសល្យដូចជាកាឡីទាសៈ, សែកកេស្ពៀ, កុមារដ៏មហាអស្ចារ្យដូចជា រាមានុជន, ប៉ាស្កាល, មូសាតវ៍, ប៊ីថូវែន, រាផែល, និងអ្នកដទៃៗទៀត និងពួកកុមារតូចៗដែលធ្លាប់ចេះភាសាខុសៗគ្នា និងប្រធានបទដែលមិនបានសិក្សា នៅក្នុងជីវិតបច្ចុប្បន្នរបស់គេទេឬ? ។

សិទ្ធិទទួលមត៌កតែម្យ៉ាង មិនអាចរៀបរាប់សម្រាប់ពួកគេទេ, ម្យ៉ាងវិញទៀត បុព្វបុរសរបស់គេគួរតែបើកបង្ហាញរឿងនោះចេញ ដល់

មនុស្សជំនាន់ក្រោយរបស់ពួកគេ ឲ្យបានធំជាងខ្លួនគេផ្ទាល់ ហើយបានបង្ហាញវាចេញមក ។

តើគេអាចឡើងឲ្យបានខ្ពស់ត្រដែតបានទេ ប្រសិនបើពួកគេមិនបានរស់នៅក្នុងជីវិតដ៏ប្រសើរ ហើយបានទទួលបន្ថែមទៀត នូវបទពិសោធន៍ដូចគ្នានៅក្នុងអតីតជាតិ ?។ តើវាគ្រាន់តែជាឱកាស ចៃដន្យ ដែលគេបានកើតមកពីឪពុកម្ដាយ និងបានដាក់ឲ្យនៅក្រោមព្រឹត្តិការណ៍ដ៏រុងរឿងទាំងនោះឬ ?

ទ្រឹស្ដីនៃសិទ្ធិទទួលមត៌ក គួរតែត្រូវបានបន្ថែមទៀត ដោយទ្រឹស្ដីរបស់កម្ម និងការកើតឡើងវិញ សម្រាប់ការពន្យល់ឲ្យបានគ្រប់គ្រាន់ នូវបញ្ហាទាំងឡាយដែលគួរឲ្យសង្ស័យនេះ ។ តើវាអាចមានហេតុផលដើម្បីជឿថា ចំណែកដែលខ្លីនៃជីវិតបច្ចុប្បន្ននេះ គឺជាអត្ថិភាវៈរវាងអនន្តភាព នៃស្ថានសួគ៌និងស្ថាននរកឬ ? ។

ពីរបីឆ្នាំ យើងត្រូវបានគេឲ្យសិទ្ធិដើម្បីនៅទីនេះ ក្នុងរយៈពេលប្រាំឆ្នាំជាកំណត់ ត្រូវតែជាការប្រតិបត្តិមិនបានគ្រប់គ្រាន់មួយ សម្រាប់អនាគតជាតិ ។ ប្រសិនបើបុគ្គលជឿនៅក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិជាជំនឿប្រកបដោយតក្កភាពបំផុតក្នុងអតីតជាតិ ។

ប្រសិនមានហេតុផលដើម្បីជឿថា យើងបានកើតនៅក្នុងអតីតជាតិ, មិនមានហេតុផលណាមួយដែលមិនជឿថា យើងនឹងបន្តកើតបន្ទាប់ពីជីវិតបច្ចុប្បន្នរបស់យើងទេនោះ ។

តាមពិតមានការជជែកគ្នាយ៉ាងខ្លាំងក្លាមួយថា យើងធ្លាប់បានកើតមានឡើងនៅក្នុងអតីតជាតិ បន្ទាប់មកមិនមានហេតុផលយ៉ាងពិតប្រាកដដើម្បីមិនជឿថាយើងនឹងបន្តកើតឡើង បន្ទាប់ពីជីវិតបច្ចុប្បន្នរបស់យើងដែលបានស្លាប់ទៅនោះទេ ។

តាមពិតទៅ ការជជែកគ្នាយ៉ាងខ្លាំងៗមួយ នៅក្នុងការយល់ស្របពីជីវិតអតីតៈនិងជីវិតអនាគតថា "នៅក្នុងលោកនេះ បុគ្គលមានគុណធម៌ជារឿយៗតែងជួបប្រទះនូវអកុសល ហើយបុគ្គលដែលធ្វើអំពើអាក្រក់នៅតែជួបសេចក្តីល្អនិងរុងរឿងជានិច្ច" ។

ការស្វែងរកឃើញខ្លះៗ ខាងផ្លូវអារម្មណ៍ដ៏ទំនើបបានងាកទៅផងដែរ ដើម្បីបង្ហាញពីអត្ថិភាវៈ (ជីវិត) ទៅក្នុងអនាគតជាតិ ។

## មូលហេតុនៃការកើតឡើងវិញ

### វដ្តៈនៃជីវិត

ដោយសង្ខេបមក កម្មដែលបានចាក់ឫសទៅក្នុងអវិជ្ជា គឺជាមូលហេតុនៃការកើតនិងការស្លាប់ ។ ដរាបណាកម្លាំងកម្មនៅតែរស់ ការកើតក៏នៅតែមានដែរ ។

ដំណើរការនៃការប្រែក្លាយ បានពន្យល់យ៉ាងច្បាស់លាស់នៅក្នុងបដិច្ចសមុប្បាទធម៌ គឺធម៌ដែលកើតឡើងអាស្រ័យគ្នា ។

គួរតែយល់ថា បដិច្ចសមុប្បាទធម៌ គឺជាធម៌ទេសនាមួយ ដែលសម្តែងពីសង្សារវដ្ត ឬដំណើរនៃការកើតនិងការស្លាប់ តែមិនមែនជាទ្រឹស្តីនៃការផ្លាស់ប្តូរភព ដែលចេញមកពីរឿងខ្វាយខ្វល់នោះទេ ។ ទាក់ទងជាមួយនឹងមូលហេតុនៃការកើតឡើងវិញ និងសេចក្តីទុក្ខ, ប៉ុន្តែមិនបានប៉ុនប៉ងដើម្បីបង្ហាញពីកំណើតនៃជីវិតឡើយ ។

អវិជ្ជា គឺការមិនដឹងនូវអរិយសច្ចទាំងបួន ជាការជាប់ពាក់ព័ន្ធដំបូងបំផុត និងជាមូលហេតុ ឬជាសមុដ្ឋាននៃកង់ជីវិត ។ អវិជ្ជាជាអ័ព្ទបិទបាំងនូវការយល់ត្រូវ ។

អាស្រ័យដោយអវិជ្ជាសង្ខារក៏កើតឡើង ។ បុញ្ញាភិសង្ខារ (សង្ខារដែលល្អ) អបុញ្ញាភិសង្ខារ (សង្ខារដែលមិនល្អ) ដែលបានចាក់ឫសគល់នៅក្នុងអវិជ្ជា ហើយបានងាកទៅរកការត្រាច់រង្គត់ដ៏វែងឆ្ងាយមួយ នៅក្នុងសង្សារវដ្តនេះ ។ ទោះជាយ៉ាងណាក៏ដោយ, កម្មល្អសំខាន់ៗក៏បានកំចាត់ចោលនូវជម្ងឺនៃមហាសមុទ្រជីវិតដែរ ។

អាស្រ័យដោយសង្ខារ ទើបធ្វើឲ្យកើតនូវវិញ្ញាណឡើង, ការភ្ជាប់អតីតជាមួយនឹងបច្ចុប្បន្ន កើតឡើងតំណាលគ្នាជាមួយនឹងការកើតឡើងនៃវិញ្ញាណ ដែលពាក់ព័ន្ធទៅនឹងការកើតឡើងវិញហៅថា នាមរូប ។

នាមនិងរូបកើតឡើង ជាហេតុបច្ច័យនាំឲ្យអាយតនៈទាំងប្រាំមួយកើតឡើង ។

អាយតនៈទាំងប្រាំមួយកើតឡើង ជាហេតុបច្ច័យនាំឲ្យផស្សៈ (ការពាល់ត្រូវ) កើតឡើង ។

ផស្សៈកើតឡើង ជាហេតុបច្ច័យនាំឲ្យវេទនាកើតឡើង ។

វេទនាកើតឡើង ជាហេតុបច្ច័យនាំឲ្យតណ្ហាកើតឡើង ។

តណ្ហាកើតឡើង ជាហេតុបច្ច័យនាំឲ្យឧបាទានកើតឡើង។

ឧបាទានកើតឡើង ជាហេតុបច្ច័យនាំឲ្យភព(កម្ម)កើតឡើង។

ភពកើតឡើងជាហេតុបច្ច័យនាំឲ្យជាតិ (កំណើតថ្មី)កើតឡើង

ជរា មរណៈ ជាផលដែលកើតឡើងមកអំពីជាតិនេះ ។

ប្រសិនបើមានហេតុផលកើតមានឡើង, ប្រសិនបើហេតុរលត់ផលក៏ត្រូវតែរលត់ដែរ ។ ការបញ្ចប់នូវអវិជ្ជាអស់ហើយ នឹងនាំទៅកាន់ការបញ្ចប់ការកើត និងការស្លាប់ ។

ដំណើរការហេតុនិងផលខាងលើ បានបន្តទៅមិនមានទីបំផុតឡើយ ។ ខាងដើមបំផុតនៃដំណើរការ មិនអាចកំណត់បានឡើយ វាមានលទ្ធភាពដើម្បីនិយាយថា ចាប់ពីទីដែលលំហូរនៃជីវិតនេះ ត្រូវបានព័ទ្ធជុំវិញដោយអវិជ្ជា ។ ប៉ុន្តែនៅពេលណាដែលអវិជ្ជាត្រូវបានប្តូរដោយវិជ្ជា,

លំហូរនៃជីវិតត្រូវបានផ្លាស់រូបរាងទៅជាវិញ្ញាណធាតុ ជាទីបំផុតនៃខ្សែជីវិត ឬក៏សង្សារវដ្ត ។

## របៀប ៤ យ៉ាង នៃការកើតនិងការស្លាប់

ព្រះពុទ្ធសាសនាអាចប្រមាណដឹងបាននូវការស្លាប់ ដែលបណ្តាលចេញមកពីមូលហេតុ ៤ យ៉ាងដូចខាងក្រោម៖

១-ការអស់ទៅនៃកម្លាំងកម្ម ដែលជាគ្រឿងផលិត, កម្មដែលជាអ្នកឲ្យនូវការកើតឡើងនៃកំណើត (កម្មខយ) ។ ជំនឿពុទ្ធសាសនាគឺដូច្នោះឯង, ដូចជាច្បាប់គ្រប់គ្រង, គំនិត, ឆន្ទះ ឬក៏បំណងប្រាថ្នា ដែលខ្លាំងបំផុតនៅក្នុងពេលរស់នៅ, ប្រែក្លាយដ៏លើសលប់នៅត្រង់ចំណុច នៃសេចក្តីស្លាប់ និងហេតុបច្ច័យនៃការកើត ដែលជាប់តាមក្រោយ ។ នៅក្នុងខណៈនៃការគិតជាចុងក្រោយនេះ គឺជាខណៈបច្ចុប្បន្នដែលជាសក្តានុពលពិសេស ។ នៅពេលណាថាមពលជាសក្តានុពល របស់កម្មដែលជាគ្រឿងផលិតនេះចុះខ្សោយទៅ ឬក៏អស់ទៅ, ជាកម្លាំងធ្វើឲ្យកើតរូបកាយ, កម្លាំងនៃជីវិតក៏បានបញ្ចប់ត្រឹមប៉ុណ្ណោះ សូម្បីតែអាយុមិនទាន់ចាស់ក៏ដោយ ។

២-ការអស់អាយុ (អាយុក្ខយ) ។ អ្វីដែលយើងទាំងអស់គ្នាបានយល់ជារួមថា ការស្លាប់តាមធម្មជាតិសមគួរដល់អាយុចាស់ ដែលត្រូវបានចាត់ជាថ្នាក់ៗ ឲ្យស្ថិតនៅក្រោមប្រភេទនេះ៖

មានកម្រឹតផ្សេងៗគ្នានៃអត្ថិភាវៈ (ជីវិត) តាមរយៈព្រះពុទ្ធសាសនា ហើយកម្រឹតនីមួយៗត្រូវបានកំណត់តាមធម្មជាតិ និងការកម្រឹតអាយុយ៉ាងច្បាស់លាស់ ។ ការមិនកំណត់កម្លាំងកម្ម ដែលត្រូវប្រព្រឹត្តទៅ, ទោះបីជាយ៉ាងណាក៏ដោយ, បុគ្គលត្រូវតែធ្លាក់ទៅរកសេចក្តីស្លាប់ នៅពេលណាអាយុ បានឈានដល់កម្រឹតអតិប្បរមាហើយ ។ អាចនិយាយបានផងដែរថា ប្រសិនបើកម្លាំងកម្មមានអំណាចខ្លាំងមែនទែន ថាមពលរបស់កម្ម បានបង្កើតឲ្យមានជារូបរាងឡើងវិញដោយខ្លួនវា នៅលើកម្រឹតដូច គ្នាឬក៏នៅក្នុងស្ថានខ្ពស់ៗ មានដូចជាស្ថានទេវតាជាដើម ។

៣-ការអស់ទាំងកម្មទាំងអាយុ (ឧភយក្ខយ) ដំណាលគ្នានៃកម្លាំងកម្ម ដែលជាគ្រឿងផលិតឡើងវិញ និងការអស់ទៅនៃអាយុកាល ។

៤-អំពើដែលមានកម្លាំងខ្លាំង (ឧបច្ឆេទកៈ) កម្មដែលចូលមកកាត់ផ្តាច់ភ្លាមៗ នូវអំណាចនៃកម្មដែលជាគ្រឿងផលិតឡើងវិញ នៅមុនកំណត់នៃអាយុកាល ។

របៀបនៃសេចក្តីស្លាប់៣ខាងដើម ហៅថា “កាលមរណៈ” (ស្លាប់តាមកាល) ហើយសេចក្តីទី៤ឈ្មោះថា “អកាលមរណៈ” (ស្លាប់មិនត្រូវតាមកាល) ។ ជាឧទាហរណ៍ ដូចជាចង្កៀងប្រេងកាតមួយដែលរលត់ដោយមូលហេតុណាមួយ នៃមូលហេតុទាំងបួនយ៉ាងនេះគឺៈ ដោយការអស់

ប្រឆេះ, ដោយការអស់ប្រេង, ដោយការអស់ប្រឆេះផងអស់ប្រេងផង និង ដោយមូលហេតុខាងក្រៅ ដូចជាកម្លាំងបក់បោកនៃខ្យល់ ។

សេចក្ដីស្លាប់របស់បុគ្គល អាចបណ្ដាលមកពីមូលហេតុ៤យ៉ាង ដូចការប្រៀបធៀបដែលបានបញ្ជាក់ខាងលើនេះ ។

## កំណើត ៤ យ៉ាងគឺ៖

១. អណ្ឌជ: កំណើតដែលកើតពីស៊ុត ជាកំណើតពីរដងមាន ដូចជាបក្សី ពស់ និងសត្វដទៃទៀត ។

២-ជលម្ពុជ: កំណើតដែលកើតពីទឹក គឺពីគភ៌នៃមាតា, មាន កំណើតមនុស្ស, ភុម្មទេវតាខ្លះ, សត្វពាហនៈមួយចំនួន ដែលចាប់បដិសន្ធិ ឡើងនៅក្នុងគភ៌មាតា ។

៣-សំសេទជ: កំណើតដែលកើតពីញើស និងសម្ភារៈសំណើម ផ្សេងៗទៀត បានដល់ពពួកសត្វល្អិត មានដូចជាមូស រុយ ជាដើម ។

៤. ឧបបាតិក: កំណើតដែលបានកើតឡើង ឬឧបត្តិកឡើងដោយ ឯងៗ (សយម្ភូត) ។ ជាទូទៅយើងមិនអាចមើលឃើញពពួកកំណើតនោះ ដោយភ្នែកធម្មតាឡើយ ។ កំណើតនេះកើតឡើងដោយកម្មពីអតីតជាតិ ជា ហេតុបច្ច័យតាក់តែង ឲ្យបានកើតឡើងភ្លាមៗ, មិនត្រូវការពឹងពាក់ឬ អាស្រ័យមាតាបិតាទេ ។ មានដូចជាព្រហ្ម ទេវតា ដែលកើតនៅក្នុងស្ថាន

ទេវលោក, ពួកប្រេត និងពួកសត្វរងទុក្ខលំបាក ដែលស្ថិតនៅក្រោមការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ រងទុក្ខសោក ក្នុងស្ថាននរកដែលចាត់ជាថ្នាក់ៗ ។

សត្វលោកមាន ៣១ ជាន់គឺៈ

ក- ទុគ្គតិ ជាស្ថានគ្មានសេចក្តីសុខមាន ៤ យ៉ាងគឺ៖

១-និរយៈ ភាវៈដែលពោរពេញដោយសេចក្តីវិនាស និងទុក្ខទារុណកម្មគ្រប់យ៉ាងដែលមិនស្ថិតស្ថេរ ប៉ុន្តែមិនមានទីបំផុត។

២-តិរច្ឆានយោនិ ជាសត្វតិរច្ឆានមានគោ ក្របី មាន់ទា ជ្រូក ឆ្កែ ឆ្មា ជាដើម ។

៣-បេតយោនិ ជាប្រេតដែលកើតនៅក្នុងបេតវិស័យ ។

៤-អសុរយោនិ ជាកំណើតពពួកយក្ស ខ្មោច ព្រាយ បិសាច និងអសុរកាយ ។

ខ- សុគតិ ជាស្ថានប្រកបដោយសេចក្តីសុខមាន ៧ ជាន់

១-មនុស្ស ស្ថានមនុស្សលោក

២-ទេវលោក ស្ថានសួគ៌ទាំង ៦ ជាន់

៣-រូបព្រហ្ម ស្ថានព្រហ្មមានរូបទាំង ១៦ ជាន់

៤-អរូបព្រហ្ម ស្ថានព្រហ្មឥតរូបទាំង ៤ ជាន់ ។

# តើកំណើតថ្មីកើតឡើងយ៉ាងដូចម្ដេច?

មនុស្សទៀបនឹងស្លាប់តែងតែឃើញនូវកម្ម គឺអំពើណាមួយដែលខ្លួនបានធ្វើ ហៅថា "កម្មនិមិត្ត" ឬ "គតិនិមិត្ត" ។ កម្ម ក្នុងទីនេះមានន័យថា អំពើខ្លះៗរាប់ទាំងអំពើល្អនិងអំពើអាក្រក់ ។ វាជាអំពើដ៏ធ្ងន់ធ្ងរទោះបីជាកុសល ឬអកុសល ដែលហៅថា "គរុកកម្ម" មានដូចជាឈានសមាបត្តិ ឬមាតុឃាត បិតុឃាត ឬក៏អនន្តរិយកម្មដទៃទៀត ។ អំពើទាំងនេះមានអំណាចខ្លាំងបំផុត ដែលគេបានធ្វើឲ្យបាត់បង់ទាំងស្រុងនូវកម្មដទៃៗទៀត និងប្រាកដឡើងយ៉ាងរស់រវើកបំផុតនៅនឹងភ្នែក (ក្នុងគំនិត) ។ ប្រសិនបើកម្មដែលបានធ្វើឲ្យល្មម មិនធ្ងន់ធ្ងរពេកទេ, អ្នកនោះទៀបស្លាប់ ប្រហែលជាជួបអារម្មណ៍ នៃកម្មដែលខ្លួនបានធ្វើហើយភ្លាមៗ នៅមុនសេចក្ដីស្លាប់របស់បុគ្គលនោះ មកដល់ជាអាសន្នកម្ម ។

អវត្តមាននៃអសន្នកម្ម អំពើជាកុសលឬជាអកុសលដដែល (អចិណ្ណកម្ម) ដែលបានបង្ហាញឡើងដូចជាការលួចប្លន់ ឬការជួយព្យាបាលជម្ងឺ ។ កំហុសឆ្គងទាំងអស់នេះ, អំពើជាមូលហេតុខ្លះ, ទាំងនោះជាអង្គមួយនៃបដិលោម បានកើតឡើងនូវកម្មអតីតៈមិនមានទីបញ្ចប់ (កតត្តាកម្ម) ក្លាយជាអារម្មណ៍របស់មនុស្សទៀបស្លាប់ ។

កម្មនិមិត្ត គឺជាការមើលឃើញ, ការស្ដាប់ឮ, ការធំក្លិន, ការភ្លក់រសជាតិ, ការស្ទាប ឬពាល់ត្រូវ និងគំនិតដែលត្រូវបានទទួលនៅពេលនៃ

ការលែងប្រើបានទៀតរបស់កម្ម, ដូចជាកាំបិតរបស់ឈ្មួញលក់សាច់, ពេទ្យព្យាបាលអ្នកជម្ងឺ, គោលបំណងនៃការគោរពបូជា នៅក្នុងករណីនៃអ្នកមានសទ្ធា ។ល។

គតិនិមិត្ត បានបង្ហាញប្រាប់នូវសញ្ញាខ្លះៗនៃទីកន្លែង ដែលបុគ្គលត្រូវធ្វើដំណើរទៅកើត, ព្រឹត្តិការណ៍ដែលបានកើតឡើងដោយមិនមានការប្រែប្រួល ដល់បុគ្គលដែលទៀបនឹងស្លាប់ ។ នៅពេលដែលការបង្ហាញ ពីកំណើតខាងមុខដែលនឹងកើតឡើង, ប្រសិនបើវាជាកម្មអកុសល វាបានងាកទៅរកអំពើល្អ ។ អំពើនេះត្រូវបានធ្វើឡើងដោយឥទ្ធិពលគំនិត នៃបុគ្គលដែលទៀបនឹងស្លាប់, ដូច្នេះគំនិតល្អរបស់មនុស្សនោះ ឥឡូវនេះអាចដើរតួជាកម្មនៅជិតៗ និងរារាំងនូវឥទ្ធិពលនៃកម្មដែលផលិតឡើងវិញដែលម្យ៉ាងទៀត វាជះឥទ្ធិពលទៅលើកំណើតបន្ទាប់មករបស់បុគ្គលនោះ ។

គតិនិមិត្តដែលបានបង្ហាញបុគ្គលឲ្យឃើញ មានដូចជាភ្លើងនរក, តំបន់ព្រៃ, តំបន់ភ្នំ, គភ៌របស់មាតា, វិមាននៃស្ថានសួគ៌ ។ល។

ការយល់ថាអារម្មណ៍របស់បុគ្គលទៀបនឹងស្លាប់ ដូចពោលខាងលើ ដំណើរការខាងគំនិតពិតជាបានប្រព្រឹត្តទៅ តាមផ្លូវរបស់វាមិនខានប្រសិនបើសេចក្ដីស្លាប់បានកើតឡើងភ្លាមៗ ។ មានពាក្យនិយាយថា ដូចជាសត្វរុយដែលត្រូវបានវាយកំទេច ដោយញញួរនៅលើដែកទ្រនាប់ ដែលបានជួបប្រទះជាដំណើរការនៃគំនិត នៅមុនបុគ្គលស្លាប់ទៅដោយពិត ។

សេចក្តីស្លាប់មានន័យថា ការបញ្ចប់នៃជីវិតដែលជានាមនិងរូបនៃ អត្តិភាវៈ (ជីវិត) របស់បុគ្គលម្នាក់ៗ ។ សេចក្តីស្លាប់កើតឡើង ដោយសារ ការឃ្លាតទៅឆ្ងាយនៃថាមពលគឺ អាយុ ភ្លើងធាតុ (ឧស្ម័ន) និង វិញ្ញាណ ។

នៅក្នុងពាក្យរបស់ទស្សនវិទូខាងបស្ចឹមប្រទេស សេចក្តីស្លាប់មាន ន័យថា គ្រាន់តែជា“ការបញ្ចប់បណ្តោះអាសន្ន នៃបាតុភូតបណ្តោះ អាសន្ន”, មិនមែនជាការសូន្យដោយពេញលេញ នៃអ្វីដែលហៅថាជីវិត នោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ, ជីវិតនៃសរីរាង្គបានបញ្ចប់, តែ ថាមពលដែលមានរហូតមកដល់ទីនេះ បានធ្វើឲ្យមានសកម្មភាពឡើងវិញ មិនទាន់ត្រូវបានបំផ្លាញនៅឡើយទេ ។

ដូចជាពន្លឺអគ្គិសនី គឺជាការបង្ហាញឲ្យឃើញចេញមកក្រៅ នៃ ថាមពលអគ្គិសនីដែលមិនអាចមើលឃើញ ដូចជាយើងដែរ ជាការបង្ហាញ ចេញមកក្រៅនៃថាមពលកម្ម ដែលមិនអាចមើលឃើញអញ្ចឹងដែរ ។ បើអំ ពូលបែកហើយ ពន្លឺក៏ត្រូវរលត់ដែរ ប៉ុន្តែចរន្តថាមពលអគ្គិសនីនៅសល់ ហើយពន្លឺអាចត្រូវបានចម្លងបន្តទៅអំពូលមួយទៀត ។

នៅពេលសេចក្តីស្លាប់, វិញ្ញាណដែលស្លាប់ហើយនោះ បាន ឲ្យកំណើតទៅវិញ្ញាណថ្មីមួយទៀត នៅក្នុងកំណើតបន្តបន្ទាប់មក ។ លំហូរជីវិតដែលកើតឡើងជាថ្មីនេះ បានទទួលមត៌កមកពីអ្វីៗទាំងអស់ នៅក្នុងជាតិកន្លងមក ។

ជីវិតថ្មីនេះមិនដូចគ្នាសុទ្ធសាធ ទៅនឹងជីវិតអតីតៈទេ ពីព្រោះថា សមាសភាព នៃការតាក់តែងរបស់វាមានលក្ខណៈខុសគ្នា ឬក៏មិនខុសគ្នាទាំងស្រុងទេ គឺទៅជាខ្សែច្រវាក់មួយដូចគ្នាបេះបិទ នៃឋាមពលរបស់កម្ម (ន ច សោ ន ច អញ្ញោ)។

ដំណើរនៃការកើតរបស់សត្វមេអំបៅ អាចត្រូវបានទាញមកជាអាគតដ្ឋាន សម្រាប់សំអាងនៅក្នុងការផ្ទុះបញ្ចាំងដល់រឿងខាងលើនេះ ។ ដំបូងវាជាស៊ុតតូចមួយ ហើយបន្ទាប់មកស៊ុតនោះបានក្លាយជាកូនសត្វដង្កូវ, ក្រោយមកទៀត សត្វដង្កូវនោះបានអភិវឌ្ឍទៅជាដឹកឌឿ (ដង្កូវក្នុងសំបុកដែលបម្រុងនឹងក្លាយទៅជាមេអំបៅ) ហើយចុងក្រោយក៏បានវិវត្តទៅជាសត្វមេអំបៅ ។ ដំណើរការនេះបានកើតឡើង នៅក្នុងរយៈពេលនៃជីវិតតែមួយ ។ មេអំបៅមិនផ្សេងគ្នា ឬក៏ដូចគ្នាទាំងស្រុងនឹងសត្វដឹកឌឿទេ ។ ទីនេះក៏ដូចគ្នាដែរ មានលំហូរនៃជីវិត ឬក៏ជាភាពបន្តមិនដាច់នៃជីវិត ។

អន្តរភាពនៃលំហូរបានកើតឡើងភ្លាមៗផងដែរ, មិនមានបន្ទប់សម្រាប់ភាវៈជាអន្តរសកម្ម (អន្តរាភាវៈ)ទេ ។ ពួកពុទ្ធសាសនិកមិនជឿថាចិត្ត ឬព្រលឹងរបស់បុគ្គលដែលបានស្លាប់ទៅ បានទៅជួលបន្ទប់សំណាក់នៅក្នុងសភាវៈពិតប្រាកដមួយ រហូតដល់បានស្វែងរកឃើញកន្លែងដែលសមរម្យមួយ សម្រាប់ការចុះចាប់បដិសន្ធិសារជាថ្មី (បុនវតារ)ទេ ។

ការចាប់កំណើតឡើងវិញបានកើតឡើងភ្លាមៗ ហើយមិនមានពេលវេលាផ្សេងគ្នា ទោះបីបុគ្គលបានទៅកើតនៅក្នុងស្ថានសួគ៌ ឬកើតជាមនុស្ស ឬក៏កើតជាសត្វតិរច្ឆានក៏ដោយ ។

## តើអ្វីដែលទៅកើតទៀត?

### មិនមែនខ្លួន (អនត្តា) ខន្ធប្រាំ (បញ្ចក្ខន្ធ)

តាមរយៈព្រះពុទ្ធសាសនា ការបែកធ្លាយនៃរូបនិងចិត្ត ដែលបានផ្សំផ្គុំឡើង ដែលហៅថាសត្វលោកនោះ, មិនមែនជាព្រលឹងអមតៈ ឬក៏ជាអត្តា (អាត្ម័ន) មិនមានទីបំផុតដែលសត្វលោក ត្រូវបានផ្តល់ឲ្យដោយអាទិទេព ឬបានទទួលនៅក្នុងមធ្យោបាយយ៉ាងអាថ៌កំបាំងពីទេវៈណាមួយ ឬកម្លាំងដ៏អាថ៌កំបាំងណាមួយឡើយ ។

ក្នុងទ្រឹស្តីរបស់ព្រះពុទ្ធសាសនា ការកើតឡើងវិញ (Rebirth) គួរតែត្រូវបានញែកចេញពីទ្រឹស្តីនៃការចាប់បដិសន្ធិសារជាថ្មី (Re-incarnation) ឬក៏ការចេញពីទីមួយទៅកាន់ទីមួយទៀត (Transmigration)ឡើយ សម្រាប់ព្រះពុទ្ធសាសនាបានបដិសេធនូវអត្ថិភាវៈ នៃការផ្លាស់ប្តូរព្រលឹងសត្វណាមួយនៅក្នុងទម្រង់រូបភាពនៃទេវតា មនុស្ស ឬក៏សត្វតិរច្ឆាន ។ ទម្រង់រូបភាពទាំងនេះ វាគ្រាន់តែជាការបង្ហាញបណ្តោះអាសន្ន នៃកម្លាំងកម្មតែប៉ុណ្ណោះឯង ។ ពាក្យ "សត្វលោក" នេះ គឺគ្រាន់តែវាក្យស័ព្ទដែល

លើកយកប្រើសម្រាប់គោលបំណង ជាការសន្មតយ៉ាងសាមញ្ញៗតែប៉ុណ្ណោះ ។

ប្រសិនបើមិនមានទម្រង់រូបភាពនៃចិត្ត ឬ ព្រលឹង ឬក៏ វិញ្ញាណ ដែលឆ្លងចេញពីជីវិតនេះទៅកាន់ជីវិតមួយទៀត តើអ្វីទៅដែលត្រូវទៅកើតទៀតនោះ ?

នៅក្នុងការសួរនូវសំណួរនេះ តើបុគ្គលបាននាំយកនូវអ្វីខ្លះទៅជាមួយ សម្រាប់ការទៅកើតទៀត ?

នៅក្នុងអតីតកាល ក៏ធ្លាប់បានជជែកគ្នាយ៉ាងខ្លាំងដែរ នៅក្នុងទស្សនវិជ្ជា ដែលគោលការណ៍បង្កើតឡើងនូវជីវិត (អត្ថិភាវៈ) នៃការរស់នៅអំពីដំណើរការនៃការគិត ឬការដឹងរបស់វា ។ ដូចជារូបមន្តរបស់លោក Descartes (១៦៤១) Cogito, ergosum “I think, therefore I am.” ។ តាមពិតទៅ វាត្រូវតែបង្ហាញជាដំបូងថា ខ្ញុំគិត ព្រោះហេតុនោះវាគឺជាខ្ញុំ ។

ខ្ញុំនិយាយថា គ្មាន ខ្ញុំ គិតទេ ។ នៅក្នុងការដកដង្ហើម ខ្ញុំ ប្រឆាំងខ្លួនឯង ។ ត្រូវហើយ, វាត្រូវតែព្រមទទួលថា យើងមិនអាចគេចចេញ ពីការប្រើពាក្យសន្មតដ៏សាមញ្ញនេះទេ ។

យើងនិយាយថា ព្រះអាទិត្យរះឡើងនៅទិសខាងកើត ហើយលិចទៅវិញនៅទិសខាងលិច, ថ្វីបើអ្វីដែលអ្នកវិទ្យាសាស្ត្រ បានបង្ហាញភស្តុតាងប្រាប់យើងហើយក៏ដោយ ។ យើងមិនអាចវាយកន្លែងមួយពីរដងទេ ទោះបីទៅរកការប្រាកដឡើងទាំងអស់ ដែលយើងបានធ្វើដូច្នោះហើយក៏ដោយ ។ អ្វីៗទាំងអស់បានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស, សូម្បីអាកាសក៏បានផ្លាស់ប្តូរ នៅក្នុងខណៈទីពីរដែរ ។

តាមរយៈព្រះពុទ្ធសាសនា ដែលហៅថា សត្វលោកត្រូវបានផ្សំឡើងដោយនាមធម៌ (ចិត្ត) និងរូបធម៌ (រូបកាយ) ។ រូបគឺគ្រាន់តែជាការបង្ហាញពីកម្លាំងថាមពល និងគុណភាពតែប៉ុណ្ណោះ ។

នៅសម័យបុរាណ ពួកឥសីជាតិឥណ្ឌាមានជំនឿ នៅក្នុងអាតូមដ៏ល្អិតដែលមិនអាចចែកបាន ហៅថា បរមាណូ ។ ព្រះពុទ្ធបានវិភាគលើរបស់នោះ ដែលហៅថា បរមាណូ មិនអាចចែកបាននិងបានប្រកាសថា វាគ្រាន់តែជាការបង្ហាញ នូវថាមពលជាអន្តរៈទំនាក់ទំនង ដែលព្រះអង្គបានហៅថា បរមត្ថៈ ឬកងដែលជាគោលសំខាន់ៗនៃរូប ។

បរមត្ថៈទាំងនេះមាន បឋវី, អបោ, តេជោ និងវាយោ ។ បឋវីមានន័យថា ធាតុដីដែលជាមូលដ្ឋានគ្រឹះនៃរូប ។ អបោ គឺជាធាតុទឹក ឬវត្ថុរាវ ឬក៏ស្អិត ។ តេជោ ជាធាតុភ្លើង ឬធាតុក្តៅ ។ វាយោ ជាធាតុខ្យល់ ឬជាធាតុដែលធ្វើឱ្យកម្រើក ។

រូបសំខាន់ៗទាំងបួននេះ ត្រូវបានបញ្ចូលគ្នាដោយមិនប្រែប្រួល ជាមួយនឹងគោចរគាហិករូប ៤ យ៉ាងមានវណ្ណៈ (ពណ៌សម្បុរ) គន្ធៈ (ក្លិន) រសៈ (រសជាតិ) និងឱជៈ (អាហារ)។

ធាតុទាំង៤ និងគោចរគាហិករូប មិនអាចញែកចេញឲ្យដាច់ពីគ្នាបានឡើយ និងជាអន្តរៈទំនាក់ទំនង ប៉ុន្តែធាតុមួយអាចមានចំនួនលើសលុបលើធាតុដទៃទៀត, ឧទាហរណ៍ វត្ថុរឹងមានចំនួនលើសលុបនៅក្នុងធាតុដី, វត្ថុរាវនិងស្អិតមានចំនួនលើសលុបនៅក្នុងធាតុទឹក, កំដៅមានចំនួនលើសលុបនៅក្នុងធាតុភ្លើង និងធាតុកម្រើក ឬញ័ត្តិមានចំនួនលើសលុបនៅក្នុងធាតុខ្យល់ ។

ចិត្តជាផ្នែកសំខាន់បំផុត នៅក្នុងគ្រឿងយន្តរបស់មនុស្ស និងជាសមាសធាតុ ដែលលាយបញ្ចូលគ្នានូវចេតសិកមានចំនួន៥២ ។ វេទនា (ការសោយអារម្មណ៍) ១, សញ្ញា (ការដឹង)១ នៅសល់ចេតសិក៥០ទៀត ហៅដោយរួបរួមថាសង្ខារ ។ សភាវៈដែលមិនមែនជារូបទាំងនេះ កើតឡើងនៅក្នុងវិញ្ញាណ ។

ដែលហៅថា សត្វលោក គឺជាសមាសធាតុដែលជំពាក់វាក់វិនដោយខន្ធប្រាំ (បញ្ចក្ខន្ធ) មាន រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ស្ថិតនៅក្នុងសភាវៈ នៃលំហូរដែលប្រព្រឹត្តទៅជានិច្ច ។

ឯកត្តភាពរបស់បុគ្គល គឺជាការច្របាច់បញ្ចូលគ្នា នៃខន្ធទាំងប្រាំនេះ, មិនមានព្រលឹងជាអចិន្ត្រៃយ៍ ស្ថិតនៅក្នុងអ្វីដែលហៅថាសត្វលោកនោះទេ ។

## តើការកើតទៀតអាចប្រព្រឹត្តទៅដោយគ្មានព្រលឹងបានឬទេ?

ការកើតតាមធម្មតាកើតឡើងពីបញ្ចក្ខន្ធ គឺខន្ធប្រាំ, ការកើតឡើងនូវខន្ធ គឺជាការកើតឡើងនៃខន្ធម្តងហើយម្តងទៀត

ការកើតឡើងនៃភាវៈរូប ដែលបានតាក់តែងឡើងដោយសភាវៈពីមុនៗមក ដែលជាមូលហេតុរបស់វា, សូម្បីតែសត្វលោក ដែលបានមកជាជីវិតប្រកបដោយរូបនិងចិត្ត ក៏ត្រូវបានតាក់តែងឡើងដោយមូលហេតុពីមុន មកកាន់កំណើតរបស់វាដែរ ។ ដូចជាដំណើរការនៃជីវិតមួយ មានលទ្ធភាពបានដោយមិនមានវត្ថុជាអចិន្ត្រៃយ៍ ដែលបានកន្លងពីខណៈចិត្តមួយទៅខណៈចិត្តមួយទៀត ជាផ្នែកនៃដំណើរការជីវិតដែលមានលទ្ធភាពបានដោយមិនមានវត្ថុអ្វីមួយ ដើម្បីផ្លាស់ជីវិតមួយទៅកាន់ជីវិតមួយទៀតឡើយ ។

ការប្រើពាក្យដែលគេបានសន្មតថា ការស្លាប់នៃរូបកាយនេះ តាមពិតទៅ គឺជាការបញ្ជូនដោយកម្លាំងកម្មទៅកាន់រូបកាយមួយទៀត ដោយ

គ្មានអ្វីមួយដែលបានចេញពីជីវិតនេះ ទៅកាន់ជីវិតមួយទៀតទេ ។ នៅក្នុងអនាគត សត្វលោកនឹងត្រូវបានតាក់តែងឡើង ដោយកម្មបច្ចុប្បន្ន ។ សត្វលោកថ្មី មិនដូចគ្នាដាច់ខាតទៅនឹងសត្វលោកពីមុន, ព្រោះថាសមាសភាពដែលតាក់តែង មិនដូចគ្នាបេះបិទទេ, ឬក៏សត្វលោក ដែលជាខ្សែនៃឋាមពលរបស់កម្មដែលដូចគ្នា ។ ព្រោះហេតុនោះ មានតែការបន្តនៃលំហូរជីវិតយ៉ាងសំខាន់មួយ ហើយមិនមានអ្វីជាបន្ថែមទៀតទេ ។

# ១៣ ចតុរារិយសច្ច

អរិយសច្ចៈ គឺជាដំណើរការពិតដែលមិនអាចប្រកែក ឬតវ៉ាបានឡើយ ។ នៅក្នុងព្រះពុទ្ធសាសនា អរិយសច្ចៈដែលនៅជាប់នឹងខ្លួនមនុស្សមាន ៤ យ៉ាង ។

នៅក្នុងរោហិតស្សសូត្រ ព្រះពុទ្ធបានទេសនាបញ្ជាក់ថា “នៅក្នុងរូបកាយប្រវែងមួយព្យាមនេះ ប្រកបដោយសញ្ញានិងគំនិត, ហើយបានប្រកាសពីភព, កំណើតរបស់ភព, ការបញ្ចប់នៃភព និងផ្លូវទៅកាន់ការបញ្ចប់នៃភព” ។

វគ្គដែលគួរឲ្យចាប់អារម្មណ៍នេះ បានសំអាងទៅដល់អរិយសច្ចៈទាំងបួន ដែលព្រះពុទ្ធផ្ទាល់បានរកឃើញ ។ ទោះជាព្រះពុទ្ធទាំងឡាយបានកើតឡើងក្តី មិនកើតឡើងក្តី, អរិយសច្ចធម៌នេះតែងតែមានជានិច្ច ហើយព្រះពុទ្ធគ្រប់ព្រះអង្គតែងសម្តែងឡើង ពីអរិយសច្ចៈនេះឯង ដល់ពិភពលោកដែលពេញដោយអវិជ្ជា ។

សច្ចៈទាំងនេះ ជាពាក្យបាលីហៅថា អរិយសច្ចៈពីព្រោះសច្ចៈទាំងនេះ ត្រូវបានរកឃើញដោយព្រះអរិយៈ ដែលជាបុគ្គលបានបណ្តេញតណ្ហា

ឲ្យចេញឆ្ងាយ ឬពីព្រោះតែសច្ចធម៌ទាំងនេះបានដឹកនាំបុគ្គលទៅកាន់ភាពជាព្រះអរិយៈ ដែលជាទីអស់ទៅនៃតណ្ហា ។

សច្ចធម៌ទីមួយគឺ ទុក្ខ ឬ ទុក្ខៈ ។ ទុក្ខ មានន័យថា សភាវៈដែលអត់ទ្រាំបានដោយលំបាក (ទុ=លំបាក + ខ=អត់ទ្រាំ) ។ ទុក្ខ ក្នុងទីនេះ ត្រូវបានប្រើនៅក្នុងស្មារតីនៃសភាវៈគួរឲ្យស្អប់ខ្ពើម (ទុ) ភាពទទេ (ខៈ) ។ ពិភពលោកដែលពេញដោយសេចក្ដីទុក្ខ (ទុក្ខេ លោកោ បលិត្ថិតោ), ព្រោះហេតុនោះ វាជាទីគួរឲ្យស្អប់ខ្ពើមណាស់ ។ គ្មានអ្វីដែលពិតនៅត្រង់ណាមួយឡើយ ព្រោះហេតុនេះហើយវាជាអ្វីគឺទទេ និងសោះសូន្យ ។

ចំពោះមនុស្សធម្មតា ចេះត្រឹមតែទាយហេតុការណ៍ដែលកើតឡើងទុកជាមុនតែប៉ុណ្ណោះ, តែព្រះអរិយបុគ្គលបានឃើញនូវរឿងរ៉ាវដែលជារបស់ពិត ។

ចំពោះបុគ្គល ដែលឃើញបាននូវវត្ថុមិនមែនជាសេចក្ដីសុខពិតនៅក្នុងភពពេញដោយទុក្ខព្រួយ ដែលគ្រាន់តែបំភ័ន្តភ្នែក ជាមួយនឹងការរីករាយដែលបន្លំភ្នែកតែប៉ុណ្ណោះ ។ អ្វីដែលយើងហៅថាសេចក្ដីសុខនោះ គឺគ្រាន់តែជាការបំពេញចិត្តខ្លះៗ តាមបំណងតែប៉ុណ្ណឹង ។ មិនមែនជាវត្ថុប្រាថ្នាដែលបានមក ហើយស្ថិតនៅបានយូរទេ, វាក្លាយទៅជាវត្ថុឈប់រាប់រក និងមិនឆ្អែតស្កប់ស្កល់នៅក្នុងសេចក្ដីប្រាថ្នា ។

ទាំងអស់នេះ ជាកម្មវត្ថុប្រព្រឹត្តទៅកាន់ការកើត (ជាតិ), ទៅកាន់ភាពចាស់គ្រាំគ្រា (ជរា), ទៅកាន់ជម្ងឺដម្កាត់ (ព្យាធិ) និងទៅកាន់សេចក្ដីស្លាប់ (មរណៈ) ។ គ្មានអ្នកណាមួយរួចផុតចាកពីមូលហេតុទាំងបួនយ៉ាងនៃសេចក្ដីទុក្ខនេះបានឡើយ ។

ការរារាំងនូវបំណងប្រាថ្នាក៏ជាទុក្ខដែរ, ការមិនប្រាថ្នាហើយបានជួបនូវមនុស្សឬវត្ថុ ដែលមិនចូលចិត្តនោះក៏ជាទុក្ខ, ការព្រាត់ចាកនូវមនុស្ស និងវត្ថុ ដែលប្រាថ្នានោះក៏ជាទុក្ខ, ចិត្តប៉ងប្រាថ្នាអ្វីមួយ ហើយមិនបានសម្រេចតាមបំណងក៏ជាទុក្ខ ។ ជួនកាលជាឱកាសមិនសប្បាយរីករាយ តែមិនអាចអត់ទ្រាំបាន និងពេញចិត្តនូវសេចក្ដីទុក្ខ ធ្វើឲ្យមនុស្សល្ងង់ខ្លៅបានបង្ខំចិត្ត ដើម្បីធ្វើនូវអត្តឃាតបញ្ចប់ជីវិតរបស់គេក៏មាន ។

ដោយសង្ខេប, រូបកាយនេះជាមូលហេតុនៃសេចក្ដីទុក្ខ ។ ព្រះពុទ្ធសាសនាបានបញ្ចប់នូវឫសកែវនៃសេចក្ដីទុក្ខ, ប៉ុន្តែមិនបានយល់ព្រមថា ព្រះពុទ្ធសាសនាជាសាសនាទុទិដ្ឋិនិយមទេ ។ ព្រះពុទ្ធសាសនាមិនមែនជាសាសនាទុទិដ្ឋិនិយមទាំងស្រុងទេ ហើយក៏មិនមែនជាសាសនាសុទិដ្ឋិនិយមទាំងស្រុងដែរ ។ នៅលើភាពផ្ទុយគ្នាមួយ ព្រះពុទ្ធសាសនាបានបង្រៀននូវសច្ចៈ ថាជាពាក់កណ្ដាលផ្លូវនៃទុទិដ្ឋិនិយម និងសុទិដ្ឋិនិយម ។ នៅក្នុងខណៈនៃការបញ្ជាក់ពីសច្ចៈនៃសេចក្ដីទុក្ខនេះ ព្រះពុទ្ធបានណែនាំពីមធ្យោ

បាយដើម្បីកំចាត់ចោលសេចក្ដីទុក្ខ និងទទួលបានមកវិញនូវសេចក្ដីសុខក្រៃលែង ។

មូលហេតុធំនៃសេចក្ដីទុក្ខ គឺតណ្ហាដែលជាអរិយសច្ចទីពីរ ។ គម្ពីរធម្មបទខុទ្ទកនិកាយបញ្ជាក់ថា:

"សេចក្ដីសោកកើតមកពីតណ្ហា, សេចក្ដីខ្លាចកើតមកពីតណ្ហា សោកនិងភ័យនឹងមានមកពីណា ដល់បុគ្គលដែលអស់តណ្ហា ? " ។

សេចក្ដីទុក្ខនៅមានដរាបណានៅមានតណ្ហា ឬការជាប់ជំពាក់ ។ តណ្ហាមាន៣យ៉ាងគឺ ទីមួយ តណ្ហាធម្មតាដែលប្រកាន់ខ្ជាប់នូវការរីករាយក្នុងកាម ហៅថា កាមតណ្ហា ។ ទីពីរ តណ្ហា ដែលរីករាយ ទាក់ទងជាមួយទិដ្ឋិដែលប្រកាន់ថា ភពមិនមានទីបំផុត ហៅថា ភវតណ្ហា ។ ទីបី តណ្ហាដែលទាក់ទងដល់ការយល់ឃើញនូវភាពទទេ ហៅថា វិភវតណ្ហា ។

តណ្ហាដ៏ធាត់ធំនិងល្អិតល្អន់ បានដឹកនាំឲ្យមានការកើតឡើងដដែលៗនៅក្នុងវដ្តសង្សារ ហើយធ្វើការតោងភ្ជាប់ទៅរកទ្រង់ទ្រាយនៃជីវិត ។ តណ្ហានេះ គឺជាកម្លាំងមួយដែលពោរពេញដោយអំណាចខ្លាំង ដែលបុគ្គលត្រូវតែហៅរកនូវកម្លាំង ដែលពេញដោយអំណាចស្មើគ្នាទាំងប្រាំបី (ផ្លូវប្រកបដោយអង្គប្រាំបី) ទៅកាន់អំណាចដ៏លើសលុប ទៅលើសត្រូវទោលមួយនេះ ។

រូបភាពដ៏ធំនៃតណ្ហា ត្រូវបានធ្វើឲ្យថយកម្លាំងជាដំបូង ដោយការបានសម្រេចនូវសកទាគាមី ហើយត្រូវបានកំចាត់ចោល ដោយការបានសម្រេចនូវអនាគាមី ។ រូបភាពតូចល្អិតនៃតណ្ហា អាចត្រូវបានកំចាត់ចោល ដោយការបានដល់នូវភាពជាព្រះអរហន្ត ។

អរិយសច្ចៈទី៣ គឺជាការបញ្ចប់ទាំងស្រុងនូវសេចក្ដីទុក្ខ ដែលហៅថានិព្វាន ជាសេចក្ដីសុខដ៏ខ្ពស់បំផុត ។ និព្វានត្រូវបានសម្រេច ដោយការកំចាត់ចោលទាំងស្រុង នូវទ្រង់ទ្រាយទាំងអស់នៃតណ្ហា ។

អរិយសច្ចៈទី៤ គឺផ្លូវនាំទៅកាន់ការបញ្ចប់សេចក្ដីទុក្ខ ដែលហៅថាអរិយមគ្គប្រកបដោយអង្គប្រាំបី ជាមធ្យោបាយមាសរបស់ព្រះពុទ្ធបរមគ្រូ ។

អរិយសច្ចៈពីរខាងដើមជាលោកិយៈ ហើយអរិយសច្ចៈពីរខាងចុងគឺជាលោកុត្តរៈ ។ អរិយសច្ចៈបីដំបូង ទាក់ទងជាមួយទស្សនវិជ្ជានៃសាសនារបស់ព្រះពុទ្ធ, ហើយអរិយសច្ចទីបួន ជាមួយនឹងការប្រតិបត្តិស្របទៅនឹងទស្សនវិជ្ជា ។

ព្រះពុទ្ធសាសនាមិនមែនជាទស្សនវិជ្ជាធម្មតា ឬក៏មិនមែនជាប្រព័ន្ធសីលធម៌ធម្មតាឡើយ, តែវាជាការបង្រៀននូវសីលធម៌ និងទស្សនវិជ្ជាដែលបានបង្កើតឡើងនៅលើគោលការណ៍គ្រឹះ នៃហេតុការណ៍ដែល

ត្រូវបានសាកល្បង និងបញ្ជាក់ឲ្យបានច្បាស់ ដោយឆ្លងកាត់បទពិសោធផ្ទាល់ខ្លួន ។

និយាយដោយដាច់ខាតថា ព្រះពុទ្ធសាសនាមិនត្រូវហៅថាជា "លទ្ធិ"ទេ ពីព្រោះពុទ្ធសាសនាមិនមែនជាប្រព័ន្ធនៃជំនឿ និងការធ្វើសក្ការៈបូជាតែម៉្យាង ដែលផ្តោតទៅលើអត្ថិភាវៈ(ជីវិត) នៃអាទិទេពហួសវិស័យធម្មតាឡើយ។ ប្រសិនបើជាលទ្ធិ (Religion) គឺមានន័យថា ការប្រៀនប្រដៅ (អាគម) ដែលបានញែកចេញរវាងខុសនិងត្រូវ និងដែលផ្តល់ឲ្យមនុស្សលោក ជាមួយនឹងការនាំផ្លូវឆ្ពោះទៅកាន់ចរិយាដ៏សមរម្យ, តាមពិតទៅពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺជាសាសនានៃសាសនាទាំងឡាយ ។

# ១៤ និព្វាន

## និយមន័យ

និព្វាន ជាពាក្យបាលី (សំស្ក្រឹត និរ្វាណៈ) ដែលផ្សំចេញ មកពីពាក្យដើមថា “និ +វាន” ។ “និ” ជាអព្យយស័ព្ទ គឺជាពាក្យ សម្រាប់ថ្លែងបញ្ជាក់ការបដិសេធ ប្រែថា “ចេញ”, រីឯ “វាន” មានន័យថា “ព្រៃ, តណ្ហា” ។ និព្វាន មានន័យថា ចេញចាកព្រៃគឺ កិលេស, ឬ ចេញចាកគ្រឿងចាក់ស្រេះគឺ តណ្ហា ។ តណ្ហានេះឯងដែលបានដើរតួដូចជាខ្សែពួរ ឬច្រវាក់សម្រាប់ចងភ្ជាប់សត្វលោក ពីជីវិតមួយទៅជីវិតមួយទៀត ។

ដរាបណាបុគ្គល នៅតែត្រូវបានចងភ្ជាប់ដោយខ្សែ ពោលគឺតណ្ហាបានន័យថាបុគ្គលនៅតែប្រមូលកម្លាំងកម្មថ្មីៗ ដែលជាថាមពលបង្កើតរូបឲ្យនៅក្នុងទម្រង់មួយស្ថិតនៅក្នុងវដ្តៈ នៃការកើតនិងការស្លាប់មិនមានទីបំផុត ។ នៅពេលណារូបភាពទាំង អស់របស់តណ្ហា ត្រូវបានគាស់រំលើងចោលហើយ កម្លាំងកម្មទាំងអស់ក៏បញ្ឈប់ប្រតិបត្តិការដែរ ហើយបុគ្គលបានសម្រេចនិព្វាន ដែលអាចគេចចេញផុតពីវដ្តៈ នៃការកើតនិងការស្លាប់ ។ ទស្សនៈព្រះពុទ្ធសាសនា មិនមែនគ្រាន់តែបង្រៀនពីការគេចចេញ

ពីបាប និងនរកប៉ុណ្ណោះទេ តែបានបង្រៀនពីមធ្យោបាយសម្រាប់ការ គេចចេញពីវដ្តៈនៃការកើត និងការស្លាប់ផងដែរ ។

ដូច្នេះនិព្វានក៏ត្រូវបានពន្យល់ផងដែរថា ជាដំណើររលត់នៃភ្លើងលោភៈ ទោសៈ និងមោហៈ ដោយពិត ។

## តើនិព្វានសូន្យឬ?

ដើម្បីនិយាយថានិព្វានគឺជាភាពសូន្យ ។ តាមធម្មតាបុគ្គលគ្រប់រូបមិនអាចស្គាល់និព្វាន ដោយវិញ្ញាណទាំងប្រាំឡើយ មិនមែនជាតក្កវិជ្ជាដែលត្រូវនិយាយថា ពន្លឺមិនមានពីព្រោះងងឹត ។ នៅក្នុងរឿងព្រេងមួយនិទានពីត្រីដែលរស់នៅក្នុងទឹក បានស្គាល់ត្រឹមទឹកតែម្យ៉ាងគត់ ។ នៅពេលមួយ ត្រីបានឈ្លោះគ្នាជាមួយនឹងអណ្តើក ព្រោះតែអណ្តើកនិយាយប្រាប់ថានៅខាងក្រៅទឹកមានដី ។ ដោយខ្លួនកើតឡើងនិងធំធាត់នៅក្នុងទឹក ត្រីក៏សន្និដ្ឋានយ៉ាងដាច់អហង្កាថាគ្មានផែនដីទេ ។ ឯអណ្តើកវិញជាសត្វធ្លាប់រស់នៅក្នុងទឹកផងនិងលើគោកផង ក៏មិនអាចពន្យល់ត្រីនោះ ឲ្យយល់នូវផែនដីបានឡើយ ។ ចំណែកត្រីមិនអាចយល់នូវអ្វីដែលហៅថាដី ដូចដែលខ្លួនធ្លាប់រស់នៅក្នុងទឹកតែម្យ៉ាងនោះបានឡើយ ។ ដូចគ្នានេះដែរ, ព្រះអរហន្តទាំងឡាយ ដែលធ្លាប់ស្គាល់លោកិយសុខផង និងលោកុត្តរសុខផង មិនអាចឲ្យអត្ថន័យពិតប្រាកដ នូវអ្វីដែលជាលោកុត្តរៈ ដោយពាក្យពេចន៍ជាលោកិយ៍នេះបានឡើយ ឬក៏មិនអាចពន្យល់ឲ្យបានទូលំទូលាយ នូវអ្វី

ដែលជាលោកុត្តរៈ ដោយត្រឹមតែចំណេះដឹង ជាលោកិយ៍នេះបានឡើយ ។ ជាសភាវៈរបស់ លោកុត្តរៈ ត្រូវតែយល់បានច្បាស់ដោយអព្ភន្តរញ្ញាណផ្ទាល់ (Intuitive Knowledge) របស់បុគ្គលតែប៉ុណ្ណោះ ។

អ្វីជានិព្វាននោះ គឺមិនអាចនិយាយមានទេ, បុគ្គលអាចនិយាយបានត្រឹមតែជាន័យប្រៀបប៉ុណ្ណោះ ។ អ្វីដែលជាអត្ថន័យ ជាក់លាក់របស់និព្វាននោះ បុគ្គលមិនអាចបញ្ជាក់ឲ្យបានត្រឹមត្រូវ នៅក្នុងពាក្យសាមញ្ញៗឡើយ ។ និព្វាន គឺជាការយល់ច្បាស់ដោយខ្លួនឯង ។

## សឧបាទិសេសនិព្វាន និង អនុបាទិសេសនិព្វាន

និព្វានមិនមានពីរយ៉ាងទេ គឺនិព្វានមានតែម៉្យាងប៉ុណ្ណោះឯង ដែលមានឈ្មោះទៅតាមប្រភេទ ដែលព្រះអរិយបុគ្គលបានសម្រេចនៅមុន និងក្រោយពេលបែកធ្លាយរូបកាយ ។

និព្វានអាចសម្រេចបាន នៅក្នុងជីវិតបច្ចុប្បន្ននេះ, ព្រះពុទ្ធសាសនាមិនបានបញ្ជាក់ថា និព្វានអាចទៅដល់សម្រាប់តែក្រោយស្លាប់ប៉ុណ្ណោះទេ, តែបុគ្គលអាចធ្វើនិព្វានឲ្យជាក់ច្បាស់បាន នៅក្នុងជីវិតនេះ ទាំងរូបកាយកំពុងតែរស់នៅ ។ និព្វានរបៀបនេះ ហៅថា សឧបាទិសេសនិព្វាន ។ ព្រះអរហន្តដែលបានចូលនិព្វាន បន្ទាប់ពីការបែកធ្លាយរូបកាយទៅ គ្មានផ្នែក

ណាមួយនៃរូបកាយនេះសល់នៅឡើយ ។ និព្វានរបៀបនេះហៅថា អនុបាទិសេសនិព្វាន ។

## និព្វានមានលក្ខណៈខុសគ្នា ៣ យ៉ាង

និព្វានជាគុណជាតិផ្ទុយគ្នានិងសង្ខារៈ, ព្រះពុទ្ធទ្រង់ត្រាស់សម្តែងថា មិនមានទីបំផុត(ធុវ), គួរឲ្យចង់បាន(សុភ) និងសុខក្រៃលែង (សុខ) ។

តាមទ្រឹស្តីព្រះពុទ្ធសាសនា អ្វីៗទាំងអស់គ្រាន់តែជាលោកធាតុ, ហើយលោកធាតុនេះ (Hypercosmic) ត្រូវបានចាត់ជាថ្នាក់ៗ នៅក្រោមការចែកចេញជាពីរយ៉ាងទៀត គឺអ្វីៗដែលតាក់តែងឡើងប្រកបដោយហេតុបច្ច័យ (សង្ខតធម៌) និងអ្វីៗដែលមិនបានតាក់តែងឡើង ដោយហេតុបច្ច័យណាមួយឡើយ (អសង្ខតធម៌) ។

និព្វានមិនបានតាក់តែងឡើង ដោយហេតុបច្ច័យណាមួយឡើយ, ព្រោះហេតុនោះទើបនិព្វានមិនមានការកើតឡើង និងការរលត់ទៅវិញឡើយ ។ មិនកើតឡើងទៀត (អជាតំ), មិនចាស់គ្រាំគ្រា (អជរំ), មិនឈឺ (អព្យាធិ) និងមិនស្លាប់ (អមរណំ) ។ និព្វានមិនមែនជាហេតុ និងមិនមែនជាផលឡើយ ។

អ្វីៗទាំងអស់ដែលប្រកបដោយហេតុបច្ច័យ ហើយអ្វីៗទាំងអស់នៅក្នុងលោកនេះ សុទ្ធតែស្ថិតនៅក្នុងទ្វិកភាព (Duality) គឺភាពដែលផ្ទុយ

គ្នា, តែងផ្លាស់ប្តូរជានិច្ច ដោយគ្មានកើតឡើង និងតាំងនៅក្នុងរយៈពេលពីរខណៈជាប់ៗ ឲ្យដូចគ្នាបានឡើយ ។

អ្វីៗដែលបានផុសចេញពីហេតុ ត្រូវតែឃ្លាតទៅវិញ មិនអាចជៀសផុតបានឡើយ ដូចជាអសុភដែលជារបស់មិនគប្បីប្រាថ្នា, នោះហើយដែលមានន័យថា មិនស្ថិតស្ថេរ និងមិនគប្បីប្រាថ្នា ដែលមិនអាចទៅជាសេចក្តីសុខពិតបានឡើយ ។ និព្វាន មិនមែនកើតឡើងពីហេតុបច្ច័យឡើយ, អ្វីៗដែលមិនបានកើតឡើងពីហេតុបច្ច័យ នៃបាតុភូតអត្ថិភាវៈមួយ (Phenomenal existence) ដែលស្ថិតនៅក្នុងភាពផ្ទុយគ្នាមិនមានទីបំផុត, ដែលគប្បីប្រាថ្នា និងពេញដោយសេចក្តីសុខពិតឡើយ ។

សេចក្តីសុខនៃព្រះនិព្វាន គប្បីញែកចេញឲ្យបានដាច់គ្នាពីសេចក្តីសុខធម្មតា ។ សេចក្តីសុខព្រះនិព្វាន កើតឡើងពីផលនៃ ភាពស្ងប់តណ្ហា (វូបសមោ), មិនដូចសេចក្តីសុខនៅក្នុងលោក ដែលជាផលបានមកពីការបំពេញតណ្ហា និងបំណងប្រាថ្នាតែប៉ុណ្ណោះ (វេទយិត)ឡើយ ។

នៅក្នុងពាក្យសន្ទតមួយ ព្រះពុទ្ធអង្គសម្តែងថា “និព្វានំ បរមំ សុខំ” ព្រះនិព្វានជាទីសុខក្រៃលែង ។

សុខក្នុងព្រះនិព្វានជាសុខដ៏ខ្ពស់ក្រៃលែង ពីព្រោះមិនមែនជាសេចក្តីសុខឆ្លងកាត់វិញ្ញាណឡើយ, តែវាជាសភាវៈដែលពោរពេញដោយសេចក្តីសុខជាវិជ្ជមាន ។

ដោយពិតទៅ ការបញ្ចប់សេចក្តីទុក្ខ ដែលពាក្យធម្មតាឲ្យឈ្មោះថាសេចក្តីសុខ មិនមានពាក្យសមរម្យណាមួយ ដើម្បីពណ៌នាឲ្យបានចំទៅតាមធម្មជាតិពិត របស់និព្វានបានឡើយ ។

## ព្រះនិព្វាននៅឯណា?

"ដូចជាភ្លើងដែរ គេមិនបានរក្សាវាទុកនៅក្នុងកន្លែងពិសេសណាមួយឡើយ, ប៉ុន្តែភ្លើងកើតឡើងបាននៅពេលណា ហេតុបច្ច័យសំខាន់ៗកើតមានឡើង ។ ដូច្នេះ និព្វានមិនបាននិយាយថា ស្ថិតនៅក្នុងទីពិសេសណាមួយឡើយ ប៉ុន្តែនិព្វានត្រូវតែបានសម្រេច នៅពេលណាហេតុបច្ច័យសំខាន់ៗ ត្រូវបានគេបំពេញឲ្យបានគ្រប់គ្រាន់ហើយ" ។

នៅក្នុងរោហិតស្សសូត្រ ព្រះពុទ្ធទ្រង់បានសម្តែងថា "នៅក្នុងរូបកាយដែលមានប្រវែងមួយព្យាមនេះ ព្រមជាមួយនឹងសញ្ញា និងការគិតផង, តថាគតបានប្រកាសថាជាភព, ការកើតឡើងនូវភព, ការបញ្ចប់នូវភព និងផ្លូវនាំទៅកាន់ទីបញ្ចប់នូវភព" ។

ក្នុងទីនេះ ភព មានន័យថា សេចក្តីទុក្ខ ។ ព្រោះហេតុនោះ ការបញ្ចប់នូវភពមានន័យថា ការបញ្ចប់នូវសេចក្តីទុក្ខ គឺជាព្រះនិព្វាន ។

និព្វានរបស់បុគ្គល គឺអាស្រ័យទៅលើរូបកាយនេះ ។ និព្វានមិនមែនជារបស់ដែលបង្កើតឡើងដោយខ្លួនឯងទេ ឬក៏មិនមែនជារបស់ដែលអ្នកណាម្នាក់បង្កើតឲ្យឡើយ ។

និព្វាន មិនមែនជាប្រភេទនៃស្ថានសួគ៌ ជាកន្លែងដែលអត្តៈ(អាត្ម័ន) ល្អិតឆ្មារអាស្រ័យនៅនោះទេ, ប៉ុន្តែការសម្រេច (ធម្មៈ) ដែលស្ថិតនៅក្នុងក្របខ័ណ្ឌមួយ នៃការឈានទៅដល់បានគ្រប់ៗគ្នា ។

## អ្វីដែលនាំឲ្យសម្រេចនិព្វាន?

សំណួរនេះសំខាន់ណាស់ ត្រូវដាក់នៅក្បែរអ្វីៗដែលមិនទាក់ទង, ចំពោះទស្សនៈព្រះពុទ្ធសាសនា បានបដិសេធអត្ថិភាវៈ នៃអង្គធាតុដែលទៀង ឬព្រលឹងអមតៈ ។

ឥឡូវនេះ និងក្នុងទីនេះ មិនមានអ្វីដែលយើងប្រកាន់ថាខ្លួន(អត្តា) នោះទៀតទេ, ហើយសត្វលោកទាំងអស់ក៏ដូចគ្នាដែរ មិនត្រូវការនិយាយថា មិនមាន “អញ” នៅក្នុងនិព្វានឡើយ ។

នៅក្នុងគម្ពីរវិសុទ្ធិមគ្គបានបញ្ជាក់ថា:

“ព្រះនិព្វានមានពិត តែមិនមានអ្នកស្វែងរកនិព្វានទេ,

ផ្លូវសម្រាប់ដើរមាន ប៉ុន្តែមិនមានអ្នកដើរទេ “ ។

ភាពខុសគ្នាជាចម្បងរវាងទស្សនៈព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា អំពីរឿងនិព្វានបានផ្តេកផ្តួលទៅក្នុងការពិត ដែលពួកពុទ្ធសាសនិក យល់ឃើញពីគោលដៅរបស់ពួកគេក្នុងការមិនមានអាត្ម័ន (ព្រលឹង) ដែលស្ថិតស្ថេរ និងអាទិទេពបង្កើតលោក ក្នុងខណៈដែលពួកព្រាហ្មណ៍យល់ថាមានពិតនោះ ។

នេះជាហេតុផលមួយថា ហេតុអ្វីក៏ព្រះពុទ្ធសាសនា មិនត្រូវបានគេហៅថាជាលទ្ធិមិនមានទីបំផុត (Eternalism) ឬជាលទ្ធិសូន្យសុង (Nihilism) ។ នៅក្នុងគំនិតនិព្វាន មិនមានអ្វីមួយដែលស្ថិតស្ថេរចិរកាល ឬក៏មិនមានអ្វីដែលមិនសាបសូន្យឡើយ ។

# ១៥ អដ្ឋង្គិកមគ្គ

មាគ៌ាប្រកបដោយអង្គប្រាំបីហៅថា "អដ្ឋង្គិកមគ្គ" ដែលត្រូវបានរកឃើញដោយព្រះពុទ្ធអង្គ ជាផ្លូវតែមួយគត់ឆ្ពោះទៅកាន់ព្រះនិព្វាន និងជាផ្លូវងាកចេញពីការធ្វើខ្លួន ឲ្យលំបាកឥតប្រយោជន៍ (អត្តកិលមថានុយោគ) ដែលធ្វើឲ្យប្រាជ្ញាស្មារតីចុះខ្សោយ និងការប្រកបខ្លួនឲ្យជាប់ជំពាក់ក្នុងកាម (កាមសុខល្លិកានុយោគ) ដែលជំអក់ដល់ការលូតលាស់ខាងផ្លូវចិត្ត ។

ផ្លូវប្រកបដោយអង្គប្រាំបីនេះគឺ:

១-ការយល់ត្រូវ (សម្មាទិដ្ឋិ)

២-ការត្រិះរិះត្រូវ (សម្មាសង្កប្បោ)

៣-សម្ដីត្រូវ (សម្មាវាចា)

៤-ការងារត្រូវ (សម្មាកម្មន្តោ)

៥-ការចិញ្ចឹមជីវិតត្រូវ (សម្មាអាជីវោ)

៦-ការព្យាយាមត្រូវ (សម្មាវាយាមោ)

៧-ការរលឹកត្រូវ(សម្មាសតិ)

៨-ការតម្កល់ចិត្តត្រូវ (សម្មាសមាធិ) ។

១-ការយល់ត្រូវ គឺការយល់ច្បាស់នូវអរិយសច្ចបួន។ ចំណុចគោលរបស់ព្រះពុទ្ធសាសនា ស្ថិតនៅលើការយល់ច្បាស់ និងមិនជឿទៅលើជំនឿដែលគ្មានហេតុផលឡើយ ។

២-ការត្រិះរិះត្រូវ ចែកចេញជា៣យ៉ាងគឺៈ ក.ត្រិះរិះក្នុងការចេញចាកកាម(នេក្ខម្មសង្កប្បៈ) ទប់ស្កាត់ដល់ចិត្តដែលត្រេកត្រអាលក្នុងសេចក្ដីលោភលន់, ខ.ត្រិះរិះក្នុងការផ្សាយមេត្តា (អព្យាបាទសង្កប្បៈ) ដែលទប់ស្កាត់ទៅនឹងចិត្តទោសៈ, គ.ត្រិះរិះក្នុងការមិនធ្វើអំពើហិង្សា (អវិហិង្សាសង្កប្បៈ) ដែលទប់ស្កាត់ទៅនឹងអំពើហិង្សាគ្រប់យ៉ាង ។ ការត្រិះរិះទាំងអស់នេះ អាចធ្វើចិត្តឲ្យបរិសុទ្ធបាន ។

៣-សម្ដីត្រូវ បានដល់ការទប់ស្កាត់នូវការពោលពាក្យកុហក, ការនិយាយចាក់រុក ឬមូលបង្កាច់, ពាក្យទ្រគោះបោះបោក និងពាក្យរោយរាយឥតប្រយោជន៍ ។

៤-ការងារត្រូវ បានដល់ការទប់ស្កាត់ការសម្លាប់, ការលួច និងការប្រព្រឹត្តខុសក្នុងផ្លូវកាម ។

៥-ការចិញ្ចឹមជីវិតត្រូវ បានដល់ជំនួញខុស៥ប្រការ ដែលត្រូវតែជៀសវាងឲ្យផុត ។ ជំនួញខុសទាំង៥ប្រការនោះ មានការជួញអាវុធ, ការជួញមនុស្ស, ការជួញសាច់ (សត្វដែលត្រូវគេសម្លាប់), ការជួញគ្រឿងស្រ

រឹងនិងគ្រឿងញៀន, និងការជួញថ្នាំពុល ។ ពួកភិក្ខុសង្ឃប្រព្រឹត្តកិរិយាលាក់ពុត មានអានេសនៈ២១ និងបាបធម៌៥ ក៏ត្រូវចាត់ទុកជាការចិញ្ចឹមជីវិតក្នុងផ្លូវខុសដែរ ។

៦-ការព្យាយាមត្រូវ ចែកជា៤យ៉ាងគឺៈ ក.ការព្យាយាមលះបង់ចោល នូវអំពើអាក្រក់ដែលកើតឡើងហើយ, ខ.ការព្យាយាមរារាំងមិនឲ្យអំពើបាបកើតឡើង, គ.ការព្យាយាមធ្វើអំពើល្អ, ឃ.ការព្យាយារក្សាអំពើល្អ ដែលបានកើតឡើងហើយ ។

៧-ការរលឹកត្រូវ ចែកជា៤យ៉ាងគឺៈ ក.រលឹកដល់កាយ, ខ.រលឹកដល់វេទនា, គ.រលឹកដល់ចិត្ត, ឃ.រលឹកដល់ធម្មៈ ។

៨-ការតម្កល់ចិត្តត្រូវ គឺជាភាពមុតស្រួចរបស់ចិត្ត ។

អង្គទាំងពីរខាងដើមចាត់ជាតួបញ្ញា, អង្គចំនួនបីបន្ទាប់មកទៀតចាត់ជាតួសីល ហើយអង្គបីខាងចុងចាត់ជាតួសមាធិ

សីល:
- -សម្តីត្រូវ
- -ការងារត្រូវ
- -ការចិញ្ចឹមជីវិតត្រូវ

| | | |
|---|---|---|
| | | -ព្យាយាមត្រូវ |
| សមាធិ | | -ការរលឹកត្រូវ |
| | | -ការតម្កល់ចិត្តត្រូវ |
| | | -ការយល់ត្រូវ |
| បញ្ញា | | -ការត្រិះរិះត្រូវ |

អរិយមគ្គមានអង្គប្រាំបីប្រការ បានប្រកាសពីគុណភាពរបស់ចិត្ត (ចេតសិក)ទាំងប្រាំបី ដែលបានរកឃើញរួមនៅក្នុងថ្នាក់ទាំងបួន នៃលោកុត្តរវិញ្ញាណ ដែលជាវត្ថុបំណងគឺព្រះនិព្វាន ។

តាមរបៀបនៃការចម្រើនឲ្យកើតនូវសីល សមាធិ បញ្ញា ដែលជាដំណាក់កាលទាំងបីរបស់អរិយមគ្គ ។

ដំណាក់កាលទាំង៣ ជាតំណាងនៅក្នុងគាថាខាងក្រោម:

សព្វបាបស្ស អករណំ កុំធ្វើអំពើបាបទាំងពួង

កុសលស្សូបសម្បទា បំពេញកុសល

សចិត្តបរិយោទបនំ ជុសខាត់ចិត្តឲ្យបរិសុទ្ធ

ឯតំ ពុទ្ធានសាសនំ ទាំងនោះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។

សីលជាដំណាក់កាលខាងដើម គឺមិនសម្លាប់សត្វបំបាត់ជីវិត ឬធ្វើឲ្យមានរបួស ឬក៏ឈឺចាប់ ដល់សត្វលោកណាមួយឡើយ, រាល់មុខរបរត្រូវធ្វើជាមួយនឹងទឹកចិត្តល្អ និងមានចិត្តមេត្តាករុណា អាណិតអាសូរដល់សត្វលោក ។ ការវៀរចាកអំពើលួចប្លន់ ហើយបុគ្គលគួរតែទៀងត្រង់ និងស្មោះត្រង់ជានិច្ច ។ វៀរចាកការប្រព្រឹត្តខុសក្នុងផ្លូវកាម គឺបុគ្គលគួរតែប្រព្រឹត្តនូវអ្វីៗដែលបរិសុទ្ធ និងប្រព្រឹត្តព្រហ្មចរិយធម៌ ។ ការវៀរចាកការនិយាយពាក្យកុហក គឺបុគ្គលគួររក្សានូវពាក្យពិត ។ ការវៀរចាកការសេពគ្រឿងស្រវឹង ដែលនាំបុគ្គលឲ្យវិនាស និងជម្រុញទៅរកការធ្វេសប្រហែស ។

សាសនិកទាំងអស់របស់ព្រះពុទ្ធអង្គ គួរតែរក្សាសីលប្រាំ ដែលហៅថានិច្ចសីល ទុកជាទម្លាប់ក្នុងជីវិតប្រចាំថ្ងៃ និងជាឱកាសជម្រុញបុគ្គលឲ្យបោះជំហានទៅមុខ ឆ្ពោះទៅរកការសមាទានសីលប្រាំបី និងសីលដប់ ។

នៅក្នុងខណៈដែលបុគ្គលបានចម្រើនសន្សឹមៗ និងធ្វើឲ្យប្រាកដប្រជា ជាមួយនឹងការអប់រំកាយវាចាចិត្ត ដែលកម្លាំងនៃការខិតខំប្រឹងប្រែងនេះ បានបង្ខំឲ្យបុគ្គលលះបង់ចោល នូវការត្រេកអរក្នុងផ្លូវលោកនេះ និងបានប្រកាន់យកនូវជីវិតជាអ្នកបួស ។ ការយល់ច្បាស់នូវភាពឥតប្រយោជន៍ នៃការត្រេកត្រអាលក្នុងផ្លូវលោក ហើយក៏លះបង់នូវទ្រព្យសម្បត្តិជាលោកិយ៍ ស្លៀកដណ្ដប់សំពត់ជ្រលក់ទឹកអម្ចត់ ជាអ្នកបួស

ព្យាយាមដើរទៅកាន់ជីវិតប្រសើរ នៅក្នុងផ្លូវបរិសុទ្ធ ។ បុគ្គលគួរតែយល់ថា ការគេចខ្លួនចេញ និងការនាំជីវិតតាមវិថីអ្នកបួសហៅថាបព្វជិត ។ ជីវិតជាភិក្ខុបានធ្វើឡើងដោយរួសរាន់ និងអប់រំឲ្យមានការលូតលាស់ខាងផ្លូវចិត្ត, ចំពោះគ្រហស្ថក៏ជាបុគ្គល អាចបាននូវភាពជាសន្តិបុគ្គលដែរ ។ មានឧទាហរណ៍ជាច្រើននៃគ្រហស្ថ ដែលបានដល់នូវព្រះនិព្វាន ដោយគ្មានបានចេញទៅបួសទេ ។ អនាថបណ្ឌិកសេដ្ឋី និងមហាឧបាសិកាវិសាខាបានសម្រេចសោតាបន្នៈ, សាក្យៈមហានាមបានសម្រេចថ្នាក់សកទាគាមិ, ស្នូផ្ទាំងឈ្មោះឃដីការ បានសម្រេចអនាគាមិ និងស្តេចសុទ្ធោទនៈបានសម្រេចថ្នាក់អរហត្តផល ហើយបរិនិព្វានទៅក្នុងភាពជាគ្រហស្ថ ។

ភិក្ខុដែលប្រាថ្នានាំជីវិតតាមផ្លូវជាបុគ្គលគ្មានផ្ទះ និងការប្រតិបត្តិតាមចតុប្បរិសុទ្ធិសីល ជាសីលដ៏ខ្ពស់ប្រកបដោយអង្គបួន ហៅថាអធិសីល មាននៅក្នុងវិន័យដែលជាពុទ្ធប្បញ្ញត្តិ មានបាតិមោក្ខសំវរសីល ការសង្រួមតាមសិក្ខាបទ ដែលមាននៅក្នុងព្រះបាតិមោក្ខ, ឥន្ទ្រីយសំវរសីល ការសង្រួមនូវឥន្ទ្រីយ៍ទាំងប្រាំមួយ, អាជីវបរិសុទ្ធសីល ការចិញ្ចឹមជីវិតតាមផ្លូវបរិសុទ្ធ វៀរចាកបាបធម៌៥ និងអានេសនៈ២១, និងបច្ចយនិស្សិតសីល ការរស់នៅអាស្រ័យដោយបច្ច័យទាំងឡាយ៤ សម្រាប់ចិញ្ចឹមជីវិត ។

ការបានមកដោយកម្លាំងស្ទួង នៅលើផែនដីគឺសីល, ភិក្ខុប្រតិបត្តិ សមាធិជាន់ខ្ពស់ ដើម្បីអប់រំនិងគ្រប់គ្រងចិត្ត ត្រូវបានចាត់ទុកជាដំណាក់កាលទីពីរ ។ សមាធិគឺជាកម្លាំងជម្រុញរបស់ចិត្ត ។

នៅពេលណា ភិក្ខុបានទទួលកម្លាំងជម្រុញមុតស្រួច គ្រប់គ្រាន់ក្នុងចិត្តហើយ អាចមានលទ្ធភាពដើម្បីបង្កើតអំណាចជាន់ខ្ពស់(អភិញ្ញា)ទាំង៥ មានៈ ១.ទិព្វចក្ខុ ភ្នែកទិព្វ, ២.ទិព្វសោតៈ ត្រចៀកទិព្វ, ៣.បុព្វេនិវាសានុស្សតិញាណ រលឹកឡើងវិញនូវជាតិកំណើត ពីអតីតកាល, ៤.បរចិត្តវិជ្ជាញាណ ដឹងពីគំនិតរបស់អ្នកដទៃ, ៥.ឥទ្ធិវិធៈ អំណាចខាងផ្លូវចិត្តផ្សេងៗ ។ មិនត្រូវយល់ថា អំណាចជាន់ខ្ពស់ ជាផ្នែកសំខាន់សម្រាប់អ្នកបួសទេ ។

បើចិត្តត្រូវបានបន្សុទ្ធល្អហើយ អាចដឹកនាំភិក្ខុនោះទៅរក ភាពស្ងប់ស្ងាត់ ក្នុងការងាកទៅរកផ្លូវចេញចាកតណ្ហា ។ ការរម្ងាប់ តណ្ហានាំឲ្យភិក្ខុស្រោលចាកថីនមិទ្ធៈ គឺភាពងោកងុយនិងខ្ជិលច្រអូស ។ ការអប់រំចិត្តគឺជាផ្នែកសំខាន់មួយ ប៉ុន្តែវិបស្សនាបញ្ញាដែលបុគ្គលបានធ្វើឲ្យកើតហើយ អាចមើលឃើញនូវធម្មជាតិជាធម៌ពិត ។ នេះជាដំណាក់កាលចុងក្រោយនៅលើផ្លូវទៅកាន់ព្រះនិព្វាន ។

ចិត្តដែលមានកម្លាំងជម្រុញហើយ នាំឲ្យភិក្ខុមើលឃើញនូវលោកទាំងមូល ហើយបង្កើតបាននូវការយល់ត្រូវនៃជីវិត ។ ភិក្ខុបានចម្រើនសមាធិ ទៅលើសាមញ្ញលក្ខណៈធម៌ទាំង៣យ៉ាងមាន អនិច្ចំ មិនទៀង, ទុក្ខំ

សេចក្តីទុក្ខ និងអនត្តា គឺភាពមិនមានអត្តា (ខ្លួន) ។ ការយល់ច្បាស់ថា អ្វីៗទាំងអស់ដែលតាក់តែងឡើង ដោយហេតុបច្ច័យ គឺជារបស់មិនទៀង (សព្វេ សង្ខារា អនិច្ចា), អ្វីៗទាំងអស់ ដែលតាក់តែងឡើងដោយហេតុបច្ច័យ គឺជាទុក្ខ (សព្វេ សង្ខារា ទុក្ខា), អ្វីៗទាំងអស់ដែលតាក់តែងដោយហេតុបច្ច័យ និងមិនមែនតាក់តែងឡើងដោយហេតុបច្ច័យ គ្មានចិត្ត គ្មានវិញ្ញាណ (សព្វេ ធម្មា អនត្តា) ។ ត្រៃលក្ខណ៍ទាំង៣នេះ បាននាំចិត្តឆ្ពោះទៅរកវិបស្សនាញាណ និងនាំឲ្យយល់ច្បាស់នូវព្រះនិព្វាន ព្រមទាំងបានបំផ្លាញចោលនូវសំយោជនៈ៣ខាងដើម មានសក្កាយទិដ្ឋិ (ការយល់ខុសប្រកាន់ថាមានកាយក្នុងកាយ) វិចិកិច្ឆា (ការសង្ស័យ) សីលព្វតបរមាសៈ (ការប្រកាន់ខុសនៅក្នុងសីលព្វត្ត) ។

នៅក្នុងដំណាក់កាលនេះ ភិក្ខុនោះហៅថាសោតាបន្នបុគ្គល (ជាបុគ្គលបានចូលទៅកាន់ខ្សែ ដែលនាំទៅកាន់ព្រះនិព្វាន) ។ នៅពេលភិក្ខុមិនបានកំចាត់បង់ចោល នូវច្រវាក់នៃតណ្ហាទាំងអស់ទេ ភិក្ខុពិតជានឹងកើតឡើងវិញយ៉ាងយូរប្រាំជាតិទៀត ។ ការអប់រំឲ្យមានចិត្តក្លាហានឡើង ជាផលនៃការឃើញព្រះនិព្វានពីចម្ងាយ ភិក្ខុបានអប់រំវិបស្សនាយ៉ាងជ្រៅ បានក្លាយទៅជាសកទាគាមិ (ការត្រឡប់មកកើតតែមួយជាតិទៀត) អាចធ្វើឲ្យសំយោជនៈពីរទៀតចុះខ្សោយគឺ កាមរាគៈ (ការត្រេកអរក្នុងកាម) និងបដិឃៈ (ការថ្នាំងថ្នាក់ចិត្ត) ។ ភិក្ខុនោះមានឈ្មោះថាសកទាគាមិ ព្រោះភិក្ខុ

នោះកើតនៅក្នុងភព នេះតែមួយជាតិទៀតប៉ុណ្ណោះ បើភិក្ខុនោះមិនទាន់បាន សម្រេចព្រះអរហត្តផលទេនោះ ។

នៅក្នុងដំណាក់កាលទីបី នៃជីវិតសន្តិបុគ្គល គឺអនាគាមិ (ជាអ្នក មិនត្រឡប់កើតទៀតឡើយ) ដែលភិក្ខុបានបោះបង់ចោលអស់ នូវសំយោជនៈពីរខាងលើ ។ បន្ទាប់មកភិក្ខុមិនត្រឡប់មកកាន់ភព ឬក៏មិនស្វែងរកកំណើតនៅក្នុងលោកនេះទៀតទេ, ចាប់តាំងពីភិក្ខុមិនមានប្រាថ្នា នូវការត្រេកអរនៅក្នុងផ្លូវកាមមក ។ បន្ទាប់ពីស្លាប់ទៅ ភិក្ខុបានកើតនៅក្នុងស្ថានបរិសុទ្ធ (សុទ្ធាវាសព្រហ្ម) ជាកន្លែងដែលគួរឲ្យចូលចិត្ត មានន័យដាច់ដោយឡែកសម្រាប់តែព្រះអនាគាមិបុគ្គល និងព្រះអរហន្ត ។

អ្នកប្រតិបត្តិធម៌ពិតប្រាកដ បានខិតខំប្រឹងប្រែង បានធ្វើឲ្យជឿនលឿនទៅមុខ និងបានបំផ្លាញសំយោជនៈទាំងប្រាំដែលនៅសល់គឺ រូបរាគៈ (ការប្រកាន់មាំនៅក្នុងរូបភព), អរូបរាគៈ (ការប្រកាន់មាំនៅក្នុងអរូបភព), មានៈ (ភាពក្រអឺតក្រទម), ឧទ្ធច្ចៈ (ភាពរសាប់រសល់, អន្ទះអន្ទែង) អវិជ្ជា (ភាពល្ងិតល្ងង់) បានក្លាយជាសន្តិបុគ្គល ដោយការសម្រេចនូវភាពជាព្រះអរហន្ត ។

បន្ទាប់ពីនោះមក លោករស់នៅដរាបកម្លាំងកម្មដែលបានផលិតឡើងវិញ (អចិណ្ណកម្ម) របស់លោកបានដល់ទីបំផុត ។ ការអស់កំណត់នៃរូបកាយ លោកក៏បានចូលបរិនិព្វានទៅ ។

# ១៦ នីវរណធម៌

នីវរណៈ (នី =រារាំង, បង្អាក់+វរ = បន្ទច់បង្អាក់, រាំងស្ទះ) ។ នីវរណៈ គឺជាការបន្ទច់បង្អាក់ការលូតលាស់របស់បុគ្គល ឬការរាំងស្ទះផ្លូវទៅកាន់ការរួចផុតចាក (វិមុត្តិ) និងស្ថានសួគ៌ ។ ត្រូវបានពន្យល់ផងដែរថាជា "គ្រឿងបិទបាំង, គ្រឿងរឹច, គ្រឿងខ្ទប់, ឬក៏អន្ទាក់របស់ចិត្ត" ។

**នីវរណៈមាន ៥ យ៉ាងគឺ៖**

១- កាមច្ឆន្ទៈ (បំណងប្រាថ្នាក្នុងកាម)

២- ព្យាបាទៈ (គំនិតគុំគួន)

៣- ថីនមិទ្ធៈ (ភាពងោកងុយ និង ខ្ជិលច្រអូស)

៤-ឧទ្ធច្ចកុក្កច្ចៈ (ភាវៈនៃចិត្តរាយមាយនិងអណ្តែតអណ្តូង)

៥- វិចិកិច្ឆា (ការមន្ទិលសង្ស័យ) ។

១-កាមច្ឆន្ទៈ មានន័យថា ការត្រេកអរក្នុងផ្លូវកាម ឬការប្រកាន់មាំនៅក្នុងអារម្មណ៍ ដែលអាចឲ្យរីករាយក្នុងផ្លូវកាម មានដូចជា រូប សម្លេង ក្លិន រស សម្ផស្ស ។ កាមច្ឆន្ទៈនេះចាត់ទុកថាជានីវរណៈមួយ ដែលចងរឹតបុគ្គលឲ្យជាប់នៅក្នុងសង្សារវដ្ត ។

ជនសាមញ្ញ ត្រូវបានបោកបញ្ឆោតដោយអារម្មណ៍ស្រើបស្រាល និងត្រេកត្រអាលក្នុងផ្លូវកាមទាំងឡាយ ។ ការខ្វះខាតសតិដើម្បីត្រួតពិនិត្យតណ្ហាដោយខ្លួនឯង បាននាំមកនូវការកើតឡើងវិញដដែលៗ ដែលមិនអាចជៀសរួចឡើយ ។ នីវរណៈនេះត្រូវបានរារាំងដោយឯកគ្គតា ដែលជាអង្គមួយចំណោមអង្គទាំង៥របស់ឈាន ។ នីវរណៈទីមួយនេះ ក៏ត្រូវបានកាត់បន្ថយ ដោយការបានដល់នូវសកទាគាមិ ហើយអាចកំចាត់ចោលទាំងស្រុងដោយការបានដល់នូវអនាគាមិ ។ សុខុមរូប គឺរូបល្អិតដែលបានប្រកាន់មាំដូចជា រូបរាគៈ និង អរូបរាគៈ (ឧបាទាននៅក្នុងរូបភព និងអរូបភព) ត្រូវបានកាត់ផ្តាច់ចោលទាំងស្រុង ដោយការបានសម្រេចនូវភាពជាព្រះអរហន្តដែរ ។

## ធម៌សម្រាប់ការបំផ្លាញចិត្តត្រេកមាន ៦ យ៉ាង

១-ការដឹងនូវអារម្មណ៍ជាបដិកូល

២-ការចម្រើនសមាធិឲ្យបានមាំលើអសុភជាអារម្មណ៍ គួរឲ្យខ្ពើមរអើម

៣-គ្រប់គ្រងលើអាយតនៈទាំង៦

៤-ចេះប្រមាណក្នុងការបរិភោគអាហារ

៥-សេពគប់កល្យាណមិត្ត

៦-និយាយតែកិច្ចការណាដែលមានប្រយោជន៍ ។

២-ព្យាបាទៈ គឺបំណងអាក្រក់ ឬ ការទាស់ចិត្ត ។

អារម្មណ៍ដែលជាទីប្រាថ្នា តែងនាំទៅកាន់ឧបាទាន, តែអារម្មណ៍មិនជាទីប្រាថ្នាក៏នាំទៅកាន់ការទាស់ចិត្ត ។ អារម្មណ៍ទាំងពីរនេះគឺជាគំនរភ្លើងធំ ដែលដុតរោលរាលពិភពលោកទាំងមូល ។ អវិជ្ជាបូករួមជាមួយអារម្មណ៍ទាំងពីរនេះ បង្កើតចេញជាសេចក្តីទុក្ខនៅក្នុងលោក ។

ព្យាបាទ រារាំងដោយបីតិដែលជាអង្គរបស់ឈាន ។ នីវរណៈថ្នាក់នេះត្រូវបានកាត់បន្ថយ ដោយការសម្រេចធម៌ថ្នាក់សកទាគាមិ និងកាត់ផ្តាច់ចោលទាំងស្រុងដោយថ្នាក់អនាគាមិ ។

## ធម៌សម្រាប់ការកាត់ផ្តាច់ព្យាបាទ មាន ៦ យ៉ាង

១-ការដឹងនូវអារម្មណ៍ និងតែងគិតតែបំណងល្អៗ

២-ការផ្សាយមេត្តាឲ្យបានខ្ជាប់ខ្ជួន និងទូលាយ

៣-គិតទៅដល់កម្មថាជារបស់ផ្ទាល់ខ្លួន

៤-ការប្រកាន់ខ្ជាប់នូវទស្សនៈត្រូវ

៥-សេពគប់កល្យាណមិត្ត

៦-និយាយតែកិច្ចការណាដែលមានប្រយោជន៍ ។

៣-ថីនៈ គឺភាពងោកងុយ លោកប្រៀបដូចជាមនុស្សកើតរោគខូចចិត្ត, មិទ្ធៈ ប្រៀបដូចជាមនុស្សកើតរោគខូចសតិដែរ ។ ចិត្តដែលមានអារម្មណ៍ព្រងើយៗ “ដូចជាសត្វប្រចៀវតោងមែកឈើមិនកម្រើកសោះ ឬ

ដូចរង្វង់ទឹកអំពៅដែលជាប់ស្អិតទៅនឹងចង្កឹះ” ។ ភាពខ្ជិលច្រអូស និងភាពស្ពឹកស្រពន់ក្នុងចិត្ត មានលក្ខណៈខុសពីភាពងងុយដេកធម្មតា, ព្រះអរហន្តទាំងឡាយ ដែលលោកបានបំផ្លាញសភាវៈទាំងពីរនេះ, ក៏នៅតែជួបប្រទះភាពរសេះរសោះ និងធុញទ្រាន់ខាងរូបកាយនេះផងដែរ ។ អកុសលធម៌ទាំងពីរនេះ ជាសត្រូវនឹងការព្យាយាម (វិរិយៈ) ។ នីវរណៈទាំងអស់នេះត្រូវបានរារាំងដោយអង្គនៃឈានគឺវិតក្កៈ ហើយអាចបំផ្លាញចោលឲ្យអស់បាន ដោយការសម្រេចនូវភាពជាព្រះអរហន្ត ។

### ធម៌សម្រាប់កំចាត់ចោលថីនមិទ្ធៈមាន ៦ យ៉ាង

១-ការត្រិះរិះនូវអារម្មណ៍ ដែលស្គាល់ប្រមាណក្នុងអាហារ

២-ការផ្លាស់ប្តូរឥរិយាបថកាយឲ្យបានញឹកញាប់

៣-នឹកគិតដល់អារម្មណ៍ភ្លឺៗ (អាលោកសញ្ញា)

៤-រស់នៅក្នុងទីលំហស្រឡះ

៥-សេពគប់កល្យាណមិត្ត

៦-និយាយតែអ្វីដែលមានប្រយោជន៍ ។

៤-ឧទ្ធច្ចៈ គឺជាភាពរសាប់រសល់ អន្ទះអន្ទែង និងច្រាស់ច្រាល់ ឬក៏ការរំជួយចិត្ត ។ ជាសភាវៈនៃចិត្តដែលភ្ជាប់ជាមួយនឹងវិញ្ញាណដែលថយថោក, ជាការគ្រប់គ្រងនូវអំពើអាក្រក់មួយ ដែលធ្វើឡើងជាមួយភាពរំជួយចិត្ត ឬក៏ភាពអន្ទះអន្ទែងក្នុងចិត្ត ។

កុក្កុច្ចៈ គឺជាភាពខ្វល់ ឬ ភាពព្រួយបារម្ភ ។ ជាការស្តាយក្រោយលើអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្ត ឬលើអំពើល្អដែលខ្លួនមិនបានធ្វើ ។ ការស្តាយក្រោយលើអំពើអាក្រក់របស់ខ្លួន ដែលយល់ថាអំពើអាក្រក់នោះមិនបានលើកលែងដល់ខ្លួន ហើយផលវិបាកក៏មិនអាចជៀសរួចដែរ ។ ការស្តាយក្រោយនោះ គឺមានបំណងមិនធ្វើអំពើអាក្រក់នោះដដែលៗហ្នឹងឯង ។

នីវរណៈទាំងពីរនេះ អាចត្រូវរារាំងបានដោយសុខៈ ដែលជាអង្គរបស់ឈាន ។ ឧទ្ធច្ចៈ អាចបំផ្លាញចោលឲ្យអស់បាន ដោយការសម្រេចនូវភាពជាព្រះអរហន្ត ហើយកុក្កុច្ចៈក៏ត្រូវបានបំផ្លាញចោលអស់ ដោយការសម្រេចនូវភាពជាព្រះអរហន្តដែរ ។

### ធម៌សម្រាប់បំផ្លាញចោលឧទ្ធច្ចកុក្កុច្ចៈ មាន ៦ យ៉ាង

១-ពហុស្សុតៈ ស្តាប់ច្រើន និងរៀនច្រើន

២-លើកឡើងនូវសំណួរ ឬក៏ធ្វើសាកច្ឆាធម៌

៣-យល់ដឹងពីធម៌វិន័យ

៤-សេពគប់ជាមួយព្រះសង្ឃជាថេរៈមានការចេះដឹង

៥-សេពគប់កល្យាណមិត្រ

៦-និយាយតែពីរឿងមានប្រយោជន៍ ។

៥-វិចិកិច្ឆា ការសង្ស័យ ឬ ភាពអល់អែក ។ នីវរណៈ ដែលមិនបានក្នុងការជួយកែលំអដល់បញ្ហា គឺវិចិកិច្ឆា (វិ=ទទេ, គ្មានបានការ + ចិកិច្ឆា = បញ្ហា) ។ ពាក្យនេះត្រូវបានពន្យល់ផងដែរថា ជាការរុកគួន, ការឆាឆៅទៅដល់ការគិតដោយស្មាក់ស្មើរ (វិចិ= ការស្វែងរក + កិច្ឆា = ការរុកគួន)

ទីនេះ វិចិកិច្ឆា មិនត្រូវបានប្រើនៅក្នុងន័យនៃក្តីសង្ស័យ ជាមួយការគោរពដល់ព្រះពុទ្ធ ។ល។ ចំពោះបុគ្គលដែលមិនមែនជាពុទ្ធសាសនិក រារាំងអកុសលធម៌នេះបានហើយ ក៏អាចឲ្យបាននូវឈានដែរ ។ វិចិកិច្ឆា គឺការសង្ស័យលើព្រះពុទ្ធមែន។ល។ ប៉ុន្តែវាជានីវរណៈដែលជាឧបសគ្គមួយដែលបានបង្ហាញប្រាប់ ពីភាពរារែកក្នុងចិត្ត ឬក៏ភាពមិននឹងន់នៅក្នុងវត្ថុសំខាន់អ្វីមួយ ដែលកំពុងតែបំពេញ ។ អដ្ឋកថាចារ្យពន្យល់ថា វិចិកិច្ឆា គឺជាការមិនមានសមត្ថភាព ដើម្បីសម្រេចអ្វីមួយ ឲ្យបានច្បាស់លាស់ឡើយ ។

នីវរណៈនេះ ត្រូវរារាំងដោយវិចារៈជាអង្គរបស់ឈាន, ហើយត្រូវបានបំផ្លាញចោល ដោយការដល់នូវលោកុត្តរៈថ្នាក់សោតាបត្តិ ។

## ធម៌សម្រាប់កំចាត់វិចិកិច្ឆាមាន ៦ យ៉ាង

១-យល់ដឹងពីធម៌វិន័យ

២-ធ្វើសាកច្ឆា ឬក៏សួរដេញដោល

៣-យល់ច្បាស់ពីវិន័យ

៤-ត្រេកអរក្នុងទីស្ងាត់

៥-សេពគប់កល្យាណមិត្រ

៦-និយាយតែពាក្យមានប្រយោជន៍ ។

# ១៧. សង្គាយនា

## បឋមសង្គាយនា

ព្រះពុទ្ធបរមគ្រូយាងចូលបរិនិព្វាន នៅក្នុងព្រះជន្មគម្រប់៨០ព្រះវស្សាគត់ គឺនៅក្នុងថ្ងៃអង្គារ ពេញបូណ៌មី ១៥កើត ខែពិសាខ ឆ្នាំម្សាញ់ ។ ការចូលបរិនិព្វានរបស់ព្រះពុទ្ធអង្គ គឺជាការបាត់បង់មួយមិនអាចជួសជុលបាន, សាវ័កទាំងអស់របស់ព្រះអង្គ លើកលែងតែសាវ័កដែលបានសម្រេចធម៌ជាន់ខ្ពស់ ថ្នាក់អនាគាមិនិងអរហត្តចេញ, សាវ័កដទៃក្រៅពីនោះបានធ្លាក់យ៉ាងជ្រៅ ទៅក្នុងសេចក្ដីសោកក្រៀមក្រំ ហើយបាននាំគ្នាទួញយំត្អូញត្អែរ សោកស្ដាយព្រះបរមគ្រូយ៉ាងក្រៃលែង ។ ប៉ុន្តែខណៈនោះ មានភិក្ខុមួយរូបឈ្មោះសុភទ្ទ បានចូលមកបួសនៅក្នុងពេលខ្លួនមានវ័យចាស់ជរា ជាបុគ្គលមួយរូបដែលរីករាយ ចំពោះការយាងចូលបរិនិព្វានរបស់ព្រះពុទ្ធបរមគ្រូ ។

ភិក្ខុរូបនោះបានពោលទៅកាន់ភិក្ខុឯទៀតថា “ម្នាលគ្នាយើងអើយ! ចូរកុំសោយសោកធ្វើអ្វី, កុំយំធ្វើអ្វី, ឥឡូវនេះពួកយើងមានសេរីភាព រួចពីមហាសមណៈអង្គនោះហើយ ។ កាលព្រះអង្គគង់នៅតែងស្ដីបន្ទោស និងធ្វើឲ្យពួកយើងខ្វល់ខ្វាយក្នុងចិត្តជានិច្ច ដោយព្រះតម្រាស់ថា ធ្វើយ៉ាងនេះ

ត្រឹមត្រូវតាមវិន័យ ធ្វើយ៉ាងនោះមិនត្រឹមត្រូវតាមវិន័យ ។ ឥឡូវនេះយើងមានសេរីភាពហើយ ចង់ធ្វើអ្វីក៏ធ្វើតាមដែលយើងចង់ហើយតើ...” ។

ពាក្យចម្រូងចម្រាស់នេះ បានជ្រុះចុះពីបបូរមាត់សាវ័ករបស់ព្រះពុទ្ធ នៅពេលដែលព្រះបរមគ្រូបរិនិព្វានកន្លងទៅ មិនទាន់បានពេញមួយសប្តាហ៍ផង ។ ពាក្យនេះជាមូលហេតុនាំឲ្យព្រះមហាកស្សប ជាសាវ័កច្បងលំដាប់ទីបី ផ្តើមគំនិតដឹកនាំព្រះអរហន្ត៥០០អង្គ លើកសង្គាយនាឡើងដើម្បីការពារនិងពង្រឹងធម៌វិន័យ ដែលជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធបរមគ្រូ (ពុទ្ធវចនៈ) ។ ព្រះមហាកស្សបបានពិគ្រោះយោបល់ ជាមួយព្រះថេរៈដទៃៗទៀត ហើយព្រះអរហន្តទាំងនោះ ក៏បានយល់ស្របតាមសំណើនោះឯង ។

ស្តេចអជាតសត្តុជាព្រះចៅក្រុងរាជគ្រឹះ ក៏ទ្រង់បានយល់ពីបំណងប្រាថ្នា របស់ព្រះសង្ឃទាំងអស់អង្គនោះដែរ ទ្រង់បញ្ជាឲ្យគេចាត់ចែងកិច្ចការសំខាន់ៗ សម្រាប់ថ្វាយដល់ការប្រជុំសង្ឃ នៅត្រង់ទ្វារចូលទៅកាន់សត្តបណ្ណគុហា ទៀបក្រុងរាជគ្រឹះ ។

អាសនៈចំនួនប្រាំរយបានរៀបចំទុក នៅក្នុងសាលប្រជុំដ៏ធំទូលាយមួយ, ប៉ុន្តែព្រះសង្ឃជាព្រះអរហន្ត មានតែចំនួន៤៩៩អង្គប៉ុណ្ណោះ ដែលបានជ្រើសរើសសម្រាប់ការចូលរួមក្នុងសង្គាយនានោះ ។ អាសនៈមួយនៅទំនេ ត្រូវគេរក្សាទុកសម្រាប់ព្រះអានន្ទ ដែលបានសម្រេចត្រឹមតែថ្នាក់

សោតាបន្នៈប៉ុណ្ណោះ, ប៉ុន្តែលោកត្រូវបានព្រះអរហន្តទាំងអស់ ប្រមើលទុកជាមុនថាលោកនឹងបានសម្រេចជាព្រះអរហន្ត នៅក្នុងពេលសមស្របមួយ ។ ក្រោយនោះបន្តិចមក ព្រះអានន្ទបានសម្រេចនូវភាពជាព្រះអរហន្តដូចដែលបានគិតទុកមែន, បន្ទាប់ពីបានសម្រេចជាព្រះអរហន្តមក លោកបានបង្ហាញខ្លួននៅក្នុងអង្គប្រជុំ ដោយឫទ្ធិខាងផ្លូវចិត្តដែលលោកមាន ដើម្បីចូលទៅគង់នៅលើអាសនៈទំនេនោះ ។

ព្រះមហាកស្សប ត្រូវបានតែងតាំងធ្វើជាប្រធាននៃអង្គប្រជុំ ព្រះឧបាលិនិងព្រះមហាអានន្ទ ធ្វើជាអ្នកដឹកនាំខាងវិន័យ និងព្រះធម៌ ។

បឋមសង្គាយនា បានលើកឡើងក្នុងរយៈពេលបីខែ បន្ទាប់ពីព្រះពុទ្ធបរមគ្រូបរិនិព្វានទៅ និងនៅក្នុងឆ្នាំទី៨ នៃការឡើងគ្រងរាជ្យរបស់ស្តេចអជាតសត្តុ ។ បឋមសង្គាយនានេះ បានប្រព្រឹត្តអស់ថេរៈវេលា៧ខែគត់ ។

## ត្រៃបិដក

វិន័យ គឺជាសរសៃឈាមរស់របស់ព្រះពុទ្ធសាសនា ដែលត្រូវបានលើកយកមកបង្ហាត់បង្រៀនមុនគេបង្អស់ ។

## ព្រះវិន័យចែកចេញជា ៥ គម្ពីរគឺ៖

១-បារាជិកគរុកាបត្តិ (អាបត្តិមានទោសធ្ងន់)

២-បាចិត្តិយៈ លហុកាបត្តិ (អាបត្តិមានទោសស្រាល)

} វិភង្គ

៣-មហាវគ្គ ផ្នែកធំ

៤-ចុល្លវគ្គ ផ្នែកតូច

} ខន្ធកៈ

៥-បរិវារៈ សេចក្តីសង្ខេបរបស់វិន័យ

## ព្រះធម៌ចែកចេញជា ៥ និកាយ គឺ៖

១-ទីឃនិកាយ ការប្រមូលព្រះធម៌ទេសនាខ្នាតវែង

២-មជ្ឈិមនិកាយ ការប្រមូលព្រះធម៌ទេសនាខ្នាតកណ្តាល

៣-សំយុត្តនិកាយ ការប្រមូលសុភាសិតដែលដូចៗគ្នា

៤-អង្គុត្តរនិកាយ ការប្រមូលព្រះធម៌ទេសនាដែលបានចាត់ចែងការអនុញ្ញាតជាមួយនឹងចំនួន ។

៥-ខុទ្ទកនិកាយ ការប្រមូលព្រះធម៌ខ្នាតតូចៗ ។

## គម្ពីរខុទ្ទកនិកាយចែកជា ១៥ គម្ពីរគឺ៖

១-ខុទ្ទកបាឋ អត្ថបទខ្លី

២-ធម្មបទ ផ្លូវនៃសច្ចៈ

៣-ឧទាន កាបន្លឺឡើង

| | |
|---|---|
| ៤-ឥតិវុត្តកៈ | ព្រះធម៌ទេសនាដែលបាន "និយាយដូច្នេះថា" |
| ៥-សុត្តនិបាត | ព្រះធម៌ទេសនាដែលបានប្រមូលហើយ |
| ៦-វិមានវត្ថុ | រឿងរ៉ាវទាំងឡាយស្ដីពីទេវវិមាន |
| ៧-បេតវត្ថុ | រឿងរ៉ាវទាំងឡាយស្ដីពីពួកប្រេត |
| ៨-ថេរគាថា | សុភាសិតរបស់ព្រះថេរៈ |
| ៩-ថេរីគាថា | សុភាសិតរបស់ព្រះថេរី |
| ១០-ជាតក | រឿងរ៉ាវពីជាតិកំណើត |
| ១១-និទ្ទេស | ការថ្លែងនិទាន |
| ១២-បដិសម្ភិទា | ចំណេះដឹងក្នុងការវិភាគ |
| ១៣-អបទាន | ជីវិតរបស់ព្រះអរហន្ត |
| ១៤-ពុទ្ធវំសៈ | ប្រវត្តិរបស់ព្រះពុទ្ធ |
| ១៥-ចរិយាបិដក | ទម្រង់នៃចរិយា ។ |

គួរកត់សម្គាល់ថា ស្ទើរគ្រប់ព្រះសូត្រសុទ្ធសឹងតែផ្ដើមឡើង ដោយពាក្យថា "ឯវម្មេ សុតំ... ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះថា..." ត្រូវបានសូត្រផ្ទាល់មាត់ដោយព្រះអានន្ទត្ថេរ ។

គម្ពីរអភិធម្ម តាមប្រពៃណីត្រូវបានបង្ហាត់ ដោយព្រះអរហន្តទាំងអស់អង្គ ដែលមានវត្តមាននៅក្នុងអង្គប្រជុំនោះ ។

# អភិធម្មបិដកចែកចេញជា ៧ គម្ពីរមាន

១-ធម្មសង្គណិ ការចាត់ព្រះធម៌ជាថ្នាក់ៗ

២-វិភង្គ គម្ពីរដែលបំបែកធម៌ជាក្រុម

៣-កថាវត្ថុ ចំណុចដែលមានការមិនចុះសម្រុងគ្នា

៤-បុគ្គលប្បញ្ញត្តិ ការអធិប្បាយពីបុគ្គល

៥-ធាតុកថា ការជជែកដេញដោលជាមួយការអះអាងដល់ធាតុ

៦-យមកៈ គម្ពីរដែលចែកធម៌ជាគូៗ

៧-បដ្ឋាន គម្ពីរដែលទាក់ទងគ្នា ។

គម្ពីរទាំង៣១នេះ ត្រូវបានគេប្រមូលរួមគ្នាឲ្យឈ្មោះថា ត្រៃបិដក (កញ្ជើបី) ។ ទីមួយគឺវិនយបិដក (កញ្ជើព្រះវិន័យ) ដែលទាក់ទងយ៉ាងធំជាមួយការគ្រប់គ្រង និងបទបញ្ញាផ្សេងៗ ដែលព្រះពុទ្ធបានបញ្ញត្តមកហើយសម្រាប់ជាវិន័យរបស់ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃសុត្តន្តបិដក (កញ្ជើព្រះសូត្រ) មានភាគច្រើនជាព្រះធម៌ទេសនា ដែលសម្ដែងដោយព្រះពុទ្ធ នៅក្នុងឱកាសផ្សេងៗគ្នា ។ ព្រះធម៌ទេសនាខ្លះសម្ដែងដោយព្រះមហាសារីបុត្រ ព្រះមហាមោគ្គល្លាន ព្រះមហាអានន្ទ ។ល។ ក៏ត្រូវបានរាប់បញ្ចូលទៅក្នុងបិដកនេះទាំងអស់ ។ អភិធម្មបិដក (កញ្ជើនៃគម្ពីរដ៏ខ្ពស់បំផុត) ជាទស្សនវិជ្ជាដ៏ជ្រៅបំផុត នៃពាក្យប្រដៅរបស់ព្រះពុទ្ធ ។

គម្ពីរព្រៃបិដកត្រូវបានកត់ត្រាជាដំបូង នៅក្នុងអលុវិហារ ប្រទេសស្រីលង្កា រវាង៨០ឆ្នាំមុនគ.ស. នៅក្នុងរជ្ជកាលស្ដេចវដ្ដគាមិណីអភយ ។

## ទុតិយសង្គាយនា

សង្គាយនាលើកទីពីរ ត្រូវបានលើកឡើងនៅក្រុងវេសាលី ក្នុងឆ្នាំទី១០នៃរជ្ជកាលស្ដេចកាឡាសោក បន្ទាប់ពីព្រះពុទ្ធអង្គបរិនិព្វានកន្លងទៅបាន១០០ឆ្នាំ ។

## វត្ថុ១០យ៉ាងដែលមិនមែនជាវិន័យ

សម័យនោះ នៅក្នុងក្រុងវេសាលី មានពួកភិក្ខុអលជ្ជី គ្មានការអៀនខ្មាស់ជាច្រើនអង្គ ដែលស្ថិតនៅក្នុងក្រុងវជ្ជិ បានប្រកាសថាវត្ថុ១០យ៉ាងដូចខាងក្រោមនេះ គឺជាវិន័យដែលព្រះពុទ្ធបានអនុញ្ញាតរួចហើយៈ

១.សិង្គិលោណកប្បៈ ការរក្សាអំបិលទុកនៅក្នុងស្នែង ។ល។ សម្រាប់ប្រើនៅវេលាណាដែលគ្មានអំបិល គឺជាការត្រឹមត្រូវ ។

២.ទ្វង្គុលកប្បៈ ការបរិភោគអាហារ ដរាបដល់ព្រះអាទិត្យជ្រេប្រមាណពីរធ្នាប់ ជាការត្រឹមត្រូវ ។

៣.គាមន្តរកប្បៈ ភិក្ខុដែលបានឆាន់អាហាររួចហើយ អាចទទួលឆាន់អាហារម្ដងទៀត ដោយគ្មានការនិមន្តទៅកាន់ចន្លោះភូមិសមរម្យដល់

ចារឹត្តវិន័យ ប្រសិនបើភិក្ខុនោះបានតាំងចិត្តចូលទៅកាន់ក្នុងភូមិជាការត្រឹមត្រូវ ។

៤.អាវាសកប្ប: ការសម្តែងឧបោសថនៅក្នុងអាគារបែកគ្នាបាននៅក្នុងករណីសីមាធំពេក ជាការត្រឹមត្រូវ ។

៥.អនុមតិកប្ប: ការសម្តែងវិន័យជាដំបូង ហើយបន្ទាប់មកនាំយកឆន្ទៈ នៃភិក្ខុដែលមិនបានចូលរួម ជាការត្រឹមត្រូវ ។

៦.អាចិណ្ណកប្ប: ការអនុលោមតាមការប្រតិបត្តិគ្រូឧបជ្ឈាយាចារ្យ ជាការត្រឹមត្រូវ ។

៧.អមថិតកប្ប: ភិក្ខុដែលបានបញ្ចប់ការឆាន់អាហារ ហើយអាចទទួលឆាន់ទឹកដោះ ដែលបានធ្វើឲ្យប្រាស់ចាកធាតុដើមបាន តែមិនអាចឆាន់ទឹកដោះខាប់បាន ដោយគ្មានការធ្វើឲ្យបានសមរម្យតាមព្រះវិន័យ ជាការត្រឹមត្រូវ ។

៨.ជលោគិកប្ប: ការទទួលឆាន់សុរាដែលមិនមានជាតិស្រវឹងបាន ជាការត្រឹមត្រូវ ។

៩.អទសកនិសីទនកប្ប: ការប្រើកម្រាលនិសីទនៈដែលមិនមានជាយរំយោល ជាការត្រឹមត្រូវ ។

១០.ជាតរូបទិកប្ប: ការទទួលយល់ព្រមកាន់មាសនិងប្រាក់បានជាការត្រឹមត្រូវ ។

ព្រះយសត្ថេរ ដែលបាននិមន្តមកកាន់ទីនោះ បានឮការបង្រៀនពីអញ្ញទិដ្ឋិយ៉ាងនេះហើយ បានសម្រេចចិត្តថាសូម្បីតែមានតម្លៃ ដល់បាត់បង់ជីវិតក៏ដោយ ក៏លោកត្រូវក្តិចយកពន្លកត្រួយ នៃការយល់ខុសទាំងនោះចេញឲ្យខាងតែបាន ។ លោកប្រឹងប្រែងបញ្ចុះបញ្ចូលរឿងនោះ ទៅព្រះថេរៈជាអ្នកចេះដឹងដទៃទៀត ឲ្យជួយដោះស្រាយរហូតបានទទួលជោគជ័យ ។ ព្រះរេវតត្ថេរ ដែលត្រូវបានសួរអំពីសំណួរទាំងនោះ បានផ្តល់ចម្លើយថា អំពើនោះមិនត្រឹមត្រូវតាមព្រះវិន័យទេ ។

ទីបំផុត ព្រះអរហន្តដែលមានការចេះដឹងជ្រៅជ្រះ ចំនួន៨អង្គ បានមកប្រជុំគ្នានៅវាលុការាម ក្នុងក្រុងវេសាលី ។ ព្រះសព្វកាមិ ជាព្រះអរហន្តជាន់ខ្ពស់មួយអង្គ ដែលបានរស់នៅរយៈពេល១២០ព្រះវស្សាមកហើយ ចាប់តាំងពីលោកបានឧបសម្បទាមក, ឯព្រះរេវតត្ថេរជាអ្នកលើកបញ្ហា មកសួរដេញដោលម្តងមួយចំណុចៗ ។ ចុងក្រោយបំផុត បានកាត់សេចក្តីថាការប្រព្រឹត្តទាំង១០ចំណុចនោះ សុទ្ធតែខុសនឹងព្រះពុទ្ធវិន័យទាំងអស់ ។

បន្ទាប់ពីនោះមក ព្រះរេវតត្ថេរបានជ្រើសព្រះអរហន្ត ដែលចេះដឹងចំណាន១៧០០អង្គ បានលើកសង្គាយនាឡើង ក្នុងគោលបំណងការពារព្រះធម៌វិន័យរបស់ព្រះបរមគ្រូ។ សង្គាយនាលើកទីពីរនេះមានថេរវេលា៨

ខែ ក្រោមព្រះរាជូបត្ថម្ភរបស់ស្ដេចកាឡាសោក ជាស្ដេចនៃដែនវជ្ជី ។ ព្រះសព្វកាមិ ជាប្រធាននៃទុតិយសង្គាយនានេះ ។

ចំណោមព្រះអរហន្ត ដែលបានចូលធ្វើសង្គាយនានោះ មានព្រះសព្វកាមិ, ព្រះសាឡ្ហៈ, ព្រះរេវតៈ, ព្រះខុជ្ជសោភិតៈ, ព្រះយសៈ, ព្រះសម្ភូតៈ, និងព្រះសានវាសិកៈ ។ ទាំងអស់អង្គខាងលើនេះសុទ្ធតែជាសិស្សរបស់ព្រះមហាអានន្ទ, ព្រះវសភគាមិកៈ និងព្រះសុមនៈ ជាសិស្សរបស់ព្រះអនុរុទ្ធ ដែលមានព្រះជន្មរស់នៅ តាំងពីសម័យព្រះពុទ្ធគង់ធរមាននៅឡើយ ។

## តតិយសង្គាយនា

ការប្រោសបានស្ដេចធម្មាសោកមួយអង្គ គឺជាសម្បត្តិមហាសាលរបស់ព្រះពុទ្ធសាសនា, ទ្រង់បានជួយឧបត្ថម្ភគាំទ្រដល់ព្រះពុទ្ធសាសនា ធ្វើឲ្យមានភាពរុងរឿងក្រៃលែង និងធ្វើឲ្យព្រះពុទ្ធសាសនារបស់ព្រះតថាគតរីកលូតលាស់ឡើងបន្តិចម្ដងៗ ទាំងផ្នែកគុណភាព(ខ្លឹមសារ) ទាំងផ្នែកបរិមាណ(ចំនួន) ។ មានអ្នកចូលមកបួសបួម(បន្លំ) នៅក្នុងព្រះពុទ្ធសាសនា គឺមាននិកាយប្លែកៗយ៉ាងច្រើន ចូលមកបួសនៅក្នុងជួរសង្ឃ ហើយបានបំពុលព្រះពុទ្ធសាសនា ដោយការចិញ្ចឹមជីវិតក្នុងផ្លូវអាក្រក់ និងការសម្ដែងចេញពីទស្សនៈនៃលទ្ធិរបស់ពួកគេផ្ទាល់ ។

ព្រះមហាមោគ្គលីបុត្តិស្សត្ថេរ ដែលជាព្រះអរហន្តចាស់ទុំជាងគេ បានយល់ច្បាស់ពីការបំពុលនៅក្នុងជួរសង្ឃ, លោកក៏ឈប់ធ្វើឧបោសថជាមួយភិក្ខុសង្ឃអស់រយៈពេល៧ឆ្នាំ ហើយទៅគង់នៅតំបន់ដាច់ស្រយាលមួយ នៅទៀបមាត់ស្ទឹងអហោគង្គា ។

នៅពេលនោះ ស្តេចធម្មាសោកមានការសង្ស័យចំពោះអំពើមិនបានគិតទុកមួយ ដែលបានបង្កឡើងដោយមន្ត្រីមិនទទួលខុសត្រូវម្នាក់ ។ មានគេទូលថ្វាយព្រះអង្គថា ព្រះអរហន្តមោគ្គលីបុត្តិស្សត្ថេរមានសមត្ថភាព អាចជម្រះនូវក្តីមន្ទិលសង្ស័យនេះថ្វាយព្រះអង្គបាន ។ ស្តេចបានបញ្ជូនព្រះរាជសារទៅថ្វាយព្រះអរហន្ត ប៉ុន្តែលោកមិនបាននិមន្តមកតាមការនិមន្តនោះទេ ។ ក្រោយពីបរាជ័យចំនួនពីរលើក ស្តេចក៏បញ្ជូនអ្នកនាំព្រះរាជសារជាលើកទីបីទៀត ដើម្បីនិមន្តព្រះអង្គមកជួយការពារព្រះពុទ្ធសាសនា ។ ព្រះមហាថេរៈមោគ្គលីបុត្តិស្ស ក៏យល់ព្រមតាមការអារាធនានិមន្តនោះ ហើយក៏និមន្តទៅកាន់ទីក្រុងបាដលិបុត្រភ្លាមដែរ ។ ស្តេចធម្មាសោកបានយាងទៅស្វាគមព្រះថេរៈ ប្រកបដោយកិត្តិយសក្រៃលែង ហើយបញ្ជាឲ្យរៀបចំកន្លែង សម្រាប់ថ្វាយព្រះថេរៈគង់នៅក្នុងវត្តអសោការាម ដែលបានកសាងឡើងដោយព្រះរាជាធម្មាសោកផ្ទាល់ ។ ស្តេចបានស្នាក់នៅជាមួយព្រះមោគ្គលីបុត្តិស្ស ដើម្បីស្តាប់ព្រះធម៌, ទ្រង់គង់នៅក្បែរព្រះបាទរបស់ព្រះអរហន្ត រយៈពេលប្រាំពីរថ្ងៃ ។

ពួកភិក្ខុជាប់សង្ស័យ ដែលត្រូវបានធ្វើការសាកសួរដេញដោល បានឆ្លើយសំណួរតាមការយល់ឃើញរបស់ពួកគេ ដែលខុសពីធម៌វិន័យរបស់ព្រះពុទ្ធបរមគ្រូ ត្រូវបានបណ្តេញចេញពីជួរសង្ឃពិតប្រាកដ ។

ពួកភិក្ខុបរិសុទ្ធដែលគង់នៅ បានព្រមព្រៀងធ្វើឧបោសថកម្មជាលើកដំបូង បន្ទាប់ពីខកខានមិនបានធ្វើអស់ពេលប្រាំពីរឆ្នាំមកហើយ ។ នៅក្នុងឱកាសនោះ ព្រះមហាមោគ្គលីបុត្តិស្សត្ថេរខ្លួនព្រះអង្គផ្ទាល់ បានលើកឡើងនូវសង្គាយនាលើកទី៣ នៅក្នុងបំណងការពារពុទ្ធសាសនា ។

ព្រះអរហន្តចំនួន ១០០០អង្គ បាននិមន្តចូលរួមជាសមាជិក នៅក្នុងសង្គាយនានោះ ។ មហាសន្និបាតសង្ឃលើកទី៣នេះ ដែលត្រូវបានលើកឡើង នៅក្នុងវត្តអសោការាម ក្រុងបាដលិបុត្រ នៅក្នុងឆ្នាំទី១៨នៃការឡើងគ្រងរាជសម្បត្តិរបស់ស្តេចធម្មាសោក, នៅរវាង២៣៦ឆ្នាំបន្ទាប់ពីបរិនិព្វានរបស់ព្រះពុទ្ធអង្គ ។ ព្រះមហាមោគ្គលិបុត្តិស្សត្ថេរ ជាប្រធាននៃតតិយសង្គាយនា និងជាអ្នកទទួលខុសត្រូវក្នុងការឆ្លើយ និងក្នុងការតាក់តែងគម្ពីរកថាវត្ថុបករណ៍ ជាគម្ពីរមួយក្នុងចំណោមគម្ពីរទាំងប្រាំពីរ របស់គម្ពីរអភិធម្មបិដក ។ សង្គាយនាលើកទី៣ ជាមហាសន្និបាតសង្ឃមួយ គួរឲ្យគោរពនិងសរសើរក្រៃលែង ។

# ១៨ ស្ដេចធម្មាសោក និង បេសកកម្ម

រាជធានីដែលកសាងថ្មីឈ្មោះបាដលិបុត្រ គ្រប់គ្រងដោយស្ដេចមោរ្យ៉នឈ្មោះចន្ទ្រគុប្ដៈ ។ ស្ដេចពិន្ទុសារជាបុត្ររបស់ព្រះអង្គ មានព្រះមហេសីចំនួន១៦អង្គ ដែលបានប្រសូតបុត្ររហូតដល់ទៅ១០១អង្គ ។ បណ្ដាព្រះរាជបុត្រទាំងនោះ ព្រះអង្គម្ចាស់អសោក មានឈ្មោះល្បីរន្ទឺខ្លាំងណាស់ ។ មាតារបស់ព្រះអង្គឈ្មោះសុភទ្រង្គិ នៅមានឈ្មោះមួយទៀតថា "ធម្មា", បងប្រុសរួមបិតាដែលចាស់ជាងគេ ឈ្មោះសុមនៈ ឬ សុសិមា, ចំណែកប្អូនប្រុសរួមផ្ទៃមាតា គឺព្រះម្ចាស់អសោកតិស្សៈ និងមានឈ្មោះមួយទៀតថា វិតសោក ឬ វិគតសោក ។

## ព្រះអង្គម្ចាស់អសោក

ព្រះអង្គម្ចាស់អសោកមានមហេសីប្រាំព្រះអង្គ ។ នៅខណៈដែលព្រះអង្គយាងទៅបំពេញបេសកកម្ម ក្នុងនាមជារាជានុសិទ្ធិនៅដែនអវន្តិទ្រង់បានរៀបអភិសេកជាមួយព្រះរាជធីតា របស់សាក្យត្រកូលមួយអង្គឈ្មោះទេវី ហើយនៅមានមហេសីប្អូនអង្គទៀតគឺ ព្រះនាងការុវកិ, ព្រះនាងអសន្ធិមិត្តា (ជាព្រះរាជអគ្គមហេសី) ព្រះនាងបទុមវតិ និងព្រះនាងតិស្សរក្ខិតា ។

ព្រះអង្គម្ចាស់អសោកមានព្រះរាជបុត្របួនអង្គ និងរាជធីតាពីរអង្គ, ព្រះមហិន្ទ្រះនិងព្រះនាងសង្ឃមិត្តា ជាបុត្រប្រសូតចេញពីព្រះនាងទេវី ។ ព្រះអង្គម្ចាស់តិសវៈជាបុត្ររបស់ព្រះនាងករុវាកិ ហើយព្រះអង្គម្ចាស់កុនាល ជាបុត្ររបស់ព្រះនាងបទុមវតី ។ ស្ដេចអសោកមានបុត្រមួយអង្គទៀត ឈ្មោះជលោកៈ និងបុត្រីមួយអង្គទៀតឈ្មោះចារុមតិ ។

ព្រះអង្គម្ចាស់អគ្គិមុខ ជាស្វាមីរបស់នាងសង្ឃមិត្តា, ចំណែកព្រះអង្គម្ចាស់ទេវបាលក្សត្រីយ៍ នៃរាជធានីលិតបុរៈ ប្រទេសនេប៉ាល់ ជាស្វាមីរបស់ព្រះបុត្រីឈ្មោះចារុមតិ និងជាបុត្រប្រសាររបស់ស្ដេចអសោក ។

ព្រះអង្គម្ចាស់ទសរថ បានឡើងគ្រងរាជ្យស្នងព្រះបាទធម្មាសោក, ឯព្រះអង្គម្ចាស់សម្បតិ ជាបុត្ររបស់ព្រះអង្គម្ចាស់កុនាល, ព្រះអង្គម្ចាស់សុមនៈជាព្រះរាជបុត្ររបស់ព្រះនាងសង្ឃមិត្តា និងត្រូវជាចៅរបស់ស្ដេចអសោក ។

## ព្រះអង្គម្ចាស់អសោកក្លាយជាស្ដេច

យោបល់របស់អ្នកប្រាជ្ញជាច្រើននាក់ បាននិយាយឡើងថា ស្ដេចអសោកប្រសូតនៅក្នុងឆ្នាំ៣០៤មុនគ.ស. ។ តាមកាលប្បវត្តិជាភាសាបាលី ស្ដេចអសោកត្រូវបានគេអះអាងថា បានឡើងគ្រងរាជ្យជាស្ដេចនៅរវាង២១៥ឆ្នាំ ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធបរមគ្រូ, ប៉ុន្តែការរៀបចំ

ពិធីអភិសេកតាមប្រពៃណី ត្រូវបានធ្វើឡើងបួនឆ្នាំក្រោយមកទៀត ។ ស្តេចអសោកបានសោយរាជ្យអស់រយៈពេល៣៧ឆ្នាំ បន្ទាប់ពីការបានទទួលរាជាភិសេកមក ។ ព្រះអង្គប្រហែលជាឡើងគ្រងរាជ្យ នៅក្នុងព្រះជន្ម៣០ព្រះវស្សា ហើយចូលទិវង្គតនៅក្នុងព្រះជន្ម៧១ ព្រះវស្សា ។

កាលប្បវត្តិជាភាសាបាលី បានរៀបរាប់ពីរឿងរ៉ាវស្តេចអសោក និងមហិច្ឆតារបស់ព្រះអង្គ សម្រាប់ការឡើងកាន់អំណាចជាន់ខ្ពស់ ដោយការធ្វើឃាតបងប្អូនប្រុសបង្កើតទាំងអស់ លើកលែងតែប្អូនប្រុសរួមមាតាគឺព្រះអង្គម្ចាស់តិស្សៈចេញ ដែលក្រោយមកបានចូលបួសជាសង្ឃ ហើយបានសម្រេចជាព្រះអរហន្ត ។ អ្នកប្រាជ្ញខ្លះទៀត មិនយល់ព្រមតាមរឿងខាងលើនេះទេ ដោយសំអាងថាបទបញ្ញត្តិរបស់ស្តេចអសោកបង្ហាញថាបងប្អូនប្រុសខ្លះៗរបស់ស្តេចអសោក នៅមានជីវិតរស់រានទៅបន្ទាប់ពីព្រះអង្គ បានឡើងគ្រងរាជ្យមក ។

ដោយហេតុថា ព្រះអង្គសម្លាប់បងប្អូនឯងបង្កើត និងសេចក្តីទុក្ខសោកមិនអាចរៀបរាប់បាន បានកើតឡើងចំពោះគ្រួសារមួយ ដោយសារការធ្វើចម្បាំងអយុត្តិធម៌របៀបនេះ ទើបព្រះអង្គត្រូវបានគេថ្វាយនាមដ៏អសោចិ៍មួយថា ចណ្ឌាសោក (ស្តេចអសោកកំណាច), ប៉ុន្តែបន្ទាប់ពីព្រះអង្គបានងាកមកគោរពព្រះពុទ្ធសាសនា ទ្រង់បានក្លាយជាស្តេចគំរូមួយអង្គ ដែលព្រះនាមរបស់ព្រះអង្គ ត្រូវបានប្តូរទៅជាស្តេចធម្មាសោកវិញ (ស្តេច

អសោកប្រកបដោយធម៌), ទេវានម្បិយៈ (ជាទីស្រឡាញ់នៃទេវតា), បិយទស្សី (ឃើញគួរឲ្យរីករាយ) ។

## ការងាកមករកព្រះពុទ្ធសាសនា

ជាមួយនឹងប្រពៃណីនៃព្រះរាជវាំង ស្ដេចអសោកបានថ្វាយទានយ៉ាងទៀងទាត់ដល់ពួកជីព្រាហ្មណ៍, ប៉ុន្ដែព្រះអង្គមិនបានរីករាយជាមួយនឹងការប្រព្រឹត្ត របស់ពួកព្រាហ្មណ៍ទាំងនោះឡើយ ។ ថ្ងៃមួយ នៅក្នុងខណៈដែលព្រះអង្គកំពុងទតមើលតាមបង្អួចដូចធម្មតា ទ្រង់បានឃើញសាមណេរមួយអង្គ មានឥន្ទ្រីយ៍ស្រគតស្រគំ មានអាយុប្រមាណ១២ឆ្នាំ កំពុងនិមន្ដសន្សឹមៗតាមបណ្ដោយផ្លូវ ជាមួយនឹងសតិសង្រួមគួរឲ្យជ្រះថ្លាពន់ពេក ។ ស្ដេចអសោកបានឲ្យគេនិមន្ដសាមណេរនោះ ចូលក្នុងព្រះរាជវាំង ហើយបានថ្វាយនូវអាសនៈដ៏សមរម្យសម្រាប់គង់ ។ ដោយទតឃើញថា ព្រះអង្គខ្វះខាតភាពខ្ពង់ខ្ពស់ខាងផ្លូវសីលធម៌ ស្ដេចអសោកមានព្រះតម្រិះថា "ពិតប្រាកដណាស់ហើយ ព្រះអង្គនឹងទៅជាអ្នកដឹកនាំនៃកន្លែងនេះ" ។ បន្ទាប់មក ស្ដេចបានផ្គត់ផ្គង់ដល់សាមណេរនោះ ដោយកិត្តិយសខ្ពស់ក្រៃលែង ហើយព្រះអង្គវិញគង់លើអាសនៈទាបមួយ ដើម្បីស្ដាប់សាមណេរសម្ដែងធម៌ទេសនា ។ សាមណេរក្មេងនោះឈ្មោះនិគ្រោធ បានសម្ដែងធម៌ថ្វាយស្ដេចអសោក ដោយគាថាដូចខាងក្រោម ដែលជាគាថាធម្មបទ៖

“សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់
សេចក្តីប្រមាទ ជាផ្លូវនៃសេចក្តីស្លាប់,
អ្នកប្រមាទទុកដូចជាស្លាប់
អ្នកមិនប្រមាទទុកដូចជាមិនស្លាប់” ។

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូ បានទាក់ទាញស្តេចធម្មាសោក និងញុំាងព្រះអង្គឲ្យក្លាយជា អគ្គពុទ្ធសាសនិកដ៏ឆ្នើមមួយអង្គ ។ ការងាកចេញរបស់ព្រះអង្គពីព្រហ្មញ្ញសាសនា បានជាចំណុចមួយនៃការខិតខំប្រឹងប្រែង ដែលស្តេចអសោកបានកែខ្លួនបន្តិចម្តងៗ ដោយខ្លួនព្រះអង្គឯង ។ ទស្សនវិស័យរបស់ព្រះអង្គស្តីពីជីវិត ត្រូវបានផ្លាស់ប្តូរទាំងស្រុង, ទ្រង់ពេញព្រះទ័យនឹងធម្មវិជ័យ (ការគ្រប់គ្រងតាមផ្លូវធម៌) ទៅកាន់ទិគវិជ័យ (ការគ្រប់គ្រងដោយពាក្យ) ។ ផ្នែកខាងក្រោយនៃជីវិត ព្រះអង្គបានក្លាយជាអ្នកមានសទ្ធាជឿស៊ុបក្នុងព្រះពុទ្ធសាសនា និងជាអធិរាជមួយអង្គគ្រប់គ្រងនគរតាមផ្លូវព្រះធម៌ ។

ទោះបីស្តេចធម្មាសោក មានព្រះទ័យធ្ងន់លើព្រះពុទ្ធសាសនា បន្ទាប់ពីទ្រង់បានជួបសាមណេរនិគ្រោធមកក៏ដោយ ក៏ព្រះអង្គមិនបានលះបង់មហិច្ឆតារបស់ព្រះអង្គ ពីការពង្រីកអំណាចជាអធិរាជឡើយ, តែបន្ទាប់ពីសង្គ្រាមនៅរដ្ឋកាលិង្គៈ(ក្លិង្គ)មក ព្រះអង្គបានក្លាយជាអគ្គពុទ្ធសាសនិកពិតប្រាកដ ដោយការលះបង់ចោលនូវការធ្វើសង្គ្រាមដោយ

អាវុធ ។ ព្រះអង្គជាស្តេចមួយអង្គ ដែលត្រូវបានអ្នកប្រវត្តិសាស្ត្រកត់ត្រាទុកថា បានលះបង់ចោលសង្គ្រាម បន្ទាប់ពីបានទទួលជោគជ័យមក ។

បន្ទាប់ពីនោះមក ព្រះអង្គបានក្លាយជាស្តេចពុទ្ធសាសនិកយ៉ាងល្អវិសេស, ទ្រង់មានថាមពលមិនចេះរីងស្ងួត ក្នុងការផ្សព្វផ្សាយព្រះធម៌ មិនគ្រាន់តែនៅក្នុងប្រទេសឥណ្ឌា និងផ្នែកខ្លះនៃតំបន់អាស៊ីប៉ុណ្ណោះទេ, ប៉ុន្តែនៅក្នុងទ្វីបអឺរ៉ុបនិងតំបន់អាហ្វ្រិកាផងដែរ ។ ព្រះអង្គបានប្តូរព្រះពុទ្ធសាសនា ទៅជាសាសនាពិភពលោក, ទ្រង់បានធ្វើពាក្យប្រៀនប្រដៅសំខាន់ៗរបស់ព្រះពុទ្ធ ឲ្យមានប្រជាប្រិយភាព តាមបទបញ្ញត្តិជាសិលាចារឹកមួយចំនួនរបស់ព្រះអង្គ ។ ព្រះអង្គបានកសាងវិហារ(អារាម)ជាច្រើន នៅជុំវិញទីក្រុងបាដលិបុត្រ ដែលធ្វើឲ្យតំបន់នោះមានឈ្មោះថាវិហារ ក្រោយមកក្លាយជារដ្ឋពិហារ៍ ។ ស្តេចអសោកបានធ្វើធម្មយាត្រាទៅកាន់សំវេជនីយដ្ឋានសំខាន់ៗទាំងអស់ ដែលទាក់ទងនឹងជីវិតរបស់ព្រះពុទ្ធអង្គ ។ សូម្បីកន្លែងសម្លាប់សត្វសម្រាប់ការបរិភោគ នៅក្នុងព្រះរាជវាំង ក៏ត្រូវបានកាត់បន្ថយបន្តិចម្តងៗ រហូតឈានទៅបញ្ឈប់ទាំងស្រុង, ព្រះអង្គបានហាមការសម្លាប់សត្វមានជីវិតបូជាយញ្ញ ។ លោកបណ្ឌិតនេហរុនិយាយថា "...ឧទាហរណ៍របស់ស្តេចអសោក ក្នុងការផ្សាយព្រះពុទ្ធសាសនា បានផលធ្វើឲ្យការនិយមបរិភោគបន្លែ មានប្រជាប្រិយភាព" ។

ជាមួយនឹងព្រះរាជូបត្ថម្ភក៍របស់ព្រះអង្គ មិនគ្រាន់តែធ្វើឲ្យព្រះពុទ្ធសាសនាបានរុងរឿង នៅក្នុងសម័យកាលរបស់ព្រះអង្គតែប៉ុណ្ណោះទេ, ប៉ុន្តែទ្រង់ជាស្តេចពុទ្ធសាសនិកពិតមួយអង្គ មានសេចក្តីសន្តោសចំពោះសាសនាទាំងអស់ផងដែរ ។ បទបញ្ញត្តិលើសិលាចារឹកមួយ របស់ព្រះអង្គសរសេរថា:

"គ្រប់និកាយសាសនាទាំងអស់ ត្រូវគោរពចំពោះហេតុផល ឬសាសនាដទៃទៀតផង ។ ព្រោះហេតុនោះ អ្នកដែលបានធ្វើការអួតអាងពីនិកាយរបស់ខ្លួន នៅក្នុងពេលជាមួយគ្នានោះដែរ ក៏ត្រូវគោរពចំពោះនិកាយរបស់អ្នកដទៃទៀតផងដែរ..." ។

ស្តេចធម្មាសោកទ្រង់ចាប់អារម្មណ៍ខ្លាំង មិនគ្រាន់តែនៅក្នុងការអភិវឌ្ឍន៍ខាងសីលធម៌ និងផ្លូវស្មារតីរបស់ប្រជារាស្ត្រប៉ុណ្ណោះទេ, ប៉ុន្តែនៅក្នុងការអភិវឌ្ឍន៍ផ្នែកសម្ភារៈផងដែរ ។ ប្រជារាស្ត្រទាំងអស់របស់ព្រះអង្គ ទ្រង់បានរាប់អានដូចជាកូនចៅ, ព្រះអង្គមានបំណងលើកកំពស់សេចក្តីល្អជាសាធារណៈ ដែលទ្រង់មានបន្ទូលថា "នៅគ្រប់ពេលនិងគ្រប់ទីកន្លែង ទោះជាយើងកំពុងសោយអាហារក្តី នៅក្នុងបន្ទប់ជាមួយមហេសីក្តី នៅក្នុងបន្ទប់ផ្ទាល់របស់យើង ឬកំពុងផ្ទុំលក់ក្តី នៅក្នុងរាជរថ ឬនៅក្នុងព្រះរាជឧទ្យានក្តី, មន្ត្រីទាំងឡាយត្រូវថ្វាយរបាយការណ៍ដល់យើង នូវ

សេចក្តីត្រូវការរបស់ប្រជារាស្ត្រកុំខានឲ្យសោះ, យើងត្រូវធ្វើការងារគ្រប់យ៉ាងដើម្បីសុវត្ថិភាពរួមរបស់ប្រជារាស្ត្រ" ។

ពិតណាស់ ចំពោះព្រះរាជឱង្ការរបស់ព្រះអង្គ, ព្រះបាទធម្មាសោក ទ្រង់បានបំពេញការងារ ដូចជាព្រះបិតានៃប្រជារាស្ត្ររួម ។ នៅក្នុងសម័យស្តេចធម្មាសោក សួនច្បារសាធារណៈ, ឱសថបូរាណសម្រាប់ព្យាបាល, មន្ទីរពេទ្យសម្រាប់ព្យាបាលមនុស្សនិងសត្វ អណ្តូងទឹក ស្រះទឹក ផ្លូវថ្នល់ និងគ្រឹះស្ថានអប់រំបានដុះដាល និងរីកលូតលាស់ឡើងគ្រប់ទិសទីស្ទើរពេញផ្ទៃប្រទេស ។ ព្រះកិត្តិគុណរបស់ព្រះអង្គ ដែលមិនមានទីបំផុត ត្រូវបានគេនិយាយថា ស្តេចអសោកគឺជាក្សត្រដំបូងបំផុត ហើយនៅក្នុងប្រវត្តិសាស្ត្រពិភពលោក ដែលបានបង្កើតមន្ទីរព្យាបាលជម្ងឺសម្រាប់មនុស្សនិងសត្វ មិនមែនតែនៅក្នុងតំបន់អាស៊ីប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងតំបន់អឺរ៉ុប និងអាហ្វ្រិកាផងដែរ ។

ចំពោះការរិះគន់ដោយខ្វះការត្រិះរិះ បានបង្ខូចដល់កិត្តិយសព្រះពុទ្ធសាសនា ថាជាសាសនានាំឲ្យប្រទេសឥណ្ឌាស្រុតចុះ និងធ្វើឲ្យប្រទេសឥណ្ឌាវិនាសជាដើមនោះ ។ តាមពិតទៅព្រះពុទ្ធសាសនាបានរុងរឿង នៅក្នុងរជ្ជកាលរបស់ស្តេចធម្មាសោក គឺជាការឆ្លើយតបដ៏សមហេតុផលមួយហើយ ។

## បេសកកម្មរបស់ស្តេចធម្មាសោក

តាមប្រវត្តិសាស្ត្រជាភាសាបាលី នៅខាងចុងនៃតតិយសង្គាយនា ដែលបានលើកឡើងនៅក្នុងឆ្នាំទី១៧ នៃការឡើងគ្រងរាជ្យរបស់ ស្តេចធម្មាសោក, ស្ថិតនៅក្រោមអធិបតីភាព របស់ព្រះមហាមោគ្គលិ បុត្តិស្សត្ថេរ បានសម្រេចថាត្រូវបញ្ជូនព្រះអរហន្ត ដែលមានសមត្ថភាពទៅកាន់តំបន់ផ្សេងៗចំនួន៩កន្លែងខុសៗគ្នា ដើម្បីផ្សាយព្រះពុទ្ធសាសនា ។

## ព្រះនាមសាសនទូត និងឈ្មោះទីកន្លែង

| ព្រះនាមសាសនទូត | ឈ្មោះទីកន្លែង |
|---|---|
| -ព្រះមជ្ឈន្តិកត្ថេរ ............ | កាស្មៀរ និង ដែនគន្ធារៈ |
| -ព្រះមហាទេវត្ថេរ............. | មហីសកមណ្ឌលៈ |
| -ព្រះរក្ខិតត្ថេរ ................... | វនវាសី |
| -ព្រះយោនកធម្មរក្ខិតត្ថេរ ..... | អបរន្តតកៈ |
| -ព្រះមហាធម្មរក្ខិតត្ថេរ ......... | មហារដ្ឋៈ |
| -ព្រះមហារក្ខិតត្ថេរ........... | យោនកលោកៈ |
| -ព្រះមជ្ឈិមត្ថេរ ............... | ហិមវន្តបទេស |

-ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ ... សុវណ្ណភូមិ

-ព្រះមហិន្ទត្ថេរ, ព្រះឧត្តិយត្ថេរ, ព្រះឧត្តិយត្ថេរ, ព្រះសម្ពលត្ថេរ និងព្រះភទ្ទសាលត្ថេរ.............. តម្ពបណ្ណិទ្វីប ។

ឯកសារបញ្ជាក់ថា ក្នុងបេសកកម្មនីមួយៗ មានព្រះសង្ឃប្រាំអង្គ អមដំណើរជាមួយ ដើម្បីឲ្យមានលទ្ធភាពក្នុងការបំពេញឧបសម្បទា ឲ្យដល់កុលបុត្រនៅតំបន់ឆ្ងាយៗ ដែលមានបំណងចង់បួស ។

១-តំបន់កាស្មៀរ ស្ថិតនៅភាគពាយ័ព្យនៃប្រទេសឥណ្ឌា ។ សព្វថ្ងៃទីក្រុងប៉េសាវា (Peshawar), និងតំបន់រ៉ាវលបិណ្ឌិ (Raval pindi) ស្ថិតនៅខាងជើងរដ្ឋបញ្ចាប រាប់បញ្ចូលក្នុងដែនគន្ធារៈ ។ ព្រះមជ្ឈន្តិកត្ថេរនិមន្តទៅដល់ទីនោះ កាលស្ថិតនៅក្រោមអំណាចស្តេចនាគអរ៉ាវាល, ដោយឫទ្ធិអំណាចខាងផ្លូវចិត្តរបស់ព្រះអង្គ ព្រះថេរៈទ្រង់បានទូន្មាន ដោយការសម្តែងធម៌ទេសនាអំពី អាសិវិសោបមសូត្រ ។

២-តំបន់មហិសកមណ្ឌលៈ បានបញ្ជាក់ថាដូចគ្នានឹងតំបន់មីសរ៍ (Mysore) ស្ថិតនៅប្រទេសឥណ្ឌាភាគខាងត្បូង ក្នុងពេលសព្វថ្ងៃនេះ ។ ព័ត៌មានខ្លះថា ជាប្រទេសភាគខាងត្បូងមួយនៃជួរភ្នំវិន្ធ្យៈ (Vindhya) ។ ព្រះថេរៈបានសម្តែងធម៌ទេសនា អំពីទេវទូតសូត្រនៅទីនោះ ។

៣-វនវាសី គឺជាកណារៈភាគខាងជើង ស្ថិតនៅឥណ្ឌាភាគខាងត្បូង, សូម្បីសព្វថ្ងៃនេះ មានទីក្រុងមួយមានឈ្មោះវនវាសី នៅក្នុងតំបន់នោះដដែល ។ ព្រះសូត្រឈ្មោះអនមតគ្គ ជាប្រធានបទនៃព្រះធម៌ទេសនា។

៤-អបរន្តៈ (នៅចុងខាងលិច) តាមការគិតស្មានថាអាចស្ថិតនៅភាគខាងលិចប្រទេសឥណ្ឌា ។ តាមគម្ពីរបូរាណៈបញ្ជាក់ជាប្រទេសមួយនៃប្រទេសទាំងប្រាំ ដែលមាននៅក្នុងប្រទេសឥណ្ឌាបូរាណ គឺជាអបរន្តៈ ។ រាជធានីរបស់អបរន្តៈ គឺជាកំពង់ផែសុប្បរកៈ (សព្វថ្ងៃហៅថាសោបារៈ) ។ គុជរ៉ាត់ (គជរដ្ឋ) ខាងជើង, កតិយវរៈ,កច្ឆៈ, សិន្ធៈ ក៏ត្រូវបានរាប់បញ្ចូលទៅក្នុងអបរន្តៈផងដែរ ធម៌ទេសនាដែលត្រូវសម្តែងនៅទីនោះគឺអគ្គិក្ខន្ធោបមសូត្រ ។

៥-មហារត្ថៈ សព្វថ្ងៃគឺរដ្ឋមហារាស្ត្រនេះឯង ដែលរាប់បញ្ចូលឥណ្ឌាភាគកណ្តាលនិងភាគខាងលិច ។ ធម៌ទេសនាដែលនាំទៅសម្តែងនៅទៅនោះ គឺមហានារទកស្សបជាតក ។

៦-យោនករត្ថៈ គឺរាជាណាចក្រក្រិកនេះឯង ។ មែនទែនទៅវាត្រូវតែជារាជាណាចក្រក្រិកហើយ ដែលមាននៅខាងលិចប្រទេសឥណ្ឌានោះ, អាចរាប់បញ្ចូលប្រទេសអេហ្ស៊ីប ស៊ីរីយ៉ា និងប្រទេសក្រិកផងដែរ ។ កាឡករាមសូត្រត្រូវបានលើកយកទៅសម្តែងទេសនានៅទីនោះ ។

៧-បានបញ្ជាក់ថា ព្រះអរហន្តកស្សបគោត្តៈ, អាឡកទេវៈ, មហាទេវៈ និង ទុន្ទុភិស្សរ បានដង្ហែព្រះអរហន្តមជ្ឈិមៈទៅកាន់តំបន់ហិម៉ាល័យហើយបានទេសនាអំពីធម្មចក្កប្បវត្តនសូត្រ ។

៨-អ្នកប្រាជ្ញខ្លះបានបញ្ជាក់ប្រាប់ថា សុវណ្ណភូមិ ស្ថិតនៅប្រទេសភូមា ។ អ្នកប្រាជ្ញខ្លះទៀតនិយាយថា កណ៌សុវណ៌ ស្ថិតនៅក្នុងតំបន់បឹងហ្គាល់ ហើយមានអ្នកប្រាជ្ញខ្លះទៀតសន្និដ្ឋានថា ស្ថិតនៅក្នុងស្រុកហិរណ្យវាហៈ តាមបណ្តោយដងស្ទឹងសោណា ។ ព្រហ្មជាលសូត្រគឺជាប្រធានបទធម៌ទេសនា ដែលត្រូវបានលើកយកទៅសម្តែងនៅទីនោះ ។

៩-តម្ពបណ្ណិទ្វីប គឺប្រទេសសីហឡៈ ឬស្រីលង្កា ។

## បេសកកម្មទៅកាន់ប្រទេសស្រីលង្កា

ព្រះរាជបុត្ររបស់ស្តេចធម្មាសោក អមដំណើរដោយព្រះភិក្ខុសង្ឃបួនអង្គ សាមណេរមួយអង្គនិងឧបាសកម្នាក់ បានចេញដំណើរទៅកាន់ប្រទេសស្រីលង្កា ក្នុងនាមជាសាមណទូត ដើម្បីប្រោសជនជាតិសីហឡៈទាំងមូល ។ ស្ថិតនៅចំថ្ងៃបុណ្យប្រពៃណីមួយ ដែលព្រះសង្ឃជាសមណទូតទាំងនោះ បានទៅដល់ដែនដីសីហឡៈ ហើយបានជួបស្តេចគ្រងអំណាចមួយអង្គ ឈ្មោះទេវានម្បិយតិស្សៈ ដែលយាងចេញទៅបរបាញ់សត្វកំសាន្ត ជាមួយនឹងពួកបរិវារ នៅតាមជួរភ្នំមានឈ្មោះមិស្សកៈ (សព្វថ្ងៃនេះហៅ ថាភ្នំមហិន្ទលេ) ។ ព្រះមហិន្ទត្ថេរបានញ៉ាំងព្រះរាជាឲ្យយកព្រះ ទ័យស្តាប់ ដោយព្រះអង្គមានថេរដីកាយ៉ាងសាមញ្ញថា “តិស្សៈ” ។ បន្ទាប់មកមានការសន្ទនាគួរឲ្យចាប់អារម្មណ៍មួយ ដែលមានសេចក្តី

ជាបន្តបន្ទាប់។ បន្ទាប់ពីព្រះមហិន្ទត្ថេរបានសម្តែងធម៌ទេសនា អំពីចុល្លហត្ថិបទោបមសូត្រ ថ្វាយស្តេចនិងបរិវារទាំងអស់របស់ព្រះអង្គមក បានឮថាទាំងស្តេចទាំងបរិវារ បានស្វែងរកទីពឹងទីរលឹកនៅក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ហើយបានទទួលកាន់យកនូវសាសនាថ្មីនោះទៅ ។

បេសកកម្មផ្សាយព្រះពុទ្ធសាសនា របស់ព្រះមហិន្ទត្ថេរទៅកាន់កោះសីហឡ:(ស្រីលង្កា)នោះ បានទទួលជោគជ័យធំធេងណាស់ ។ ព្រះអង្គបានស្វែងរកឃើញប្រទេសស្រីលង្កា នូវដែនដីសម្បូរណ៍ជីជាតិ ដើម្បីសាបព្រួសនូវព្រះធម៌ដ៏ប្រសើរវិសេស របស់ព្រះពុទ្ធបរមគ្រូ ជាមួយនឹងព្រះរាជូបត្ថម្ភ ដែលបានបង្កើតឡើងយ៉ាងរឹងមាំ នៅក្នុងប្រទេសស្រីលង្កា ។

នៅពេលនោះ ព្រះនាងអនុលាបានសម្រេចសោតាបន្ន: ដោយសារបានស្តាប់ព្រះធម៌ទេសនាលើកដំបូង ដែលសម្តែងនៅក្នុងរាជធានីអនុរាធបុរ: ។ ព្រះនាងមានបំណងចង់បួស, ព្រះមហិន្ទត្ថេរបានបញ្ជូនអ្នកនាំសារទៅកាន់ប្រទេសឥណ្ឌា ដើម្បីនិមន្តព្រះភិក្ខុនីសង្ឃមិត្តាថេរី ជាប្អូនស្រីបង្កើតរបស់ព្រះអង្គ មកកាន់ប្រទេសស្រីលង្កា ក្នុងបំណងបង្កើតភិក្ខុនីសង្ឃ ។ នៅពេលបានទទួលការនិមន្តហើយ ព្រះថេរីក៏និមន្តទៅកាន់ប្រទេសស្រីលង្កា ដោយនាំយកមែកមហាពោធិព្រឹក្ស ពីតំបន់ពុទ្ធគយា ហើយដង្ហែដោយពួកមនុស្សមានកិត្តយសយ៉ាងច្រើន ដែលបានជាវិភាគ

ទានយ៉ាងធំ ចំពោះការអភិវឌ្ឍន៍ខាងប្រាជ្ញាញាណ និងស្មារតីសីលធម៌ដល់ប្រទេសស្រីលង្កា ។

ចំពោះព្រះកិត្តិគុណមិនមានទីបំផុត នៃពួកពុទ្ធសាសនិកប្រទេសស្រីលង្កា គួរតែនិយាយថាពួកគេបានការពារព្រះពុទ្ធវចនៈ ដែលជាព្រះធម៌ដ៏ប្រសើរវិសេស នៅក្នុងសេចក្តីបរិសុទ្ធដំបូងរបស់ពួកគេ ដោយពួកគេបានកត់ត្រាព្រះពុទ្ធវចនៈ ទុកលើស្លឹករឹតជាលើកដំបូង នៅក្នុងប្រវត្តិសាស្ត្រពុទ្ធសាសនា ។

# ១៩. មង្គលសូត្រ

បានស្ដាប់មកយ៉ាងនេះថា

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ នៅពេលរាត្រីបឋមយាមកន្លងទៅ មានទេវតាមួយអង្គប្រាកដឡើង ហើយបានញុំាងវត្តជេតពនទាំងមូល ឲ្យភ្លឺស្វាងដោយពន្លឺរស្មីដ៏រុងរឿង ។ ទេវតាអង្គនោះបានចូលទៅរក ព្រះដ៏មានព្រះភាគ ហើយថ្វាយបង្គំដោយសេចក្ដីគោរព រួចស្ថិតនៅក្នុងទីដ៏សមគួរមួយ ។ ពេលស្ថិតនៅក្នុងទីសមគួររួចហើយ ទេវតាអង្គនោះក៏ទូលសួរព្រះ ដ៏មានព្រះភាគដោយសំណួរដូច្នេះថា៖

១-ទេវតានិងមនុស្សទាំងឡាយ ប្រាថ្នានូវសួស្ដី បានគិតរកនូវមង្គលទាំងឡាយ[១] សូមព្រះមានព្រះភាគសម្ដែងប្រាប់ ខ្ញុំព្រះអង្គនូវមង្គលដ៏ឧត្ដម

ព្រះពុទ្ធសម្ដែងតបទេវតានោះថា៖

---

[១] អដ្ឋកថាពន្យល់ថា ពាក្យថា មង្គល មានន័យថាជាលក្ខណៈនៃសេចក្ដីសុខ និងសេចក្ដីចម្រើន ។ អ្នកនិរុត្តិសាស្ត្រនិយម បានស្រង់ពាក្យនេះចេញមកពីព្យាង្គថា មំ (ភាវៈពេញដោយទុក្ខសោក) និង គលៈ (ការទៅ, ច្រូតកាត់, លះ) ហើយបានពន្យល់ថា ជាការបន្ទុចបង្អាក់ផ្លូវទៅកាន់សេចក្ដីទុក្ខវេទនា ។

២-ការមិនសេពគប់បុគ្គលពាលទាំងឡាយ១, ការសេពគប់ជនជាបណ្ឌិត១, និងការបូជាដល់បុគ្គលដែលគួរបូជា១, ទាំង៣នេះជាមង្គលដ៏ឧត្តម ។

៣-ការនៅក្នុងប្រទេសដ៏សមគួរ១, ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន១, ការតម្កល់ខ្លួនដោយប្រពៃ១, ទាំង៣នេះជាមង្គលដ៏ឧត្តម ។

៤-ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយច្រើន១, សិល្បសាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាស់ក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ១, វិន័យដែលបុគ្គលបានសិក្សាហើយដោយល្អ១, វាចាដែលពោលឡើងហើយដោយត្រឹមត្រូវ១, ទាំង៤នេះជាមង្គលដ៏ឧត្តម ។

៥-ការបម្រើមាតាបិតា១, ការសង្គ្រោះដល់បុត្រនិងភរិយា១, ការងារទាំងឡាយមិនច្របូកច្របល់១, ទាំង៣នេះ ជាមង្គលដ៏ឧត្តម។

៦-ការឲ្យទាន១, ការប្រព្រឹត្តតាមធម៌១, ការសង្គ្រោះដល់ពួកញាតិ១, ការងារដែលមិនមានទោស១, ទាំង៤នេះជាបុគ្គលដ៏ឧត្តម។

៧-ការមិនត្រេកអរក្នុងបាប និងការវៀរចាកបាប១, ការសង្រួមចាកកិរិយាផឹកទឹកស្រវឹង១, ការមិនប្រមាទក្នុងធម៌ទាំងឡាយ ១, ទាំង៣នេះ ជាមង្គលដ៏ឧត្តម ។

៨-ការគោរពចំពោះបុគ្គលដែលគួរគោរព១, ការប្រព្រឹត្តបន្ទាបនូវខ្លួន១, ការត្រេកអរចំពោះរបស់ដែលខ្លួនមាន១, ភាពនៃបុគ្គលអ្នកដឹងនូវឧបការៈគុណ ដែលអ្នកដទៃធ្វើហើយដល់ខ្លួន១, ការស្ដាប់នូវធម៌តាមកាល១, ទាំង៥នេះជាមង្គលដ៏ឧត្ដម ។

៩-សេចក្ដីអត់ធន់១, ភាពជាបុគ្គលប្រដៅបានដោយងាយ១, ការបានឃើញបានជួបសមណៈទាំងឡាយ១, ការសន្ទនាធម៌ទៅវិញទៅមកតាមកាល១, ទាំង៤នេះជាមង្គលដ៏ឧត្ដម ។

១០-ការព្យាមដុតនូវបាបធម៌១, ការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ១, ការឃើញនូវអរិយសច្ចទាំងឡាយ១, ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន១, ទាំង៤នេះជាមង្គលដ៏ឧត្ដម ។

១១-ចិត្តនៃបុគ្គលដែលលោកធម៌ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ១, មិនមានសេចក្ដីសោក១, មានធូលីគឺរាគៈទៅប្រាសហើយ១, ចិត្តក្សេមក្សាន្ត១, ទាំង៤នេះជាមង្គលដ៏ឧត្ដម ។

១២-ទេវតានិងមនុស្សទាំងឡាយ បានធ្វើនូវមង្គលទាំងឡាយឲ្យប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្ដីក្នុងទីទាំងពួង (ម្នាលទេវតាចូរអ្នកប្រកាន់ជឿថា) មង្គលទាំង៣៨ប្រការ មានការមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតានិងមនុស្សទាំងនោះ ជាមង្គលដ៏ឧត្ដម ។

# ២០. បរាភវសូត្រ

បានស្តាប់មកយ៉ាងនេះថា:

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ នៅពេលរាត្រីបឋមយាមកន្លង ទៅ មានទេវតាមួយអង្គប្រាកដឡើង ហើយបានញ៉ាំងវត្តជេតពនទាំងមូល ឲ្យភ្លឺស្វាងដោយពន្លឺរស្មីដ៏រុងរឿង ។ ទេវតាអង្គនោះបានចូលទៅរកព្រះដ៏ មានព្រះភាគ ហើយថ្វាយបង្គំដោយសេចក្តីគោរព រួចស្ថិតនៅក្នុងទីដ៏សម គួរមួយ ។ ពេលស្ថិតនៅក្នុងទីសមគួររួចហើយ ទេវតាអង្គនោះក៏ទូលសួរ ព្រះដ៏មានព្រះភាគ ដោយសំណួរដូច្នេះថា៖

១-យើងទាំងឡាយបានមក ដើម្បីទូលសួរព្រះដ៏មានព្រះភាគ អំពី ហេតុនាំឲ្យបុរសស្ត្រីក្នុងលោកដល់នូវក្តីវិនាស ។ បពិត្រព្រះគោតមដ៏ ចម្រើន ! យើងខ្ញុំសូមព្រះអង្គមេត្តាសម្តែងប្រាប់ថា អ្វីទៅជាប្រធាននៃក្តី វិនាសនោះ ។

២-អ្នកដែលចម្រើនជាបុគ្គល គឺពួកជនជាបណ្ឌិតដឹង បានដោយ ងាយ, អ្នកដែលវិនាសក៏ពួកជនបណ្ឌិតដឹងបានដោយងាយដែរ, អ្នកប្រាថ្នា ធម៌រមែងចម្រើន ចំណែកអ្នកស្អប់ធម៌តែងវិនាស ។

៣-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាសទី១ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធានទី២ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

៤-អ្នកដែលស្រឡាញ់ពេញចិត្តតែជនអសប្បុរស ហើយមិនស្រឡាញ់ចំពោះពួកជនសប្បុរស, ពេញចិត្តចំពោះធម៌នៃពួកជនអសប្បុរសនោះ, នោះជាប្រធាននៃសេចក្តីវិនាស ។

៥-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាសទី២ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធានទី៣ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

៦-អ្នកដេកច្រើនក្តី, អ្នកនិយាយច្រើនក្តី, អ្នកមិនខ្មីឃ្មាតក្តី អ្នកខ្ជិលច្រអូសក្តី, អ្នកពេញដោយការក្រោធខឹងក្តី, នោះជាប្រធាននៃសេចក្តីវិនាស ។

៧-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាសទី៣ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធានទី៤ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

៨-បុគ្គលជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ តែមិនចិញ្ចឹមនិងថែរក្សាមាតាបិតា ដែលមានវ័យចាស់ជរា, នោះជាប្រធាននៃសេចក្តីវិនាស ។

៩-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាស ទី៤ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធាន ទី៥ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

១០-បុគ្គលកុហកឬបញ្ឆោតពួកព្រាហ្មណ៍ក្តី ពួកសមណៈ អ្នកបួសក្តី ឬពួកស្មូមដទៃទៀតក្តី, នោះជាប្រធាននៃសេចក្តីវិនាស ។

១១-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាស ទី៥ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធាន ទី៦ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

១២-បុគ្គលមានទ្រព្យធនធានច្រើន មានមាសប្រាក់និងសម្បូណ៌ ដោយអាហារភោជន ហើយបរិភោគអាហារភោជនឆ្ងាញ់តែម្នាក់ឯង, នោះជាប្រធាននៃសេចក្តីវិនាស ។

១៣-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាស ទី៦ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធានទី៧ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

១៤-ជនដែលប្រកាន់ចិត្តរឹងត្អឹង ដោយអាងជាតិកំណើត ទ្រព្យសម្បត្តិ ឬក៏អាងត្រកូល ហើយស្អប់ខ្ពើម និងមើលងាយញាតិសន្តានរបស់ខ្លួន, នោះជាប្រធាននៃសេចក្តីវិនាស ។

១៥-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃ សេចក្តីវិនាស ទី៧ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធានទី៨ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

១៦-បុរសអ្នកប្រព្រឹត្តល្បែងស្រី(ឥត្ថីធុត្ត) ល្បែងស្រា (សុរាធុត្ត) និងល្បែងភ្នាល់ស៊ីសង (អក្ខធុត្ត) ដែលញ៉ាំងទ្រព្យខ្លួនមានឲ្យអន្តរាយទៅវិញ, នោះជាប្រធាននៃសេចក្តីវិនាស ។

១៧-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាស ទី៨ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធាន ទី៩ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

១៨-ប្រុសមិនត្រេកអរនឹងភរិយារបស់ខ្លួន ហើយទៅសប្បាយនឹងពួកស្រីពេស្យា ឬខូចនឹងប្រពន្ធរបស់អ្នកដទៃ, នោះជាប្រធាននៃសេចក្តីវិនាស ។

១៩-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាស ទី៩ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធានទី១០ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

២០-បុរសមានវ័យចាស់ នាំយកស្រីក្មេងដែលមាន ដោះក្បំដូចផ្លែទន្លាប់មកធ្វើជាភរិយា រមែងដេកមិនលក់ព្រោះការប្រច័ណ្ឌចំពោះស្រីនោះ, នោះជាប្រធាននៃសេចក្តីវិនាស ។

២១-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាសទី១០ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធានទី១១ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

២២-ប្រុសតាំងស្ត្រីដែលខ្លះខ្លាយ មិនចេះប្រមាណ ឲ្យទទួលខុសត្រូវ, ឬស្ត្រីតាំងប្រុសដែលមានសភាពដូចគ្នានេះដែរ ឲ្យទទួលខុសត្រូវ (ជាមេផ្ទះ), នោះជាប្រធាននៃសេចក្តីវិនាស ។

២៣-យើងបានដឹងច្បាស់ហើយថា នោះជាប្រធាននៃសេចក្តីវិនាសទី១១ ។ បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គសម្តែងប្រាប់នូវប្រធានទី១២ អ្វីទៅជាប្រធាននៃសេចក្តីវិនាស ។

២៤-បុគ្គលកើតក្នុងត្រកូលក្សត្រ មានភោគទ្រព្យតិច តែមានសេចក្តីប្រាថ្នាធំ ចង់ធ្វើជាស្តេចគ្រប់គ្រងអំណាច, នោះជាប្រធាននៃសេចក្តីវិនាស ។

២៥-បុគ្គលជាបណ្ឌិត បរិបូណ៌ដោយការឃើញដ៏ប្រសើរ ពិចារណាឃើញច្បាស់ នូវសេចក្តីវិនាសនោះក្នុងលោក ដែលមានសេចក្តីសុខក្សេមក្សាន្ត ។

# ២១. មេត្តាសូត្រ

១-កុលបុត្រដែលជំនាញ និងប៉ិនប្រសប់នៅក្នុងអំពើល្អរបស់ខ្លួន ហើយប្រាថ្នាដើម្បីបានសម្រេចនូវភាពស្ងប់គួរធ្វើ ដូច្នេះ៖

២-បុគ្គលជាអ្នកអាចហ៊ានផង, ត្រង់ដោយកាយនិងវាចាផង ត្រង់ល្អដោយចិត្តផង, ជាអ្នកប្រដៅងាយផង សុភាពទន់ភ្លន់ផង និងមិនមានមានះដ៏ក្រៃលែងផង, ជាអ្នកសន្តោសៈផង គេចិញ្ចឹមបានដោយងាយផង មានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាលក្នុងកាយនិងចិត្តផង, ជាអ្នកមានឥន្ទ្រីយ៍ស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង, ជាអ្នកមិនឆ្គងផង មិនជាប់ក្នុងត្រកូលទាំងឡាយផង ។

៣-បុគ្គលមិនគួរប្រព្រឹត្តអំពើអាក្រក់សូម្បីតិចតួច ដែលជាហេតុនាំឲ្យវិញ្ញូជនទាំងឡាយរិះគន់បាន ។ សព្វសត្វទាំងឡាយ សូមឲ្យមានសេចក្តីសុខសេចក្តីក្សេម សូមឲ្យបេះដូងរបស់គេពេញ ដោយកុសល និងសុខភាពជានិច្ច ។

៤-សព្វសត្វទាំងឡាយ ទោះជាសត្វមានសេចក្តីតក់ស្លុតគឺនៅមានតណ្ហាក្តី ជាអ្នកមាំមួនគឺឥតមានតណ្ហាក្តី, សត្វទាំងឡាយមានកាយវែងក្តីធំក្តី មានកាយយ៉ាងណាក្តី ខ្លីក្តី មានកាយសុគមក្តី ធាត់ក្តី, សត្វទាំងឡាយដែលមើលឃើញក្តី មិនឃើញក្តី, សត្វទាំងឡាយដែលស្ថិតនៅទីឆ្ងាយក្តី នៅ

ក្នុងទីជិតក្តី, ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទីកើតក្តី ។ សូមឲ្យសត្វទាំងអស់មានសេចក្តីសុខនៅក្នុងចិត្ត ។

៥-សូមកុំឲ្យ(អ្នកណាមួយ) មើលងាយអ្នកដទៃទៀត, ឬក៏ស្អប់បុគ្គលណាមួយនៅក្នុងកន្លែងណាមួយឡើយ ។ សត្វទាំងឡាយមិនត្រូវប្រាថ្នា នូវសេចក្តីទុក្ខដល់គ្នានឹងគ្នាដោយការខឹង និងសេចក្តីក្រេវក្រោធដោយបដិឃសញ្ញា គឺសេចក្តីចង្អៀតចង្អល់ក្នុងចិត្ត ។

៦-មាតារក្សាការពារកូនតូចតែមួយរបស់នាង សូម្បីជីវិតក៏នាងហ៊ានលះបង់ដែរ បុគ្គលគួរចម្រើនចិត្តដោយគ្មានកំណត់ ឆ្ពោះទៅរកសព្វសត្វទាំងឡាយ ។

៧-សូមឲ្យបុគ្គលចម្រើននូវមេត្តាចិត្ត មិនមានកំណត់ ជាធម៌មិនចង្អៀត មិនមានពៀរ ផ្សាយទៅក្នុងលោកទាំងមូល ទាំងខាងលើទាំងខាងក្រោម ទាំងខាងទទឹងគឺត្រង់កណ្តាល ។

៨-បុគ្គលអ្នកចម្រើននូវមេត្តាចិត្ត ទោះឈរ ដើរ អង្គុយ ដេក, ជាបុគ្គលមិនមានការងោកងល់ គឺជាអ្នកមិនដេកលក់អស់កាលត្រឹមណា ។

៩-(បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនស៊ប់នៅក្នុងទិដ្ឋិ ជាអ្នកមានសីលប្រកបដោយទស្សនសម្ប័ទ គឺសោតាបត្តិមគ្គ បន្ទោរបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយ, រមែងមិនចុះមកចាប់បដិសន្ធិនៅក្នុងគភ៌ គឺថាមិនកើតទៀតឡើយ ។

# ២២. ព្យគ្ឃបជ្ជសូត្រ

បានស្តាប់មកហើយយ៉ាងនេះថា:

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគម ឈ្មោះកក្ករបត្តៈ របស់កោឡិយក្សត្រ នៅក្នុងដែនកោឡិយៈ ។ គ្រានោះ ទីឃជាណុកោឡិយបុត្រ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយបានថ្វាយបង្គំព្រះអង្គដោយសេចក្តីគោរព រួចអង្គុយនៅក្នុងទីដ៏សមគួរមួយ ។ ពេលអង្គុយរួចហើយ ទីឃជាណុកោឡិយបុត្រ បានក្រាបទូលសួរព្រះមានព្រះភាគដូចខាងក្រោម:

"បពិត្រព្រះអង្គដ៏ចម្រើន, យើងខ្ញុំព្រះអង្គជាគ្រហស្ថ តែងរីករាយនៅក្នុងលោកប្រកបដោយកាម, តែងនាំជីវិតដោយភារៈដ៏ធ្ងន់ ចង្អៀតដោយភរិយានិងបុត្រ ។ យើងខ្ញុំព្រះអង្គបានប្រើខ្លឹមចន្ទន៍ មកពីដែនកាសីសម្រាប់ប្រស់ព្រំ តុបតែងខ្លួនដោយកម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាបទាំងឡាយ ។ យើងខ្ញុំព្រះអង្គតែងត្រេកអរ ដោយការប្រើមាសនិងប្រាក់ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ មេត្តាសម្តែងអំពីធម៌បែបនោះដល់យើងខ្ញុំព្រះអង្គ ដែលជាធម៌ប្រព្រឹត្តទៅដើម្បីប្រយោជន៍បច្ចុប្បន្នផង ដើម្បីសេចក្តីសុខនៅក្នុងជីវិតនេះផង និងដើម្បីប្រយោជន៍ក្នុងបរលោក និងសេចក្តីសុខនៅក្នុងបរលោកផង" ។

ទិដ្ឋធម្មិកត្ថប្រយោជន៍ (ប្រព្រឹត្តទៅដើម្បីប្រយោជន៍បរលោក)

ម្នាលព្យគ្ឃបជ្ជៈ ! ធម៌ទាំងឡាយ៤ប្រការនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខក្នុងបច្ចុប្បន្នដល់កុលបុត្រ ។ ធម៌៤ប្រការនោះ តើដូចម្តេច?

១-ឧដ្ឋានសម្បទា (ដល់ព្រមដោយការប្រឹងប្រែងស្វែងរក)។

២-អារក្ខសម្បទា (ដល់ព្រមដោយការថែរក្សារបស់ដែលរកបានមកហើយ)

៣-កល្យាណមិត្តតា (ការសេពគប់កល្យាណមិត្រ) ។

៤-សមជីវិតា (ការចិញ្ចឹមជីវិតរស់នៅដោយស្មើ)

ម្នាលព្យគ្ឃបជ្ជៈ ចុះឧដ្ឋានសម្បទាតើដូចម្តេច?

ម្នាលព្យគ្ឃបជ្ជៈ, កុលបុត្រក្នុងលោកនេះ ចិញ្ចឹមជីវិតដោយការប្រឹងប្រែងចិញ្ចឹមក្នុងការងារឯណានីមួយ ទោះបីការធ្វើស្រែចំការក្តី ការធ្វើជំនួញក្តី ការឃ្វាលគោក្របីក្តី ការងារខ្មាន់ធ្នូក្តី, ការងារជាមន្ត្រីរាជការក្តី ឬសិល្បៈណាមួយក្តី ជាអ្នកប៉ិនប្រសប់ក្នុងការងារទាំងនោះ និងមិនខ្ជិលច្រអូស ប្រកបដោយមធ្យោបាយជាគ្រឿងពិចារណា ក្នុងការងារទាំងនោះថា គួរធ្វើគួរចាត់ចែង ។ នេះឯងហៅថាឧដ្ឋានសម្បទា ។

ម្នាលព្យគ្ឃបជ្ជៈ ចុះអារក្ខសម្បទា តើដូចម្តេច?

ម្នាលព្យគ្ឃបជ្ជៈ ទ្រព្យទាំងឡាយ ដែលកុលបុត្រក្នុងលោកនេះ បានមកដោយកម្លាំងព្យាយាមប្រឹងប្រែង សន្សំដោយកម្លាំងដៃ បែកញើស ហូរញើស, ជាទ្រព្យប្រកបដោយធម៌ បានមកដោយធម៌, កុលបុត្រនោះ បានញុំាងទ្រព្យទាំងឡាយនោះ ឱ្យសម្រេចដោយការរក្សាគ្រប់គ្រង ដោយគិតថាត្រូវធ្វើដូចម្ដេច កុំឱ្យមានការរឹបអូសពីស្ដេច, កុំឱ្យចោរលួច, កុំឱ្យភ្លើងឆេះ, និងកុំឱ្យទឹកជំនន់គួចយកទៅ កុំឱ្យពួកទាយាទណាមួយមិនជាទីស្រឡាញ់ ដណ្ដើមនាំយកទៅបាន ។ នេះឯងហៅថា អារក្ខសម្បទា ។

ម្នាលព្យគ្ឃបជ្ជៈ ចុះកល្យាណមិត្តតា តើដូចម្ដេច?

ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ នៅអាស្រ័យក្នុងស្រុក ឬនិគម ពួកជនទោះជាគហបតីក្ដី គហបតិបុត្រក្ដី ក្មេងតែងចម្រើនដោយសីលក្ដី ចាស់ហើយតែចម្រើនដោយសីលក្ដី ពេញដោយសទ្ធា បរិបូណ៌ដោយសីលៈ បរិបូណ៌ដោយចាគៈ និង បរិបូណ៌ដោយបញ្ញា ។ កុលបុត្រនោះតែងឈរសាកច្ឆាជាមួយពួក ក្រុម តែងសិក្សានូវសទ្ធាសម្បទា និងពួកជនអ្នកបរិបូណ៌ដោយសទ្ធា, តាមសមគួរសិក្សានូវសីលសម្បទា និងពួកជនអ្នកបរិបូណ៌ដោយសីល, តាមសមគួរសិក្សានូវចាគសម្បទា និងពួកជនបរិបូណ៌ដោយចាគៈ, តាមសមគួរសិក្សានូវបញ្ញាសម្បទា និងពួកជនបរិបូណ៌ដោយបញ្ញា ។ នេះឯងហៅថា កល្យាណមិត្តតា ។

ម្នាលព្យគ្ឃបជ្ជៈ ចុះសមជីវិតា តើដូចម្ដេច ?

ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ដឹងច្បាស់នូវការចម្រើននៃភោគទ្រព្យទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅនៃភោគទ្រព្យទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនត្បិតត្បៀតពេក, ដោយគិតថាចំណូលរបស់អាត្មាអញ ស្ថិតនៅខ្ពស់ជាងការចំណាយ ប៉ុន្តែការចំណាយរបស់អាត្មាអញ កុំឲ្យខ្ពស់ជាងការចំណូល, ប្រៀបដូចជាអ្នកថ្លឹងជញ្ជីងក្តី កូនសិស្សនៃជនអ្នកថ្លឹងជញ្ជីង លើកនូវកូនជញ្ជីង លើកនូវជញ្ជីងថ្លឹង, ហើយក៏ដឹងថា ជញ្ជីងនេះទន់ទៅម្ខាងផង បះទៅម្ខាងផង, យ៉ាងណាមិញ កុលបុត្រដឹងច្បាស់នូវការចម្រើន នៃភោគទ្រព្យទាំងឡាយផង ដឹងច្បាស់នូវការវិនាសភោគទ្រព្យទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនត្បិតត្បៀតពេក ដោយគិតថាចំណូលរបស់អាត្មាអញ ច្រើនលើសពីការចំណាយ, ហើយសូមកុំឲ្យការចំណាយរបស់អញលើសពីការចំណូល ។ នេះហៅថា សមជីវិតសម្បទា ។

ម្នាលព្យគ្ឃបជ្ជៈ ប្រសិនបើកុលបុត្រ មានប្រាក់ចំណូលតិចតួច ហើយរស់នៅក្នុងជីវិតប្រណិត ដោយការចំណាយលើសលុប, អ្នកផងតែងនិយាយចំពោះកុលបុត្រនោះថា “កុលបុត្រនេះបរិភោគនូវភោគទ្រព្យទាំងឡាយ ដូចជាបុគ្គលស៊ីផ្លែល្វា” ។ ម្នាលព្យគ្ឃបជ្ជៈ ប្រសិនបើកុលបុត្រនោះ មានចំណូលយ៉ាងច្រើន ហើយចិញ្ចឹមជីវិតដោយត្បិតត្បៀត អ្នកផង

ទាំងឡាយរមែងនិយាយចំពោះបុគ្គលនោះថា កុលបុត្រនោះមុខជានឹងស្លាប់ដោយអត់ទីពឹង ។

ម្នាលព្យគ្ឃបជ្ជៈ ភោគទ្រព្យដែលប្រមូលបានតែងវិនាសទៅវិញដោយផ្លូវ ៤ យ៉ាងគឺៈ

ក.ជាអ្នកប្រព្រឹត្តល្បែង ងប់នឹងស្រី (ឥត្ថីធុត្តោ)

ខ.ជាអ្នកសេពសុរា និងគ្រឿងស្រវឹង (សុរាធុត្តោ)

គ.ជាអ្នកលេងល្បែងភ្នាល់ និងល្បែងស៊ីសង (អក្ខធុត្តោ)

ឃ.ការគប់មិត្រ ឬស្និទ្ធស្នាលជាមួយមិត្រអាក្រក់ (បាបមិត្ត)

ម្នាលព្យគ្ឃបជ្ជៈ ដូចជាស្រះទឹកដ៏ធំមានទ្វារទឹក៤ សម្រាប់បង្ហូរទឹកចេញនិងបង្ហូរទឹកចូល, ប្រសិនបើបុគ្គលបិទទ្វារទឹកចូលទាំងអស់ ហើយបើកទ្វារទឹកចេញទាំងអស់, ម៉្យាងភ្លៀងធ្លាក់មិនគ្រប់គ្រាន់ទៀតផង, ទឹកក្នុងស្រះនឹងស្រកចុះមិនខានឡើយ, គេសង្ឃឹមថាទឹកក្នុងស្រះនោះ នឹងមិនមានទឹកកើនឡើងទេ ។ យ៉ាងណាមិញ, ម្នាលព្យគ្ឃបជ្ជៈ អបាយមុខទាំង៤ តែងធ្វើឲ្យវិនាសនូវភោគទ្រព្យទាំងឡាយ ដែលប្រមូលបានមកហើយ ។

ម្នាលព្យគ្ឃបជ្ជៈ ភោគទ្រព្យទាំងឡាយតែងចម្រើនដោយផ្លូវធំៗ ៤ យ៉ាង គឺៈ

ក.ការវៀរចាកពីការប្រព្រឹត្តល្បែងស្រី

ខ.ការវៀរចាកការប្រព្រឹត្តល្បែងស្រា

គ.ការវៀរចាកការប្រព្រឹត្តល្បែងស៊ីសង និងល្បែងភ្នាល់

ឃ.ការសេពគប់កល្យាណមិត្រ និងសប្បុរស ។

ប្រៀបដូចជាស្រះទឹកដែលមានទ្វារធំៗ៤ សម្រាប់បញ្ចូលទឹក ប្រសិនបើបុគ្គលបើកទ្វារទាំងអស់ឲ្យទឹកចូល ហើយបិទទ្វារទាំងអស់កុំឲ្យទឹកចេញ, ម្យ៉ាងទៀត ភ្លៀងធ្លាក់ក៏ចុះមកយ៉ាងសមរម្យផងដែរ ដែលធ្វើឲ្យទឹកកើនឡើងដោយពិតប្រាកដ, គេសង្ឃឹមថានៅក្នុងស្រះនោះ នឹងមិនមានទឹកស្រកចុះឡើយ, ដូចទ្វារធំៗទាំង៤បានបញ្ជាក់ខាងលើហើយ អាចធ្វើឲ្យភោគទ្រព្យដែលប្រមូលបានមកនោះកើនឡើង ។

ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំង៤ប្រការប្រព្រឹត្តទៅដើម្បីសេចក្ដីជាប្រយោជន៍ក្នុងបច្ចុប្បន្ននេះ និងដើម្បីសេចក្ដីសុខក្នុងបច្ចុប្បន្នដល់កុលបុត្រ

សម្បរាយិកត្ថប្រយោជន៍ (ប្រព្រឹត្តទៅដើម្បីប្រយោជន៍បរលោក)

ម្នាលព្យគ្ឃបជ្ជៈ ធម៌ ៤ ប្រការនោះ តើអ្វីខ្លះ?

ម្នាលព្យគ្ឃបជ្ជៈ ធម៌ ៤ ប្រការនោះគឺ

ក.សទ្ធាសម្បទា ដល់ព្រមដោយសទ្ធា

ខ.សីលសម្បទា ដល់ព្រមដោយសីល

គ.ចាគសម្បទា ដល់ព្រមដោយការបរិច្ចាគ

ឃ.បញ្ញាសម្បទា ដល់ព្រមដោយបញ្ញា

អ្វីទៅជាសទ្ធាសម្បទា ?

កុលបុត្រក្នុងលោកនេះ មានសទ្ធាជឿលើការត្រាស់ដឹង របស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ, ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ។ ម្នាលព្យគ្ឃបជ្ជៈ នេះឯងហៅថា សទ្ធាសម្បទា ។

អ្វីទៅហៅថា សីលសម្បទា ?

កុលបុត្រក្នុងលោកនេះ វៀរចាកការសម្លាប់ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការពោល ពាក្យកុហក និងវៀរចាកការសេពនូវសុរានិងគ្រឿងស្រវឹង ដែលនាំឲ្យកើតសេចក្តីប្រមាទ ។ ម្នាលព្យគ្ឃបជ្ជៈនេះឯងហៅថា សីល សម្បទា ។

អ្វីទៅហៅថា ចាគសម្បទា ?

កុលបុត្រក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានបាតដៃលាងហើយ មានចិត្តរីករាយក្នុងការឲ្យ បានថ្វាយបិណ្ឌបាត្រទានដល់ព្រះសង្ឃ និងស្នូមជាដើម ។ ម្នាលព្យគ្ឃបជ្ជៈ នេះឯងហៅថា ចាគសម្បទា ។

អ្វីទៅហៅថា បញ្ញាសម្បទា ?

កុលបុត្រក្នុងលោកនេះ មានប្រាជ្ញាប្រកបដោយប្រាជ្ញា ជាដំណើរយល់ពីសេចក្តីចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរមុះមុត

ជាដំណើរយល់ពីការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលព្យគ្ឃបជ្ជៈ នេះឯង ហៅថាបញ្ញាសម្បទា ។

ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំងបួនយ៉ាងនេះឯង រមែងនាំទៅរកប្រយោជន៍ក្នុងបរលោក ដើម្បីសេចក្តីសុខក្នុងបរលោក ដល់កុលបុត្រ ។

កុលបុត្រអ្នកមានព្យាយាមប្រឹងប្រែង នៅក្នុងការងារទាំងឡាយ១, មិនប្រហែសធ្វេសក្នុងការចាត់ចែង១, ចិញ្ចឹមជីវិតស្មើ១, ចេះថែរក្សាភោគទ្រព្យ ដែលរកបានមក១, មានសទ្ធា១, បរិបូណ៌ដោយសីល១, ដឹងនូវពាក្យពេចន៍១, ប្រាសចាកសេចក្តីកំណាញ់ រមែងជម្រះនូវផ្លូវសួស្តី ជាផ្លូវទៅកាន់បរលោកជានិច្ច១, ធម៌ទាំង៨ប្រការនេះ តែងនាំមកនូវសេចក្តីសុខក្នុងលោកទាំងពីរ ដែលព្រះដ៏មានព្រះភាគ ព្រះអង្គជាសច្ចនាម ទ្រង់សម្តែងហើយដល់កុលបុត្រអ្នកស្វែងរកផ្ទះ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងបរលោកផង ដោយប្រការដូច្នេះ, ការបរិច្ចាគនឹងបុណ្យកុសលនេះ តែងចម្រើនដល់គ្រហស្ថទាំងឡាយយ៉ាងនេះ ៕

# ចប់

# ពន្យល់ពាក្យ

| | |
|---|---|
| កាមតណ្ហា | តណ្ហាដែលទាក់ទងដល់កាមភព |
| ការបូជាយញ្ញ | ការធ្វើពិធីបូជាចំពោះអាទិទេព ដោយគ្រឿងបូជា មានការបូជាដោយការសម្លាប់ជីវិតសត្វ ដើម្បីយកឈាមបូជាជាដើម ។ |
| ឈាន | គឺជាការអភិវឌ្ឍន៍ខាងផ្លូវចិត្ត តាមរយៈការប្រតិបត្តិសមាធិ តាមន័យក្នុងអក្សរសាស្ត្រ ឈាន មានន័យថាការដុតបំផ្លាញចោលនូវតណ្ហា ឬការសង្កត់ចិត្តឲ្យនៅក្នុងអារម្មណ៍តែមួយ ។ |
| តបៈ | ការដុតកំដៅអំពើបាប និងកិលេស ដោយប្រព្រឹត្តខ្លួនឲ្យបានតឹងរ៉ឹង |
| ទុក្កកិរិយា | ការប្រព្រឹត្តធ្វើបាបរូបកាយយ៉ាងតឹងរ៉ឹងបំផុត |
| ទិព្វញ្ញាណ | ញាណជាទិព្វ ខុសពីញាណធម្មតា |
| បរាភវៈ | (បរា+ភវ) មានន័យថា ការធ្លាក់ចុះ |
| បដិច្ចសមុប្បាទ | ច្បាប់ដែលកើតឡើងអាស្រ័យគ្នា ជាប់គ្នាដូចជាច្រវាក់ ។ធម្មចក្កកង់នៃសច្ចៈ, កង់នៃភាពត្រឹមត្រូវ, អាណាចក្រនៃភាពត្រឹមត្រូវ ។ល។ តាមការអធិប្បាយរបស់អដ្ឋកថាពន្យល់ថា ធម្មៈ ក្នុងទីនេះមានន័យថា បញ្ញា ឬក៏ចំណេះដឹង, ហើយចក្រមានន័យ |

| | |
|---|---|
| | ថា ការបង្កើតឡើង ឬការកសាងឡើង ។ ធម្មចក្ក មានន័យថា ការបង្កើតឡើងនូវបញ្ញា ឬការកសាងឡើងនូវបញ្ញា, ធម្មចក្កប្បវត្តន មាន ន័យថា ការនិទានពីការកសាងឡើងនូវបញ្ញា ។ |
| ពោធិសត្វ | សត្វដែលកំពុងប្រាថ្នាឲ្យបានសម្រេច នូវភាពជាព្រះពុទ្ធ ហៅថាព្រះពោធិសត្វ ប្រែថា "សត្វដែលនឹងបានត្រាស់ដឹងជាព្រះពុទ្ធ" ។ ពាក្យក្នុងទីនេះសំដៅយកព្រះសិទ្ធត្ថកុមារ នៅមុនពេលព្រះអង្គបានត្រាស់ដឹង ។ |
| ភវតណ្ហា | ជាតណ្ហាដែលទាក់ទងជាមួយការយល់ ភាពមិនមានទីបំផុត (សស្សតទិដ្ឋិ) ។ |
| មោក្សធម៌ | ធម៌ជាគ្រឿងរំដោះខ្លួនចេញពីវដ្តសង្សារ |
| មហាបុរិសលក្ខណៈ | លក្ខណៈពិសេសនៃរូបកាយរបស់ព្រះពោធិសត្វ |
| មជ្ឈិមបដិបទា | ផ្លូវកណ្តាលមានអង្គប្រាំបី ។ |
| យមកប្បាដិហារិយៈ | ការសម្តែងឫទ្ធិខាងផ្លូវកាយ ដែលមនុស្សធម្មតាមិនអាចធ្វើបានឡើយ |
| វិមុត្តិសុខ | សេចក្តីសុខដែលកើតចេញមកពីផលនៃការត្រាស់ដឹង និងការបានដល់នូវព្រះនិព្វាន ។ |
| វិភវតណ្ហា | តណ្ហាដែលទាក់ទងជាមួយការយល់ និងភាពសូន្យ (ឧច្ឆេទទិដ្ឋិ) |

| | |
|---|---|
| សោតាបន្ន | អរិយមគ្គថ្នាក់ដំបូង ដែលបុគ្គលថ្នាក់នេះ មិនធ្លាក់ទៅក្នុងអបាយភូមិទេ ។ |
| សម្មាសម្ពោធិញ្ញាណ | ញាណដែលបានត្រាស់ដឹងដោយប្រពៃ ។ |
| សសរស្តម្ភ | ជាសសរថ្មតាន់ ដែលស្តេចធម្មាសោកកសាងទុកនៅតាមពុទ្ធស្ថាននានា នៅដែនដីឥណ្ឌាបូរាណ (បច្ចុប្បន្ននេះមានប្រទេសឥណ្ឌា នេប៉ាល់ ប៉ាគីស្ថាន អាហ្គានីស្ថានជាដើម)មានសម្រាប់ទុកជាទីសំគាល់ មាននៅរហូតដល់សព្វថ្ងៃនេះ ។ |
| អនិមិស្សកចេតីយ៍ | ឈ្មោះទីស្ថានដែលព្រះពុទ្ធគង់នៅ ។ ព្រះចេតីយ៍នេះបានកសាងឡើង ដោយស្តេចធម្មាសោកនៅសតវត្សទី៣មុនគ.ស. មានឈ្មោះថាអមិស្សកចេតីយ៍ មាននៅរហូតដល់សព្វថ្ងៃនេះ ។ |
| អរូបលោក | ជាភពមិនមានរូប គឺជាស្ថានដែលសត្វលោកទៅកើតបានដោយផលនៃការចម្រើនអរូបជ្ឈាន ។ |
| អទិស្សមានកាយ | ពពួកភូតដែលមានរូបកាយ តែមនុស្សយើងពុំអាចមើលពួកគេឃើញដោយចក្ខុធម្មតាបានឡើយ ។ |
| អរិយទ្រព្យ | ទ្រព្យដ៏ប្រសើរ ជារបស់ព្រះអរិយបុគ្គល មាន៧យ៉ាង គឺ ១.សទ្ធា ជឿចំពោះហេតុដែលគួរជឿ, ២.សីល រក្សាសីល, ៣.ហិរិ ការខ្មាស់បាប, ៤.ឱត្តប្បៈ ការខ្លាចបាប, ៥.ពាហុសច្ចៈ ការរៀនសូត្រ និងស្តាប់ |

បានច្រើន, ៦.ចាគ ការលះសេចក្តីកំណាញ់ ហើយបរិច្ចាគទាន, ៧.បញ្ញា ប្រាជ្ញា ។

ឥន្ទ្រិយ៍ — ធម្មជាតិជាធំ ឬភារៈជាធំ បានភ្នែក (ចក្ខុន្ទ្រិយ៍) ត្រចៀក (សោតិន្ទ្រិយ៍) ច្រមុះ (ឃានិន្ទ្រិយ៍) អណ្តាត(ជីវ្ហិន្ទ្រិយ៍) កាយ (កាយិន្ទ្រិយ៍) និងចិត្ត (មនិន្ទ្រិយ៍) ។

ឧបសម្បទា — ការបំពេញផ្នួសជាភិក្ខុ ទ្រទ្រង់អធិសីលសិក្ខា ។

អត្តកិលមថានុយោគកម្ម — អំពើដែលធ្វើខ្លួនឲ្យលំបាក ដូចជាការអត់អាហារ ការប្រកាន់ឥរិយាបថតែមួយ, អាំងភ្លើង នូវរដូវក្តៅ ចុះត្រាំទឹកនៅក្នុងរដូវត្រជាក់ ។

អភិនេស្រ្កមណ៍ — ការចេញបួសរបស់ព្រះសិទ្ធត្ថកុមារ

អស្សាសបស្សាស: — ខ្យល់ដកដង្ហើមចេញចូល

អភិធម្ម — គឺជាគម្ពីរខ្ពស់បំផុត ដែលទាក់ទងជាមួយនឹងទស្សនវិជ្ជាព្រះពុទ្ធសាសនា

ឯកតារម្មណ៍ — ចិត្តដែលស្ថិតនៅក្នុងអារម្មណ៍តែមួយ

# ឯកសារពិគ្រោះ


ឱម ណាគ្រី, ពុទ្ធប្បវត្តិនិទាន, បណ្ណាគារជឹង-ងួនហួត, ភ្នំពេញ កម្ពុជា, ១៩៥៤

សម្ដេច ហួត តាត, ធម្មសង្គហៈ, រោងពុម្ពខេមររដ្ឋ ភ្នំពេញ, បោះពុម្ពលើកទី៤, ១៩៦៧

អ៊ុម ស៊ូរ អភិធម្មត្ថសង្គហៈ, ផ្សាយចេញដោយពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពលើកទី៨ ព.ស. ២៥០០

David J. Kalupahana A History of Buddhist Philosophy (Continuities and Discontinuities) Motilal Banarsidass Publishers Private Limited, Delhi. 1994

I.N. Singh An Introduction to Abhidharmakosa Bhasyam (Prathama Kosasthana), Vidyanidhi Prakashan Delhi, 2010

H.R. Perera Buddhism in Sri lanka, A short History, Buddhist Publication Society, Kindy 1988

K.Sri Dhammnanda, Do you believe in Rebirth? Published by Singapore Buddhist Meditation Center 1988

Narada, A manual of Buddhism, Buddhist cultural centre 125, Anderson Road, Nedimala, Dehiwela. Sri Lanka, 2000.

Narada, The Buddha and His Teachings, Published by Jaico, publishing House 121, Mahatma Gandhi Road, Mumbai-400-023, 2006

Sir Edwin Arnold, The Light of Asia, Published by Intellectual Publishing House 23, Daryaganj, New Delhi, 1996

Thich Nhat Hanh, Old Path White Clouds, printed at Dot Security Press Pvt. Ltd. Delhi-110028, Fifth Indian Edition, 2005

Wilhelm Geiger, The Mahavansa (the great chronicle of Ceylon),Trans. PTS. Luzac & Company, LTD. London, 1964.